# 3 ផែនការមេគ្រប់គ្រងសំណល់រឹង

## 3.1 ផែនការមេ

### 3.1.1 គោលបំណង

ដូចបានបញ្ជាក់នៅក្នុងជំពូកទី ២ សមត្ថភាពបច្ចុប្បន្នក្នុងការគ្រប់គ្រងសំណល់រឹងក្នុងក្រុងភ្នំពេញនៅមានភាពខ្សោយ ដែលធ្វើឱ្យបរិស្ថានទីប្រជុំជនក្រុង និងជីវភាពប្រជាជនត្រូវទទួលបន្ទុកយ៉ាងធ្ងន់ ។ ស្ថានភាពនេះមានលក្ខណៈធ្ងន់ធ្ងរ ។

**គោលបំណងគ្រឹះនៃផែនការមេសំរាប់គ្រប់គ្រងសំណល់រឹងក្នុងក្រុងភ្នំពេញ គឺ : "ដើម្បីបង្កើតនូវប្រព័ន្ធគ្រប់គ្រងសំណល់រឹងដោយនិរន្តរភាពក្នុងក្រុងភ្នំពេញ ក្នុងឆ្នាំគោលដៅ ២០១៥"** ។

ការបង្កើតប្រព័ន្ធនេះគឺដើម្បី :

- ថែរក្សាបរិស្ថានទីប្រជុំជន និងសុខភាពសាធារណៈក្នុងក្រុងភ្នំពេញដែលជាមជ្ឈមណ្ឌល នៃសកម្មភាពសេដ្ឋកិច្ច និងឧស្សាហកម្មរបស់ព្រះរាជាណាចក្រកម្ពុជា និងដែលមានប្រជាជន ៨,៧% នៃប្រជាជនសរុបទូទាំងប្រទេស (ជំរឿនក្នុងឆ្នាំ១៩៩៨) ហើយដែលជាការអភិវឌ្ឍន៍ដល់ជីវភាពនៅតាមទីប្រជុំជនក្នុងក្រុង ។
- ជំរុញលើកទឹកចិត្តការវិនិយោគបរទេសដែលអាចឱ្យសេដ្ឋកិច្ចប្រទេសកម្ពុជាមានការវិវត្តន៍ ។

នៅក្នុងប្រព័ន្ធគ្រប់គ្រងសំណល់រឹងដោយនិរន្តរភាពស្ថានភាពដូចខាងក្រោមនេះគួរតែត្រូវបានបង្កើតឡើង ។

- ការកាត់បន្ថយសំណល់ ត្រូវបានលើកទឹកចិត្តនៅតាមប្រភពបង្កើតសំណល់ដូចជាតាមផ្ទះ និងតាមកន្លែងធ្វើការ ។
- សំណល់ដែលបានបង្កើតរួចក្រោយពេលមានការព្យាយាមកាត់បន្ថយ ត្រូវបានយកមកប្រើប្រាស់ឡើងវិញ ឬកែច្នៃឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន ។
- មានតែការខិតខំកាត់បន្ថយ ប្រើប្រាស់ឡើងវិញ ឬកែច្នៃនេះទេ ទើបសំរាមអាចប្រមូល ធ្វើប្រព្រឹត្តិកម្ម និងចាក់ចុងក្រោយបានត្រឹមត្រូវដោយគ្មានហេតុប៉ះពាល់បរិស្ថានជាអវិជ្ជមាន ។
- ប្រព័ន្ធគ្រប់គ្រងសំណល់រឹងនេះ នឹងត្រូវបានបង្កើតតាមរយៈតំរូវការទទួលខុសត្រូវរបស់រដ្ឋាភិបាលទៅតាមវិស័យអង្គភាពឯកជន និងស្ថាប័នសាធារណៈទូទៅ ក្រោមបទបញ្ញត្តិដែលមានតម្លាភាព និងត្រឹមត្រូវ ។

វិធីសាស្ត្រដើម្បីឱ្យសំរេចដល់គោលដៅជាក់លាក់ មានសង្ខេបដូចខាងក្រោមនេះ ។

### 3.1.2 ឆ្នាំគោលដៅ

ឆ្នាំគោលដៅរបស់ផែនការមេ គឺ ២០១៥ ។ ដើម្បីសំរេចគោលដៅផែនការមេជាបណ្តើរៗ រយៈពេលនៃការធ្វើផែនការមេត្រូវបានបែងចែកជា ៣ដំណាក់កាល ដូចតទៅ :

**ដំណាក់កាលទី ១: ២០០៥-២០០៧ (កែលំអបន្ទាន់)**[៤]

[៤] ស្របពេលដែលសំណើពង្រីកទីលាន ៦,០ ហ.ត ត្រូវបានផ្លាស់មកត្រឹមតែ ៣,៦ ហ.តវិញ សមត្ថភាពផ្ទុករបស់ទីលានចាក់សំរាមស្ទឹងមានជ័យ ត្រូវកាត់បន្ថយស្មើរតែពេញមួយឆ្នាំប្រតិបត្តិការណ៍ ។ ហេតុដូច្នេះ ឆ្នាំដំបូងនៃការ កែលំអជាបន្ទាន់ ត្រូវបានបង្ខំចាប់ពីឆ្នាំ ២០០៨ មកឆ្នាំ ២០០៧ វិញ ។

ដើម្បីអភិវឌ្ឍន៍ទីលានថ្មី ស្របពេលដែលទីលានទៅស្ទឹងមានជ័យត្រូវបានកែលំអ ។ ប្រព័ន្ធប្រមូលសំរាមក្រោមកិច្ចសហការជាមួយដៃគូរការងារ ស្ថាប័នសាធារណៈ ស្ថាប័នឯកជន ត្រូវបានបង្កើតឡើង ។

**ដំណាក់កាលទី ២: ២០០៨-២០១២ (កែលំអរយៈពេលខ្លី)**

ទីលានចាក់សំរាមថ្មី និងប្រព័ន្ធប្រមូលដែលត្រូវបង្កើតនៅក្នុងដំណាក់កាលនេះ ត្រូវបានប្រតិបត្តិការណ៍ត្រឹមត្រូវ ។

**ដំណាក់កាលទី ៣: ២០១៣-២០១៥ (កែលំអរយៈពេលមធ្យម)**

គោលដៅនៃផែនការមេត្រូវបានសំរេចហើយការរៀបចំការងារសំរាប់គោលដៅផែនការបន្ទាប់ ដែលមាកំរិតគ្រប់គ្រងខ្ពស់នឹងត្រូវចាប់ផ្តើម ។

# 3.2 គ្របខ័ណ្ឌការងារសំរាប់ធ្វើផែនការមេ

## 3.2.1 ការព្យាករណ៍ចំនួនប្រជាជន

មានការបញ្ជាក់ដែរថា តួលេខចំនួនប្រជាជននាពេលអនាគតដែលបានធ្វើការព្យាករណ៍រួចនៅក្នុងការសិក្សាអំពីផែនការ មេលើការដឹកជញ្ជូនក្នុងក្រុងភ្នំពេញ : ខែកញ្ញា ឆ្នាំ២០០១ ដោយ JICA ត្រូវបានយកមកប្រើ ក្នុងការសិក្សានេះដូច មានបញ្ជាក់ក្នុងកិច្ចប្រជុំស្តីពីរបាយការណ៍បណ្តោះអាសន្នដែលរៀបចំធ្វើកាលពីថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០៣ ។ ចំនួន ប្រជាជនព្យាករណ៍សំរាប់ឆ្នាំ ២០១៥ មាន ១,៧លាន គឺប្រហែល ២០០.០០០នាក់ តិចជាងចំនួនដែលបាន រំពឹងទុកដោយវិទ្យាស្ថានជាតិស្ថិតិ ។ ដោយសារតែភាពខុសគ្នានេះមានទំហំធំពេកនោះក្រុម សិក្សាបានធ្វើការប៉ាន់ស្មានរយះពេលលៃការប្រតិបត្តិកានៃទីលានថ្មី ដោយយោងលើការព្យាករណ៍ចំនួនប្រជាជនធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិ ដែលជាសេណារីយ៉ូដ៏ល្អបំផុត។

Table 3-1: ព្យាករណ៍ចំនួនប្រជាជន

| ខ័ណ្ឌ | ២០០៣ | ២០០៧ | ២០១២ | ២០១៥ |
|---|---|---|---|---|
| ១. ចំការមន | ២០៨.៧៥០ | ២២៧.៦៦៤ | ២៤៦.៧៧៧ | ២៥៣.៩៣៥ |
| ២. ដូនពេញ | ១៣៧.១៨៦ | ១៤១.៧៤៤ | ១៤៦.៣២០ | ១៤៨.០២៨ |
| ៣. ៧ មករា | ១០៤.០១៣ | ១១០.៨១៥ | ១១៧.៦៨១ | ១២០.២៥៣ |
| ៤. ទួលគោក | ១៧៨.៣៧៣ | ១៩៩.១១៥ | ២២០.១០៩ | ២២៧.៩៤១ |
| **ខ័ណ្ឌតាមទីប្រជុំជនក្នុងក្រុង** | **៥៧១,០៩២** | **៦៧៩,៣៣៨** | **៧៣០,៨៨៧** | **៧៥០,១៥៧** |
| ៥. ដង្កោ | ១១៤.៣៣៣ | ១២៦.៩០៤ | ១៦១.៨៧១ | ២០៨.១៣៦ |
| ៦. មានជ័យ | ២១០.០២៧ | ២៥៨.៣៣៦ | ៣០៧.២៩៥ | ៣២៥.៤៨៩ |
| ៧. ឫស្សីកែវ | ២៤៦.៧៣២ | ៣០៧.៤០៣ | ៣៨១.៣៧៩ | ៤១៨.៣៨៤ |
| **ខ័ណ្ឌទាំង៣ តាមជាយក្រុង** | **៥៧១.០៩២** | **៦៩២.៦៤៣** | **៨៥០.៥៤៥** | **៩៥២.០០៩** |
| ភ្នំពេញទាំងមូល | **១.១៩៩.៤១៤** | **១.៣៧១.៩៨១** | **១.៥៨១.៤៣២** | **១.៧០២.១៦៦** |

### 3.2.2 ក្របខ័ណ្ឌសេដ្ឋកិច្ច

ក្រុមសិក្សាប្រើអត្រាកំណើនសេដ្ឋកិច្ចនិងអត្រាអតិផរណាដែលត្រូវបានព្យាករណ៍ក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច ៥ឆ្នាំ សំរាប់ក្របខ័ណ្ឌសេដ្ឋកិច្ចរហូតដល់ឆ្នាំ២០០៥ និងត្រូវបានព្យាករណ៍សំរាប់បន្ទាប់ពីឆ្នាំ ២០០៦ ដោយផ្អែកលើ "ការបង្កើនអភិបាលកិច្ចល្អសំរាប់ការអភិវឌ្ឍន៍ប្រកបនិរន្តភាព" នៅឆ្នាំ២០០០ ដោយធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។

មានការរំពឹងទុក២ នៅក្នុងរបាយការណ៍របស់ ADB ។ មួយគឺត្រូវបានព្យាករណ៍ចំពោះសេណារីយ៉ូមួយដែលមិនមានការកែទំរង់ និងមួយទៀតគឺចំពោះសេរ៉ារីយ៉ូមួយដែលមានការកែទំរង់ ។ ក្រុមសិក្សាបានសំរេចទៅនឹងតំលៃដែលបានព្យាករណ៍ទុកចំពោះសេណារីយ៉ូដែលមានការកែទំរង់ជាអទិភាពដើម្បីចៀសវាងផលប៉ះពាល់គ្រោះថ្នាក់ផ្សេងៗដូចជាការផ្លាស់ប្តូរអនាម័យបរិស្ថានមានភាពស្រុតចុះ ដោយសារតែការពន្យានូវផែនការអភិវឌ្ឍន៍ទីលានថ្មី និងប្រព័ន្ធប្រមូលសំណល់ ដោយមូលហេតុនៃការគិតស្មានមិនដល់ ។ រដ្ឋាភិបាលកម្ពុជាបានជំរុញការកែទំរង់រដ្ឋបាលដោយផ្អែកលើសេណារីយ៉ូដែលត្រូវកែទំរង់ ។

Table 3-2: សន្ទស្សន៍សេដ្ឋកិច្ចក្នុងតំបន់សិក្សា

| | ២០០៣ | ២០០៤ | ២០០៥ | ២០០៥-២០១០ | ២០១០-២០១៥ |
|---|---|---|---|---|---|
| អត្រាកំណើនសេដ្ឋកិច្ច(%/ឆ្នាំ) | ៦,០ | ៦,៥ | ៧,០ | ៨,៤ | ៦,៨ |
| អត្រាអតិផរណា (%/ឆ្នាំ) | ៣,៧ | ៣,៧ | ៣,៧ | ៣.៤ | ៣,៥ |

### 3.2.3 ព្យាករណ៍បរិមាណ និងសមាសភាពសំណល់នាពេលអនាគត

**a. ព្យាករណ៍បរិមាណសំណល់ចាក់**

ក្រុមសិក្សាបានព្យាករណ៍អាត្រានៃការបង្កើតសំណល់ដោយផ្អែកទៅលើការប៉ាន់ស្មានថា វានឹងមានការកើនឡើងដោយសមមាត្រទៅនឹងកំណើន GDP ក្នុងម្នាក់ៗ ។ ស្ថិតិរបស់ជប៉ុនដែលមាននៅក្នុងតារាងពិភពលោកហើយដែលក្រុមសិក្សាបានធ្វើការស្រាវជ្រាវចាប់ពីឆ្នាំ ១៩៦៣ ដល់ ១៩៨៨ បង្ហាញថា និន្នាការនៃអាត្រានេះអាស្រ័យទៅលើការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច។ ក្រុមសិក្សានេះបានអនុម័តយកអត្រាកំណើន ៥០% ចាប់ពីឆ្នាំ ១៩៦៣ ដល់ ១៩៧០ ដែលជាឆ្នាំមានកំណើនសេដ្ឋកិច្ច ខ្ពស់ ប៉ុន្តែគ្មានវិធានការកាត់បន្ថយសំណល់ទេ ។ល។

ដោយយោងលើតួលេខខាងលើ ក្រុមសិក្សាបានធ្វើការសង្ខេបការកើនឡើងនៃសំណល់ដែលចាក់ក្នុងមួយនាក់ក្នុងមួយឆ្នាំ ដូចខាងក្រោម ។

២០០៣-២០០៥: ១.៧-២.០% ក្នុងមួយឆ្នាំ

២០០៦-២០១០: ២.៣% ក្នុងមួយឆ្នាំ

២០១៣-២០១៥: ១.៩% ក្នុងមួយឆ្នាំ

ទោះជាយ៉ាងណា ការកើនឡើងនៃសំណល់បញ្ចេញតាមឆ្នាំ ដូចដែលបានបង្ហាញខាងលើ នឹងមិនស៊ីសង្វាក់ទៅនិងការសំអាតជាសាធារណទេ ដូចជាការសំអាតផ្លូវ សួនច្បារ តែបរិមាណនេះនឹងកើនច្រើនតាមកំនើនប្រជាពលរដ្ឋការីកលាលដាលនៃទីក្រុងជាដើម ។

ម្យ៉ាងវិញទៀតចំនួនប្រភពបង្កើតសំណល់ត្រូវបានព្យាករណ៍ដោយផ្អែកទៅតាមការសន្មត់ថា វានឹងមានការកើនឡើងទៅតាមសមមាត្រនៃអត្រាកំណើន GDP ។

Table 3-3: ព្យាករណ៍ឯកត្តានៃការបង្កើតសំណល់

| ប្រភពបង្កើតសំណល់ | | ឯកតា | ២០០៣ | ២០០៧ | ២០១២ | ២០១៥ |
|---|---|---|---|---|---|---|
| តាមផ្ទះ | | ក្រ/ម្ន/ថ្ងៃ | ៤៨៧ | ៥២៩ | ៥៨៨ | ៦២២ |
| កន្លែងអាជីវកម្ម | ភោជនីយដ្ឋាន | ក្រ/តុ/ថ្ងៃ | ១.៦៦៤ | ១.៨០៧ | ២.០២០ | ២.១២៧ |
| | ហាងផ្សេងៗ | ក្រ/ហ/ថ្ងៃ | ៤.៥០២ | ៤.៨៨៩ | ៥.៤៣៨ | ៥.៧៥៤ |
| តាមផ្សារ | | ក្រ/តូ/ថ្ងៃ | ១.៨២៣ | ១.៩៨០ | ២.២០២ | ២.៣៣០ |
| សាលារៀន | | ក្រ/ម្ន/ថ្ងៃ | ២០ | ២២ | ២៤ | ២៦ |
| សំរាមបោសតាមផ្លូវ | | ក្រ/គ.ម/ថ្ងៃ | ៥៣.៣៧៣ | ៥៣.៣៧៣ | ៥៣.៣៧៣ | ៥៣.៣៧៣ |
| សណ្ឋាគារ | | ក្រ/ប/ថ្ងៃ | ២៣១ | ២៥១ | ២៧៩ | ២៩៥ |
| កន្លែងធ្វើការ | | ក្រ/ការិ/ថ្ងៃ | ៣.៥៦០ | ៣.៨៦៦ | ៤.៣០០ | ៤.៥៥០ |

Table 3-4: ព្យាករណ៍ចំនួនប្រភពចាក់សំណល់

| ប្រភពបង្កើតសំណល់ | | ឯកតា | ២០០៣ | ២០០៧ | ២០១២ | ២០១៥ |
|---|---|---|---|---|---|---|
| តាមផ្ទះ | ជនបទ | នាក់ | ៥៧១.០៩២ | ៦៩២.៦៤៣ | ៨៥០.៥៤៥ | ៩៥២.០០៩ |
| | ទីប្រជុំជន | | ៦២៣.៣២២ | ៦៧៩.៣៣៨ | ៧៣០.៨៨៧ | ៧៥០.១៥៧ |
| | សរុប | | ១.១៩៩.៤១៤ | ១.៣៧១.៩៨១ | ១.៥៨១.៤៣២ | ១.៧០២.១៦៦ |
| កន្លែងអាជីវកម្ម | ភោជនីយដ្ឋាន | តុ | ២៧.៨០៨ | ៣២.២៨៥ | ៣៩.០៧០ | ៤៣.១៨៦ |
| | ហាងផ្សេងៗ | ហាង | ៣៣.៥២៤ | ៣៨.៩២១ | ៤៧.១០១ | ៥២.០៦៣ |
| តាមផ្សារ | | តូប | ៥១.៧៦៦ | ៦០.១០០ | ៦២.៦៣៧ | ៨០.៣៩៣ |
| សាលារៀន | | សិស្ស | ៣៨៥.០១៣ | ៤៤៧.០០០ | ៥៤០.៩៤៣ | ៥៩៧.៩២៥ |
| សណ្ឋាគារ | | បន្ទប់ | ១៣.៣៨៥ | ១៥.៥៤០ | ១៨.៨០៦ | ២០.៧៨៧ |
| កន្លែងធ្វើការ | | ការិយាល័យ | ៣៦៨ | ៤២៧ | ៥១៧ | ៥៧២ |

ដូច្នេះហើយ ចំនួនបង្កើតឡើងនៃសំណល់គឺប៉ាន់ស្មានទៅតាមបរិមាណប្រភពបង្កើត និងចាក់សំណល់ ។

Table 3-5: ព្យាករណ៍បរិមាណបង្កើតសំណល់

| តំបន់ | ឯកតា | ២០០៣ | ២០០៧ | ២០១២ | ២០១៥ |
|---|---|---|---|---|---|
| ទូទាំងក្រុងភ្នំពេញ | តោន/ថ្ងៃ | ៩២៧,៨ | ១.១៥៨,៧ | ១.៥១១,៩ | ១.៧៣៩,៣ |
| តំបន់ទីប្រជុំជន | តោន/ថ្ងៃ | ៥៥៦,១ | ៦៥៩,៤ | ៨០៨,៤ | ៨៩៤,២ |
| តំបន់ជាយក្រុង | តោន/ថ្ងៃ | ៣៧១,៧ | ៤៩៩,៣ | ៧០៣,៥ | ៨៤៥,១ |

**b. ព្យាករណ៍សមាសភាពសំណល់**

សមាសភាពសំណល់នៅពេលអនាគត ត្រូវបានព្យាករណ៍ដោយធ្វើការប្រៀបធៀបលទ្ធផលនៃការស្រាវជ្រាវ បរិមាណ និងសមាសភាពជាមួយនឹងទិន្នន័យសំណល់ដែលមាននៅតាមប្រទេសផ្សេងៗទៀត ។ ការព្យាករណ៍នេះផ្អែកជាចំបងទៅ លើការសន្មត់ដូចតទៅ :

- សារៈសំខាន់នៃការប្រែប្រួលទំលាប់ចំណីអាហារ និងបរិស្ថានរស់នៅ មិនត្រូវបានរំពឹងទុក ។ ហេតុដូច្នេះ បរិមាណចាក់សំណល់ផ្ទះបាយ សំណល់សួនច្បារ ( ស្មៅ កំទេចព័រស៊ីឡែន កៅស៊ូ ស្បែក និងថ្ម ។ល។) ដែលបានចាក់ចោលត្រូវបានសន្មត់ថានៅដដែល ។
- បរិមាណសំណល់ចាក់ចោលនៃប្រភេទគ្រឿងវេចខ្ចប់ ដូចជា ក្រដាស ប្លាស្ទិច ដប និងកែវ ត្រូវបានសន្មត់ថាមានការកើនឡើង អាស្រ័យទៅនឹងកំណើនសេដ្ឋកិច្ច ។

Table 3-6: ព្យាករណ៍សមាសភាពសំណល់

| ចំណាត់ថ្នាក់ | | | ២០០៣ | ២០០៧ | ២០១២ | ២០១៥ |
|---|---|---|---|---|---|---|
| សំណល់ងាយឆេះ | ក្រដាស | % | ៦.៤ | ៨.៥ | ៩.៩ | ១០.៩ |
| | ជ័រ និងស្បែក | % | ០.១ | ០.១ | ០.១ | ០.១ |
| | សំណល់ផ្ទះបាយ | % | ៦៣.៣ | ៥៦.៣ | ៥១.៤ | ៤៧.៩ |
| | សំណល់វាយនភ្ណ | % | ២.៥ | ៣.៣ | ៣.៨ | ៤.២ |
| | ប្លាស្ទិច | % | ១៥.៥ | ២០.២ | ២៣.៧ | ២៥.៩ |
| | ស្មៅ និងកំទេចឈើ | % | ៦.៨ | ៦.១ | ៥.៥ | ៥.២ |
| | សរុបតាមផ្នែក | % | ៩៤.៦ | ៩៤.៥ | ៩៤.៤ | ៩៤.២ |
| សំណល់មិនឆេះ | លោហៈ | % | ០.៦ | ០.៩ | ១.០ | ១.១ |
| | កែវ និងដប | % | ½ | ១.៥ | ១.៨ | ២.០ |
| | ព័រស៊ីឡែន និងថ្ម | % | ១.៥ | ½ | ១.១ | ១.១ |
| | ផ្សេងៗ | % | ២.១ | ១.៩ | ១.៧ | ១.៦ |
| | សរុបបន្ទាប់ | % | ៥.៤ | ៥.៥ | ៥.៦ | ៥.៨ |
| សរុប | | % | ១០០.០ | ១០០.០ | ១០០.០ | ១០០.០ |

## 3.2.4 ព្យាករណ៍សំណល់ឧស្សាហកម្ម និងវេជ្ជសាស្ត្រ

បរិមាណសំណល់វេជ្ជសាស្ត្រ និងឧស្សាហកម្មដែលបានបង្កើតក្នុងក្រុងភ្នំពេញ ត្រូវបានព្យាករណ៍ដូចមានបង្ហាញក្នុងតារាង ខាងក្រោមយោងទៅតាមលទ្ធផលនៃការស្រាវជ្រាវលើស្ថាប័នវេជ្ជសាស្ត្រ រោងចក្រ និងអត្រាកំណើនសេដ្ឋកិច្ច ។

Table 3-7: ព្យាករណ៍នៃការបង្កើតសំណល់វេជ្ជសាស្ត្រ

| ដំណាក់កាល<br>ផ្នែក | បច្ចុប្បន្ន<br>(២០០៣) | ដំណាក់កាលទី ១<br>(២០០៧) | ដំណាក់កាលទី ២<br>(២០១២) | ដំណាក់កាលទី ៣<br>(២០១៥) |
|---|---|---|---|---|
| ការបង្កើត (ត/ថ្ងៃ) | ទូទៅ ៩.៧<br>វេជ្ជសាស្ត្រ ០.៥៦ | ទូទៅ ១២.៣<br>វេជ្ជសាស្ត្រ ១.២២ | ទូទៅ ១៦.៥<br>វេជ្ជសាស្ត្រ ១.៦៣ | ទូទៅ ១៩.៣<br>វេជ្ជសាស្ត្រ ១.៩១ |

Table 3-8: ព្យាករណ៏នៃការបង្កើតសំណល់ឧស្សាហកម្ម

| ដំណាក់កាល<br>ផ្នែក | បច្ចុប្បន្ន<br>(២០០៣) | ដំណាក់កាលទី ១<br>(២០០៧) | ដំណាក់កាលទី ២<br>(២០១២) | ដំណាក់កាលទី ៣<br>(២០១៥) |
|---|---|---|---|---|
| ការបង្កើត (ត/ថ្ងៃ) | ទូទៅ ២៩,៧<br>ឧស្សាហកម្ម ២៨,៥ | ទូទៅ ៣៧,៥<br>ឧស្សាហកម្ម ៣៦,០ | ទូទៅ ៥០,៥<br>ឧស្សាហកម្ម ៤៨,៥ | ទូទៅ ៥៩,០<br>ឧស្សាហកម្ម ៥៦,៦ |

## 3.3 ការជ្រើសរើសប្រព័ន្ធបច្ចេកទេសប្រសើរបំផុត

ក្រុមសិក្សាបានជ្រើសរើសប្រព័ន្ធបច្ចេកទេសប្រសើរបំផុតដូចមានបង្ហាញក្នុងតារាងខាងក្រោម សំរាប់ធ្វើការគ្រប់គ្រងសំណល់រឹងក្នុងក្រុងភ្នំពេញ ក្នុងចំណោមប្រព័ន្ធបច្ចេកទេសមួយចំនួន ។

Table 3-9: : ការជ្រើសរើសប្រព័ន្ធបច្ចេកទេសប្រសើរបំផុត

| ការងារ | ប្រព័ន្ធស្នើ |
|---|---|
| **ការទុក និងការចាក់** | • វិធីទុក : ថង់ប្លាស្ទិច<br>• ការណែនាំលើបទបញ្ញត្តិចាក់ : វិធីចាក់តាមស្តង់ដា ពេលម៉ោងចាក់<br>• វិធីចាក់:ចាក់ទុកក្នុងកុងទែន័រកញ្ជេរធ្វើពីឬស្សី និងទប់ស្កាត់ចំពោះការពង្រាយសំណល់<br>• ការញែកតាមប្រភព(នៅក្នុងតំបន់ដែលមានមណ្ឌលកែច្នៃ) :ការញែកសំណល់ដែលអាចរលួយ និងមិនរលួយ ។ |
| **ការប្រមូល** | ***<u>តំបន់មានសេវាកម្ម រ.គ.ស.ភ</u>***<br>• ចំនួនដងនៃការប្រមូលៈច្រើនជាង៣ដងក្នុងមួយសប្តាហ៏(រាល់ថ្ងៃសំរាប់សំណល់ អាជីវកម្ម) ។<br>វិធីប្រមូលៈប្រមូលចំរុះ និងប្រមូលដោយញែក : ញែកការប្រមូល (នៅតំបន់ដែលនឹងមានមណ្ឌលកែឆ្នៃ) ។<br>• ប្រព័ន្ធប្រមូល : ដោយរទេះរុញ និងដោយរថយន្ត ចំរុះគ្នា ប្រមូលតាមចិញ្ចើមថ្នល់ និងមានស៊ីប្លេ ។<br>• ពេលម៉ោងប្រមូល : ប្រមូលពេលថ្ងៃ<br>• រថយន្តប្រមូលសំរាម : ប្រភេទរថយន្ត Skip Loader trucks, Compactor trucks (១៥ម$^{៣}$ និង ៨ម$^{៣}$) ។<br>• ប្រព័ន្ធដឹកជញ្ជូន : ដឹកផ្ទាល់ពីចំណុចប្រមូល គួរពិចារណាលើស្ថានីយផ្ទេរផ្អែកទៅតាមទីតាំងទីលានចាក់សំរាម និងប្រសិទ្ធិភាពការងារ ។<br>**<u>តំបន់មានសេវាកម្មក្រុមហ៊ុនស៊ីនទ្រី</u>**<br>ប្រព័ន្ធប្រមូលធ្វើឡើងតាមរយៈក្រុមហ៊ុនស៊ីនទ្រី ។ |
| **ការបោសសំអាតថ្នល់** | • បោសដោយដៃនៅតំបន់មានសេវាកម្ម រ.គ.ស.ភ<br>• បោសដោយដៃ និងដោយគ្រឿងចក្រ នៅតំបន់មានសេវាកម្មក្រុមហ៊ុនស៊ីនទ្រី<br>• សំរាមនៅតាមសួនច្បារ ជាទូទៅប្រមូលតាមធុងកុងទែន័ររួម |
| **ការកែច្នៃ** | • សកម្មភាពកែច្នៃត្រូវបានលើកទឹកចិត្តតាមរយៈការជួយគាំទ្រ រ.គ.ស.ភ និងកម្មវិធីអប់រំ |
| **ប្រព្រឹត្តិកម្មពាក់កណ្តាលសំរេច** | **<u>ការធ្វើជីកំប៉ុស្ត និងការញែកនៅមជ្ឈមណ្ឌលកែច្នៃ</u>**<br>• **សំណល់មិនរលួយ** ញែកដោយដៃ<br>• **សំណល់រលួយ** រោងចក្រធ្វើជីកំប៉ុស្ត<br>• **សំណល់ក្រោយពីញែកក្នុងរោងចក្រនិងពីការផលិតជីកំប៉ុស្ត** ទីលានបច្ចេកទេស |

| ការងារ | ប្រព័ន្ធស្នើ |
|---|---|
| | **<u>ការធ្វើជីកំប៉ុស្តនៅទីលាន</u>**<br>• **សំណល់រលួយ** រោងចក្រធ្វើជីកំប៉ុស្ត<br>• **សំណល់ក្រោយពីញែកក្នុងរោងចក្រនិងពីការផលិតជីកំប៉ុស្ត** ទីលានបច្ចេកទេស |
| **ទីលានចាក់ចុងក្រោយ** | • លើកស្ទួយដល់គំរោងជាអាទិភាពទីមួយ ចំពោះការសាងសង់ទីលានបច្ចេកទេស<br>• ទីលានបច្ចេកទេសដែលមានបំពាក់ប្រព័ន្ធប្រព្រឹត្តិកម្មទឹកស្អុយត្រូវបានអនុវត្ត |
| **ឧបករណ៍និងគ្រឿងចក្រប្រតិបត្តិការណ៍ និងការថែទាំ** | • សំរាមនៅតាមសួនច្បារជាទូទៅប្រមូលតាមធុងកុងទែន័រ រួមបង្កើតរោងជាងតូចមួយសំរាប់ការងារជួសជុលតូចតាច<br>• ការជួសជុលក៏រិតធំ នឹងត្រូវយកទៅរោងជាងឯកជន |
| **ការគ្រប់គ្រងសំណល់រឹងវេជ្ជសាស្ត្រ** | • សំរាមនៅតាមសួនច្បារជាទូទៅប្រមូលតាមធុងកុងទែន័ររួមសំណល់ឆ្លងនិងសំណល់គ្រោះថ្នាក់ត្រូវយយកចេញពីសំណល់ធម្មតា មុននឹងយកទៅចាក់នៅទីលាន ។<br>• រាល់សំណល់ឆ្លង និងសំណល់គ្រោះថ្នាក់ដែលមាននៅក្នុងតំបន់គោលដៅនឹងត្រូវរំលាយនៅក្នុងឡដុត ដែលនឹងត្រូវបង្កើតឡើងសំរាប់ធ្វើប្រព្រឹត្តិកម្មលើសំណល់ទាំងនេះក្រោមការពិនិត្យរបស់ ក្រសួងសុខាភិបាល និងក្រសួងបរិស្ថាន ។ |
| **ការគ្រប់គ្រងសំណល់ឧស្សាហកម្ម** | សំរាមនៅតាមសួនច្បារ ជាទូទៅប្រមូលតាមធុងកុងទែន័ររួម សំណល់ឧស្សាហកម្មគ្រោះថ្នាក់ ត្រូវញែកចេញពីសំណល់ធម្មតា មុនពេលយកទៅចាក់នៅទីលានចុងក្រោយ ។<br>• រាល់សំណល់ឧស្សាហកម្មគ្រោះថ្នាក់ដែលមាននៅក្នុងតំបន់គោលដៅ នឹងត្រូវចាក់នៅទីលានដោយឡែកក្រោមការយល់ព្រមពីក្រសួងបរិស្ថាន ។ |

## 3.4 បញ្ហាស្ថាប័ន

ការពិចារណាលើស្ថាប័ន ដូចជាការកែសំរួលប្រព័ន្ធផ្ដាច់មុខលើការប្រមូលសំរាម យុទ្ធសាស្ត្រពង្រឹង រ.គ.ស.ភ ដែលជាភ្នាក់ងារអនុវត្ត និងអភិវឌ្ឍន៍លើប្រព័ន្ធច្បាប់ស្តង់ដាសំរាប់បង្កើតការងារគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ គឺមានសារៈសំខាន់សំរាប់បង្កើតផែនការមេគ្រប់គ្រងសំណល់រឹងក្រុងភ្នំពេញ ។

### 3.4.1 ប្រព័ន្ធច្បាប់

#### a. ការអភិវឌ្ឍន៍ចំណាត់ថ្នាក់សំណល់រឹងលំអិត

អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង បានចាត់ថាក់សំណល់រឹងជាប្រភេទសំណល់គ្មានគ្រោះថ្នាក់ និងប្រភេទគ្រោះថ្នាក់ហើយដែលការចាត់ថ្នាក់នេះមានលក្ខណៈសមហេតុសមផល ។

ដើម្បីបង្កើតការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវ ក្រុមសិក្សាបានដាក់ស្នើនូវចំណាត់ថ្នាក់លំអិតលើសំណល់រឹងសំរាប់ធ្វើការសិក្សា ដូចមានក្នុងតារាងខាងក្រោម ។

Table 3-10 ចំណាត់ថ្នាក់សំណល់រឹង

| ចំណាត់ថ្នាក់តាមអនុក្រឹ. | ចំណាត់ថ្នាក់តាមប្រភព | ចំណាត់រង | ចំណាត់ថ្នាក់លំអិត ឬអធិប្បាយ |
|---|---|---|---|
| សំណល់គ្មានគ្រោះថ្នាក់ | សំណល់ក្រុង | សំណល់ផ្ទះ | ១- សំណល់តាមផ្ទះ<br>២-សំណល់ស្ថាប័ន( សាលា កន្លែងធ្វើការរដ្ឋ ។ល ។)<br>៣-តំបន់សំអាតសាធារណៈ( ផ្លូវប្រព័ន្ធបង្ហូរ ។ល ។)<br>៤-ទឹកស្អុយ |
| | | សំណល់អាជីវកម្ម | ៥-សំណល់អាជីវកម្ម (ហាង ការិយាល័យ ភោជនីយដ្ឋាន សណ្ឋាគារ ។ល ។)<br>៦-សំណល់ផ្សារ<br>៧-សំណល់សំណង់ |
| | សំណល់ឧស្សាហ-រោងចក្រ | សំណល់ឧស្សាហកម្ម មិនគ្រោះថ្នាក់ | ៨-សំណល់ឧស្សាហកម្មមិនគ្រោះថ្នាក់មកពី ប្រភពមិនធ្វើផលិតកម្ម<br>៩-សំណល់ឧស្សាហកម្មមិនគ្រោះថ្នាក់មកពី ប្រភពដំណើរការផលិតកម្ម |
| | សំណល់វេជ្ជសាស្ត្រ | សំណល់វេជ្ជសាស្ត្រទូទៅ | ១០-សំណល់វេជ្ជសាស្ត្រមិនឆ្លងនិងមិនគ្រោះថ្នាក់ |
| | សំណល់កសិកម្ម[១] | សំណល់កសិកម្ម | ១១-សំណល់កសិកម្មមិនមានគ្រោះថ្នាក់ |
| សំណល់គ្រោះថ្នាក់ | សំណល់ក្រុង | សំណល់គ្រោះថ្នាក់ក្រុង | ១២-សំណល់គ្រោះថ្នាក់ក្នុងស្រុក<br>១៣-សំណល់គ្រោះថ្នាក់អាជីវកម្ម |
| | សំណល់ឧស្សាហ-រោងចក្រ | សំណល់ឧស្សាហកម្មគ្រោះថ្នាក់ | ១៤-សំណល់រោងចក្រមានគ្រោះថ្នាក់ |
| | សំណល់វេជ្ជសាស្ត្រ | សំណល់វេជ្ជសាស្ត្រ | ១៥-សំណល់វេជ្ជសាស្ត្រឆ្លង<br>១៦-សំណល់វេជ្ជសាស្ត្រគ្រោះថ្នាក់ |
| | សំណល់កសិកម្ម[១] | សំណល់កសិកម្មគ្រោះថ្នាក់ | ១៧-សំណល់កសិកម្មមានគ្រោះថ្នាក់ |

(ចំណាំ) [១] : ការសិក្សានេះមិនបានគិតបញ្ចូលនូវសំណល់កសិកម្មទេ

### b. ការរៀបចំបទបញ្ជាក្រុង លើការគ្រប់គ្រងសំណល់រឹង

អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹងបានចែងថាក្រសួងបរិស្ថានត្រូវបង្កើតគោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ មិនគ្រោះថ្នាក់ ។ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងមហាផ្ទៃ រួមគ្នាបានបង្កើត "ប្រកាសអន្តរក្រសួងស្តីពីការគ្រប់គ្រងសំណល់រឹង (សំណល់មិនគ្រោះថ្នាក់) នៅតាមខេត្តក្រុងក្នុងព្រះរាជាណាចក្រកម្ពុជា" កាលពីថ្ងៃ ទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៣ ។ ឆ្លើយតបទៅនឹងប្រកាសនេះ ម.ប.ស្ត រាជធានី បានរៀបចំពង្រាងណែនាំសំរាប់ដឹកនាំ អនុវត្តប្រកាសអន្តរក្រសួង ប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន លេខ ៨០ ចុះថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីកាគ្រប់គ្រងសំណល់រឹងក្រុងភ្នំពេញ ដើម្បីបង្កើតបទបញ្ជាក្រុងមួយស្តីពីការគ្រប់គ្រងកាកសំណល់រឹងក្នុងទីក្រុងភ្នំពេញ។ ដើម្បីធានាបាននូវការអនុវត្តន៍និងបង្កើតការគ្រប់គ្រងសំណល់រឹងក្នុងទីក្រុងភ្នំពេញបានត្រឹមត្រូវនោះ គឺតំរូវជាបន្ទាន់អោយមានការប្រជុំជាមួយប្រជាពលរដ្ឋដែលពាក់ព័ន្ធទាំងឡាយ ដើម្បីពិភាក្សាលើពង្រាងបទបញ្ជាក្រុង ។

c. គោលការណ៍ណែនាំសំរាប់គ្រប់គ្រងសំណល់រឹង

ទោះបីជាក្រសួងបរិស្ថានកំពុងនឹងបង្កើតគោលការណ៍ណែនាំមួយចំនួនសំរាប់គ្រប់គ្រងសំណល់រឹង ឱ្យបានសមស្របក៏ដោយ ក៏គោលការណ៍ណែនាំមួយចំនួនដូចខាងក្រោមនេះចាំបាច់ត្រូវរៀបចំជាបណ្តើរៗ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

- គោលការណ៍ណែនាំបច្ចេកទេស សំរាប់រៀបចំទីលាន និងប្រតិបត្តិការណ៍ ។
- បទបញ្ញាលំអិត និងគោលការណ៍ណែនាំសំរាប់ប្រមូល និងធ្វើប្រព្រឹត្តិកម្មសំណល់វេជ្ជសាស្ត្រ ។
- បទបញ្ញាលំអិតនិងគោលការណ៍ណែនាំសំរាប់គ្រប់គ្រងសំណល់គ្រោះថ្នាក់ដែលមិនមែនជាសំណល់វេជ្ជសាស្ត្រ ។
- បទបញ្ញា និងគោលការណ៍ណែនាំសំរាប់វិភាគហេតុប៉ះពាល់បរិស្ថាន និងការស្ទង់មតិសាធារណៈ ។
- គោលការណ៍ណែនាំសំរាប់បង្កើតប្រព័ន្ធប្រមូលសំរាមឱ្យបានសមស្របនៅតាមតំបន់ទីប្រជុំជនក្រីក្រ។ ដែលគ្មានលទ្ធភាពទទួលបានសេវាប្រមូលសំរាមជាប្រចាំ ។
- គោលការណ៍ណែនាំសំរាប់បង្កើតតម្លៃសេវា ការណែនាំលើការប្រមូល និងតម្លៃចាក់នៅទីលាន។
- បទបញ្ញាលើការផ្តត់ផ្តង់និងគោលការណ៍ណែនាំសំរាប់ការចែងកិច្ចសន្យាលើប្រភេទសេវាគ្រប់គ្រង។ សំណល់រឹងរួមបញ្ចូលទាំងគំរូកិច្ចសន្យា ។

ក្រុមសិក្សាបានផ្តល់ជាអនុសាសន៍ទៅក្រសួងបរិស្ថាន និងស្ថាប័នទទួលខុសត្រូវដើម្បីស្នើសុំកិច្ចសហការបច្ចេកទេសបរទេស សំរាប់ធ្វើការរៀបចំគោលការណ៍ណែនាំខាងលើនេះ ។

## 3.4.2 រដ្ឋបាល និងការរៀបចំ

a. ការបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវលើការគ្រប់គ្រងសំណល់រឹង

បច្ចុប្បន្ន តួនាទី និងការទទួលខុសត្រូវលើការគ្រប់គ្រងសំណល់រឹងក្នុងក្រុងភ្នំពេញ មានភាពស្រពេចស្រពិល និងឬជាន់គ្នានៅតាមមន្ទីរនាយកដ្ឋាន និងអង្គភាពមួយចំនួនចំណុះឱ្យសាលាក្រុងភ្នំពេញ។ ទោះបីជាការធ្វើសមាហរណកម្មនេះមានលក្ខណៈខ្ពស់ទៅលើការធ្វើសេចក្តីសំរេចរបស់សាលាក្រុង (ផ្នែកនយោបាយ) ក្រុមសិក្សាបានស្នើនូវការទទួលខុសត្រូវលើការគ្រប់គ្រងសំណល់រឹងក្នុងក្រុងភ្នំពេញនៃសាលាក្រុងភ្នំពេញ ហើយដែលបានឯកភាពនៅក្នុងអង្គប្រជុំស្តីពីរបាយការណ៍បណ្តោះអាសន្ន ដែលបានប្រព្រឹត្តិទៅកាលពី ខែកញ្ញា ឆ្នាំ ២០០៣ :

- រ.គ.ស.ភ គឺជាអង្គភាពផ្តល់សេវាគ្រប់គ្រងសំណល់រឹង ចំណុះឱ្យសាលាក្រុងភ្នំពេញ
- ស.ក.ភ.ព ត្រួតពិនិត្យមើលការផ្តល់សេវាគ្រប់គ្រងសំណល់រឹងនេះ
- មន្ទីរបរិស្ថានរដ្ឋធានីមានតួនាទីជំរុញការទទួលខុសត្រូវសំរាប់ធ្វើការត្រួតពិនិត្យ និងអង្កេតលើសេវាគ្រប់គ្រងសំណល់រឹងដែលត្រូវផ្តល់ឱ្យដោយ រ.គ.ស.ភ និងអ្នកម៉ៅការឯកជន ។

b. លក្ខន្តិកៈរបស់ រ.គ.ស.ភ

ទោះបីជាលក្ខន្តិកៈ រ.គ.ស.ភ ត្រូវបានព្រមព្រៀងដោយ សាលាក្រុងភ្នំពេញកាលពីថ្ងៃទី៩ ខែកញ្ញា ឆ្នាំ ២០០៣ ហើយក៏ដោយ ក៏វានៅមិនទាន់ត្រូវបានរដ្ឋាភិបាលផ្តល់អំណាចឱ្យនៅឡើយដែរ គឺថា រ.គ.ស.ភ នៅខ្វះឯករាជ្យភាព និងអំណាចនៅតាមតំបន់ជាក់ស្តែង ដើម្បីអនុវត្តអណត្តិរបស់ខ្លួនដូចមានរៀបរាប់ពីខាងលើ ។ អភិបាលរាជធានីភ្នំពេញ បានចាត់តាំង និងកំណត់នូវក្រុមគ្រប់គ្រងមួយក្រុម (អភិបាល និងអភិបាលរងនៃ រ.គ.ស.ភ) ។ ក្នុងន័យនេះ អភិបាល

រ.គ.ស.ភ គួរតែជ្រើសរើសអនុរបស់ខ្លួនតាមការចាត់តាំង ដែលមានការអនុម័តដោយគណៈកម្មាធិការទទួលបន្ទុកខាងអាជីវកម្ម ។ ទង្វើដូចនេះអាចធ្វើឱ្យអភិបាល រ.គ.ស.ភ មានការទទួលខុសត្រូវច្រើនលើសកម្មភាពគ្រប់គ្រងរដ្ឋាករ ។

កំរិតទាបនៃប្រាក់បៀវត្សរ៍បច្ចុប្បន្ន នាំឱ្យមានអំពើពុករលួយលើកម្លាំងពលកម្ម និងកាត់បន្ថយនូវប្រសិទ្ធិភាព និងសក្តានុភាពជាក់ស្តែង ។ ស្ថិតក្រោមកាលៈទេសៈនេះ រ.គ.ស.ភ អាចជួបប្រទះនឹងផលវិបាកជាមួយអ្នកម៉ៅការឯកជន ។ គណៈកម្មាធិការទទួលបន្ទុកខាងអាជីវកម្មគួរតែមានអំណាចលើការកំណត់ប្រាក់បៀវត្សរ៍ដោយយោងទៅតាមផែនការចីរភាពអាជីវកម្ម ។

លក្ខន្តិកៈរបស់ រ.គ.ស.ភ បានចែងថា រ.គ.ស.ភ ត្រូវត្រួតពិនិត្យ និងអង្កេតតាមដានសកម្មភាពសំអាតដែលធ្វើដោយក្រុមហ៊ុនឯកជន ប៉ុន្តែទោះយ៉ាងណាក៏ដោយ វាមានភាពចំរូងចំរាស់គ្នារវាងស្ថាប័នប្រតិបត្តិ និងអ្នកចាត់ចែងការ ។

ក្រុមសិក្សាបានផ្តល់ជាអនុសាសន៍ថា មន្ទីរបរិស្ថានរាជធានីគួរតែជាស្ថាប័នត្រួតពិនិត្យ និងអង្កេតតាមដានលើសេវាសំអាតដែលផ្តល់ដោយក្រុមហ៊ុនឯកជន និងស្ថាប័នសាធារណៈ ហើយដែលសាលាក្រុងបានឯកភាពទៅលើសំណើនេះនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំ។ ចាប់តាំងពីលក្ខន្តិកៈបច្ចុប្បន្នរបស់ រ.គ.ស.ភ មានចំណុចមួយចំនួនត្រូវធ្វើវិសោធនកម្មនោះក្រុមសិក្សាបានផ្តល់អនុសាសន៍ថាសាលាក្រុងគួរតែពិនិត្យវាឡើងវិញដោយយោងទៅតាមផែនការមេ ។

### 3.4.3 ដៃគូសាធារណៈ និងឯកជន

សាលាក្រុងគួរតែលប់បំបាត់នូវតំបន់ដែលគ្មានសេវាប្រមូលសំរាមឱ្យបានឆាប់តាមដែលអាចធ្វើបាន និងបង្កើតនូវ ប្រព័ន្ធអភិរក្សបរិស្ថានទីប្រជុំជនមួយដែលប្រជាជនរីករាយក្នុងការទទួលបានសេវាកម្មដោយស្មើភាពគ្នា ។

#### a. ការពណ៌នាស្តីពីការទទួលខុសត្រូវនិងតួនាទីរវាងសាលាក្រុងភ្នំពេញ និងអ្នកផ្តល់សេវាកម្មឯកជន

ក្រុមហ៊ុន ស៊ិនទ្រី ដែលជាក្រុមហ៊ុនឯកជនមួយមានសិទ្ធិក្នុងការផ្តល់សេវាប្រមូលសំរាមនៅក្នុងទីក្រុងភ្នំពេញទាំងមូល ដោយយោងលើកិច្ចសន្យាសម្បទានរយៈពេលវែងនោះ មិនអាចផ្តល់សេវាកម្មប្រមូលសំណល់ដល់តំបន់ដែលមិនមានកំរៃផ្នែកសេដ្ឋកិច្ចទេ ។ ហេតុដូច្នេះហើយបានជាស្ថាប័នសាធារណ ពោលគឺសាលាក្រុងភ្នំពេញត្រូវតែផ្តល់សេវាកម្ម ដល់តំបន់ទាំងនោះ ។ យោងលើស្ថានភាពបច្ចុប្បន្នតាមការសិក្សា ក្រុមសិក្សាបានស្នើរថា ក្រុមហ៊ុនឯកជនត្រូវផ្តល់សេវាកម្មនៅតំបន់ទីប្រជុំជន ៤ ខណ្ឌដែលមានសេវាកម្មគ្របដណ្តប់ប្រមាណ ៩០ភាគរយ ហើយអត្រាប្រមូលសំណល់គួរត្រូវឈានដល់កំរិតអតិបរិមារគឺ ១០០ភាគរយ នាឆ្នាំ ២០១២ ។ ស្របពេលគ្នានេះដែរ គេដឹងថាអត្រាប្រមូលសំណល់នៅខណ្ឌជនបទទាំងបីមានប្រមាណ ៥០ភាគរយ ហើយមាននៅសេសសល់តំបន់ជាច្រើនដែលមិនមានសេវាកម្ម (តាមរយៈការសិក្សា) ។ ទោះជាយ៉ាងណា វាជាការលំបាកណាស់សំរាប់ក្រុមហ៊ុនឯកជនដើម្បីផ្តល់សេវាកម្មទៅតំបន់ទាំងនោះ ដោយសារថាមិនមានផលកំរៃដែលនឹងទទួលបានមកវិញ ហើយស្របពេលដែលទីលំនៅរបស់ប្រជាពលរដ្ឋមានសភាពរាយប៉ាយ និងប្រាក់ចំនូលប្រចាំគ្រួសារនៅមានកំរិតទាប ។ ដោយយោងលើសភាពការនេះ ក្រុមសិក្សាបានស្នើអោយមានការសហការគ្នារវាងស្ថាប័នរដ្ឋ និងឯកជនដើម្បីលុបបំបាត់តំបន់គ្មានសេវាកម្មនានានៅក្នុងខណ្ឌជាយក្រុងទាំងបី ក្រោមកិច្ចសហការគ្នា។ ក្រុមសិក្សាបានធ្វើវិសោធន៍កម្មលើការទទួលខុសត្រូវលើតំបន់សេវាកម្មទាំងស្រុង និងតួនាទីរបស់រដ្ឋាករ និងក្រុមហ៊ុនស៊ីនទ្រី ។ រដ្ឋាករ និងក្រុមហ៊ុន ស៊ីនទ្រីត្រូវតែសំរេចអោយបាននូវផែនកាមេដែលមានចែងក្នុងជំពូក ៣-១១ តាមតំបន់សេវាដែលទទួលខុសត្រូវរៀង ៗខ្លួន ។

Table 3-11: ការស្នើរការទទួលខុសត្រូវរវាងសេវាករទាំងពីរ

| តំបន់ / ការងារ | ខណ្ឌប្រជុំជន ៤ | ខណ្ឌជនបទ ៣ |
|---|---|---|
| ត្រួតពិនិត្រ និងតាមដាន | MPP | MPP |
| ប្រមូល និងដឹកជញ្ជូន | CINTRI | PPWM/CINTRI |
| ប្រព្រឹត្តកម្ម និងកែឆ្នៃ | CINTRI | PPWM/CINTRI |
| ទីលានចាក់សំណល់ | PPWM | PPWM |
| សំអាតសាធារណ | CINTRI | PPWM/CINTRI |
| ការប្រមូលកំរៃសេវា | CINTRI | PPWM/CINTRI |

ដោយយោងលើតួនាទី និងការទទួលខុសត្រូវខាងលើ សាលាក្រុង និងក្រុមហ៊ុន ស៊ីនទ្រីបានបង្កើតក្រុមការងារកាលពីពាក់កណ្តាលខែមករា ឆ្នាំ២០០៥ ដែលមានតួនាទីកំណត់តំបន់ដែលមិនមានសេវាកម្មផ្តល់ដោយក្រុមហ៊ុនស៊ីនទ្រីនាពេលបច្ចុប្បន្ន ។ ទោះជាយ៉ាងនេះក្តី ភាគីទាំងពីរមិនបានសំរេចនូវកិច្ចព្រមព្រៀងស្តីពីការបែងចែកតំបន់គ្នាឡើយ ។

## b. កិច្ចសន្យាគ្រប់គ្រងសំរាប់ក្រុមហ៊ុនឯកជន

### b.1 មូលដ្ឋាននៃការពិចារណា

ការបង្ហាញហេតុផលយុត្តិកម្មសំរាប់លើកទឹកចិត្តដល់ក្រុមហ៊ុនឯកជនក្នុងការអនុវត្តន៍សេវាគ្រប់គ្រងសំណល់រឹង និង ដែលមានហេតុផលដូចតទៅ :

១. ដេញថ្លៃដោយចំហរ និងមានតម្លាភាព ទៅលើសេវាកិច្ចសន្យា ដែលនាំឱ្យមានតម្លៃទាបសំរាប់អ្នកប្រើប្រាស់

២. សកម្មភាពសេវា និងតម្លៃការងារឯកជនរបស់អ្នកម៉ៅការ ត្រូវបានដាក់ឱ្យមានការប្រកួតប្រជែង និងអង្កេតដោយមន្ទីរសំអាតក្រុង តាមរយៈការលើកទឹកចិត្តដល់អ្នកម៉ៅការដើម្បីរក្សានូវស្តង់ដាផ្តល់សេវាឱ្យមានកិរតខ្ពស់ និងមានតម្លៃទាប ។

៣. អ្នកម៉ៅការនឹងត្រូវទទួលខុសត្រូវចំពោះអតិថិជន និងអ្នកជាវលើស្តង់ដា និងបញ្ហាផ្សេងៗ ទៀតដែលខ្លួនបានផ្តល់ ។ ការពេញចិត្តរបស់អតិថិជននឹងជះឥទ្ធិពលដល់តម្លៃសេវាដែលក្រុមហ៊ុនបានដាក់ ផ្ទុយទៅវិញក្រុមហ៊ុនអាចនឹងត្រូវផាកពិន័យក្នុងករណីដែលមិនបានធ្វើតាមកិច្ចសន្យាលំអិតហើយដែលជំរុញឱ្យអ្នកម៉ៅការត្រូវតែធ្វើ ឱ្យសំរេចកិច្ចសន្យាលំអិតនោះ ។

៤. ចុងបញ្ចប់ ការធ្វើសវនកម្មគណនីរបស់អ្នកម៉ៅការ ដោយក្រុមហ៊ុនសវនកម្មឯករាជ្យអាចទុកចិត្តបាន និងធានាដល់តម្លាភាព និងការបញ្ចៀសខាននូវអំពើពុករលួយ ។

ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ លក្ខ័ណ្ឌមូលដ្ឋានភាគច្រើនសំរាប់ការបង្ហាញហេតុផលក្នុងការជំរុញឱ្យក្រុមហ៊ុនឯកជនមិនត្រូវខានធានាឡើយចំពោះការគ្រប់គ្រងសំណល់រឹងបច្ចុប្បន្ន ។

### b.2 កិច្ចសន្យាគ្រប់គ្រងសំរាប់ក្រុមហ៊ុនឯកជន

ដូចបានបញ្ជាក់ពីលើមកហើយថាការផ្តល់សេវាគ្រប់គ្រងសំណល់រឹង នឹងត្រូវបានចុះកិច្ចសន្យាដល់ក្រុមហ៊ុនឯកជនតាម រយៈការធ្វើឱ្យមានតម្លាភាព និងនិតិវិធីដេញថ្លៃដោយចំហរ និងត្រឹមត្រូវ ។ សេវាកម្មទាំងនេះត្រូវអនុវត្តក្រោម

លក្ខ័ណ្ឌ ប្រកួតប្រជែងនិងប្រឡងប្រណាំងគ្នា ។ តួនាទី និងការទទួលខុសត្រូវរបស់ក្រុមហ៊ុនឯកជន គឺត្រូវផ្តល់សេវាទៅតាមលក្ខ័ណ្ឌនៃកិច្ចសន្យាច្បាប់ដែលអាចឱ្យអនុវត្តខាននូវបទបញ្ជាផ្សេងៗនិងកាតព្វកិច្ច។ ហេតុដូច្នេះ ឯកសារស្នើសុំត្រូវផ្តោតលើ :

- បទបញ្ជាសេវា (បទបញ្ជារបស់សាលាក្រុងលើការគ្រប់គ្រងសំណល់រឹង ។ល។) និងបទបញ្ញត្តិ
- ខ្លឹមសារសេវា ដូចជាថា តំបន់ផ្តល់សេវា សំណល់គោលដៅ ចំនួនប្រជាជនដែលត្រូវផ្តល់សេវា ចម្ងាយ និង ឬតំបន់ផ្តល់សេវាសំអាត ចំនួនដងផ្តល់សេវា ។ល។
- ការបង់ខ្ទាក់ និងការផាកពិន័យ ចំពោះការរំលោភកិច្ចសន្យា
- ករណីចាំបាច់ផ្សេងៗ

នៅពេលដែលកិច្ចសន្យាត្រូវបានធ្វើ (សាលាក្រុង និងមន្ទីរបរិស្ថាន) ត្រូវបង្កើតការអង្កេត និងត្រួតពិនិត្យសកម្មភាពរបស់ក្រុមហ៊ុន ឯកជនដោយយោងទៅតាមលក្ខខណ្ឌដែលបានចែងនៅក្នុងកិច្ចសន្យា ។

### 3.4.4 ការកសាងសមត្ថភាព

ក្រុមសិក្សាបានបង្កើតផែនការមេសំរាប់គ្រប់គ្រងសំណល់រឹង ពាក់ព័ន្ធនឹងរាល់ទិដ្ឋភាពសមត្ថភាពរបស់សាលាក្រុងសំរាប់ការគ្រប់គ្រងសំណល់រឹងឱ្យបានត្រឹមត្រូវដែលនៅខ្សោយ ហើយដែលការកសាងសមត្ថភាពត្រូវផ្តោតទៅលើ :

- សមត្ថភាពសំរាប់ដឹកនាំប្រព័ន្ធគ្រប់គ្រងសំណល់រឹង
- សមត្ថភាពសំរាប់បង្កើតគោលនយោបាយ និងបទបញ្ជាគ្រប់គ្រងសំណល់រឹង
- សមត្ថភាពសំរាប់សំរបសំរួលកសាងមធ្យោបាយគ្រប់គ្រងសំណល់រឹង ដូចជា ទីលានបច្ចេកទេស
- សមត្ថភាពជំរុញដូចជា ការចាត់ចែងការងារ អង្កេត និងត្រួតពិនិត្យលើសេវាគ្រប់គ្រងសំណល់រឹង

## 3.5 តួលេខគោលដៅ និងយុទ្ធសាស្ត្ររបស់ផែនការមេ

### 3.5.1 តួលេខគោលដៅ

Table 3-12: តួលេខគោលដៅនៃផែនការមេគ្រប់គ្រងសំណល់រឹងក្នុងភ្នំពេញ

| ផ្នែកបច្ចេកទេស | បច្ចុប្បន្ន (២០០៤) | ដំណាក់កាល ១ (២០០៧) | ដំណាក់កាល ២ (២០១២) | ដំណាក់កាល ៣ (២០១៥) |
|---|---|---|---|---|
| សេវាគ្របដណ្តប់លើការប្រមូលសំណល់តាមចំនួនប្រជាពលរដ្ឋ[១] (សេវាកម្មនៃការប្រមូលសំណល់ទៅបរិមាណបញ្ចេញសំណល់[៥]) | | | | |
| ខ័ណ្ឌក្នុងក្រុងទាំង ៤ | ៩៥,៦% (៩០,៧%) | ៩៧,៨%(៩២,៥%) | ១០០% (៩៤,១%) | ១០០%(៩៣,៨) |
| ខ័ណ្ឌទាំង ៣ នៅជាយក្រុង | ៥៣,៤%(៤៨,២%) | ៧៣,៤%(៦៨,) | ៨៨,៨%(៨៣,០%) | ៩៥,៧% (៨៩,៧) |
| **កាត់បន្ថយបរិមាណបង្កើត** | | | | |

| ផ្នែកបច្ចេកទេស | បច្ចុប្បន្ន (២00៤) | ដំណាក់កាល ១ (២00៧) | ដំណាក់កាល ២ (២0១២) | ដំណាក់កាល ៣ (២0១៥) |
|---|---|---|---|---|
| អត្រាក(សំណល់តាមផ្ទះ បញ្ចេញសរុប)<br>កំណើនសំណល់តាមផ្ទះ[*៣]<br>អត្រាកំណើនសំណល់អាជីវកម្ម[*៤]<br>(សមមាត្រនៃសំណល់អាជីវកម្មធៀបនឹងបរិមាណបង្កើត សរុប) | ១,00 (៦៣,0%)<br><br>១,00 (៣៧,0%) | ១,១៤ (៦២,៦%)<br><br>១,១៦ (៣៧,៤%) | ១,៣២ (៦១,៥%)<br><br>១,៤១ (៣៨,៥%) | ១,៤២ (៦0,៩%)<br><br>១,៥៥(៣៩,១%) |
| សមមាត្រសំណល់កែច្នៃធៀប នឹងបរិមាណ បង្កើតសរុប[*៥]<br>ខ័ណ្ឌក្នុងក្រុងទាំង ៤<br>ខ័ណ្ឌទាំង ៣ នៅជាយក្រុង | <br>១១,១%<br>៦,៨% | <br>១៤,៦%<br>៨,៣% | <br>១៥,៥%<br>១0,៤% | <br>១៦,0%<br>១១,៧% |
| សមមាត្រនៃសំណល់ធ្វើកំប៉ុស (សំណល់ធ្វើប្រព្រឹត្តិកម្មពាក់កណ្តាលសំរេច) ធៀបនឹងបរិមាណបង្កើតសរុប(ចំនួនធ្វើប្រព្រឹត្តិកម្មត/ថ្ងៃ) | 0,១% (១,៣%) | ២,៤% (២៦,៣) | ២,0% (២៩,៣%) | ១,៩% (៣២,៣) |
| សមមាត្រនៃសំណល់តាមផ្ទះចាក់ខុសច្បាប់ ធៀបនឹងបរិមាណបង្កើតសរុប[៦]<br>ខ័ណ្ឌក្នុងក្រុងទាំង ៤<br>ខ័ណ្ឌទាំង ៣ នៅជាយក្រុង | <br>២,២%<br>១៣,៨% | <br>១,១%<br>៧,២% | <br>0,0%<br>១,៨% | <br>0,0%<br>0,0% |
| ការបោសតាមផ្លូវ<br>ខ័ណ្ឌក្នុងក្រុងទាំង ៤<br>ខ័ណ្ឌទាំង ៣ នៅជាយក្រុង | <br>៤៦ គ.ម<br>១0 គ.ម | <br>៤៦ គ.ម<br>១៤ គ.ម | <br>៤៦ គ.ម<br>១៩ គ.ម | <br>៤៦ គ.ម<br>២៤ គ.ម |
| វិធីចាក់សំណល់ក្រុងចុងក្រោយ | ប្រព័ន្ធសំរាប់កាត់បន្ថយការបង្កើតសំណល់ ការកែច្នៃ ប្រព្រឹត្តិកម្ម និងទីលាននឹងត្រូវបង្កើតឡើងក្នុងជំហាននានា | | | |

### 3.5.2 យុទ្ធសាស្ត្រដើម្បីសំរេចគោលដៅ

យុទ្ធសាស្ត្រសំរាប់ដំណាក់កាលទាំង៣ ដែលនឹងត្រូវយកមកអនុវត្តដើម្បីឱ្យសំរេចគោលដៅផែនការយុទ្ធសាស្ត្រត្រូវបានបង្ហាញដូចខាងក្រោម ។ ទោះបីថា ផែនការមេអាចនឹងកែប្រែតាមកិច្ចប្រមព្រៀងរវាងសាលាក្រុង និង ក្រុមហ៊ុនស៊ិនទ្រីក្តី តែយុទ្ធសាស្ត្រសំរាប់អនុវត្តផែនការមេអាស្រ័យលើការទទួលខុសត្រូវតាមតំបន់ រវាង រ.ក.ស.ភ និងក្រុមហ៊ុនសិនទ្រី ដូចក្នុងតារាង ៣-១៣ ខាងក្រោម ។

## Table 3-13: យុទ្ធសាស្ត្រដើម្បីសំរេចគោលដៅផែនការមេគ្រប់គ្រងសំណល់រឹង

| យុទ្ធសាស្ត្រ | ខ័ណ្ឌទាំង ៤ ក្នុងក្រុង | ខ័ណ្ឌទាំង ៣ ជាយក្រុង |
|---|---|---|
| ១.ការបង្កើត និងគ្រប់គ្រងសំណល់តាមប្រភព | • ម.ប.ស្ថ.ភ អនុវត្តយុទ្ធនាការអប់រំសាធារណៈដោយសហការជាមួយ រ.គ.ស.ភ និងក្រុមហ៊ុន ស៊ិនទ្រី និងផ្សព្វផ្សាយការកាត់បន្ថយការចាក់សំរាមខុសច្បាប់ និងបទបញ្ជានៃការចាក់<br>• យុទ្ធនាការបានលើកស្ទួយជាពិសេសដល់ការកាត់បន្ថយសំណល់ផងដែរ<br>• ម.ប.ស្ថ.ភ ផ្តល់ការណែនាំ និងវាយតម្លៃលើវិធីទុកដាក់សំណល់ឱ្យបានត្រឹមត្រូវយោងតាមចំនួននៃការប្រមូល ។ | |
| ២. ការចាក់ ការប្រមូល និងការដឹកជញ្ជូន | • ប្រតិបត្តិការណ៍ប្រមូលដោយរថយន្តក្នុងតំបន់ NIP ត្រូវបានផ្ទេរទៅឱ្យក្រុមហ៊ុនស៊ិនទ្រី<br>• ស៊ិនទ្រីកំណត់ផ្លូវដែលត្រូវប្រមូល ពេលវេលា និងបន្តផ្តល់សេវានេះ<br>• ស៊ិនទ្រីណែនាំប្រព័ន្ធប្រមូលដោយរទេះ រុញ ឬចំណុចប្រមូលជាមួយប្រព័ន្ធប្រតិបត្តិសាធារណៈនៅតាមតំបន់ដែលឡានមិនអាចចេញចូលទៅដល់បាន និងលប់បំបាត់តំបន់ដែលគ្មានសេវា ( ប្រព័ន្ធនេះត្រូវបានសំរេចដោយក្រុមហ៊ុនស៊ិនទ្រី)<br>• ស៊ិនទ្រីបញ្ជូនវិក័យប័ត្រផ្អែកទៅតាមកិច្ចព្រមព្រៀងសេវាដែលបានចុះ ហត្ថ លេខារវាងក្រុមហ៊ុន និងអតិថិជន ។<br>• ស្ថានីយបញ្ចេញសំរាមនឹងអាស្រ័យលើក្រុមហ៊ុន សិនទ្រី ។ | រ.គ.ស.ភ<br>• រ.គ.ស.ភ ពង្រឹងសមត្ថភាពខ្លួនលើសេវាប្រមូលសំរាប់ខ័ណ្ឌជាយក្រុងទាំង ៣ នៅចុងឆ្នាំ ២០០៦ និងចាប់ផ្តើមផ្តល់សេវានៅដើមឆ្នាំ ២០០៧<br>១. ដើម្បីសំរេចតំបន់ផ្តល់សេវា និងប្រព័ន្ធប្រមូលដូចជាការប្រមូលតាមចិញ្ចើមថ្នល់ តាមស៊ីប្លេ ឬតាមកុងទែន័រ ផ្អែកតាមលក្ខខណ្ឌតំបន់<br>១. ដើម្បីសំរេចបាននូវប្រព័ន្ធមួយ ចំណុចប្រមូល ឬការប្រមូលតាមរទេះរុញសំរាប់តំបន់និមួយៗដែលមានប្រើប្រព័ន្ធកុងទែន័រ<br>២. រ.គ.ស.ភ សហការជាមួយ NGOs និងសហគមន៍ក្នុងការរៀបចំកម្មវិធីប្រមូលតាមរទេះរុញ និងតាមរថយន្តនៅតាមកន្លែងដែលអាចបង្កើនគុណភាពដល់អតិថិជនឱ្យមានប្រសិទ្ធិភាព និងការផ្តល់ឱកាសការងារ<br>៣. ចំណាយសំរាប់ការប្រមូលតាមរទេះរុញបានមកពីសហគមន៍ខ្លួនឯង តម្លៃត្រូវបានសំរេចដោយមានការព្រមព្រៀងពី រ.គ.ស.ភ សង្កាត់ និងសហគមន៍<br>• រ.គ.ស.ភ ធ្វើកិច្ចព្រមព្រៀងផ្តល់សេវាជាមួយអតិថិជន ដោយសហការជាមួយសង្កាត់<br>• រ.គ.ស.ភ ពិនិត្យលើការណែនាំចំពោះចំណុចផ្ទេរសំរាមសំរាប់តំបន់នៅឆ្ងាយជាង ២០គ.ម ពីទីលានចាក់ចុងក្រោយ ។<br><br>ស៊ិនទ្រី<br>• ដូចគ្នានឹងក្រលោនខាងឆ្វេង |

| យុទ្ធសាស្ត្រ | ខ័ណ្ឌទាំង ៤ ក្នុងក្រុង | ខ័ណ្ឌទាំង ៣ ជាយក្រុង |
|---|---|---|
| | • សាលាក្រុងភ្នំពេញគាំទ្រដល់សហគមន៍ក្នុងការសំរេចបង្កើតឱ្យមានការប្រមូលតាមរទេះរុញ | |
| ៣. ការបោសតាមផ្លូវ និង ការសំអាតសួនច្បារ | • ប្រព័ន្ធសំអាតបច្ចុប្បន្នតាមទីសាធារណៈ ដែលផ្អែកទៅលើកម្លាំងពលកម្ម គួរតែផ្តោតជាចំបង លើទស្សនៈនៃការបង្កើតការងារ ។<br>• ម.ប.ស្ថ.ភ អនុវត្តយុទ្ធនាការអប់រំសាធារណៈ និងជួយសម្របសម្រួលរាល់ទង្វើខុសច្បាប់ ដូចជា ការចាក់ខុសច្បាប់ ដើម្បីបញ្ឈប់នូវការពង្រាយក្នុងក្រុង ។<br>• សាលាក្រុងប្តេជ្ញាធានាដល់ធនធានក្នុងឆ្នាំ ២០០៦ ដូច្នេះ រ.គ.ស.ភ អាចរៀបចំសម្ភារៈ និង ធនធានមនុស្ស ដែលត្រូវការសំរាប់កាន់កាប់សេវាសំអាតនៅក្នុងតំបន់សេវាកម្ម រ.គ.ស.ភ ពីអ្នកម៉ៅការឯកជនក្នុងឆ្នាំ ២០០៧ ។ | |
| ៤.ប្រព្រឹត្តិកម្មពាក់ កណ្តាលសំរេច និង ការកែច្នៃ | • រ.គ.ស.ភ បង្កើតរោងចក្រផលិតជីកំប៉ុសមួយដើម្បីកាត់បន្ថយនិងកែច្នៃសំណល់សរីរាង្គដែលប្រមូលបានពីទីផ្សារ នៅឯទីលានថ្មីដង្កោ ។<br>• សាលាក្រុងឆ្លងតាម រ.គ.ស.ភ ធានាដល់ធនធានល្បើសរបស់រដ្ឋាភិបាល ប/ដីផ្សេងទៀត និង បំពាក់ឧបករណ៍សំភារៈធម្មតាសំរាប់ឱ្យ NGO ក្រុមសហគមន៍ជួយខ្លួនឯង ដើម្បីប្រតិបត្តិសកម្មភាពកែច្នៃ និងធ្វើជីកំប៉ុសក្នុងន័យបង្កើនការកែច្នៃ និងបង្កើតការងារ ។<br>• សាលាក្រុងឆ្លងតាម រ.គ.ស.ភ បង្កើតបទបញ្ជា និងគោលនយោបាយ ដើម្បីលើកស្ទួយដល់ការ កែច្នៃឯកជន និងធ្វើការកែលំអសកម្មភាពមិនត្រឹមត្រូវ ឬគ្រោះថ្នាក់ ។<br>• សាលក្រុងបង្កើតការគាំទ្រដល់ប្រព័ន្ធកែច្នៃរយៈពេលយូររបស់ក្រុមហ៊ុនឯកជន ដើម្បីថែរក្សា និង អភិរក្សប្រព័ន្ធកែច្នៃមានស្រាប់ ។<br>• សាលាក្រុងសហការជាមួយក្រសួងឧស្សាហកម្ម ។ល។ លើកទឹកចិត្តដល់សកម្មភាពកែច្នៃក្នុង ស្រុក សំរាប់ធនធានសំណល់ដែលមានតម្លៃដែលប្រមូលបាន ។<br>• ក្រសួងបរិស្ថាន សហការជាមួយក្រសួងពាក់ព័ន្ធផ្សេងទៀត លើកទឹកចិត្តចំពោះផលិតផលដែល អាចប្រើប្រាស់ឡើងវិញ និងកែច្នៃបាន និងជំរុញកម្មវិធី 3Rs ដោយបញ្ចូលនូវការពង្រីកការ ទទួលខុសត្រូវរបស់ផលិតករផង ។ | |
| ៥.ការចាក់ចុងក្រោយ និង ប្រតិបត្តិការណ៍និង តំហែទាំគ្រឿងចក្រ | • រ.គ.ស.ភ កែលំអទីលានចាក់សំរាមស្ទឹងមានជ័យផ្អែកតាមបទពិសោធន៍គំរោងសាកល្បង ដែលបានអនុវត្តក្នុងពេលធ្វើការសិក្សា និងប្រើប្រាស់ទីលានឱ្យបានច្រើនតាមដែលអាចធ្វើបាន<br>• រ.គ.ស.ភ រៀបចំអ្នករើសសំរាមតាមរយៈការបិទទីលានក្នុងឆ្នាំ ២០០៦ និងជំរុញឱ្យពួកគាត់ធ្វើ ការទៅតាមបទបញ្ញត្តិថែង ។ ជាងនេះទៀត រ.គ.ស.ភ លើកទឹកចិត្តឱ្យអ្នករើសសំរាមចូលធ្វើ ការងារជាអ្នកប្រមូលសំរាមតាមរទេះរុញ ឬតាមរថយន្តក្រោយពីការបិទទីលានចាស់នេះ ។<br>• រ.គ.ស.ភ សាងសង់ទីលានចាក់សំរាមថ្មីនៅដង្កោ និងជាវរថយន្ត និងគ្រឿងចក្រចាំបាច់ដោយ ប្រើប្រាស់ថវិការបស់ខ្លួន និងជំនួយពីខាងក្រៅក្នុងឆ្នាំ ២០០៥ ព្រមទាំងចាប់ផ្តើមប្រតិបត្តិការណ៍ នៅទីលានថ្មីក្នុងឆ្នាំ ២០០៧ ។ ការរើសសំរាមនៅទីលានថ្មីនេះមិនត្រូវបានអនុញ្ញាតឡើយ ។<br>• ផែនការផ្ទែកសំភារៈ គួរតែពិចារណាដើម្បីចៀសវាងការហូរទឹកសំអុយចេញក្រៅ ។ គួររៀបចំ វិធានការទប់ស្កាត់ការហូរចេញទឹកសំអុយទៅខាងក្រៅ នៅពេលដែលមានជំនន់ទំហំធំជា យថាហេតុណាមួយកើតឡើង ។ | |

| យុទ្ធសាស្ត្រ | ខ័ណ្ឌទាំង ៤ ក្នុងក្រុង | ខ័ណ្ឌទាំង ៣ ជាយក្រុង |
|---|---|---|
| | • រ.គ.ស.ភ សាងសង់រោងជាងថែទាំ ដោយប្រើរបាស់ថវិការបស់ខ្លួន និងជំនួយពីខាងក្រៅដែលអាចឱ្យធ្វើការជួសជុលតូចតាចសំរាប់រថយន្ត និងគ្រឿងចក្ររបស់ រ.គ.ស.ភ បាន ។<br>• រ.គ.ស.ភ គួរតែប្រើប្រាស់ឧស្ម័ននៅទីលាន ។<br>• ផែនការបិទទីលានស្ទឹងមានជ័យត្រូវបានកែលំអ ។ | |
| **៦. ការគ្រប់គ្រងទឹកស្អុយ** | • រ.គ.ស.ភ សិក្សា និងស្វែងយល់ពីស្ថានភាពនៃការចាក់ទឹកស្អុយបច្ចុប្បន្ន និងការប្រើប្រាស់អាងទឹកស្អុយក្នុងទីក្រុង ។<br>• រ.គ.ស.ភ បង្កើតផែនការគ្រប់គ្រងទឹកស្អុយ និងផែនការសកម្មភាព ដែលស្របគ្នាទៅនឹងផែនការដៃគូសាធារណៈ និងឯកជន ហើយដែលគួរបញ្ចូលផែនការនេះសំរាប់អភិវឌ្ឍន៏ឧបករណ៏ចាក់ និងធ្វើប្រព្រឹត្តិកម្មទឹកស្អុយថ្មី ។<br>• រ.គ.ស.ភ បែងចែកថវិកាសំរាប់អនុវត្តផែនការសកម្មភាព ហើយនឹងបំលែងវាឱ្យទៅជាសកម្មភាពជាក់ស្តែងទាក់ទងនឹងស្ថាប័នឯកជន ។<br>• រ.គ.ស.ភ បង្កើតគោលការណ៏ណែនាំសំរាប់គ្រប់គ្រងអាងទឹកស្អុយឱ្យបានសមស្រប ។<br>• ក្រសួងបរិស្ថាន ពិនិត្យប្រព័ន្ធច្បាប់ដើម្បីទប់ស្កាត់ការចាក់ទឹកស្អុយខុសច្បាប់ ។ | |
| **ទិដ្ឋភាពស្ថាប័ន** | | |
| **៧. ប្រព័ន្ធច្បាប់** | • ក្រ.ប.ស្ថ បញ្ជាក់នូវភាពមិនច្បាស់លើអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង បន្ថែមការពន្យល់ និងបង្កើតបទបញ្ញត្តិ ស្តង់ដា ឬគោលការណ៏ណែនាំដែលសមស្របទៅនឹងបញ្ហាជាអាទិភាព<br>• ក្រ.ប.ស្ថ លើកទឹកចិត្តដល់ក្រុងនានា ដើម្បីបង្កើតបទបញ្ជាក្រុងដែលបំពេញខ្លឹមសារឱ្យប្រព័ន្ធច្បាប់នៅថ្នាក់ជាតិ<br>• ក្រ.ប.ស្ថ ផ្សព្វផ្សាយវិធីសាស្ត្រអភិវឌ្ឍន៏ផែនការគ្រប់គ្រងសំណល់រឹង ចំពោះទីក្រុងសំខាន់ ផ្សេង ៗ ទៀតក្នុងប្រទេសកម្ពុជាដោយសហការជាមួយ សាលាក្រុងភ្នំពេញ/រ.គ.ស.ភ ផ្អែក តាមលទ្ធផលនៃការសិក្សាបច្ចុប្បន្ន ។<br>• ក្រ.ប.ស្ថ ជំរុញដល់ការសាងសង់ឧបករណ៏ធ្វើប្រព្រឹត្តិកម្ម និងចាក់សំណល់ និងធ្វើនិយ័តកម្មឱ្យបានម៉ត់ចត់ចំពោះការចាក់ និងការធ្វើប្រព្រឹត្តិកម្មសំណល់ដែលមិនត្រឹមត្រូវ<br>• សាលាក្រុង អនុម័តពង្រាងបទបញ្ញត្តិស្តីពីការគ្រប់គ្រងសំណល់រឹងដែលរៀបចំដោយ ម.ប.ស្ថ.ភ និងពង្រឹងបទបញ្ញត្តិនៃការចាក់សំណល់ខុសច្បាប់<br>• សាលាក្រុង បង្កើតបទបញ្ជាក្រុងស្តីអំពីការគ្រប់គ្រងសំណល់រឹង និងគោលការណ៏ណែនាំសំរាប់ការចាក់សំណល់ និងសកម្មភាពផ្សេងទៀតដើម្បីឱ្យមានការសហការពីសំណាក់ប្រជាជន | |
| **៨. រដ្ឋបាល និងការរៀបចំ** | • សាលាក្រុងបញ្ជាក់ពីការរៀបចំទទួលខុសត្រូវសំរាប់ការគ្រប់គ្រងសំណល់រឹងក្រុងភ្នំពេញ :<br>✓ សាលាក្រុង/ខុទ្ទកាល័យ បង្កើតគោលនយោបាយពង្រីកការគ្រប់គ្រងសំណល់រឹង និងអនុវត្ត<br>✓ ស.ក.ភ.ព ចាត់ចែងការងារសាងសង់ទីលាន និងសេវាប្រមូលសំរាមដែលនឹងអនុវត្តដោយ សាលាក្រុង/រ.គ.ស.ភ<br>✓ ម.ប.ស្ថ.ភ ត្រួតពិនិត្យ និងអង្កេតការគ្រប់គ្រងសំណល់រឹងដែលប្រតិបត្តិដោយ រ.គ.ស.ភ និងទទួលខុសត្រូវលើការអប់រំសាធារណះ | |

| យុទ្ធសាស្រ្ត | ខ័ណ្ឌទាំង ៤ ក្នុងក្រុង | ខ័ណ្ឌទាំង ៣ ជាយក្រុង |
|---|---|---|
| | ✓ រ.គ.ស.ភ ប្រតិបត្តិ និងថែរក្សាការគ្រប់គ្រងសំណល់រឹងក្នុងដែនយុត្តាធិការបស់ខ្លួន<br>✓ សាលាក្រុង/ខុទ្ទកាល័យ បង្កើតគណៈកម្មាធិការដឹកនាំដែលរួមមានស្ថាប័ន៤ ខាងលើ ដើម្បីសំរបសំរួលមុខងារនិមួយៗ និងគ្រប់គ្រងអង្គប្រជុំជាប្រចាំដោយរលូន<br>• សាលាក្រុងពង្រឹង រ.គ.ស.ភ ក្នុងន័យទ្រព្យធន (គ្រឿងចក្រ និងឧបករណ៍) ធនធានមនុស្ស (គុណភាព និងបរិមាណបុគ្គលិក) និងហិរញ្ញវត្ថុតាមរយៈការប្រើប្រាស់កម្មវិធីជំនួយអន្តរជាតិឱ្យបានច្រើនតាមដែលអាចធ្វើបានដើម្បីឱ្យ រ.គ.ស.ភ អាចប្រតិបត្តិ និងត្រួតពិនិត្យប្រព័ន្ធបច្ចេក ទេសស្មើខាងលើ ។ | |
| ៩.ដៃគូសាធារណៈ និង ឯកជន | • សាលាក្រុងធ្វើវិសោធនកម្មកិច្ចសន្យាជាមួយក្រុមហ៊ុនស៊ិនទ្រី និងផ្ទេរការងារប្រមូលសំណល់ និង ការសំអាតសាធារណៈតំបន់ជាយក្រុងដូចបង្ហាញក្នុងសេណារីយ៉ូ២ឱ្យ រ.គ.ស.ភ នៅចុងឆ្នាំ ២០០៦<br>• សាលាក្រុងបង្កើតប្រព័ន្ធសំរាប់ត្រួតពិនិត្យទិន្នន័យ និងអង្កេត ដែលសាលាក្រុងអាចពិនិត្រ ថ្លៃគំរោង និងចំណេញ ថ្លៃគំរោង និងប្រសិទ្ធភាព ថ្លៃគំរោង និងផលប៉ះពាល់។ សាលាក្រុង ក៏ គួរបង្កើតប្រព័ន្ធទិន្នន័យរាល់សកម្មភាព ហើយអោយ រ.ក.ស.ភ និងក្រុមហ៊ុនឯកជនបន្តពិនិត្រ ការផ្តល់សេវាកម្ម និងតំលៃសេវារបស់ខ្លួន ។ | |
| ១០. កសាងសមត្ថភាព | • រ.គ.ស.ភ បង្កើតកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្សដើម្បីកសាងសមត្ថភាពបុគ្គលិកតាមវិស័យសកម្មភាពសំខាន់ៗនិមួយៗ(ការគ្រប់គ្រង គណនេយ្យ និងរដ្ឋបាល ការប្រមូលសំណល់រឹងតំហែ ទាំឧបករណ៍ និងប្រតិបត្តិការណ៍នៅទីលានបច្ចេកទេស)<br>• ម.ប.ស្ថ.ភ បង្កើតប្រព័ន្ធត្រួតពិនិត្យ និងអង្កេត ដើម្បីបំពេញឱ្យសំរេចនូវលក្ខន្តិកៈរបស់ រ.គ.ស.ភ<br>• ម.ប.ស្ថ.ភ បង្កើតប្រព័ន្ធត្រួតពិនិត្យ និងអង្កេត ដើម្បីបំពេញឱ្យសំរេចនូវកិច្ចសន្យាជាមួយ ក្រុមហ៊ុនឯកជន ។ | |
| ១១. ហិរញ្ញវត្ថុ | • ស៊ិនទ្រី ជួលសវនករហិរញ្ញកិច្ចពីខាងក្រៅដែលត្រូវធ្វើសវនកម្មលើចំណូល និងចំណាយលើការប្រមូលសំណល់ និង សេវាសំអាតសាធារណៈ បើចំហរចំពោះលទ្ធផលនៃការធ្វើសវនកម្ម និងបង្ហាញនូវយុត្តិកម្មនៃតម្លៃសំណល់ ។ | រ.គ.ស.ភ<br>• សាលាក្រុងដកថវិកាហិរញ្ញវត្ថុពីម្ចាស់ជំនួយទ្វេភាគី និងពហុភាគីដើម្បីពង្រឹងត្រួតពិនិត្យ រ.គ.ស.ភ លើសមត្ថភាពនៃការគ្រប់គ្រងំណល់រឹង<br>• រ.គ.ស.ភ បង្កើតប្រព័ន្ធប្រមូលថ្លៃសំរាមទាក់ទងជាមួយសង្កាត់ផ្អែកតាមលទ្ធផលនៃគំរោងសាកល្បងដែលបានអនុវត្តក្នុងការសិក្សាបច្ចុប្បន្ន<br>• សាលាក្រុងភ្នំពេញបែងចែកថវិកាសំរាប់ រ.គ.ស.ភ ដើម្បីចាប់ផ្តើមការងារសំអាតក្នុងឆ្នាំ ២០០៧ នាតំបន់សាធារណ។<br><br>ស៊ីនទ្រី<br>ដូចគ្នានឹងក្រលោនខាងឆ្វេង |
| ១២. ការអប់រំសាធារណៈ និងកិច្ចសហការ | • សាលាក្រុង/ម.ប.ស្ថ.ភ លើកកំពស់ចំណេះដឹងសាធារណៈតាមរយៈការអប់រំមូលដ្ឋានដូចជាភាពចាំបាច់នៃអនាម័យសាធារណៈ និងការអភិរក្សបរិស្ថាន ។ | |

| យុទ្ធសាស្ត្រ | ខ័ណ្ឌទាំង ៤ ក្នុងក្រុង | ខ័ណ្ឌទាំង ៣ ជាយក្រុង |
|---|---|---|
| | • សាលាក្រុង/ម.ប.ស្ថ.ភ សហការជាមួយ រ.គ.ស.ភ និងស៊ិនទ្រី អនុវត្តយុទ្ធនាការអប់រំសាធារ ណៈ ដើម្បីមានការចូលរួមពីសាធារណៈជន ។ វាលើកស្ទួយដល់កិច្ចសហការជាមួយ NGOs<br>• រ.គ.ស.ភ និងស៊ិនទ្រី អនុវត្តការអប់រំសាធារណៈ និងសកម្មភាព PR ដើម្បីឱ្យមានកិច្ចសហការជាសាធារណៈ និងស្វែងយល់ពីប្រជាជន ។ ដើម្បីសំរេចការងារនេះបានពួកគាត់សហការ ជាមួយ NGOs ។ | |
| ១៣.ការគ្រប់គ្រង សំណល់គ្រោះថ្នាក់ | • ក្រ.ប.ស្ថ សិក្សាពីស្ថានភាពជាក់ស្តែងលើការបង្កើតសំណល់គ្រោះថ្នាក់ដោយសហការជាមួយ ប្រភពបង្កើតនានាដូចជា រោងចក្រ និងពិនិត្យលើការធ្វើប្រព្រឹត្តិកម្មឱ្យបានត្រឹមត្រូវ និងមានវិធានការលើការចាក់តាមរយៈការមើលទៅលើទំហំសេដ្ឋកិច្ច និងបរិមាណបង្កើតសរុប<br>• ក្រ.ប.ស្ថ លើកស្ទួយដល់ការសាងសង់មធ្យោបាយធ្វើប្រព្រឹត្តិកម្ម និងចាក់ឱ្យបានត្រឹមត្រូវសំរាប់សំណល់គ្រោះថ្នាក់ និងពង្រឹងការត្រួតពិនិត្យលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ដែលមិនត្រឹម ត្រូវ ។<br>• ក្រ.ប.ស្ថ បង្កើតក្រមសីលធម៌សំរាប់គ្រប់គ្រងសំណល់វេជ្ជសាស្ត្រដោយសហការជាមួយក្រសួងសុខាភិបាល ។ ក្រ.ប.ស្ថ ពង្រឹងផ្នែកដែលពាក់ព័ន្ធរបស់ខ្លួនដើម្បីបង្កើតប្រព័ន្ធត្រួតពិនិត្យ/ចាត់ចែងការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រឱ្យបានត្រឹមត្រូវ<br>• ម.ស (មន្ទីរសុខាភិបាល) និង រ.គ.ស.ភ ណែនាំនូវប្រព័ន្ធញែកសំណល់ លើសំណល់ឆ្លង និងរៀបចំសំរបសំរួលការចាក់នៅទីលានចាក់សំរាមក្រុង ។<br>• ម.ស ពិនិត្យទៅលើការធ្វើសមាហរណកម្មឡដុតសំណល់ដែលមានស្រាប់ ឬណែនាំមធ្យោបាយធ្វើប្រព្រឹត្តិកម្មថ្មីដែលទទួលសំណល់ពីស្ថាប័នវេជ្ជសាស្ត្រមួយចំនួន ដោយគិតទៅដល់ប្រសិទ្ធិភាពនៃការកែលំអប្រតិបត្តិការណ៍ប្រព្រឹត្តិកម្ម ។<br>• រ.គ.ស.ភ ត្រួតពិនិត្យតឹងរឹងចំពោះការហូរចូលសំណល់គ្រោះថ្នាក់ទៅទីលានចាក់សំរាម ។ | |
| ដំណាក់កាលទី ២ (២០០៨-២០១២)<br>ទិដ្ឋភាពបច្ចេកទេស | | |
| ១.ការបង្កើត និង គ្រប់គ្រងសំណល់តាមប្រភព | • រ.គ.ស.ភ សហការជាមួយ ស៊ិនទ្រី អនុវត្តយុទ្ធនាការអប់រំសាធារណៈ និងធ្វើនិយ័តកម្មការចាក់ខុសច្បាប់ និងការចោលសំណល់តាមផ្ទះមិនត្រឹមត្រូវ ។ ចុងបញ្ចប់ ការចាក់ខុសច្បាប់ និងចាក់ដោយខ្លួនឯងមិនត្រឹមត្រូវ ត្រូវបានលប់បំបាត់ចោលនៅក្នុងឆ្នាំ ២០១២<br>• យុទ្ធនាការក៏លើកស្ទួយដល់ការកាត់បន្ថយសំណល់ផងដែរ | រ.គ.ស.ភ<br>• រ.គ.ស.ភ អនុវត្តយុទ្ធនាការអប់រំសាធារណៈ និងធ្វើនិយ័តកម្មការចាក់ខុសច្បាប់ និងការចោលសំណល់តាមផ្ទះមិនត្រឹមត្រូវ ដើម្បីកាត់បន្ថយអត្រាទាំងនេះឱ្យដល់ ១,៨% ក្នុងឆ្នាំ ២០១២<br>• យុទ្ធនាការក៏លើកស្ទួយដល់ការកាត់បន្ថយសំណល់ផងដែរ<br><br>ស៊ិនទ្រី<br>ដូចគ្នានឹងក្រលោនខាងឆ្វេង |

<table>
<tr><th>យុទ្ធសាស្ត្រ</th><th>ខ័ណ្ឌទាំង ៤ ក្នុងក្រុង</th><th>ខ័ណ្ឌទាំង ៣ ជាយក្រុង</th></tr>
<tr><td rowspan="2">២. ការចាក់ ការប្រមូល និងការដឹកជញ្ជូន</td><td rowspan="2">• សាលាក្រុង/ម.ប.ស្ថ.ភ គ្រប់គ្រងការប្រមូលសំរាមដែលធ្វើដោយ ស៊ិនទ្រី<br>• ស៊ិនទ្រី សហការជាមួយ NGOs រៀបចំអ្នករើសសំរាមដើម្បីធ្វើជាអ្នកប្រមូលដោយរទេះរុញនិងអាចសំរេចបានអត្រាប្រមូល ១០០% ក្នុងឆ្នាំ ២០១២<br>• ការប្រមូលដោយញែក នឹងត្រូវបន្តធ្វើក្នុងតំបន់ NIP ។</td><td>រ.គ.ស.ភ<br>• រ.គ.ស.ភ សហការជាមួយ NGOs រៀបចំអតីតអ្នករើសសំរាមដើម្បីធ្វើជាអ្នកប្រមូលតាមរទេះរុញ និងតាមរថយន្ត<br>• រ.គ.ស.ភ កែលំអប្រសិទ្ធិភាពនៃការប្រមូលរបស់ខ្លួន និងបង្កើនអត្រាប្រមូលរបស់ខ្លួនដល់ ៨៨.៨% សមមាត្រទៅនឹងចំនួនប្រជាជនដែលទទួលសេវា<br>• រ.គ.ស.ភ ណែនាំការប្រមូលសំណល់ដោយញែកនៅក្នុងផ្នែកខ្លះនៃតំបន់ប្រមូល<br>• អនុលោមតាមលទ្ធផលត្រួតពិនិត្យក្នុងដំណាក់កាលទី ១ រ.គ.ស.ភ ណែនាំនូវចំណុចផ្ទេរសំណល់ ។</td></tr>
<tr><td>ស៊ិនទ្រី<br>ដូចគ្នានឹងក្រលោនខាងឆ្វេង</td></tr>
<tr><td>៣. ការបោសតាមផ្លូវ និងការសំអាតសួនច្បារ</td><td colspan="2">• ពលកម្មផ្នែកតាមប្រព័ន្ធសំអាតតាមកន្លែងសាធារណៈគួរតែត្រូវបានថែរក្សា ស្របពេលដែលវាមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចលើការសំអាតគ្រឿងចក្រ<br>• រ.គ.ស.ភ បន្តអនុវត្តយុទ្ធនាការអប់រំសាធារណៈ និងធ្វើនិយ័តកម្មលើសកម្មភាពខុសច្បាប់នានា ដូចជាការចាក់ខុសច្បាប់ ដើម្បីបញ្ឈប់នូវការពង្រាយសំរាមក្នុងទីក្រុង</td></tr>
<tr><td>៤.ប្រព្រឹត្តិកម្មពាក់ កណ្តាលសំរេច និង ការកែច្នៃ</td><td colspan="2">• រ.គ.ស.ភ ប្រតិបត្តិការណ៍លើមធ្យោបាយធ្វើជីកំប៉ុស្តនៅទីលានចាក់សំរាមដង្កោ<br>• រ.គ.ស.ភ លើកស្ទួយការកែច្នៃតាមរយៈការសាងសង់មណ្ឌលកែច្នៃខ្នាតតូចដែលក្រុមអតីតអ្នករើសសំរាមត្រូវធ្វើការញែកសំណល់ និងការធ្វើជីកំប៉ុស្តក្នុងរោងធម្មតា នៅពេលដែលបានទទួល ដីហើយដែលរៀបចំដោយ NGOs<br>• រ.គ.ស.ភ លើកស្ទួយកែលំអសកម្មភាពកែច្នៃ តាមរយៈអ្នកកែច្នៃផ្ទាល់ខ្លួន និងធ្វើនិយ័តកម្មការកែច្នៃមិនត្រឹមត្រូវ</td></tr>
<tr><td>៥.ការចាក់ចុងក្រោយ និងប្រតិបត្តិការណ៍ និងតំហែទាំគ្រឿងចក្រ</td><td colspan="2">• រ.គ.ស.ភ បន្តប្រតិបត្តិការណ៍ទីលានបច្ចេកទេសនៅដង្កោ<br>• រ.គ.ស.ភ សាងសង់ទីលានចាក់សំរាមក្នុងជំហានទី ២ នៅតំណាច់ឆ្នាំ ២០១២<br>• រ.គ.ស.ភ អនុវត្តការថែទាំកំរិតតូចតាចចំពោះរថយន្ត និងគ្រឿងចក្ររបស់ខ្លួនឱ្យទៀងទាត់<br>• តម្លើងបំពង់ស្រូបឧស្ម័ន និងការងារលប់ដី ត្រូវបានអនុវត្តនៅទីលានស្ទឹងមានជ័យ ក្រោយពេលបិទនៅដើមឆ្នាំ ២០០៧ ។</td></tr>
</table>

<table>
<tr><th>យុទ្ធសាស្ត្រ</th><th>ខណ្ឌទាំង ៤ ក្នុងក្រុង</th><th>ខណ្ឌទាំង ៣ ជាយក្រុង</th></tr>
<tr><td>៦. ការគ្រប់គ្រងទឹកស្អុយ</td><td colspan="2">• រ.គ.ស.ភ និងស្ថាប័នឯកជនតាមដានផែនការគ្រប់គ្រងទឹកស្អុយនិងផែនការសកម្មភាពដែលបានបង្កើតក្នុងដំណាក់កាលទី ១<br>• រ.គ.ស.ភ គ្រប់គ្រងមធ្យោបាយចាក់ទឹកស្អុយឱ្យបានត្រឹមត្រូវ<br>• រ.គ.ស.ភ និងស្ថាប័នឯកជន អនុវត្តយុទ្ធនាការអប់រំសាធារណៈ ដើម្បីជំរុញអនុវត្តគោលការណ៍ណែនាំដែលបានចេញក្នុងដំណាក់កាលទី ១<br>• ក្រ.ប.ស្ថ បង្កើតច្បាប់ និងវិធានការណ៍អនុវតដើម្បីទប់ស្កាត់ការចាក់ទឹកស្អុយខុសច្បាប់</td></tr>
<tr><td colspan="3">ទិដ្ឋភាពស្ថាប័ន</td></tr>
<tr><td>៧. ប្រព័ន្ធច្បាប់</td><td colspan="2">• ក្រ.ប.ស្ថ បង្កើតបទបញ្ញត្តិ ស្តង់ដា ឬគោលការណ៍ណែនាំដែលសមស្របទៅតាមអនុក្រឹត្យ<br>• ក្រ.ប.ស្ថ លើកទឹកចិត្តដល់ក្រុងនានា ដើម្បីបង្កើតបទបញ្ជាក្រុង<br>• ក្រ.ប.ស្ថ ជួយលើកទឹកចិត្តចំពោះទីក្រុងសំខាន់ផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ដើម្បីអនុវត្តការគ្រប់គ្រងកាកសំណល់រឹង ។<br>• ក្រ.ប.ស្ថ និងក្រសួងសុខាភិបាល ធ្វើនិយ័តកម្មឱ្យខានម៉ត់ចត់ថែមទៀត ទៅលើការចាក់ និងការធ្វើប្រព្រឹត្តិកម្មសំណល់ដែលមិនត្រឹមត្រូវ<br>• ក្រ.ប.ស្ថ ជាមួយសាលាក្រុងភ្នំពេញផ្សព្វផ្សាយបទបញ្ជាក្រុងស្តីពីការគ្រប់គ្រងសំណល់រឹង និងគោលការណ៍ណែនាំសំរាប់ការចាក់សំណល់ និងសកម្មភាពផ្សេងទៀត ដើម្បីឱ្យមានការសហការពីសំណាក់ប្រជាជន ។</td></tr>
<tr><td>៨. រដ្ឋបាល និងការរៀបចំ</td><td colspan="2">• សាលាក្រុងភ្នំពេញបន្តពង្រឹង រ.គ.ស.ភ<br>• សាលាក្រុងភ្នំពេញអង្កេតលើការវិវត្តន៏របស់ផែនការមេ ។</td></tr>
<tr><td>៩.ដៃគូសាធារណៈ និង ឯកជន</td><td colspan="2">• សាលាក្រុងពិនិត្យកិច្ចសន្យាជាមួយ ស៊ិនទ្រី ឡើងវិញ និងពិនិត្យមើលវិសោធនកម្មចាំបាច់ដើម្បីលើកឡើងនូវយន្តការទីផ្សារ<br>• សាលាក្រុង/មន្ទីរបរិស្ថាន ជំរុញប្រព័ន្ធត្រួតពិនិត្យទិន្នន័យ និងអង្កេត ។ ឆ្លងតាមប្រព័ន្ធនេះ សាលាក្រុង/មន្ទីរបរិស្ថាន អាច នឹងធ្វើការវាយតម្លៃសកម្មភាពរបស់ខ្លួននិងរបស់អ្នក ម៉ៅការឯកជនដោយទៀង ទាត់តាមរយៈការ ពិនិត្យលើឯកតាតម្លៃសំរាប់ផ្នែកមួយៗនៃការគ្រប់គ្រងសំណល់រឹង និងលើ សន្ទស្សន៏ទង្វើសំខាន់ៗ លទ្ធផលនៃការវាយតម្លៃនេះគួរតែបង្ហាញ ជាចំហរដល់សាធារណៈ ។</td></tr>
<tr><td>១០. កសាងសមត្ថភាព</td><td colspan="2">• រ.គ.ស.ភ អនុវត្តកម្មវិធីបណ្តុះបណ្តាលដែលសមស្របសំរាប់ការងារផ្សេងៗរបស់បុគ្គលិកទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង ។</td></tr>
<tr><td>១១. ហិរញ្ញវត្ថុ</td><td>• ស៊ិនទ្រី កែលំអពតិមានហិរញ្ញវត្ថុឱ្យមានតម្លាភាព និងបង្កើនអត្រាថ្លៃប្រមូលសំរាមរបស់ខ្លួន ។</td><td>រ.គ.ស.ភ<br>• រ.គ.ស.ភ ពង្រឹងប្រព័ន្ធប្រមូលថ្លៃសំរាមក្នុងតំបន់សេវារបស់ខ្លួនលើថ្លៃសរុប<br>• សាលាក្រុងបែងចែកថវិកាសំរាប់ រ.គ.ស.ភ អនុវត្តការងារសំអាតតាមទីសាធារណៈចាប់ពីឆ្នាំ ២០០៧</td></tr>
</table>

| យុទ្ធសាស្ត្រ | ខ័ណ្ឌទាំង ៤ ក្នុងក្រុង | ខ័ណ្ឌទាំង ៣ ជាយក្រុង |
|---|---|---|
| | | ស៊ីនទ្រី<br>ដូចគ្នានឹងក្រលោនខាងឆ្វេង |
| ១២. ការអប់រំសាធារណៈ និងកិច្ចសហការ | • រ.គ.ស.ភ និងក្រុមហ៊ុន ស៊ីនទ្រី បន្តអនុវត្តការអប់រំសាធារណៈ និងសកម្មភាព PR ហើយដើម្បីសំរេចការងារនេះខាងពួកគាត់សហការជាមួយ NGOs ដើម្បីឱ្យមានកិច្ចសហការជាសាធារណៈ និងស្វែងយល់ពីប្រជាជន ។ | |
| ១៣.ការគ្រប់គ្រង សំណល់គ្រោះថ្នាក់ | • ក្រ.ប.ស្ថ លើកស្ទួយដល់ការសាងសង់មធ្យោបាយធ្វើប្រព្រឹត្តិកម្ម និងចាក់ឱ្យបានត្រឹមត្រូវសំរាប់សំណល់គ្រោះថ្នាក់ និងពង្រឹងការត្រួតពិនិត្យលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ ដែលមិនត្រឹម ត្រូវ ។<br>• ក្រ.ប.ស្ថ សិក្សាពីស្ថានភាពជាក់ស្តែងលើការបង្កើតសំណល់គ្រោះថ្នាក់ និងណែនាំស្ថាប័នពាក់ព័ន្ធដើម្បីអនុវត្តវិធានការចាក់ និងការធ្វើប្រព្រឹត្តិកម្មដែលសមស្របជាងគេ<br>• ស្ថាប័នវេជ្ជសាស្ត្រនិមួយៗ អនុវត្តតាមក្រមសីលធម៌សំរាប់គ្រប់គ្រងសំណល់វេជ្ជសាស្ត្រ<br>• ម.ស/មន្ទីរបរិស្ថាន ណែនាំស្ថាប័នវេជ្ជសាស្ត្រឱ្យបែងចែកសំណល់ឆ្លង/គ្រោះថ្នាក់ និងធ្វើការត្រួតពិនិត្យទៅលើតម្លៃចំណាយសំរាប់គ្រប់គ្រងចាំបាច់ (រួមទាំងការប្រមូល និងការចាក់ចុង ក្រោយ) នៃសំណល់វេជ្ជសាស្ត្រ<br>• ម.ស លើកស្ទួយការធ្វើសមាហរណកម្មឡខ្នាតតូចសំរាប់ដុតសំណល់វេជ្ជសាស្ត្រឆ្លង និងសំណល់គ្រោះថ្នាក់ និងកាត់បន្ថយចំនួន ទាំងនេះឱ្យដល់កំរិតអប្បបរមា ។ | |
| ដំណាក់កាលទី ៣ (២០១៣-២០១៥)<br>ទិដ្ឋភាពបច្ចេកទេស | | |
| ១.ការបង្កើត និង គ្រប់គ្រងសំណល់តាមប្រភព | • សាលាក្រុង/ម.ប.ស្ថ.ភ សហការជាមួយ រ.គ.ស.ភ និង ស៊ីនទ្រី អនុវត្តយុទ្ធនាការអប់រំ សាធារណៈ និងធ្វើនិយ័តកម្មការចាក់ និងការចោលសំណល់តាមផ្ទះមិនត្រឹមត្រូវខុសច្បាប់ ។<br>• យុទ្ធនាការក៏លើកស្ទួយដល់ការកាត់ បន្ថយសំណល់ផងដែរ | |
| ២. ការចាក់ ការប្រមូល និងការដឹកជញ្ជូន | • សាលាក្រុង/ម.ប.ស្ថ.ភ គ្រប់គ្រងការងារប្រមូលសំណល់ធ្វើដោយស៊ីនទ្រី<br>• ស៊ីនទ្រី បន្តផ្តល់សេវាប្រមូល ១០០%<br>• ស៊ីនទ្រីពិនិត្យមើលលើការណែនាំប្រព័ន្ធប្រមូលសំណល់ញែក នៅក្នុងតំបន់ខ្លួនលើកលែងតែតំបន់ NIP ។ | រ.គ.ស.ភ<br>• រ.គ.ស.ភ កែលំអប្រសិទ្ធិភាពនៃការប្រមូលរបស់ខ្លួន និងបង្កើនអត្រាប្រមូលរបស់ខ្លួនដល់ ៩៥.៧% សមមាត្រទៅនឹងចំនួនប្រជាជនក្នុងឆ្នាំ ២០១៥<br>• រ.គ.ស.ភ ពង្រីកតំបន់លើការប្រមូលសំណល់ដោយញែក<br>• យោងតាមលទ្ធផលនៃការសិក្សាលើកទីមួយ រ.គ.ស.ភ អាចបង្ហាញទីតាំងផ្ទេរ បើអាច ។<br>ស៊ីនទ្រី<br>ដូចគ្នានឹងក្រលោនខាងឆ្វេង |

| យុទ្ធសាស្ត្រ | ខ័ណ្ឌទាំង ៤ ក្នុងក្រុង | ខ័ណ្ឌទាំង ៣ ជាយក្រុង |
|---|---|---|
| ៣. ការបោសតាមផ្លូវ និងការសំអាតសួនច្បារ | • ពលកម្មផ្អែកតាមប្រព័ន្ធសំអាតតាមកន្លែងសាធារណៈគួរតែត្រូវបានថែរក្សា ស្របពេលដែលវាមានផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចលើការសំអាតគ្រឿងចក្រ<br>• សាលាក្រុង/ម.ប.ស្ថ.ភ បន្តអនុវត្តយុទ្ធនាការអប់រំសាធារណៈ និងធ្វើនិយ័តកម្មលើសកម្មភាពខុសច្បាប់នានា ដូចជាការចាក់ខុសច្បាប់ ដើម្បីបញ្ឈប់នូវការពង្រាយសំរាមក្នុងទីក្រុង ។ | |
| ៤.ប្រព្រឹត្តិកម្មពាក់ កណ្តាលសំរេច និង ការកែច្នៃ | • រ.គ.ស.ភ ប្រតិបត្តិការណ៍លើមធ្យោបាយធ្វើជីកំប៉ុស្តនៅទីលានចាក់សំរាមដង្កោ<br>• រ.គ.ស.ភ បន្តលើកស្ទួយសកម្មភាពកែច្នៃរបស់អង្គការ NGOs<br>• រ.គ.ស.ភ លើកស្ទួយកែលំអសកម្មភាពកែច្នៃ តាមរយៈអ្នកកែច្នៃផ្ទាល់ខ្លួន និងធ្វើនិយ័តកម្មការកែច្នៃមិនត្រឹមត្រូវ<br>• រ.គ.ស.ភ សាកល្បងដឹកនាំប្រព័ន្ធប្រមូលសំណល់ញែក និងសកម្មភាពរបស់អ្នកកែច្នៃឯកជន | |
| ៥.ការចាក់ចុងក្រោយ និងប្រតិបត្តិការណ៍ និងតំហែទាំគ្រឿងចក្រ | • រ.គ.ស.ភ បន្តប្រតិបត្តិការណ៍ទីលានបច្ចេកទេសនៅដង្កោ<br>• រ.គ.ស.ភ ថែទាំរថយន្ត និងគ្រឿងចក្ររបស់ខ្លួនបានត្រឹមត្រូវ ។ | |
| ៦. ការគ្រប់គ្រងទឹកស្អុយ | • រ.គ.ស.ភ និងស្ថាប័នឯកជន តាមដានផែនការគ្រប់គ្រងទឹកស្អុយ និងផែនការសកម្មភាព ។ | |
| ទិដ្ឋភាពស្ថាប័ន | | |
| ៧. ប្រព័ន្ធច្បាប់ | • ក្រ.ប.ស្ថ ជួយលើកទឹកចិត្តចំពោះទីក្រុងសំខាន់ផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ដើម្បីអនុវត្តការគ្រប់គ្រងកាកសំណល់រឹង ។<br>• ក្រ.ប.ស្ថ និងក្រសួងសុខាភិបាល ធ្វើនិយ័តកម្មឱ្យបានម៉ត់ចត់ថែមទៀត ទៅលើការចាក់ និងការធ្វើប្រព្រឹត្តិកម្មសំណល់ដែលមិនត្រឹមត្រូវ<br>• ក្រ.ប.ស្ថ សហការជាមួយសាលាក្រុង ផ្សព្វផ្សាយបទបញ្ជាក្រុងស្តីពីការគ្រប់គ្រងសំណល់រឹង និងគោលការណ៍ណែនាំសំរាប់ ការចាក់សំណល់ និងសកម្មភាពផ្សេងទៀត ដើម្បីឱ្យមានការសហការពីសំណាក់ប្រជាជនចំពោះ ក្រុងផ្សេងៗទៀតនៅក្នុងប្រទេស ។ | |
| ៨. រដ្ឋបាល និងការរៀបចំ | • សាលាក្រុងភ្នំពេញបន្តពង្រឹង រ.គ.ស.ភ<br>• សាលាក្រុងភ្នំពេញវាយតម្លៃលើការវិវត្តន៏របស់ផែនការមេ និងបង្កើតផែនការមេថ្មីមួយទៀត ដែលចាប់ផ្តើមពីឆ្នាំ ២០១៦ ទៅ ។ | |
| ៩.ដៃគូសាធារណៈនិងឯកជន | • សាលាក្រុង ធ្វើវិសោធនកម្មកិច្ចសន្យាជាមួយ ស៊ិនទ្រី និងអភិវឌ្ឍន៏ដៃគូឯកជន និងសាធារណៈដោយផ្អែកតាមយន្តការទីផ្សារ<br>• សាលាក្រុងភ្នំពេញ/ម.ប.ស្ថ.ភ រក្សាការរៀបចំការអង្កេតតាមបែបប្រព័ន្ធ និង ត្រួតពិនិត្យ ទិន្នន័យ ។ ការងារវាយតម្លៃលើសកម្មភាព និងការបោះពុម្ពរបស់ខ្លួន គួរតែបន្តធ្វើទៀត ។ | |
| ១០. កសាងសមត្ថភាព | • រ.គ.ស.ភ អនុវត្តកម្មវិធីបណ្តុះបណ្តាលដែលសមស្របសំរាប់ការងារផ្សេងៗរបស់បុគ្គលិកទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង ។ | |

| យុទ្ធសាស្ត្រ | ខ័ណ្ឌទាំង ៤ ក្នុងក្រុង | ខ័ណ្ឌទាំង ៣ ជាយក្រុង |
|---|---|---|
| ១១. ហិរញ្ញវត្ថុ | • ស៊ិនទ្រី កែលំអពតិមានហិរញ្ញវត្ថុឱ្យមានតម្លាភាព និងបង្កើនអត្រាថ្លៃប្រមូលសំរាមរបស់ខ្លួន ។ | រ.គ.ស.ភ<br>• រ.គ.ស.ភ រក្សាប្រព័ន្ធចីរភាពហិរញ្ញវត្ថុ តាមរយៈប្រមូលថ្លៃសំរាមពីប្រជាជន<br>• សាលាក្រុងបែងចែកថវិកាសំរាប់ រ.គ.ស.ភ អនុវត្តការងារសំអាត ។ |
| | | ស៊ិនទ្រី<br>ដូចគ្នានឹងក្រលោនខាងឆ្វេង |
| ១២.ការអភិវឌ្ឍន៍ ធនធានមនុស្ស | • រ.គ.ស.ភ អនុវត្តកម្មវិធីបណ្តុះបណ្តាលដែលសមស្របសំរាប់ការងារផ្សេងៗរបស់បុគ្គលិកទាំងអស់ពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹង ។ | |
| ១៣. ការអប់រំសាធារណៈ និងកិច្ចសហការ | • សាលាក្រុងភ្នំពេញ/ម.ប.ស្ថ.ភ សហការជាមួយ រ.គ.ស.ភ និងក្រុមហ៊ុនស៊ិនទ្រី បន្តអនុវត្តការអប់រំសាធារណៈ និងសកម្មភាព PR ហើយដើម្បីឱ្យមានកិច្ចសហការជាសាធារណៈ និងស្វែងយល់ពីប្រជាជន ពួកគាត់ត្រូវសហការយ៉ាងជិតស្និតជាមួយ NGOs ។ | |
| ១៤.ការគ្រប់គ្រងសំណល់គ្រោះថ្នាក់ | • ក្រ.ប.ស្ថ លើកស្ទួយដល់ការសាងសង់មធ្យោបាយធ្វើប្រព្រឹត្តិកម្ម និងចាក់ឱ្យខានត្រឹមត្រូវសំរាប់សំណល់គ្រោះថ្នាក់ និងពង្រឹងការត្រួតពិនិត្យលើការគ្រប់គ្រងសំណល់គ្រោះថ្នាក់ដែលមិនត្រឹម ត្រូវ ។<br>• អង្គការពាក់ព័ន្ធនានាអនុវត្តតួនាទីរបស់ខ្លួនក្នុងការគ្រប់គ្រងសំណល់គ្រោះថ្នាក់<br>• ក្រ.ប.ស្ថ និង ម.ប.ស្ថ.ភ ធ្វើនិយ័តកម្ម និងចាត់ចែងប្រព័ន្ធគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ<br>• ក្រ.ប.ស្ថ និង ម.ប.ស្ថ.ភ ធ្វើនិយ័តកម្ម ឡរំលាយខ្នាតតូចលើសំណល់វេជ្ជសាស្ត្រគ្រោះថ្នាក់ និងឆ្លង ។ | |

## 3.5.3 លំហូរសំណល់នាពេលអនាគត

តំបន់សិក្សាទាំងមូលឆ្នាំ ២០០៧




តំបន់ទីប្រជុំជនក្រុងឆ្នាំ ២០០៧




តំបន់ជាយក្រុងឆ្នាំ ២០០៧




Figure 3-1: លំហូរសំណល់ក្នុងឆ្នាំ ២០០៧




Figure 3-2: លំហូរសំណល់ក្នុងឆ្នាំ ២០១២




Figure 3-3: លំហូរសំណល់ក្នុងឆ្នាំ ២០១៥

## 3.5.4 ផែនការមេគ្រប់គ្រងសំណល់រឹង

| ដំណាក់កាល<br>សមាសភាព | បច្ចុប្បន្ន<br>(២០០៤) | ដំណាក់កាលទី ១<br>(២០០៧) | ដំណាក់កាលទី ២<br>(២០១២) | ដំណាក់កាលទី ៣<br>(២០១៥) |
|---|---|---|---|---|
| **១. ការបង្កើតសំណល់ទីក្រុង** | | | | |
| ចំនួនប្រជាជនក្នុងក្រុងភ្នំពេញ | ជាយក្រុង : 601,449<br>ទីប្រជុំជន : 642,392<br>សរុប : 1,242,841 | ជាយក្រុង : 724,409<br>ទីប្រជុំជន : 692,036<br>សរុប : 1,416,445 | ជាយក្រុង : 850,545<br>ទីប្រជុំជន : 730,887<br>សរុប : 1,581,432 | ជាយក្រុង : 952,009<br>ទីប្រជុំជន : 750,157<br>សរុប : 1,702,166 |
| បរិ.សំ.ទីក្រុង (ត/ថ្ងៃ)<br>ការបង្កើត<br>ការចាក់ចោល<br>ការប្រមូល | 977.6<br>716.6<br>ជាយក្រុង : 189.8<br>រ.គ.ស.ភ : 29.9<br>ស៊ីនទ្រី : 159.9<br>ទីប្រជុំជន : 502.8<br>សរុប : 692.6 | 1,158.7<br>950.7<br>ជាយក្រុង : 325.1<br>រ.គ.ស.ភ : 156.5<br>ស៊ីនទ្រី : 168.6<br>ទីប្រជុំជនៈ 548.8<br>សរុប : 873.9 | 1,511.9<br>1,344.6<br>ជាយក្រុង : 551.1<br>រ.គ.ស.ភ : 281.1<br>ស៊ីនទ្រី : 270.0<br>ទីប្រជុំជន : 683.1<br>សរុប : 1,234.2 | 1,739.3<br>1,597.5<br>ជាយក្រុង : 710.0<br>រ.គ.ស.ភ : 404.4<br>ស៊ីនទ្រី : 305.6<br>ទីប្រជុំជន : 751.4<br>សរុប : 1,461.4 |
| សមាសភាពសំ.ទីក្រុង (%)<br>គ្មានល្បាយ<br>ល្បាយ | 29.9<br>70.1 | 38.4<br>61.6 | 43.1<br>56.9 | 46.9<br>53.1 |
| **២. ធនធានប្រមូល និងការដឹកជញ្ជូន** | | | | |
| អត្រាប្រមូល (%) | ជាយក្រុង : 48.2<br>ទីប្រជុំជន : 90.7<br>សរុប : 73.3 | ជាយក្រុង : 68.1<br>ទីប្រជុំជន : 92.5<br>សរុប : 82.0 | ជាយក្រុង : 83.0<br>ទីប្រជុំជន : 94.1<br>សរុប : 88.9 | ជាយក្រុង : 89.7<br>ទីប្រជុំជន : 93.8<br>សរុប : 91.8 |
| អត្រានៃការចាក់មិនសមស្រប ធៀបនឹងការបង្កើត (%) | ជាយក្រុង : 13.8<br>ទីប្រជុំជន : 2.2<br>សរុប : 6.9 | ជាយក្រុង : 7.2<br>ទីប្រជុំជន : 1.1<br>សរុប : 3.7 | ជាយក្រុង : 1.8<br>ទីប្រជុំជន : 0.0<br>សរុប : 0.8 | ជាយក្រុង : 0.0<br>ទីប្រជុំជន : 0.0<br>សរុប : 0.0 |
| អត្រាប្រមូលសំណល់ញែក ធៀបនឹងការប្រមូល (%) | ជាយក្រុង : 0<br>ទីប្រជុំជន : 0.7<br>សរុប : 4 ត/ថ | ជាយក្រុង : 1.8<br>ទីប្រជុំជន : 0.7<br>សរុប : 6 ត/ថ | ជាយក្រុង : 1.6<br>ទីប្រជុំជន : 0.7<br>សរុប : 9 ត/ថ | ជាយក្រុង : 1.7<br>ទីប្រជុំជន : 0.7<br>សរុប : 12 ត/ថ |
| ប្រព័ន្ធប្រមូលសំណល | <u>រ.គ.ស.ភ</u><br>ប្រមូលតាមផ្ទះ/រថយន្ត<br>ប្រមូលតាមកន្លែងចាក់រួម<br>ប្រមូលដោយរទេះ និងតាមធុងសំរាម<br><u>ឯកជន</u><br>ប្រមូលតាមចិញ្ចើមថ្នល់/ស៊ីប្លេ<br>ប្រមូលតាមកុងទែន័រ | <u>រ.គ.ស.ភ</u><br>ប្រមូលតាមចិញ្ចើមថ្នល់/ស៊ីប្លេ<br>តាមទីតាំងដាក់កុងទែន័រ<br>ប្រមូល<br>តាមរទេះរុញនិងកុងទែន័រ<br><u>ស៊ីនទ្រី</u><br>អាស្រ័យតាមផែនការចុះកិច្ចសន្យារបស់ក្រុមហ៊ុនឯកជន | <u>រ.គ.ស.ភ</u><br>ប្រមូលតាមចិញ្ចើមថ្នល់/ស៊ីប្លេ<br>តាមទីតាំងដាក់កុងទែន័រ<br>ប្រមូល<br>តាមរទេះរុញនិងកុងទែន័រ_<br><u>ស៊ីនទ្រី</u><br>អាស្រ័យតាមផែនការចុះកិច្ចសន្យារបស់ក្រុមហ៊ុនឯកជន | <u>រ.គ.ស.ភ</u><br>ប្រមូលតាមចិញ្ចើមថ្នល់/ស៊ីប្លេ<br>តាមទីតាំងដាក់កុងទែន័រ<br>ប្រមូល<br>តាមរទេះរុញនិងកុងទែន័រ<br><u>ស៊ីនទ្រី</u><br>អាស្រ័យតាមផែនការចុះកិច្ចសន្យារបស់ក្រុមហ៊ុនឯកជន |

| ដំណាក់កាល<br>សមាសភាព | បច្ចុប្បន្ន<br>(២០០៤) | ដំណាក់កាលទី ១<br>(២០០៧) | ដំណាក់កាលទី ២<br>(២០១២) | ដំណាក់កាលទី ៣<br>(២០១៥) |
|---|---|---|---|---|
| ប្រភេទរថយន្តសំខាន់ៗ<br>(ឯកតា)<br>CT: Compactor Truck<br>SL: Skip Loader<br>CO: Container | CT (18 m$^3$): 1<br>CT (4.5 m$^3$): 1<br>CT (4 m$^3$): 2<br>SL : 1<br>CO (5 m$^3$): 10 | រ.គ.ស.ភ<br>CT (15 m$^3$): 8<br>CT (8 m$^3$): 3<br>CT (4 m$^3$): 3<br>SL : 5<br>CO (5 m$^3$): 37<br>WL: 1 | រ.គ.ស.ភ<br>CT (15 m$^3$): 16<br>CT (8 m$^3$): 4<br>CT (4 m$^3$): 5<br>SL : 8<br>CO (5 m$^3$): 61<br>WL: 1 | រ.គ.ស.ភ<br>CT (15 m$^3$): 19<br>CT (8 m$^3$): 6<br>CT (4 m$^3$): 8<br>SL : 11<br>CO (5 m$^3$): 86<br>WL: 1 |
| ចំនួនបុគ្គលិក<br>(កម្មករប្រមូលសំរាម) | រ.គ.ស.ភ : 21(16) | រ.គ.ស.ភ : 75 (48) | រ.គ.ស.ភ : 108 (74) | រ.គ.ស.ភ : 142 (100) |
| ប្រព័ន្ធដឹកជញ្ជូន | ដឹកជញ្ជូនផ្ទាល់ | ដឹកជញ្ជូនផ្ទាល់ | ដឹកជញ្ជូនផ្ទាល់ | ដឹកជញ្ជូនផ្ទាល់ |
| អង្គភាពប្រតិបត្តិ | រ.គ.ស.ភ : តំបន់ NIP<br>ក្រុមហ៊ុនឯកជន : ភ្នំពេញទាំងមូល លើកលែងតែតំបន់ NIP | ជាយក្រុង : រ.គ.ស.ភ<br>ស៊ីនទ្រី<br>ទីប្រជុំជនៈ ស៊ីនទ្រី | ជាយក្រុង : រ.គ.ស.ភ<br>ស៊ីនទ្រី<br>ទីប្រជុំជនៈ ស៊ីនទ្រី | ជាយក្រុង : រ.គ.ស.ភ<br>ស៊ីនទ្រី<br>ទីប្រជុំជនៈ ស៊ីនទ្រី |
| តម្លៃឯកតា (ដុល្លា/តោន) | 6.73( in 2003) | 8.14(តំបន់ រ.គ.ស.ភ) | 6.98 (តំបន់ រ.គ.ស.ភ) | 7.07 (តំបន់ រ.គ.ស.ភ) |
| **៣. ការសំអាតតំបន់សាធារណៈ** | | | | |
| វិធីបោសសំអាត | បោសដោយដៃ<br>ដោយក្រុមហ៊ុនឯកជន | ជាយក្រុង :<br>រ.គ.ស.ភៈ បោសដោយដៃ<br>ស៊ីនទ្រីៈ ផែនការឯកជន<br>ទីប្រជុំជនៈ ស៊ីនទ្រី | ជាយក្រុង :<br>រ.គ.ស.ភៈ បោសដោយដៃ<br>ស៊ីនទ្រីៈ ផែនការឯកជន<br>ទីប្រជុំជនៈ ស៊ីនទ្រី | ជាយក្រុង :<br>រ.គ.ស.ភៈ បោសដោយដៃ<br>ស៊ីនទ្រីៈ ផែនការឯកជន<br>ទីប្រជុំជនៈ ស៊ីនទ្រី |
| ប្រភេទរថយន្តប្រមូល<br>នៅតំបន់ជាយក្រុង | - | Dump truck: 1 | Dump truck: 1 | Dump truck 1 |
| Length of served road<br>(km) | ជាយក្រុង :10km<br>ទីប្រជុំជន : 46 km | ជាយក្រុង :<br>រ.គ.ស.ភ : 4 km<br>ស៊ីនទ្រី : 6 km<br>ទីប្រជុំជន : 46 km | ជាយក្រុង :<br>រ.គ.ស.ភ : 7 km<br>ស៊ីនទ្រី : 6 km<br>ទីប្រជុំជន : 46 km | ជាយក្រុង :<br>រ.គ.ស.ភ : 8 km<br>ស៊ីនទ្រី : 6 km<br>ទីប្រជុំជន : 46 km |
| ធ្វើដោយ | ជាយក្រុង : ស៊ីនទ្រី<br>ទីប្រជុំជន : ស៊ីនទ្រី | ជាយក្រុង : រ.គ.ស.ភ<br>ស៊ីនទ្រី<br>ទីប្រជុំជន : ស៊ីនទ្រី | ជាយក្រុងៈ រ.គ.ស.ភ<br>ស៊ីនទ្រី<br>ទីប្រជុំជន : ស៊ីនទ្រី | ជាយក្រុង : រ.គ.ស.ភ<br>ស៊ីនទ្រី<br>ទីប្រជុំជន : ស៊ីនទ្រី |
| ចំនួនបុគ្គលិក (អ្នកបោស) | រ.គ.ស.ភ : 0 | រ.គ.ស.ភ : 28 (25) | រ.គ.ស.ភ : 47 (44) | រ.គ.ស.ភ : 53 (50) |
| តម្លៃឯកតា (ដុល្លា/តោន) | - | 238.8 (តំបន់ រ.គ.ស.ភ) | 183.0 (តំបន់ រ.គ.ស.ភ) | 153.9 (តំបន់ រ.គ.ស.ភ) |
| **៤. ការធ្វើប្រព្រឹត្តិកម្មកែច្នៃពាក់កណ្តាលសំរេច** | | | | |
| កន្លែងផលិតជីកំប៉ុស្ត ១ | ទីលានស្ទឹងមានជ័យ | ទីលានដង្កោ | ទីលានដង្កោ | ទីលានដង្កោ |
| បរិមាណធ្វើ (តោន/ឆ្នាំ) | 365 | 7,300 | 7,300 | 7,300 |
| តម្លៃឯកតា<br>(ដុល្លា/សំណល់-តោន) | គ្មាន | 10.3 | 10.3 | 10.3 |
| (ដុល្លា/ផលិតផល-តោន) | គ្មាន | 51.4 | 51.4 | 51.4 |

| ដំណាក់កាល<br>សមាសភាព | បច្ចុប្បន្ន<br>(២០០៤) | ដំណាក់កាលទី ១<br>(២០០៧) | ដំណាក់កាលទី ២<br>(២០១២) | ដំណាក់កាលទី ៣<br>(២០១៥) |
|---|---|---|---|---|
| ការកែច្នៃនៅកន្លែងបង្កើត | សំណល់ផ្សារ ។ល។ | សំណល់ផ្សារ ។ល។ | សំណល់ផ្សារ ។ល។ | សំណល់ផ្សារ ។ល។ |
| អត្រាកែច្នៃសរុប | 0.4 | 1.8 | 1.4 | 1.2 |
| ប្រព័ន្ធកែច្នៃ | Windrow | Windrow | Windrow | Windrow |
| កន្លែងធ្វើជីកំប៉ុស្តទី ២ | ជាយក្រុង : -<br>ទីប្រជុំជនៈមណ្ឌលអភិវឌ្ឍន៍កែច្នៃសំណល់ | ជាយក្រុង : មណ្ឌលកែច្នៃសំណល់(ម.ក.ស)<br>ទីប្រជុំជន : ម.អ.ក.ស | ជាយក្រុង : ម.ក.ស<br>ទីប្រជុំជន : ម.អ.ក.ស | ជាយក្រុង : ម.ក.ស<br>ទីប្រជុំជន : ម.អ.ក.ស |
| បរិមាណធ្វើ (តោន/ឆ្នាំ) | 110 | 110+2,190= 2,300 | 110+3,285= 3,395 | 110+4,380= 4,490 |
| តម្លៃឯកតា (ដុល្លា/តោន) | គ្មាន | គ្មាន | គ្មាន | គ្មាន |
| កែច្នៃនៅកន្លែងបង្កើត | សំណល់ក្រុង | សំណល់ក្រុង | សំណល់ក្រុង | សំណល់ក្រុង |
| អត្រាកែច្នៃសរុប | 0.4 | 0.6 | 0.7 | 0.8 |
| ប្រព័ន្ធកែច្នៃ | Windrow | Windrow | Windrow | Windrow |
| **៥. ការចាក់ចុងក្រោយ** | | | | |
| វិធីប្រតិបត្តិការណ៍ | ចាក់គ្មានបច្ចេកទេស | ទីលានបច្ចេកទេសកំរិត ៤ | ទីលានបច្ចេកទេសកំរិត ៤ | ទីលានបច្ចេកទេសកំរិត ៤ |
| ទីលានចាក់សំរាមចុងក្រោយ | ទីលានស្ទឹងមានជ័យ | ទីលានដង្កោ | ទីលានដង្កោ | ទីលានដង្កោ |
| ចំងាយពីទីក្រុង (គ.ម) | 5 | 10 | 10 | 10 |
| ធ្វើដោយ | រ.គ.ស.ភ | រ.គ.ស.ភ | រ.គ.ស.ភ | រ.គ.ស.ភ |
| បរិមាណចាក់ (តោន/ថ្ងៃ) | 715 | 924 | 1,301 | 1,540 |
| ចំនួនកម្មករ | 4 | 51<br>(ទាំងបុគ្គលិករដ្ឋបាល) | 54<br>(ទាំងបុគ្គលិករដ្ឋបាល) | 61<br>(ទាំងបុគ្គលិករដ្ឋបាល) |
| តម្លៃឯកតា (ដុល្លា/តោន)<br>• គ្មានជំនួយ<br>• មានជំនួយ | 0.43 | 5.92<br>4.40 | 5.92<br>4.40 | 5.92<br>4.40 |
| Main equipment | Bulldozers (ជួល) 2 | Bulldozer 4<br>Wheel loader 1<br>Water tank truck 1<br>Dump truck 2<br>Pickup truck 2<br>Excavator 2 | Bulldozer 5<br>Wheel loader 1<br>Water tank truck 1<br>Dump truck 2<br>Pickup truck 2<br>Excavator 2 | Bulldozer 6<br>Wheel loader 1<br>Water tank truck 1<br>Dump truck 3<br>Pickup truck 2<br>Excavator 3 |
| **៦. ការថែទាំ និងជួសជុល (សំរាប់ រ.គ.ស.ភ)** | | | | |
| ការឆែកមើលតូចតាច | ដោយរោងជាងឯកជន | ដោយ រ.គ.ស.ភ | ដោយ រ.គ.ស.ភ | ដោយ រ.គ.ស.ភ |
| ការជួសជុលធំដុំ | ដោយរោងជាងឯកជន | ដោយរោងជាងឯកជន | ដោយរោងជាងឯកជន | ដោយរោងជាងឯកជន |
| ធ្វើដោយ | រ.គ.ស.ភ | រ.គ.ស.ភ | រ.គ.ស.ភ | រ.គ.ស.ភ |
| បុគ្គលិកផ្នែកថែរក្សា | [ | ប្រធានរោងជាង : 1<br>អ្នកបច្ចេកទេស : 2<br>យន្តការ : 6<br>អ្នកយាមឃ្លាំង : 1<br>បុគ្គលិករដ្ឋបាល : 2 | ប្រធានរោងជាង : 1<br>អ្នកបច្ចេកទេស : 2<br>យន្តការ : 8<br>អ្នកយាមឃ្លាំង : 1<br>បុគ្គលិករដ្ឋបាល : 2 | ប្រធានរោងជាង : 1<br>អ្នកបច្ចេកទេស : 2<br>យន្តការ : 9<br>អ្នកយាមឃ្លាំង : 1<br>បុគ្គលិករដ្ឋបាល : 2 |

| ដំណាក់កាល<br>សមាសភាព | បច្ចុប្បន្ន<br>(២០០៤) | ដំណាក់កាលទី ១<br>(២០០៧) | ដំណាក់កាលទី ២<br>(២០១២) | ដំណាក់កាលទី ៣<br>(២០១៥) |
|---|---|---|---|---|
| **៧. ហិរញ្ញវត្ថុ រ.គ.ស.ភ (ទិន្នន័យឆ្នាំ២០០៣)** | | | | |
| តម្លៃឯកតាគ្រប់គ្រងសំណល់រឹង (ដុល្លា/តោន) | 7.16 | 12.54 | 11.38 | 11.47 |
| ប្រភពចំណូល | ថវិកាសាលាក្រុង 0<br>ថ្លៃប្រមូលសំណល់រឹង 39<br>ថ្លៃឈ្នួលចាក់ 104<br>លក់អាចម៍ដី 0 | ថវិកាសាលាក្រុង 35<br>ថ្លៃប្រមូលសំណល់រឹង 663<br>ថ្លៃឈ្នួលចាក់ 1,483<br>លក់អាចម៍ដី 0 | ថវិកាសាលាក្រុង 47<br>ថ្លៃប្រមូលសំណល់រឹង1,191<br>ថ្លៃឈ្នួលចាក់ 2,090<br>លក់អាចម៍ដី 133 | ថវិកាសាលាក្រុង 51<br>ថ្លៃប្រមូលសំណល់រឹង1,714<br>ថ្លៃឈ្នួលចាក់ 2,473<br>លក់អាចម៍ដី 66 |
| ចំណូលសរុប (១.000ដុល្លា) | 143 | 2,131 | 3,461 | 4,304 |
| អត្រាថ្លៃប្រមូលសំណល់ | ផ្ទះធម្មតា 80%<br>កន្លែងអាជីវកម្ម 0% | ផ្ទះធម្មតា 80%<br>កន្លែងអាជីវកម្ម 100% | ផ្ទះធម្មតា 80%<br>កន្លែងអាជីវកម្ម 100% | ផ្ទះធម្មតា 80%<br>កន្លែងអាជីវកម្ម 100% |
| ថវិកាបែងចែកពីខ្ទង់ហិរញ្ញវត្ថុទូទៅធៀបចំណូលសរុបដែលបានពីការគ្រប់គ្រងសំណល់រឹង | 0% | 2% | 2% | 2% |
| អត្រាថ្លៃប្រមូលដែលសេវាគ្របដណ្ដប់ធៀបចំណូលសរុបដែលបានពីការគ្រប់គ្រងសំណល់រឹង | 27% | 29% | 32% | 35% |
| ថ្លៃចាក់ធៀបនឹងចំណូលសរុបបានពីការគ្រប់គ្រងសំណល់រឹង | 73% | 70% | 62% | 62% |
| ថ្លៃលក់អាចម៍ដីធៀបនឹងចំណូលសរុបបានពីការគ្រប់គ្រងសំណល់រឹង | 0% | 0% | 4% | 2% |
| ចំណូលសរុបក្នុងម្នាក់ៗ (ដុល្លា/ឆ្នាំ) | 0.12 | 1.55 | 2.12 | 2.34 |
| ថវិកាប៉ាន់ស្មានរបស់ក្រុង (ពាន់ដុល្លា) | 5,811 | 8,435 | 11,305 | 13,772 |
| ថវិកាចូលរួមគ្រប់គ្រងសំណល់រឹង | 0% | 0.4% | 0.4% | 0.4% |
| **៨. ការគ្រប់គ្រងសំណល់វេជ្ជសាស្ត្រ** | | | | |
| ការបង្កើត (តោន/ថ្ងៃ) | សំណល់ទូទៅ: 9.7<br>វេជ្ជសាស្ត្រ: 1.0 | សំណល់ទូទៅ: 12.3<br>វេជ្ជសាស្ត្រ: 1.2 | សំណល់ទូទៅ: 16.5<br>វេជ្ជសាស្ត្រ: 1.6 | សំណល់ទូទៅ: 19.3<br>វេជ្ជសាស្ត្រ: 1.9 |
| ការធ្វើប្រព្រឹត្តិកម្មក្នុងពេលបង្កើតសំណល់ | ទូទៅ : ទីលានបច្ចេកទេស<br>វេជ្ជសាស្ត្រ : ឡរំលាយ | ទូទៅ : ទីលានបច្ចេកទេស<br>វេជ្ជសាស្ត្រ : ឡរំលាយ | ទូទៅ : ទីលានបច្ចេកទេស<br>វេជ្ជសាស្ត្រ : ឡរំលាយ | ទូទៅ : ទីលានបច្ចេកទេស<br>វេជ្ជសាស្ត្រ : ឡរំលាយ |
| ការចាក់សំណល់ចុងក្រោយ | សំណល់ទូទៅ:ចាក់ចំហរ | សំណល់ទូទៅ : ទីលាន | សំណល់ទូទៅ : ទីលាន | សំណល់ទូទៅ : ទីលាន |

| ដំណាក់កាល<br>សមាសភាព | បច្ចុប្បន្ន<br>(២០០៤) | ដំណាក់កាលទី ១<br>(២០០៧) | ដំណាក់កាលទី ២<br>(២០១២) | ដំណាក់កាលទី ៣<br>(២០១៥) |
|---|---|---|---|---|
| | | បច្ចេកទេសដង្កោ សំណល់វេជ្ជសាស្ត្រដែលពុំបានធ្វើប្រព្រឹត្តិកម្មមិនអនុញ្ញាតឱ្យចាក់នៅក្នុងទីលានដង្កោទេ | បច្ចេកទេសដង្កោ សំណល់វេជ្ជសាស្ត្រដែលពុំបានធ្វើប្រព្រឹត្តិកម្មមិនអនុញ្ញាតឱ្យចាក់នៅក្នុងទីលានដង្កោទេ | បច្ចេកទេសដង្កោ សំណល់វេជ្ជសាស្ត្រដែលពុំបានធ្វើប្រព្រឹត្តិកម្មមិនអនុញ្ញាតឱ្យចាក់នៅក្នុងទីលានដង្កោទេ |
| ប្រតិបត្តិការណ៍ចាក់ចុងក្រោយ | រ.គ.ស.ភ | រ.គ.ស.ភ | រ.គ.ស.ភ | រ.គ.ស.ភ |
| ៩. ការគ្រប់គ្រងសំណល់រឹងឧស្សាហកម | | | | |
| ការបង្កើត (តោន/ថ្ងៃ) | សំណល់ទូទៅ : 29.7<br>ឧស្សាហកម្ម : 28.5 | សំណល់ទូទៅ : 37.5<br>ឧស្សាហកម្ម : 36.0 | សំណល់ទូទៅ : 50.5<br>ឧស្សាហកម្ម : 48.5 | សំណល់ទូទៅ : 59.0<br>ឧស្សាហកម្ម : 56.6 |
| ការធ្វើប្រព្រឹត្តិកម្មសំណល់គ្រោះថ្នាក | គ្មាន | ទីលានបច្ចេកទេស | ទីលានបច្ចេកទេស | ទីលានបច្ចេកទេស |
| ការចាក់ចុងក្រោយ | ការចាក់ដោយចំហរ | ហាមឃាត់ និងត្រួតពិនិត្យការចាក់សំណល់គ្រោះថ្នាក់នៅទីលានដង្កោ និងត្រូវយកទៅចាក់នៅទីលានសំរាប់ចាក់សំណល់គ្រោះថ្នាក់ | ហាមឃាត់ និងត្រួតពិនិត្យការចាក់សំណល់គ្រោះថ្នាក់នៅទីលានដង្កោ និងត្រូវយកទៅចាក់នៅទីលានសំរាប់ចាក់សំណល់គ្រោះថ្នាក់ | ហាមឃាត់ និងត្រួតពិនិត្យការចាក់សំណល់គ្រោះថ្នាក់នៅទីលានដង្កោ និងត្រូវយកទៅចាក់នៅទីលានសំរាប់ចាក់សំណល់គ្រោះថ្នាក់ |

### 3.5.5 គំរោងអាទិភាព

គំរោងទាំង ៣ ដូចខាងក្រោមនេះ ត្រូវបានជ្រើសរើសជាគំរោងអាទិភាព និងត្រូវអនុវត្តជាបន្ទាន់សំរាប់លទ្ធភាពសិក្សា ក្នុងដំណាក់កាលទី ១ នៃផែនការមេ ដែលលទ្ធភាពនេះមានបង្ហាញក្នុងជំពូកទី ៦ ។

#### ១. គំរោងអភិវឌ្ឍន៍ទីលានចាក់សំរាមដង្កោ

ដោយសារតែសមត្ថភាពផ្ទុករបស់ទីលានចាក់សំរាមស្ទឹងមានជ័យមានកំរិត ដែលអាចទទួលបរិមាណសំណល់ត្រឹមចុងឆ្នាំ ២០០៦ ការអភិវឌ្ឍន៍ទីលានចាក់សំរាមថ្មីជួយជំរុញឱ្យប្រតិបត្តិការណ៍ទីលាននេះអាចបន្តចាប់ពីដើមឆ្នាំ ២០០៧ ហើយដែលជាតំរូវការបន្ទាន់ និងជាបញ្ហាធ្ងន់ធ្ងរ ។ ដើម្បីដោះស្រាយបញ្ហានេះ ក្រុមសិក្សាបានបង្កើតផែនការមេអភិវឌ្ឍន៍ទីលានចាក់សំរាមថ្មីនៅដង្កោ ដែលត្រូវបានជ្រើសរើសថាជាទីលានអាទិភាពក្នុងការសិក្សានេះ ។

#### ២. គំរោងពង្រីកសេវាប្រមូលសំរាម

គំរោងនេះគឺដើម្បីពង្រឹងសមត្ថភាព រ.គ.ស.ភ លើការផ្តល់សេវា ប្រមូលសំណល់ដើម្បីលុបបំបាត់តំបន់ដែលគ្មានសេវាកម្ម និងមានសេវាកម្មតែមិនគ្រប់គ្រាន់អោយអស់ពីទីក្រុង ដោយសហការជាមួយផ្នែកឯកជនដូចមានក្នុងតារាង ៣-១១ ។

តំបន់មានសេវាកម្មនីមួយៗនឹងត្រូវបានកំនត់តាមរយៈការចចាររវាងសាលាក្រុងនឹងស៊ីនទ្រី។ ទោះជាយ៉ាងនេះក្តី ដោយសារភាគីទាំងពីរមិនអាចឈានដល់កិច្ចព្រមព្រៀងស្តីពីការកំនត់តំបន់សេវាកម្មកាលពីចុងខែកុម្ភៈ ឆ្នាំ២០០៥បាន

ក្រុមសិក្សាបានប៉ាន់ប្រមាណពីបរិមាណសំណល់ដែលនឹងត្រូវប្រមូលដោយ រ.គ.ស.ភ ដោយផ្អែកទៅលើទីតាំងនិងទិន្នន័យជញ្ជីងថ្លឹង ហើយបានធ្វើផែនការប្រព័ន្ធប្រមូលសំណល់ដែលត្រូវការអោយស្របទៅតាមការស្នើសុំរបស់សាលាក្រុង ។

### ៣. គំរោងបិទទីលានចាក់សំរាមស្ទឹងមានជ័យ

ទីលានចាក់សំរាមស្ទឹងមានជ័យអាចប្រើប្រាស់បានរហូតដល់ដើមឆ្នាំ២០០៧ដោយសារមានការពង្រីកដីទំហំ៣.៦ ហិចតាទៀត តាមរយៈការសិក្សា។ ដោយធ្វើការបំពេញសំណល់ចាស់ទៅក្នុងរណ្តៅដីជិតទីលានតាមការស្នើរបស់ម្ចាស់ដីដែលធ្វើអោយអាយុកាលទីលានស្ទឹងមានជ័យពន្យាបានយូរ។ ដូច្នេះ រ.គ.ស.ភ អាចមានពេលវេលាបន្ថែមទៀតដើម្បីចាក់សំណល់ រហូតដល់ទីលានថ្មីចាប់ផ្តើមប្រតិបត្តិការ ។

ការរៀបចំផែនការផ្ទេរទីលានចាក់សំរាមដែលមានស្រាប់ទៅកាន់ទីលានថ្មី គឺជាបញ្ហាបន្ទាន់ដែលនឹងត្រូវអនុវត្តជាមួយការធ្វើផែនការអភិវឌ្ឍន៍ទីលានចាក់សំរាមថ្មីក្នុងពេលជាមួយគ្នា។ ប៉ុន្តែទោះយ៉ាងណាក៏ដោយគេគួរតែគិតគូដល់វិធានការដោះស្រាយដើម្បីកាត់បន្ថយហេតុប៉ះពាល់បរិស្ថានឱ្យបានដល់កំរិតអប្បបរមចំពោះតំបន់នៅជុំវិញ ដែលប្រហែលជាបង្កមកពីសំរាមដែលចាក់នៅទីលាន ។

## 3.5.6 ប្លង់ទីតាំងសំរាប់ហេដ្ឋារចនាសម្ពន្ធ័នាពេលអនាគត

មធ្យោបាយដែលបានស្នើឡើងនៅក្នុងផែនការមេដែលមានគោលដៅក្នុងឆ្នាំ ២០១៥ គឺជាទីលានចាក់ចុងក្រោយ ដេប៉ូ និងរោងជាងថែទាំសំរាប់ជួសជុលរថយន្តប្រមូលសំរាម និងមណ្ឌលកែច្នៃដែលជាកន្លែងផ្ទេរសំណល់ប្រមូលតាមរទេះ ។ ប្លង់ទីតាំងសំរាប់ហេដ្ឋារចនាសម្ពន្ធ័នាពេលអនាគតត្រូវបានរៀបចំជាផែនការដូចតទៅ :

### a. ទីលានចាក់ចុងក្រោយ

### a.1 ផ្ទៃដីទំហំ២៥ហិចតា(ផែនការដើម)

ផ្ទៃដីទំហំ ១០០ ហ.ត នៅដង្កោត្រូវបានផ្តល់ជាអនុសាសន៍ថាជាទីលានសំរាប់ពេលអនាគតក្នុងការសិក្សាដែលត្រូវបានដឹកនាំដោយសាលាក្រុងភ្នំពេញ និងទីប្រឹក្សាជនជាតិអាល្លឺម៉ង់តាំងពីឆ្នាំ ១៩៩៥។ យោងទៅតាម អនុសាសន៍នេះ សាលា ក្រុងបានទិញដីទំហំ ១១ហ.ត នៅក្នុងដង្កោកាលពីឆ្នាំ ២០០១ ។

ក្រុមសិក្សាបានធ្វើការប្រៀបធៀបទីតាំងបេក្ខភាព៤ ដែលត្រូវ បានជ្រើសរើសនៅក្នុងការសិក្សាលើកមុនដោយធ្វើការប្រៀបអំពី លក្ខណៈសមស្របនៃតំបន់ ទិដ្ឋភាពដីការអភិវឌ្ឍន៍ជុំវិញ និង លក្ខណៈសមស្របដែលអាចពង្រីកបានពេលអនាគត។ ទោះជាយ៉ាងណាក្រុមសិក្សាមិនបានប្រៀបធៀបអំពីតំរូវការតំលៃសំរាប់អភិវឌ្ឍន៍របស់ តំបន់នីមួយៗ ទេព្រោះមានការលំបាកដោយវាអាស្រ័យលើរយៈពេលប្រតិបត្តិការដែល ត្រូវបានកំនត់ទៅតាមលក្ខខ័ណ្ឌ តំបន់។ យោងទៅលើលទ្ធផលនៃការសិក្សាប្រៀបធៀប ក្រុមសិក្សាបានសន្និដ្ឋានថា ទីតាំងក្នុងខ័ណ្ឌដង្កោគឺជាទីតាំងសមស្របជាងគេ




Figure 3-4: ទីតាំងទីលានដង្កោ

ហើយទីនោះគឺជាដីដែលសាលាក្រុងភ្នំពេញបានទទួល ។

ទីតាំងដែលស្នើគឺស្ថិតនៅប៉ែកខាងត្បូងនៃតំបន់របស់ក្រុងក្រោមសំពាធភ្នំពេញ ដែលវាស្ថិតនៅតំបន់ដងស្ទឹងលាតសន្ធឹងឆ្លងកាត់ដីល្បាប់ទូល ។ តំបន់នេះត្រូវបានប្រើប្រាស់ជាវាលស្រែ និងមិនមានលំនៅក្នុងតំបន់នោះទេ ។ តំបន់នេះធ្លាប់មានទឹកជំនន់ពីស្ទឹងព្រែកត្នោត ប៉ុន្តែចាប់ពីការសាងសង់ទំនប់តាំងពីឆ្នាំ២០០២មក មិនដែលមានទឹកជំនន់ទេ ។




Figure 3-5: រូបភាពភូមិសាស្ត្រតំបន់ដែលត្រូវជ្រើសរើស

ជាដំបូងក្រុមសិក្សាបានស្នើតំបន់មួយប្រហែលជា១០០ហិចតា ដែលគ្រប់គ្រាន់សំរាប់ប្រតិបត្តិការជាង ២០ឆ្នាំ នៅក្នុងរូបភាពថតពីអាកាស វាស្ថិតក្នុងខ័ណ្ឌដង្កោ ។ បន្ទាប់មកនៅក្នុងផ្ទៃដី១០០ហិចតាដែលបញ្ជាក់ខាងលើ ក្រុមសិក្សាបានស្នើតំបន់មួយផ្ទៃដី២៥ហិចតារួមបញ្ចូលទាំងដី១១ហិចតាដែលសាលាក្រុងភ្នំពេញបានទទួលរួចហើយនោះសំរាប់ប្រើក្នុងរយៈពេលប្រហែល៥ឆ្នាំ ។

សាលាក្រុងភ្នំពេញបានអនុម័តសំនើរនេះនៅក្នុងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំនាថ្ងៃទី៣ខែកក្កដាឆ្នាំ២០០៣ និងបានដាក់ជូនរដ្ឋាភិបាលដើម្បីទទួលបានដីនេះ ។ ទីស្តីការគណៈរដ្ឋមន្ត្រីបានអនុម័តពាក្យសុំដែលដាក់ជូនដោយសាលាក្រុងភ្នំពេញនៅថ្ងៃទី២៩ ខែតុលាឆ្នាំ២០០៣ ព្រមទាំងមានការបញ្ជាក់ពីអាជ្ញាធរក្នុងភ្នំពេញ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងសេចក្តីសំរេចនេះផងដែរ ។

បន្ទាប់ពីមានការបញ្ជាក់ សាលាក្រុងភ្នំពេញបានរៀបចំគណៈកម្មាធិការវាយតំលៃដី នៅក្នុងក្រុងសំរាប់អភិវឌ្ឍន៍ទីលានថ្មី និងបានចាប់ផ្តើមជាវដី ។

**- ដី ៣១.៤ ហិចតា (វិសោធនកម្មផែនការ)**

ទោះបីជាគណៈកម្មាធិការវាយតំលៃដីបានព្យាយាមជាវដីទៅតាមផែនការអភិវឌ្ឍន៍ដែលបានរៀបចំដោយក្រុមសិក្សាក៏ដោយ ក៏តំលៃដីតាមបណ្តោយផ្លូវ៣០៣ឡើងថ្លៃយ៉ាងលឿន ដែលធ្វើអោយមានការលំបាកក្នុងការចាត់ចែងដីទៅតាមថវិកានៃតំបន់ដែលបានស្នើ ។ ដូច្នេះគណៈកម្មាធិការវាយតំលៃដីបានសំរេចផ្លាស់ប្តូរតំបន់ និងបានជាវដី ២០ហិចតា( ផ្ទៃដីសរុប៣១.៤ហិចតា) ដែលនៅជាប់ដី១១ហិចតា ចំងាយប្រហែលជា១គីឡូម៉ែត្រប៉ែកខាងលិច ផ្លូវជាតិ៣០៣ ។



Figure 3-5: ការផ្លាស់ប្តូរដីសំរាប់ទីលានថ្មី

b. ដេប៉ូ និងរោងជាងថែទាំរថយន្តប្រមូលសំណល់

រថយន្តប្រមូលសំរាមចំនួន ៣៨គ្រឿងត្រូវបានត្រៀមសំរាប់ការងារនេះផ្អែកតាមគំរោងពង្រីកសេវាកម្មប្រមូលសំណល់។ ផ្ទៃដីទំហំ ១ហ.ត គឺជាតំរូវការចាំបាច់សំរាប់ធ្វើជាកន្លែងចតរថយន្ត និងរោងជាងជួសជុល ។

សាលាក្រុងភ្នំពេញបានស្នើឱ្យបង្កើតដេប៉ូ និងរោងជាងមួយនៅក្បែរទីលានចាក់សំរាមថ្មី។

c. ដីសំរាប់មធ្យោបាយដំណើរការផ្សេងៗទៀត

ក្រុមសិក្សាបានបង្កើតផែនការផលិតជីកំប៉ុស្ត ដែលផ្តោតលើសំណល់បានពីទីផ្សារ ។ យោងតាមការពិភាក្សារវាងសាលាក្រុង និងក្រុមសិក្សា ជាលទ្ធផលគឺត្រូវបង្កើតការផលិតជីកំប៉ុស្តនៅក្នុងទីលានថ្មី។

d. មណ្ឌលកែច្នៃ

ផែនការមេ បានស្នើដល់ប្រព័ន្ធប្រមូលថា ការប្រមូលសំណល់តាមរយៈរទេះរុញដែលអនុវត្តដោយក្រុមជួយខ្លួនឯងប្រមូលសំណល់ទៅចាក់ក្នុងធុងកុងទ័ន័ររួម ឬទៅក្នុងមណ្ឌលកែច្នៃ ដើម្បីជួយសំរួលកាត់បន្ថយចំនួនតំបន់ដែលគ្មានសេវាប្រមូល ដែលរថយន្តមិនអាចចេញចូលបាន ។ ក្រុមសិក្សាបានស្នើឱ្យបន្តសកម្មភាពកែច្នៃដោយអនុលោមថា ធនធានសំណល់ញែកដែលមានតម្លៃ និងធនធានធ្វើជីកំប៉ុស្ត ត្រូវធ្វើនៅមណ្ឌលអភិវឌ្ឍន៍កែច្នៃសំណល់ក្នុងតំបន់ NIP ផ្អែកតាមកម្មវិធី 3Rs ដែលមានបង្ហាញច្បាស់ក្នុងផែនការមេ ។ តំរូវការដីសំរាប់ធ្វើមណ្ឌលកែច្នៃនឹងត្រូវជួល ឬទិញ ដោយផ្អែកទៅតាមពតិមានដែលនឹងទទួលបានពីការពង្រីកសេវាប្រមូលសំរាម ។ ទោះបីយ៉ាងណាក៏ដោយ ដីសំរាប់ធ្វើមណ្ឌលកែច្នៃមិនទាន់ត្រូវបានកំណត់នៅឡើយទេ ក្រុមសិក្សាបានសន្មត់ថា មណ្ឌលមួយត្រូវការផ្ទៃដីទំហំ ១០០០ម$^{២}$ ដែលមធ្យោបាយដំណើរការខ្នាតតូចអាចតម្លើងបាន និងការពិចារណាអំពីតម្លៃចាំបាច់សំរាប់សាងសង់មធ្យោបាយដំណើរការនេះ ។

## 3.5.7 កម្មវិធីអនុវត្ត

កម្មវិធីអនុវត្តសំរាប់គំរោងអាទិភាព មានបង្ហាញក្នុងតារាងខាងក្រោម ។

Table 3-14: : កម្មវិធីអនុវត្ត

| | | ២០០៤ | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ទីលានចាក់សំរាមដង្កោ | ការធ្វើផែនការ/ព្រៀង | ■ | ■ | | | | | | ■ | | | | |
| | កសាងបរិក្ខារ | | | ■ | | | | | | ■ | | | |
| | លទ្ធកម្ម | | | ■ | | | | | | | ■ | | |
| | ប្រតិបត្តិការណ៍ | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| ការពង្រីកសេវាប្រមូលសំរាម | ការធ្វើផែនការ/ព្រៀង | ■ | ■ | | | | | | | | ■ | | |
| | លទ្ធកម្ម | | | ■ | | | | | | | ■ | | |
| | ប្រតិបត្តិការណ៍ | | | | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ | ■ |
| កសាងសមត្ថភាពប្រតិបត្តិការណ៍ | | ■ | ■ | ■ | | | | | | | | | |
| អង្កេត/ត្រួតពិនិត្យការកសាងសមត្ថភាព | | ■ | ■ | ■ | | | | | | | | | |

ការងាររៀបចំសំរាប់ការពង្រីកនៃការអភិវឌ្ឍន៍ទីលានដង្កោជំហានទីពីរ នឹងចាប់ផ្តើមពីឆ្នា២០១១ ហើយនឹងចាប់ផ្តើមប្រតិបត្តិការចាប់ពី២០១៣។

## 3.5.8 ថ្លៃដើមគំរោង

ថ្លៃគំរោងប្រចាំឆ្នាំសំរាប់ការអនុវត្តផែនការមេត្រូវបានប៉ាន់ស្មាននៅក្នុងតារាងខាងក្រោម ។

Table 3-15: ថ្លៃដើមគំរោងសំរាប់ផែនការមេ

| | | | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 | Total |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ការប្រមូល | ឡាន ប្រមូល | Invest. | 0 | 1,804 | 195 | 141 | 197 | 60 | 220 | 322 | 1,604 | 523 | 144 | 5,210 |
| | | O&M | 0 | 0 | 316 | 359 | 386 | 417 | 428 | 475 | 527 | 569 | 634 | 4,111 |
| ដឹកជញ្ជូន | ជីកំប៉ុស្តិ៍ | Invest. | 59 | 1,135 | 0 | 0 | 0 | 0 | 0 | 0 | 110 | 0 | 0 | 1,304 |
| | | O&M | 0 | 0 | 56 | 56 | 56 | 56 | 62 | 58 | 61 | 63 | 63 | 531 |
| ទីលានចាក់ | រដ្ឋបាល រោង | Invest. | 95 | 1,653 | 0 | 0 | 0 | 0 | 4 | 75 | 0 | 0 | 0 | 1,827 |
| | មធ្យោបាយ | Invest. | 316 | 5,485 | 0 | 0 | 0 | 0 | 193 | 3,349 | 0 | 0 | 0 | 9,343 |
| | សំភារៈ | Invest. | 0 | 1,341 | 0 | 0 | 0 | 175 | 0 | 0 | 1,724 | 0 | 0 | 3,240 |
| | ប្រតិបត្តិការ | Invest. | 76 | 1,498 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1,574 |
| | រដ្ឋបាល រោង | O&M | 0 | 0 | 795 | 777 | 777 | 777 | 844 | 820 | 897 | 871 | 984 | 7,542 |
| គំរោងបិទទីលានស្ទឹងមានជ័យ | | Invest. | 0 | 75 | 745 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 820 |
| | | O&M | 0 | 0 | 24 | 14 | 14 | 24 | 14 | 14 | 24 | 14 | 14 | 156 |
| Total | | | 546 | 12,991 | 2,131 | 1,347 | 1,430 | 1,509 | 1,765 | 5,113 | 4,947 | 2,040 | 1,837 | 35,656 |

## 3.5.9 ការវាយតម្លៃលើផ្នែកហិរញ្ញវត្ថុរបស់ផែនការមេ

គំរោងពង្រីកសេវាកម្មប្រមូលសំណល់ ។ គំរោងដែលផ្តោតលើការវាយតម្លៃផ្នែកហិរញ្ញវត្ថុរួមមាន :

- ការប្រប្រមូល និងការដឹកជញ្ជូនសំណល់រឹងក្រុងនៅក្នុងតំបន់ដែលបានបង្ហាញក្នុងសេណារីយ៉ូ២ ដោយ រ.គ.ស.ភ ។
- គំរោងទីលានចាក់សំរាមចុងក្រោយថ្មីនៅដង្កោ

ចំពោះការប្រមូលនិងដឹកជញ្ជូនសំណល់រឹងក្នុងតំបន់ដែលនៅសល់ពីតំបន់សេវាកម្មរ.គ.ស.ភក្រុមសិក្សាបានស្នើឱ្យស៊ិនទ្រីជាអ្នកអនុវត្តន៍ ដែលបច្ចុប្បន្ននេះក្រុមហ៊ុនកំពុងធ្វើការក្នុងក្រុងភ្នំពេញ។ប៉ុន្តែទោះយ៉ាងណាក៏ដោយដោយសារតែក្រុមហ៊ុនមិនបើកឱ្យដឹង អំពីទិន្នន័យថ្លៃដើមនិងផ្នែកហិរញ្ញវត្ថុ ការសិក្សាមិនធ្វើការវាយតម្លៃទៅលើប្រតិបត្តិការណ៍របស់ក្រុមហ៊ុននេះទេ ។

### a. តំលៃបច្ចុប្បន្នលើការគ្រប់គ្រងសំណល់រឹងក្រុងបច្ចុប្បន្ន

យោងតាមទិន្នន័យដែល រ.គ.ស.ភ បានផ្តល់ឱ្យថ្លៃដើមប្រមូលនិងដឹកជញ្ជូនសំណល់រឹងក្រុងក្នុងតំបន់ NIP ក្នុងមួយតោន និងថ្លៃប្រតិបត្តិការណ៍សំណល់មួយតោននៅទីលានស្ទឹងមានជ័យ មានបង្ហាញក្នុងតារាងដូចខាងក្រោមនេះ ។

Table 3-16: : ថ្លៃប្រមូល/ដឹកជញ្ជូនសំណល់រឹងក្រុង និងប្រតិបត្តិការណ៍នៅទីលាន ស្ទ.ម.ជ ដោយ រ.គ.ស.ភ

| ឆ្នាំ<br>ការគ្រប់គ្រងសំណល់រឹង | ឯកតា | ២០០២ | ២០០៣ |
|---|---|---|---|
| ការប្រមូល និងដឹកជញ្ជូន | ដុល្លា/តោន | ៦,៩៣ | ៦,៧៣ |
| ការចាក់សំណល់ចុងក្រោយ | ដុល្លា/តោន | ០,៥៧ | ០,៤៣ |
| សរុប | ដុល្លា/តោន | ៧,៥០ | ៧,១៦ |

សំគាល់ : តម្លៃខាងលើនេះមិនគិតបញ្ចូលថ្លៃរំលោះ អាគារ រថយន្ត និងឧបករណ៍ ទេ ។ ថ្លៃប្រមូល និងដឹកជញ្ជូនសំណល់រឹងក្រុងដោយស៊ិនទ្រីក៏មិនគិតបញ្ចូល ក្នុងការខ្មាន់ស្មានខាងលើនេះដែរ ។

### b. ការវាយតម្លៃលើផ្នែកហិរញ្ញវត្ថុរបស់ផែនការមេ

បុរេលក្ខខណ្ឌដូចខាងក្រោមនេះត្រូវបានបង្កើតឡើងដើម្បីធ្វើការវាយតម្លៃលើហិរញ្ញវត្ថុរបស់ផែនការមេ ។

Table 3-17: បុរេលក្ខណ្ឌរបស់គំរោង

| អង្គភាពអនុវត្ត | រ.គ.ស.ភ |
|---|---|
| រយៈពេលគំរោង | ១២ ឆ្នាំ ចាប់ពីឆ្នាំ ២០០៤ ដល់ ២០១៥ |
| ចំណូលរបស់គំរោង | (ប្រាក់ចំណូលដែលបានមកពីការប្រមូលសំរាម និងដឹកជញ្ជូនដោយ រ.គ.ស.ភ )<br>•ប្រាក់ចំណូលណូលបានពីអ្នកប្រើប្រាស់សេវាក្នុងតំបន់ រ.គ.ស.ភ ពីឆ្នាំ២០០៧ ដល់២០១៥ ។<br>(ប្រាក់ចំណូលដែលបានមកពីទីលានចាក់សណល់ដង្កោ)<br>• ចំណូលដែលបានពីថ្លៃចាក់នៅទីលានពីក្រុមហ៊ុន ស៊ិនទ្រី និង រ.គ.ស.ភ ។<br>• ចំណូលបានពីលក់អាចម៍ដី (ចំណូលមធ្យមប្រចាំឆ្នាំ ២៧៩.០០០ដុល្លាសហរដ្ឋដែលសន្មត់ថានឹងអាចរកបានសំរាប់រយៈពេលប្រតិបត្តិការណ៍របស់ខ្លួនពីឆ្នាំ ២០០៧-២០១៥) ។<br>• ចំណូលរកបានពីលក់ជីកំប៉ុស្តដែលផលិតក្នុងរោងចក្រជីកំប៉ុស្តក្នុងអត្រា ២០០០រៀល/គ.ក្រ (ចំណូលមធ្យមប្រចាំឆ្នាំ ៦១.២៥០ដុល្លាសហរដ្ឋ ដែលសន្មត់ថានឹងអាចរកបានសំរាប់រយៈពេលប្រតិបត្តិការណ៍របស់ខ្លួនពីឆ្នាំ ២០០៧-២០១៥) ។ |

| | |
|---|---|
| **តម្លៃវិនិយោគ** | **១. ការប្រមូល និងដឹកជញ្ជូនសំណល់រឹងទីក្រុង**<br>ការផ្តើមវិនិយោគត្រូវបានធ្វើក្នុងឆ្នាំ ២០០៦ សំរាប់បំរើឱ្យគោលបំណងដូចតទៅ ។<br>(ទិញរថយន្ត)<br>• រថយន្ត Compactor truck (សមត្ថភាពផ្ទុក ៤ម$^{៣}$, ៨ម$^{៣}$ និង ១៥ម$^{៣}$)<br>• រថយន្ត Skip<br>• កុងទ័ឺន័រ Skip (៥ ម$^{៣}$ )<br>• Wheel Loader<br>• រទេះរុញ<br>• Pickup truck<br>• Dump truck<br>(ការសាងសង់)<br>• កន្លែងដាក់ធុងកុងទែន័រ<br>• រោងជាងថែទាំរថយន្ត<br>រថយន្តប្រមូល និងដឹកជញ្ជូននឹងត្រូវបានជាវដោយអាស្រ័យទៅតាមកំនើនឡើងនៃអ្នកប្រើប្រាស់សេវា និងការពង្រីកតំបន់សេវាប្រពេលដែលអាយុកាលរបស់រថយន្ត និងឧបករណ៍នឹងត្រូវបានផ្លាស់ចេញដែរ ។<br>**២. ទីលានចាក់ចុងក្រោយនៅដង្កោ**<br><br>ការផ្តើមវិនិយោគត្រូវបានធ្វើពីឆ្នាំ ២០០៤-២០០៦ ។<br>២០០៤: ជាវដី (២៦ហ.ត)<br>២០០៥-២០០៦: រៀបចំ និងសាងសង់ទីលាន និងរោងចក្រដីកំប៉ុស្ត<br>២០០៧: ចាប់ផ្តើមធ្វើប្រតិបត្តិកាណ៏នៅថ្ងៃទី ០១ ខែ មករា<br>ការអភិវឌ្ឍន៍ទីលាននៅដំណាក់កាលទី ២ នឹងចាប់ផ្តើមក្នុងឆ្នាំ ២០១២ សំរាប់ការប្រតិបត្តិរបស់វាគឺពីឆ្នាំ ២០១៣ ។ |
| **តម្លៃប្រតិបត្តិការណ៍ និងថែទាំ** | តម្លៃប្រតិបត្តិការណ៍ និងថែទាំត្រូវបានប៉ាន់ស្មានសំរាប់ឆ្នាំនិមួយៗ ពីឆ្នាំ ២០០៧-២០១៥ អាស្រ័យទៅតាមតម្លៃមួយឯកតា និងបរិមាណ ។ |
| **រំលោះ** | **១. ការប្រមូល និងដឹកជញ្ជូនសំណល់រឹងទីក្រុង**<br>រយៈពេលរំលោះ ២០ឆ្នាំ ១៥ឆ្នាំ និង ៧ឆ្នាំត្រូវបានកំណត់សំរាប់ការសាងសង់ ប្រភេទរថយន្ត និងឧបករណ៍និមួយៗ ។ តម្លៃរំលោះ១០% សំរាប់រាល់ឧបករណ៍ និងរថយន្តទាំងអស់ គឺ ប៉ុន្តែសំរាប់សំណង់អាគារគឺសន្មត់ថាត្រូវរំលោះអស់តម្លៃ ។<br>**២. ទីលានចាក់ចុងក្រោយនៅដង្កោ**<br>ការអភិវឌ្ឍន៍ និងការសាងសង់ទីលានសំរាប់ការប្រើប្រាស់ទូទៅ រួមបញ្ចូលទាំងផ្លូវថ្នល់ អាគាររដ្ឋបាល មធ្យោបាយធ្វើប្រព្រឹត្តិកម្មទឹកស្អុយ រោងចក្រធ្វើដីកំប៉ុស្ត និងមធ្យោបាយផ្សេងៗ ទៀតដែលមាននៅទីលានចុងក្រោយ នឹងត្រូវធ្វើរំលោះទាំងស្រុងក្នុងរយៈពេល ២០ឆ្នាំ ស្របពេលដែលផ្ទៃដីទីលានខ្លួនឯងក៏ត្រូវបានរំលោះទាំងស្រុងក្នុងពេលប្រតិបត្តការណ៏ ។ រថយន្ត និងឧបករណ៍នានាដែលប្រើប្រាស់នៅទីលានត្រូវបានរំលោះសំរាប់រយៈពេល ៧ឆ្នាំជាមួយនឹងតម្លៃរំលោះនៅសល់ចុងក្រោយដែលអាចចោលបាន ១០% ។ |
| **ថ្លៃទីផ្សារ** | ថ្លៃដើមទាំងអស់ត្រូវបានប៉ាន់ស្មានផ្អែកទៅតាមតម្លៃទីផ្សារបច្ចុប្បន្នក្នុងឆ្នាំ ២០០៣ ។ ពុំមានតម្លៃ |

| | |
|---|---|
| | បំប៉ោង ដែលត្រូវគិតបញ្ចូលជាមួយនោះទេ ។ |
| **អត្រាចុះថ្លៃ** | អត្រាចុះថ្លៃត្រូវបានគិតត្រឹម ១០% ដោយពិចារណាលើអតិផរណា និងអត្រាទីផ្សានៅកម្ពុជា ។ |

ផ្អែកតាមបុរេលក្ខខណ្ឌខាងលើនេះ ក្រុមសិក្សាបានធ្វើការវិភាគលើអត្រាតំរូវការថ្លៃដែលនឹងត្រូវប្រមូលដោយ រ.គ.ស.ភ ពីអ្នកប្រើប្រាស់សេវាគ្រប់គ្រងសំណល់រឹងក្រុងរួមទាំងការប្រមូល ការដឹកជញ្ជូន និងការចាក់ ។ ស្របពេលដែលចំណូលរបស់ រ.គ.ស.ភ មិនអាស្រ័យតែទៅលើតម្លៃប្រមូលសំណល់រឹងក្រុង ប៉ុន្តែអាស្រ័យនឹងថ្លៃចាក់ សំរាមនៅទីលានដែលបង់ដោយក្រុមហ៊ុន ស៊ិនទ្រីផងនោះ អាត្រាតំរូវការថ្លៃសំរាប់អ្នកប្រើប្រាស់សេវាសំណល់រឹងក្រុងគឺប្រែប្រួលជាមួយឹងអត្រានៃថ្លៃចាក់នៅទីលាន ដែលបានកំណត់ចំពោះក្រុមហ៊ុនស៊ិនទ្រីផងដែរ ។

ហេតុដូច្នេះក្រុមសិក្សា បានបង្កើតករណីមួយចំនួនលើអត្រានៃថ្លៃចាក់ដែលត្រូវដាក់ចំពោះក្រុមហ៊ុនស៊ិនទ្រីដោយមាន ចាប់ពី ០,៥ រហូតដល់ ៥ដុល្លាសហរដ្ឋ ក្នុងមួយតោនសំរាមដែលចាក់នៅទីលាន និងធ្វើការប៉ាន់ស្មានអត្រាតំរូវការថ្លៃដែលនឹងត្រូវប្រមូលពីតាមផ្ទះ និងតាមកន្លែងអាជីវកម្ម សំរាប់ធៀបទៅនឹងអត្រាចាក់នៅទីលានដូចបញ្ជាក់ពីខាងលើ ។ ក្នុងករណីដែលគ្មានជំនួយឧបត្ថម្ភ អត្រាតំរូវការថ្លៃសេវាត្រូវបានកំណត់តាមរយៈការប៉ាន់ស្មានអត្រាថ្លៃដែលគំរោងអាចនឹង មានហិរញ្ញវត្ថុដំណើរការបានកំមៃកវិញ IRR ១០% ។ ក្នុងករណីមានជំនួយឧបត្ថម្ភវិញ អត្រាតំរូវការថ្លៃត្រូវបានកំណត់តាមរយៈការប៉ាន់ស្មានអត្រាថ្លៃដែលគំរោងអាចនឹងរក្សាចីរភាពហិរញ្ញវត្ថុដោយពុំមានជួបប្រទះនូវកង្វះខាតមូលនិធិក្នុងរយៈពេលប្រតិបត្តិកាណ៏គំរោង ។

## b.1 ការវាយតម្លៃលើផ្នែកហិរញ្ញវត្ថុក្នុងខណ្ឌពាក់កណ្តាលទីប្រជុំជនទាំងបីដោយ រ.គ.ស.ភ

ការវាយតំលៃហិរញ្ញកិច្ចនៃកាគ្រប់គ្រងកាកសំនល់រឹងនៅក្នុងខណ្ឌពាក់កណ្តាលទីប្រជុំជនទាំងបីដោយ (ដែលខាងក្រោមនេះហៅថា រ.គ.ស.ភ-កាគ្រប់គ្រងកាកសំនល់រឹង) ត្រូវបានធ្វើឡើងជាពីរករណី) ។ ទីមួយជាមួយការគំរោងវិនិយោគជាសាធារណធម្មតាដោយមិនមានជំនួយគ្មានសំណងនិងមួយទៀតដោយមានជំនួយដើម្បីការចាប់ផ្តើមកាវិនិយោគ ។ ការសិក្សាបានវិភាគថ្លៃអត្រានៃកាគ្រប់គ្រងកាកសំនល់រឹងដើម្បីអោយរ.គ.ស.ភ-កាគ្រប់គ្រងកាកសំនល់រឹងមានស្ថេរភាព ចំពោះផ្នែកហិរញ្ញកិច្ចទៅលើករណីទាំងពីរ ។ ជាមួយការគំរោងវិនិយោគ ជាសាធារណធម្មតាដោយមិនមានជំនួយគ្មានសំណងការសិក្សាបានកំណត់កំរិតដែលអាចទៅបាននៃផ្នែកហិរញ្ញកិច្ចនៃគំរោងនៅត្រឹម ១០% នៃ FIRR ដោយគិត បញ្ចូលនូវអត្រាបញ្ចុះថ្លៃដូចដែលបានកំណត់ខាងលើ។ ក្នុងករណីមានជំនួយ ដើម្បីការចាប់ផ្តើមកាវិនិយោគ លទ្ធភាពហិរញ្ញកិច្ចនៃគំរោងត្រូវបានធានានូវកំរិតអត្រាតំលៃដែលមានចំណូលគ្រប់គ្រាន់សំរាប់ចំណាយលើតំលៃទាំងមូល (រំលោះ ថ្លៃវិនិយោគបន្ថែម និងការចំណាយលើប្រតិបត្តិកាណ៏) ដែលត្រូវការសំរាប់រយះពេលនៃគំរោង ។

### b.1.1. ការវាយតម្លៃលើផ្នែកហិរញ្ញវត្ថុក្នុងករណីទីមួយ

**(គំរោងវិនិយោគជាសាធារណធម្មតាដោយមិនមានជំនួយគ្មានសំណង)**

ដោយយោងទៅលើបរិមាណនៃសំណល់រឹងចេញពីគេហដ្ឋាន និងការវិនិយោគនិងតំលៃទាំងស្រុងសំរាប់ការវិនិយោគរបស់ រ.គ.ស.ភ-កាគ្រប់គ្រងកាកសំនល់រឹងក្នុងផែនកាមេ ការសិក្សាបានប៉ាន់ស្មានអត្រាថ្លៃប្រមូលដើម្បីអោយឆ្លើយតបទៅ និង FIRR ជាង១០%។ អត្រាតំលៃត្រូវបានគិតជាដុល្លាសំរាប់សំណល់តាមទំងន់តោនដែលបានប្រមូល ។ តាមការសិក្សាតំបូង ប្រភាគនៃការប្រមូលសំរាប់ផ្ទះធម្មតា និងកន្លែងអាជីវកម្មត្រូវបានកំនត់៨០%ដែលស្មើនិងការប្រមូលនៅតំបន់ NIPនាឆ្នាំ២០០៣ និង១០០% សំរាប់ការវិនិយោគដែលតំលៃដូចគ្នាត្រូវបានគេកំរិតសំរាប់ផ្ទះធម្មតា និងកន្លែងអាជីវកម្ម ។ កំរៃការប្រមូលសំណល់ក្នុងមួយតោនពីផ្ទះធម្មតានិងអាជីវកម្មគឺត្រូវបានសន្មត់ស្មើគ្នាដូចនៅក្នុងករណីគោលការណ៏ណែនាំ។

លទ្ធផលនៃការប៉ាន់ស្មានក្រោមការទស្សទាយខាងលើបង្ហាញថា តំរូវការថ្លៃសំរាប់ការគ្រប់គ្រងកាក សំនល់រឹង ដើម្បីបាន FIRR១០% នោះគឺ ១៤.៩៤ដុល្លាក្នុងមួយតោននៃសំរាមដែលប្រមូល ។ ក្នុងការយកករណីនេះមក ប្រើថ្លៃជាមធ្យម សំរាប់ការគ្រប់គ្រងកាកសំនល់រឹងនៅតាមគេហដ្ឋាននឹងត្រូវបង្ហាញដូចខាងក្រោម ។

Table 3-18: អត្រាថ្លៃប៉ាន់ស្មានសំរាប់ការប្រមូលកាកសំនល់រឹងនៅតាមគេហដ្ឋាន

| | ឯកតា | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|---|---|---|
| បរិមាណសំណល់ប្រមូល | គ.ក្រ/ខែ/ផ្ទះ | ១០២ | ១០៧ | ១១៣ | ១១៨ | ១២៤ | ១១៣ | ១១៩ | ១២៥ | ១១៣ |
| **អត្រាថ្លៃសេវា** | ដុល្លា/ខែ/ផ្ទះ | ១,៤២ | ១,៤៩ | ១,៥៨ | ១,៦៤ | ១,៧៣ | ១,៥៨ | ១,៦៦ | ១,៧៤ | ១,៥៨ |

សំគាល់: ការថយចុះនៃបរិមាណប្រមូលនៅឆ្នាំ ២០១២ និង២០១៥ បណ្តាលមកពីការកើនឡើងនៃការថយចុះបរិមាណសំរាមបញ្ចេញតាមប្រភព ដោយការធ្វើការកែឆ្នៃ ដែលបានធ្វើការសន្និដ្ឋាននៅក្នុងផែនការមេ។

### b.1.2. ការវាយតម្លៃលើផ្នែកហិរញ្ញវត្ថុក្នុងករណីទីពីរ( ដោយមានជំនួយដើម្បីជាការចាប់ផ្តើមការវិនិយោគ)

ការសិក្សាបានធ្វើការវិភាគទៅលើថ្លៃអត្រានៃកាប្រមូល និងគ្រប់គ្រងកាកសំនល់រឹងក្នុងករណីមានជំនួយពីខាងក្រៅ ដើម្បីធានាបានទាំងស្រុងនូវការវិនិយោគនាឆ្នាំ ២០០៥ និង ២០០៦។ លទ្ធភាពហិរញ្ញកិច្ចរបស់ រ.គ.ស.ភ-កាគ្រប់គ្រងកាកសំនល់រឹងនឹងត្រូវបានធានាលុះណាតែគេអាចរកប្រាក់ចំណូលគ្រប់គ្រាន់សំរាបតំលៃគំរោងទាំងមូលដោយរាប់បញ្ចូលការរំលោះ ការចំណាយបន្ថែមលើគ្រឿងចក្រនិងប្រតិប្តិកាណ៍ដែលនឹងអាចកើនឡើងពេលអនុវត្តគំរោង ។ លទ្ធផលនៃការសិក្សាបង្ហាញថាអត្រាថ្លៃសេវាដែលត្រូវការសំរាប់ការប្រមូល និងគ្រប់គ្រងកាកសំនល់រឹងអាចនៅក្រោម ១១,៦១ដុល្លា ក្នុង១តោន សំណល់ក្នុងករណីយមានជំនួយ ។ អត្រាតំលៃជាមធ្យមប្រចាំខែសំរាប់គេហដ្ឋាន មានបង្ហាញ ដូចខាងក្រោម ។

Table 3-19: : អត្រាថ្លៃប៉ាន់សានសំរាប់ការគ្រប់គ្រងកាកសំនល់រឹងនៅតាមគេហដ្ឋាន

| | ឯកតា | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|---|---|---|
| បរិមាណសំណល់ប្រមូល | គ.ក្រ/ខែ/ផ្ទះ | ១០២ | ១០៧ | ១១៣ | ១១៨ | ១២៤ | ១១៣ | ១១៩ | ១២៥ | ១១៣ |
| **អត្រាថ្លៃសេវា** | ដុល្លា/ខែ/ផ្ទះ | ១,១៨ | ១,២៤ | ១,៣១ | ១,៣៧ | ១,៤៤ | ១,៣១ | ១,៣៨ | ១,៤៥ | ១,៣១ |

### b.1.3. ការវាយវិភាគលើ រ.គ.ស.ភ-កាគ្រប់គ្រងកាកសំនល់រឹង

លទ្ធផលនៃការសិក្សាខាងលើបានបង្ហាញថា ថ្លៃសេវាដែលត្រូវការសំរាប់ការគ្រប់គ្រងនិងប្រមូលសំណល់រឹងមានភាពប្រែ ប្រួលដូចមានបង្ហាញនៅក្នុងតារាងខាងក្រោម ដោយការប្រៀបធៀបករណីមាន និង គ្មានជំនួយ ។

Table 3-20: : ការប្រៀបធៀបករណីមាន និងគ្មានជំនួយលើអត្រាថ្លៃដែលត្រូវការ

| | អត្រា (US$/ton) | អត្រាសំរាប់គេហដ្ឋាន (ដុល្លា/ខែ/ផ្ទះ) | | | | |
|---|---|---|---|---|---|---|
| | | ២០០៧ | ២០០៩ | ២០១១ | ២០១៣ | ២០១៥ |
| គ្មានជំនួយ | ១៣,៩៤ | ១,៤២ | ១,៥៨ | ១,៧៣ | ១,៦៦ | ១,៥៨ |
| មានជំនួយ | ១១,៦១ | ១,១៨ | ១,៣១ | ១,៤៤ | ១,៣៨ | ១,៣១ |

អត្រាបញ្ចុះនៃការប្រមូលកាកសំណល់រឹងក្នុងករណីមានជំនួយ នោះរក្សាក្នុងកំរិតមួយដែលទាបគឺ ១៧% ។ នោះគឺវា អាស្រ័យលើតំរូវការតិចតួចសំរាប់ការវិនិយោគទៅលើគំរោងទាំងមូល ។ គំរោងត្រូវការការជំនួសគ្រឿងយន្តក្នុងរយះពេលអនុវត្តនិងតំលៃបន្ថែមសំរាប់ការទិញរថយន្តថ្មដើម្បីឆ្លើយតបទៅនិងការពង្រីកតំបន់សេវា និងការកើនឡើងនៃបរិមាណគេហដ្ឋាន។ ជាងនេះទៅទៀតតំរូវការតំលៃសំរាប់ប្រតិបត្តិការនិងលំហែទាំដូចជា តំលៃប្រេង។ល។ ធៀបទៅនឹងតំលៃគំរោងគឺ ៤៤%។ កត្តាទាំងនេះបានធ្វើអោយមានផលប៉ះពាល់ទៅលើប្រសិទ្ធភាពនៃការប្រើប្រាស់ជំនួយជាពិសេស គឺផ្នែកហិរញ្ញកិច្ច ។

ទោះបីជាករណីមានជំនួយ អត្រាថ្លៃដែលត្រូវការមានខ្ពស់ជាងប្រមាណ ៨0% នៃការប្រមូលបច្ចុប្បន្នគឺ ៧ដុល្លាក្នុង១តោនសំណល់ដែលធ្វើឡើងដោយរ.ក.ស.ភនៅក្នុងតំបន់ NIP ហើយប្រមាណជា ១,៥ដងនៃគំរោងមិនមានជំនួយ ។ ជាងនេះទៀត វាត្រូវបានគេប៉ាន់ស្មានលើសក្នុងប្រភាគនៃការប្រមូលតាមគេហដ្ឋាន(៨0%) និងកន្លែងវិនិយោគ (១00%) ។ ប្រភាគនៃការប្រមូលថ្លៃសេវាអាចនឹងថយចុះប្រសិនបើអត្រាតំលៃកើនឡើងដូចបានបង្ហាញខាងលើ ។ ប៉ុន្តែការអង្កេតលើ កន្លែងវិនិយោគបង្ហាញថា អត្រាសព្វថ្ងៃនៃអាគារវិនិយោគត្រូវបានកំណត់ជាង ១៤ដុល្លានៃសំណល់ប្រ មូលជាមធ្យម។ គេត្រូវការការតាមដាន និងវិភាគបន្ថែមសំរាប់ការបង្កើតអត្រានិងប្រភាគនៃការប្រមូលទៅលើ គេហដ្ឋាន និងការវិនិយោគ។

## b.2 ការវាយវិភាគលើហិរញ្ញកិច្ចសំរាប់ទីលានដង្កោ

គេបានធ្វើការសិក្សាទៅលើហិរញ្ញកិច្ចសំរាប់ទីលានដង្កោដែលជាទីលានអនាម័យតែមួយគត់សំរាប់ការចាក់ចោលសំណល់ នៅទីក្រុងភ្នំពេញ ។ ប្រហាក់ប្រហែលនិងករណី រ.គ.ស.ភ-កាគ្រប់គ្រងកាកសំនល់រឹងខាងលើការវិភាគត្រូវបានធ្វើឡើងជាមួយនិងការមាន និងគ្មានជំនួយពីខាងក្រៅ ។ ដើម្បីធ្វើការវិភាគលើថ្លៃទីលានដង្កោ គេបានធ្វើការសន្និដ្ឋានថាថ្លៃទីលានត្រូវបានដាក់អោយអនុវត្តដូចគ្នារវាង រ.ក.ស.ភ និងស៊ិនទ្រី ។ តំរូវការថ្លៃទីលាននៅដង្កោ នឹងត្រូវគិតតាមបរិមាណសំរាមក្នុងមួយតោន ។ ថ្លៃទីលាននឹងត្រូវបានប្រមូលតាមទម្ងន់ នៅពេលដែលអត្រាប្រមូលត្រូវបានសន្និដ្ឋានប្រមាណ ១00% សំរាប់ រ.ក.ស.ភ និងស៊ិនទ្រី ។

### b.2.1. ករណីយមិនមានជំនួយ

ប្រហាក់ប្រហែលនិងករណី រ.គ.ស.ភ-កាប្រមូលកាកសំនល់រឹង ដើម្បីអោយហិរញ្ញកិច្ចមានលំនឹងបានជាមួយនិងករណីវិនិយោគធម្មតាដោយមិនមានជំនួយ គឺត្រូវបានកំណត់នៅត្រឹម១0%នៃ FIRR។ ចំណូលពីថ្លៃទីលានត្រូវបានគិតដោយលផលគុណរវាងបរិមាណសំរាមដែលចាក់ចោលដោយ រ.ក.ស.ភ និងស៊ិនទ្រី និងថ្លៃទីលានក្នុងមួយតោន។

Table 3-21: : ការសន្និដ្ឋានលើបរិមាណសំណល់ដែលចាក់ចោលដោយ រ.ក.ស.ភ និងស៊ិនទ្រី

| | ២00៧ | ២00៨ | ២00៩ | ២0១0 | ២0១១ | ២0១២ | ២0១៣ | ២0១៤ | ២0១៥ |
|---|---|---|---|---|---|---|---|---|---|
| ស៊ិនទ្រី (៤ខណ្ឌ) | ២៨0 | ២៩៦ | ៣១៥ | ៣៣៤ | ៣៥៣ | ៣៧២ | ៣៨៤ | ៣៩៩ | ៤១៤ |
| រ.ក.ស.ភ (៣ខណ្ឌ) | ៥៧ | ៦៥ | ៧៤ | ៨២ | ៦៧ | ១0៣ | ១១៥ | ១២៦ | ១៤៨ |
| សរុប | ៣៣៧ | ៣៦១ | ៣៨៩ | ៤១៦ | ៤៤0 | ៤៧៥ | ៤៩៩ | ៥២៥ | ៥៦២ |

ក្រៅពីថ្លៃទីលានខាងលើ ចំណូលដែលបានមកពីការលក់ជីនិងជីកំប៉ុស ក៏ត្រូវបានរាប់បញ្ចូលក្នុងគំរោងដែរ។ ថ្លៃសរុបនៃគំរោងត្រូវបានយកមកពីការសន្និដ្ឋានក្នុងផែនកាមេ ។ លទ្ធផលនៃការវិភាគលើហិរញ្ញកិច្ចដោយផ្អែកលើការសន្និដ្ឋាននេះបង្ហាញថា ដើម្បីទទួលបាន FIRR ១0%សំរាប់ថ្លៃទីលាននោះគឺគេត្រូវកំរិត ៥.៩២ដុល្លា ក្នុងមួយតោននៃសំណល់ ដែលកត្តានេះមានច្រើនឬតិចជាង ៩ដង នៃការចាក់ចោលនាឆ្នាំ ២00២នៅទីលានស្ទឹងមានជ័យ ។

### b.2.2. ករណីយមានជំនួយ

ការសិក្សាបានធ្វើការវិភាគទៅលើថ្លៃអត្រានៃកាប្រមូល និងគ្រប់គ្រងកាកសំនល់រឹងក្នុងករណីមានជំនួយពីខាងក្រៅ ដើម្បីធានាបានទាំងស្រុងនូវការវិនិយោគនាឆ្នាំ ២០០៤ និង២០០៦។ ប្រហាក់ប្រហែលនិងករណី រ.គ.ស.ភ-កាគ្រប់គ្រងកាកសំនល់រឹង ហិរញ្ញកិច្ចអាចធានាបានលុះណាតែថ្លៃចំណូលសរុបអាចចំណាយទៅលើការរំលោះ ការវិនិយោគបន្ថែម និងការចំណាយលើការងារប្រតិបត្តិកាណ៏ដែលអាចកើនក្នុងរយះពេលនៃគំរោង ។ លទ្ធផលនៃការវិភាគបង្ហាញថាថ្លៃទីលាន ក្នុងករណីយនេះទាបត្រឹម ៤.៤ដុល្លា ក្នុង១ តោននៃសំណល់ ។ ទោះបីជាថ្លៃទីលានអាចបន្ថយប្រមាណ២៥% បើប្រៀបធៀបជាមួយនិងករណីមិនមានជំនួយនោះ គំរោងនៅតែត្រូវការថ្លៃអត្រាប្រមាណ៧ទៅ៨ដងនៃតំលៃចាក់សំណល់ នាពេលបច្ចុប្បន្ននៅទីលានស្ទឹងមានជ័យ ។ តំលៃទាបពេកនៃទីលានចាក់សំរាមបច្ចុប្បន្នគឺមានផលប៉ះពាល់ច្រើនដល់សុខភាពមនុស្សនិងបរិដ្ឋានតាមរយះការចាក់សំណល់រដោយទីលានចំហរ ។ ការប៉ាន់ស្មានខាងលើគ្រាន់តែបញ្ជាក់ពីថ្លៃទាបបំផុតដែលត្រូវការសំរាប់ទីលានដោយបានគិតគូរពីសុខភាពមនុស្ស និងបរិដ្ឋាន ។

ដូច្នេះហើយការសិក្សាបាន សន្និដ្ឋានថាថ្លៃទីលាន៤.៤ដុល្លាក្នុង១តោនគឺជា ថ្លៃតិចបំផុតដែលនឹងត្រូវយកពី រ.ក.ស.ភ និងស៊ិនទ្រី។

## b.3 ការវិភាគលើអត្រាថ្លៃសំរាប់ការប្រមូលកាកសំណល់រឹងនិងការចាក់ចោល និងផលប៉ះពាល់លើជីវភាព

យោងលើអត្រាដែលបានសន្និដ្ឋានសំរាប់ការប្រមូល និងការចាក់ខាងលើ គេបានវិភាគសំរាប់បញ្ហាគ្រួសារដូចខាងក្រោម។

### b.3.1 អត្រាថ្លៃសំរាប់ការប្រមូលកាកសំណល់រឹងក្នុងតំបន់ រ.ក.ស.ភ

សរុបសំរាប់ថ្លៃប្រមូល និងការចាក់សំណល់ក្នុងខណ្ឌទាំងបី ត្រូវបានគេធ្វើការសន្និដ្ឋានដូចខាងក្រោម ។

#### ១- ថ្លៃប្រមូលសេវា

ថ្លៃប្រមូលនិងការចាក់សំណល់សំរាប់ផ្ទះនិមួយៗត្រូវបានសន្និដ្ឋានដូចខាងក្រោមក្នុងករណីមាន និងមិនមានជំនួយ។

Table 3-22 : អត្រាថ្លៃប្រមូលសេវាដោយ រ.ក.ស.ភ

ឯកតា: ដុល្លា/ខែ/ផ្ទះ

| | ២០០៧ | ២០១៥ |
|---|---|---|
| ករណីមិនមានជំនួយ | ១,៤២ | ១,៥៨ |
| ករណីមានជំនួយ | ១,១៨ | ១,៣១ |

#### ២- ថ្លៃនៃការចាក់ចោលសំណល់

ថ្លៃទីលានដែលនឹងត្រូវបង់ដោយផ្ទះនិមួយៗ ត្រូវបានគិតដោយផលចែករវាងតោននៃសំរាមដែលប្រមូលពីតាមផ្ទះ និងថ្លៃ ទីលានតាមតោនសំណល់ដែលបញ្ចេញដោយគ្រួសារទាំងអស់ដែលត្រូវបានប្រមូលដោយ រ.ក.ស.ភ។ លទ្ធផលមានបង្ហាញ ខាងក្រោម ។

Table 3-23: អត្រាថ្លៃទីលានដែលត្រូវបង់ដោយគ្រួសារ

| | ឯកតា | ២០០៧ | ២០១៥ |
|---|---|---|---|
| បរិមាណសំណល់ប្រមូលតាមផ្ទះ | ត/ឆ្នាំ | ៧៤,៤៦០ | ១៧៦,២៩៩ |
| ចំនួនផ្ទះដែលត្រូវប្រមូល | ចំនួនផ្ទះ | ៦៤,៩៣០ | ១៣៥,៧៣១ |
| ១- ករណីមិនមានជំនួយ | ដុល្លា/ត | ៥.៩២ | |
| | ដុល្លា/ខែ/ផ្ទះ | 0.៥៧ | 0.៦៤ |
| ២- ករណីមានជំនួយ | ដុល្លា/ត | ៤.៤0 | |
| | ដុល្លា/ខែ/ផ្ទះ | 0.៤២ | 0.៤៨ |

### ៣- ថ្លៃសរុបសំរាប់សេវាកម្មប្រមូលសំណល់តាមផ្ទះ

តាមលទ្ធផលនៅ ១-និង២- ខាងលើ ថ្លៃសរុបសំរាប់សេវាកម្មប្រមូលសំណល់តាមផ្ទះត្រូវបានប៉ាន់ស្មានដូចខាងក្រោម ។

Table 3-24: អត្រាថ្លៃទីលានដែលត្រូវបង់ដោយគ្រួសារ

| | | ២០០៧ | ២០១៥ |
|---|---|---|---|
| ករណីមិនមានជំនួយ | ការប្រមូលសំណល់ | ១,៤២ | ១,៥៨ |
| | ការចាក់ចោល | 0,៥៧ | 0,៦៤ |
| | សរុប | ១,៩៩ | ២,២២ |
| ករណីមានជំនួយ | ការប្រមូលសំណល់ | ១,១៨ | ១,៣១ |
| | ការចាក់ចោល | 0,៤២ | 0,៤៨ |
| | សរុប | ១,៦0 | ១,៧៩ |

ម្យ៉ាងវិញទៀត លទ្ធផលនៃការសិក្សាពីឆន្ទះ និងលទ្ធភាពដើម្បីបង់ថ្លៃសេវា មាននៅក្នុងតារាងខាងក្រោម ។

Table 3-25: ឆន្ទះ និងលទ្ធភាពរបស់គ្រួសារសំរាប់បង់ថ្លៃសេវានៅឆ្នាំ ២០០៣

| | |
|---|---|
| ១- ថ្លៃសេវាបច្ចុប្បន្ន | 0.៨-១.0ដុល្លា/ខែ |
| ២- ឆន្ទះរបស់គ្រួសារសំរាប់បង់ថ្លៃសេវា ( លទ្ធផលពីការសិក្សាមតិសាធារណ) | 0.៤៧ ដុល្លា/ខែ |
| ៣-លទ្ធភាពរបស់គ្រួសារសំរាប់បង់ថ្លៃសេវា( ជាមធ្យមសំរាប់៣ខណ្ឌ, 0.៥%ជាមធ្យមប្រចាំខែនៃផ្ទះនិមួយៗដែលមានចំណូល ២១៦ ដុល្លា) | ១.0៨ ដុល្លា/ខែ |

ទោះបីជាថ្លៃបច្ចុប្បន្នសំរាប់គ្រួសារមានចាប់ពី ០.៨-១.០ ដុល្លាក្នុង១គ្រួសារ/ខែ តែការសិក្សាបានទស្សន៍ទាយពីលទ្ធភាពនៃគ្រួសារដោយផ្អែកលើលទ្ធភាពអាចបង់១.០៨ដុល្លាខាងលើ ដោយសន្និដ្ឋានថាវានឹងមានកំនើនដោយសារសន្ទុះនៃសេដ្ឋកិច្ច ដូចមានក្នុងតារាងខាងក្រោម ។

Table 3-26: ការទស្សន៍ទាយពីលទ្ធភាពនៃការបង់ថ្លៃសេវាដោយគ្រួសារនិមួយ ៗ

| ឆ្នាំ | ២០០៣ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|---|---|---|---|
| GDP | ៣.៨ | ៥.១ | ៥.៥ | ៦.០ | ៦.៥ | ៦.៩ | ៧.៤ | ៧.៩ | ៨.៤ | ៩.០ |
| អត្រាកំនើន | ៦.០ | ៨.៤ | ៨.៤ | ៨.៤ | ៨.៤ | ៦.៨ | ៦.៨ | ៦.៨ | ៦.៨ | ៦.៨ |
| អត្រាថ្លៃសេវាទាបបំផុត | ០.៨០ | ១.០៧ | ១.១៦ | ១.២៦ | ១.៣៦ | ១.៤៦ | ១.៥៦ | ១.៦៦ | ១.៧៨ | ១.៩០ |
| អត្រាថ្លៃសេវាខ្ពស់បំផុត | ១.០០ | ១.៣៤ | ១.៤៥ | ១.៥៧ | ១.៧១ | ១.៨២ | ១.៩៥ | ២.០៨ | ២.២២ | ២.៣៧ |
| អត្រាដែលអាចបង់បាន | ១.០៨ | ១.៤៥ | ១.៥៧ | ១.៧០ | ១.៨៤ | ១.៩៧ | ២.១០ | ២.២៤ | ២.៤០ | ២.៥៦ |

លទ្ធផលនៃការសិក្សាបង្ហាពីឆន្ទះ និងលទ្ធភាពដើម្បីបង់ថ្លៃសេវាតាមគ្រួសារបង្ហាញថា ការកើនឡើងនៃថ្លៃសេវាគួរត្រូវកាត់បន្ថយដើម្បីអោយគ្រួសារនិមួយៗអាចមានលទ្ធភាពបង់បាន។ ថ្លៃអត្រាត្រូវចាំបាច់ដែលបានលើកឡើងនៅក្នុងផែនកាមេនោះ មាន១,៩៩ដុល្លា/ខែ/គ្រួសារដែលជាករណីមិនមានជំនួយ រីឯ ១.៦០ ដុល្លាក្នុងករណីមានជំនួយដោយមានពី ១,១ទៅ១,៤ ដង ដែលជាថ្លៃប៉ាន់ស្មានទាបបំផុតនៅឆ្នាំ ២០០៧ ដូចមានបញ្ជាក់ក្នុងតារាងខាងលើ ។

**b.4 ការវាយតំលៃសេវាកម្មប្រមូលកាកសំណល់រឹងរបស់ រ.ក.ស.ភ និងការវិភាគភាពដែលអាចប៉ះពាល់**

លទ្ធផលនៃការសិក្សាពីហិរញ្ញកិច្ចដែលធ្វើខាងលើបញ្ជាក់ពីសេវាកម្មរបស់រ.ក.ស.ភ ដែលបានស្នើរនៅក្នុងផែនកាមេគឺជាការលំបាកសំរាប់ការងាអនុវត្តអោយមានកំរៃប្រសិនបើមិនគិតគូរពីថ្លៃសេវាដែលខ្ពស់ជាងនេះ ទោះបីក្នុងស្ថានភាពមានជំនួយក្តី ។ ជាងនេះទៀត ករណីដែលបានបង្កើតសំរាប់ការវិភាគខាងលើ ត្រូវបានធ្វើដោយមានសុទិដ្ឋិនិយមថាការប្រមូលតាមផ្ទះនឹងមាន៨០% និងការប្រមូលតាមគេហដ្ឋានវិនិយាគមាន ១០០%។ ប្រសិនបើភាគរយទាបពេកនោះគេនឹងត្រូវការថ្លៃសេវាខ្ពស់សំរាប់ការងារប្រមូលរបស់ រ.ក.ស.ភ។ ជាងនេះទៀត អត្រាសំរាប់អគារវិនិយោគដែលបានកំណត់យកដូចគេហដ្ឋានដែរនោះ (ទទួលបានផលប្រយោជនច្រើននោះ) នោះនឹងអាចកើនដោយគិតលើអត្រាថ្លៃបច្ចុប្បន្នព្រមទាំងការសិក្សាលើអគារវិនិយោគ។

ដោយគិតលើលក្ខណទាំងនេះ ការសិក្សាបានប្រមើលមើលភាពដែលអាចប៉ះពាល់ នៃថ្លៃសេវាសំរាប់ផ្ទះនិមួយៗដោយយោងលើកត្តាជាច្រើនដូចជាថ្លៃសេវា និងប្រភាគនៃការប្រមូលដើម្បីអាចពិនិត្រថាតើ គេអាចបញ្ចុះថ្លៃសំរាប់គ្រួសារហើយបង្កើនថ្លៃសំរាប់អ្នកវិនិយោគ។ ក្នុងការសិក្សានេះ គេបានជ្រើសរើសយកករណីមាន ជំនួយប្រើជាមូលដ្ឋាន។ ការសំរេចជ្រើសរើសនេះដោយយោងថាដោយមានជំនួយ នោះវាជាការចាំបាច់សំរាប់អោយមានស្ថេរភាពផ្នែកហិរញ្ញកិច្ចនៃគំរោង។ ករណីនេះក៏បានជួយសំរួលដល់ការងារដោយការយកករណីតែមួយមកសិក្សា ។

យោងតាមលទ្ធផលនៃការសិក្សាពីការវិភាគ នៅពេលដែលអត្រាតំលៃសំរាប់ផ្ទះអាជីវកម្មកើនឡើងពីរដងជាងផ្ទះធម្មតា នោះអត្រាកំរៃផ្ទះធម្មតាបានទាបជាងអាត្រាតំលៃដែលអាចបង់បាន ដូចបានបង្ហាញក្នុងតារាង ៣-២៦ ទោះបីជាផលធៀបប្រមូលកំរៃសេវាកម្មមាន៧០%។ ក្នុងលក្ខខណ្ឌដូចគ្នានេះ អាត្រាកំរៃផ្ទះធម្មតាទាបជាងអាត្រាកំរៃអប្បរិមាក្នុងឆ្នាំ ២០១៥។

ដោយគិតទៅលើទស្សនះហិរញ្ញវត្ថុ ការបង្កើនកំរៃសេវាកម្មចំពោះផ្ទះអាជីវកម្មបានធ្វើអោយអាត្រាកំរៃចំពោះផ្ទះធម្មតាទាបជាងក៏រិតដែលអាចបង់បាន ទោះបីជាផលធៀបកំរៃសេវាកម្មទាបគួរអោយកត់សំគាល់ ហើយគំរោងនេះ រ.គ.ស.ភ អាចអនុវត្តទៅបាន។

## b.5 អនុសាសន៍ទាក់ទងនឹងការអនុវត្តន៍ផែនការមេ ដោយយោងទៅលើទស្សនះហិរញ្ញវត្ថុ

ផ្អែកតាមលទ្ធផលនៃការវាយតម្លៃផ្នែកហិរញ្ញវត្ថុខាងលើបង្ហាញថា ការបង្កើនអាត្រាកំរៃសំរាប់ផ្ទះអាជីវកម្មអាចបន្ទាបអត្រាកំរៃចំពោះផ្ទះធម្មតា ទោះបីជាវាកាត់បន្ថយផលធៀបកំរៃ សេវាកម្មពីផ្ទះអាជីវកម្មក្នុងទំហំមួយជាក់លាក់ក៏ដោយ ។ លទ្ធផលការសិក្សាបានផ្តល់អនុសាសន៍ថា សាលាក្រុងគួរតែពិនិត្យឡើងវិញពីប្រព័ន្ធអាត្រាកំរៃនា ពេលបច្ចុប្បន្ននៃផ្ទះធម្មតានិងផ្ទះអាជីវកម្មដោយផ្អែកទៅលើលទ្ធផលនៃការវិភាគស្តីពីលទ្ធភាពដែលផ្ទះធម្មតាអាចបង់បាន ដូចបានបង្ហាញក្នុងតារាង ៣-២៦ ។ ដូច្នេះ អតិថិជនដែលជាអ្នកទទួលសេវាកម្មប្រមូលសំណល់អាចទទួលយកកំរៃទាំងនេះបាន ។

- **ប្រើប្រាស់នូវប្រភេទជំនួយឧបត្ថម្ភក្នុងការផ្តួចផ្តើមវិនិយោគសំរាប់ការអនុវត្តន៍ផែនការមេ**

លទ្ធផលនៃការវាយតម្លៃផ្នែកហិរញ្ញវត្ថុបានបង្ហាញច្បាស់ថា ផែនការមេនឹងមិនមានលទ្ធភាពផ្នែកហិរញ្ញវត្ថុដូចការវិនិយោគតាមលក្ខណសាធារណធម្មតាឡើយ ដោយសាថាវាត្រូវការបង្កើនអត្រាបង់ថ្លៃបច្ចុប្បន្នតាមផ្ទះដែលមិនមានលទ្ធភាពអាចបង់បាននោះ ។ អត្រាបង់ថ្លៃចាក់សំរាមនៅទីលានសំរាប់ក្រុមហ៊ុន ស៊ិនទ្រីក៏ត្រូវបង្កើនប្រមាណ ៩ ដងដែរ ។

ដោយពិចារណាលើបញ្ហានេះ ការសិក្សាបានលើកជាអនុសាសន៍ថា សាលាក្រុងគួរខិតខំប្រឹងប្រែងឱ្យអស់លទ្ធភាពដើម្បីទទួលបានជំនួយឧបត្ថម្ភពីប្រភពខាងក្រៅដើម្បីបំពេញតំរូវការវិនិយោគដំបូង ដូចលើកឡើងក្នុងផែនការមេ ដូច្នេះ អត្រាសំរាប់គេហដ្ឋាន និងថ្លៃទីលានសំរាប់ស៊ិនទ្រីក៏ត្រូវបានកាត់បន្ថយដែរ ។

- **បន្ថយអត្រាបង់ថ្លៃសេវាសំរាប់គេហដ្ឋាន**

ដើម្បីអោយការប្រមូលសំណល់របស់ រ.គ.ស.ភ-កាប្រមូលកាកសំនល់រឹង មានស្ថេរភាពផ្នែកហិរញ្ញកិច្ចនោះនោះអត្រា ថ្លៃសេវាត្រូវកើនពី ១.៥ ទៅ២.0ដង ។ ការកើនឡើងនេះជាការលំបាកសំរាប់គេហដ្ឋាននៅភ្នំពេញដែលមានប្រាក់ចំណូលទាប ។ វាគួរតែបានត្រូវកាត់បន្ថយដើម្បីអោយបជាពលរដ្ឋអាចទទួលយកបាននូវផែនកាមេដោយហើយប្រភាគ នៃការប្រមូលមានកំរិតខ្ពស់ ។ ការសិក្សាបានពិនិត្រលើលទ្ធភាពនៃការបង្កើនអត្រាសេវាលើការវិនិយោគដើម្បីកាត់បន្ថយអត្រាសេវាតាមផ្ទះ ដោយវិធីសាស្រ្តនានាដូចខាងក្រោម ។

- ➢ អគារវិនិយោគនឹងត្រុវទទួលបានសេវាកម្មប្រសើរជាងតាមផ្ទះ, ឧទាហរណ៏ថា ការប្រមូលច្រើនដងជាងការប្រមូលតាមមុខកន្លែងអាជីវកម្ម ជាដើម ។
- ➢ ការបោសសំអាតថ្នល់ និងការសំអាតជាសាធារណនោះ នឹងមិនគ្រាន់តែមានផលប្រយោជន៏ដល់អាគារវិនិយោគក្នុងន័យសុខភាព និង អនាម័យទេ តែក៏ជាការកែលំអរបរិដ្ឋានវិនិយោគដែរ ។
- ➢ អត្រាថ្លៃសេវាបច្ចុប្បន្នត្រុវបានកំរិតខ្ពស់ជាងនៅក្នុងផែនកាមេទៅទៀតនៅក្នុងការវិនិយោគជាច្រើន ។ ជាងនេះទៀតការសិក្សាលើផ្នែកវិនិយោគបង្ហាញថា ការបង់ថ្លៃជាមធ្យមមានប្រមាណ ១៤.៦ដុល្លាក្នុមួយវិនិយោគ ។ ទោះបីជាគេត្រូវធ្វើការសិក្សាលើប្រភេទ និងទំហំនៃការវិនិយោគក្តី ក៏គេអាចសន្និដ្ឋានបានថាផ្នែកវិនិយោគអាចមានលទ្ធភាពច្រើនជាងគេហដ្ឋានក្នុងការបង់ថ្លៃសេវា ។

លទ្ធផលនៃការសិក្សាលើលទ្ធភាពនៃផលប៉ះពាល់បានបង្ហាញថាការកើនឡើងនៃអត្រាសំរាប់ការវិនិយោគនឹងជួយបន្ថយអត្រាសំរាប់គេហដ្ឋាន ទោះបីជាមានការថយចុះខ្លះចំពោះប្រភាគនៃកាប្រមូលក្តី ។ ការសិក្សាបានណែនាំថាសាលាក្រុងភ្នំពេញគួរតែពិនិត្រឡើងវិញអំពីអត្រានាពេលបច្ចុប្បន្នចំពោះអាជីវកម្ម និងគេហដ្ឋានផ្អែកលើលទ្ធផលវិភាគដែលមានបង្ហាញខាងលើក្នុងតារាង ៣-២៦ ដើម្បីរាល់អតិថិជនទទួលសេវាកម្ម សំណល់ក្រុងអាចទទួលយកបាន ។

- **ពិនិត្រឡើងវិញនូវអត្រាថ្លៃចាក់ថ្មីនៅទីលានសំរាប់ក្រុមហ៊ុន ស៊ិនទ្រី**

អត្រាបង់ថ្លៃចាក់សំរាមបច្ចុប្បន្ននៅទីលានសំរាប់ក្រុមហ៊ុនស៊ិនទ្រី តិចជាង១ដុល្លា/តោន ។ តំលៃដែលត្រូវការសំរាប់ទី លានដង្កោគឺ ៤.៤០ ដុល្លាក្នុងមួយតោនសំរាមទោះបីក្នុងលក្ខណដែលមានជំនួយក្តី ។ នេះជាតំលៃទាបបំផុត

សំរាប់ទី លានមួយដែលមានការគិតគូរដល់បញ្ហាសុខភាព និងបរិដ្ឋានដែលជំនួសអោយកាងារលើទីលានចំហរដូចពេលបច្ចុប្បន្ននេះ។ ហេតុនេះ ក្រុមសិក្សាស្នើនូវអនុសាសន៍ឱ្យមានការទទួលខុសត្រូវដូចគ្នាទាំងរ.គ.ស.ភ និងក្រុមហ៊ុនស៊ិនទ្រីដោយយោងលើបរិមាណសំណល់ដែលត្រូវចាក់ចោល ។

- **បង្កើតនូវប្រព័ន្ធអត្រាថ្លៃថ្មីសំរាប់សេវាសំណល់រឹងទីក្រុង**

ដើម្បីឱ្យហិរញ្ញវត្ថុផែនការមេនេះមានលទ្ធភាពអាចធ្វើទៅបាន ប្រព័ន្ធអត្រាបង់ថ្លៃបច្ចុប្បន្ន ចាំបាច់ត្រូវបង្កើនការកែលំអដែលឆ្លើយតបទៅនឹងតម្លៃជាក់ស្តែងពីការផ្តល់សេវាថ្មីលើការគ្រប់គ្រងសំណល់រឹងក្រុង ដែលស្នើឡើងក្នុងផែនការមេ ។ នៅក្នុងការវាយតម្លៃផ្នែកហិរញ្ញវត្ថុខាងលើការសិក្សាបានប៉ាន់ស្មានលើអត្រាដែលត្រូវការដើម្បីរ៉ាប់រងថ្លៃនៃការប្រមូល និងការចាក់ចោលសំណល់ជាតោនដោយយោងលើការសន្និដ្ឋានលើការបញ្ចេញសំនល់ដោយគេហដ្ឋាន និងផ្នែកវិនិយោគ។ ប្រពន្ធ័អត្រាថ្លៃសេវានាពេលបច្ចុប្បន្ន គួរតែត្រូវបានធ្វើការកែលំអ ដូច្នេះថ្លៃនៃកាប្រមូល និងការចាក់ចោលនឹងត្រូវបានទទួលខុសត្រូវដោយអ្នកប្រើប្រាស់គ្រប់ៗរូប ដោយយោងលើបរិមាណសំណល់ដែលគេបញ្ចេញ ។ ការបង្កើតប្រព័ន្ធអត្រា បង់ថ្លៃថ្មីដោយផ្អែកលើបរិមាណសំណល់/ទំងន់ គឺជាមូលដ្ឋានស្មើភាពសំរាប់អ្នកប្រើប្រាស់សេវា។ វាគួរត្រូវបានសិក្សាលំអិតនៅក្នុងលទ្ធភាពនៃការសិក្សា។

- **ការបង្កើននូវប្រភាគនៃការប្រមូលសំណល់តាមរយះការយល់ដឹងនូវសេវាកម្មគ្រប់គ្រងកាកសំណល់ដោយអតិថិជន ដោយបង្កើតនូវប្រព័ន្ធអត្រាបង់ថ្លៃសេវាសមស្រប**

ដើម្បីអោយផែនកាមេមានប្រសិទ្ធភាពលើផ្នែកថវិកា ប្រភាគនៃកាប្រមូលត្រូវតែលើកកំពស់ដើម្បីរក្សាស្ថេរភាពប្រាក់ចំណូលនៃគំរោង ។ ចំនុចសំខាន់នោះ គឺការយល់ដឹងរបស់ប្រជាពលរដ្ឋលើការកែលំអរសេវាកម្មប្រមូលសំណល់ និងការបង្កើតនូវប្រពន្ធ័អត្រាសមស្រប និងមានតម្លាភាពដោយផ្អែកលើថ្លៃពិតប្រាកដស្តែងចេញពីសេវាកម្មដែលផ្តល់អោយ ។

- **ការចាត់ចែងថវិការបស់សាលាក្រុងលើការសំអាតផ្លូវ និងទីសាធារណ**

ដោយសាថាការប៉ាន់ស្មានខាងលើមិនបានរាប់បញ្ចូលការសំអាតផ្លូវ និងទីសាធារណនោះគេត្រូវការការចាត់ចែងថវិការពីសាលាក្រុង ។ តាមការប៉ាន់ស្មានរបស់ការសិក្សា គេត្រូវចំណាយប្រមាណ ៣៥,៤០០-៥១,២០០ ដុល្លាក្នុងមួយឆ្នាំ ដើម្បីផ្តល់សេវាកម្មបែបនេះនៅក្នុងខណ្ឌជនបទទាំងបី ។

# 4 គំរោងសាកល្បង

## 4.1 ការជ្រើសរើសគំរោងសាកល្បង

**a. គោលបំណង**

គោលបំណងនៃការអនុវត្តន៍គំរោងសាកល្បងមានដូចតទៅ :

១. ដើម្បីពង្រឹងសមត្ថភាពនៃការប្រមូលសំរាមរបស់រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ

២. ដើម្បីផ្ទៀងផ្ទាត់ការអនុវត្តន៍ពិតប្រាកដរបស់ផែនការមេ

៣. ដើម្បីអនុវត្ត ផែនការប្រតិបត្តិការណ៍ ផែនការមេ និងផ្ទៀងផ្ទាត់ការអនុវត្តន៍ពិតប្រាកដ

៤. ដើម្បីបង្ហាញវិធានការកែលំអការគ្រប់គ្រងសំណល់រឹងជូនដល់អាជ្ញាធរ និងប្រជាពលរដ្ឋដែលពាក់ពន្ធ័

៥. ដើម្បលើកតម្កើងការយល់ដឹងជាសាធារណៈអំពីការគ្រប់គ្រងសំណល់រឹង និងបង្កើនកិច្ចសហការអំពីសាធារណ

៦- ដើម្បីទទួលបាននូវទិន្នន័យជាមូលដ្ឋាន ដើម្បីធ្វើផែនការសិក្សាជាជំហានដំបូង ។

៧- ដើម្បីពង្រឹងសមត្ថភាពរបស់ស្ថាប័នប្រត្តិបត្តលើការគ្រប់គ្រងសំណល់រឹង

**b. ការជ្រើសរើសគំរោងសាកល្បង**

នៅក្នុងការសំរេចជាមួយក្រុមសិក្សា JICA និងសមភាគី គំរោងសាកល្បង ចំនួន ៥ ត្រូវបានជ្រើសរើស :

PP1: ការកែលំអទីលានចាក់សំរាមស្ទឹងមានជ័យ

PP2: ការកែលំអប្រព័ន្ធប្រមូលសំរាម

PP3: ការអភិវឌ្ឍន៍ និងជំរុញទីផ្សារកែឆ្នៃជីកំប៉ុស្តអំពីសំរាមនៅទីក្រុង

PP4: ការអភិវឌ្ឍន៍ការគ្រប់គ្រងប្រព័ន្ធទិន្នន័យសំរាប់ការគ្រប់គ្រងសំណល់រឹង ។

## 4.2 ការកែលំអទីលានចាក់សំរាមស្ទឹងមានជ័យ

### 4.2.1 ខ្លឹមសារសំខាន់ៗ នៃការកែលំអ

គំរោងកែលំអរទីលានសឹងមានជ័យត្រូវបានចាប់ផ្តើមតាំអពីខែ មេសា ឆ្នាំ ២០០៣ ។ ការងារនោះមានចំនុចសំខាន់ ៣ : ១) ការសាងសង់ ២) ការត្រួតពិនិត្រអ្នករើសសំរាម និង ៣) ការកែលំអរប្រត្តិបត្តការណ៍ ។ ផែនកាប្រត្តិបត្តការមានលំអិតក្នុងតារាងខាងក្រោម ។

ទោះបីជាការកែលំអរប្រព័ន្ធប្រមូល និងប្រព្រិត្តកម្មទឹកសំអុយត្រូវបានចាប់ផ្តើមពីខែមិថុនា ឆ្នាំ ២០០៤ ក្តីតែការសាងសង់អាង និងហេដ្ឋារចនាសម្ព័នដ៏ទៃទៀតត្រូវបានបញ្ចប់ និងប្រគល់ជូនរដ្ឋាករនាបពាក់កណ្តាលខែ មិនា ឆ្នាំ ២០០៤ ។

Table 4-1: ផែនការកែលំអទីលានចាក់សំរាមស្ទឹងមានជ័យ និងស្ថាប័នទទួលខុសត្រូវ

| ការងារ | ទិសដៅសំខាន់ៗ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| ១. ការសាងសង់ប្រព័ន្ធបំពាក់ផ្សេង ៗ | | |
| ១.១ តំឡើងជញ្ជីង | ប្រមូលទិន្នន័យ | JICA |
| ១.២ ធានាទីតាំងសំរាប់ការពង្រីក | ការពង្រីកទីលាន | រ.គ.ស.ភ |
| ១.៣ ផ្លូវក្នុងទីលាន | ច្រកចូលសុវត្ថិភាព | JICA |
| ១.៤ កន្លែងចាក់សំរាម | បែងចែកទីលាន និងអ្នករើសសំរាម | JICA |
| ១.៥ ប្លុកគំរូសំរាប់បញ្ចប់ការចាក់សំរាម | ការបង្ហាញពីទីលានអនាម័យ | JICA |
| | វាស្ថិតក្នុងលក្ខណប្រសើរ ។តំបន់ដែលមានសំរាមថ្មីត្រូវស្រុតចុះ ។ | |
| ១.៦ ទំនប់ការពារ | ការបង្ហាញពីទីលានអនាម័យ និង ការពង្រីកទីលាន | JICA |
| | ទំនប់ត្រូវស្រុតដោយសារទម្ងន់រថយន្តសំរាម និងរថយន្តដឹកដី ។ ទំនប់ដែលនៅជាប់និងតំបន់ដឹកដីកំពុងស្ថិតក្នុងភាពគ្រោះថ្នាក់ ។ | |
| ១.៧ប្រមូលទឹកសំអុយ និងធ្វើប្រព្រិត្តិកម្ម | ការបង្ហាញពីទីលានអនាម័យ | JICA |
| ១.៨ ផ្សេងៗ | ការបង្ហាញពីទីលានអនាម័យ | JICA |
| ២. អ្នករើសសំរាម និងការងារគ្រប់គ្រងពួកគេ | | |
| ២.១រៀបចំចុះបញ្ជីសំរាប់អ្នករើសសំរាម | បែងចែកទីលាន និងអ្នករើសសំរាម | រ.គ.ស.ភ និង JICA |
| ២.២ ការចេញប័ណ្ណ | បែងចែកទីលាន និងអ្នករើសសំរាម | រ.គ.ស.ភ និង JICA |
| ២.៣ ពិនិត្រច្រកចូលនៃអ្នករើសសំរាម | បែងចែកទីលាន និងអ្នករើសសំរាម | រ.គ.ស.ភ |
| ២.៤ ការចែកអាវ | គាំទ្រអ្នករើសសំរាមអោយគ្រប់គ្រង ខ្លួនឯង | រ.គ.ស.ភ និង JICA |
| ២.៥ ការចាក់ថ្នាំវ៉ាក់សាំង | បង្កើនទំនាក់ទំនងល្អជាមួយពួកអ្នករើសសំរាម និងថែរក្សាសុខភាពពួកគេ | ក្រសួង និងមន្ទីរសុខាភិបាល |
| ៣. កែលំអរប្រត្តិបត្តការ | | |
| ៣.១ ជញ្ជីង | បង្កើតទិន្នន័យសំរាប់ទីលាន | រ.គ.ស.ភ និង JICA |
| ៣.២ រៀបចំផែនកាប្រត្តិបត្ត | បង្ហាញទីលានអនាម័យ | JICA |
| ៣.៣ រៀបចំបទដ្ឋានបច្ចេកទេស | ដើម្បីត្រួតពិនិត្រប្រត្តិបត្តការទីលានដោយអ្នកម៉ៅការ | JICA |
| ៣.៤ ប្រត្តិបត្តការទីលានដែលកែលំអរ | បង្ហាញទីលានអនាម័យ | រ.គ.ស.ភ និង JICA |

## a. ការកែលំអហេដ្ឋារចនាសម្ព័ន្ធទីលាន

នៅក្នុងគំរោងសាកល្បងនេះ ផ្នែកដែលមានស្រាប់នៅក្នុងទីលានដែលជាទីលានចាក់សំរាមបែបចំហរនោះត្រូវបានធ្វើការកែលំអហើយ និងពង្រីកបន្ថែមលើផ្ទៃដីដែលធានាដោយ រ.គ.ស.ភ ។ ទីលានដែលពង្រីកបន្ថែមនេះ អាចបន្តនិរន្តរភាពរហូតដល់ឆ្នាំ ២០០៧ ពេលដែលទីលានថ្មីនឹងបើកឱ្យដំណើរការ ។ ការកែលំអមធ្យោបាយនេះ ត្រូវបានធ្វើឡើង

ដោយក្រុមហ៊ុនសាងសង់ ក្រោមការត្រួតពិនិត្យរបស់ក្រុមសិក្សាដោយយោងទៅលើផែនការកែលំអដូចមានបង្ហាញក្នុង រូបភាព 4-1 ។




| ការងារ |
|---|
| ១. ផ្លូវនៅក្នុងទីលាន |
| ១-១ ផ្លូវសំខាន់ |
| ១-២ ផ្លូវបន្ទាប់បន្សំ |
| ២. កន្លែងចូលចាក់សំរាម |
| ២-១ ផ្លូវសំខាន់ទី៣ |
| ៣. ប្លុកគំរូ |
| ៣-១ ប្លុកគំរូ |
| ៣-២ បរិក្ខាសំរាប់ស្រូបយកឧស្ម័ន |
| ៤. ទំនប់ |
| ៤-១ ទំនប់ A (គ្រប់ដោយដី) |
| ៤-២ ទំនប់ B (មិនមានគ្របដី) |

| ការងារ |
|---|
| ៥. ការប្រមូលទឹកសំអុយ និងអាងចំរោះ |
| ៥-១ តំបន់ពង្រីក A |
| (១) អាងប្រមូលទឹកសំអុយ |
| (២) បន្ទប់បូមទឹកសំអុយ |
| (៣) ម៉ាស៊ីនបូម |
| (៤) បំពង់បង្ហូរទឹកសំអុយចេញ |
| (៥) គ្រឿងបរិក្ខារសំរាប់យកឧស្ម័ន |
| ៥-២ បរិក្ខាសំរាប់សំអាតទឹកសំអុយ |
| (១) អាងចំរោះ (១-៣ អាងចំរោះ) |
| (២) ស្ថានីយ៍បូម |
| (៣) ទុយោបញ្ចេញទឹកដែលបានចំរោះរួច |
| ៦. ផ្សេងៗ |
| ៦-១ របង (ប្រភេទរឹងមាំ) និងទ្វារចូល |
| ៦-២ ការពង្រីកកន្លែងធ្វើជីកំប៉ុស្ត |
| ៦-៣ ជញ្ជីងថ្លឹង |

Figure 4-1: ផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅស្ទឹងមានជ័យ

### b. ការងារគ្រប់គ្រងអ្នករើសសំរាម

ផ្អែកលើលទ្ធផលនៃការស្ទង់មតិនិងការប្រជុំក្រុមពិភាក្សានៅដំណាក់កាលទីមួយនៃការសិក្សា បានបង្ហាញថាក្រុមអ្នករើសសំរាមទទួលស្គាល់ថាមានបញ្ហាធ្ងន់ធ្ងរចំពោះស្ថានភាពបច្ចុប្បន្ន គឺការប៉ះពាល់បរិស្ថាន និងសុវត្ថិភាពដូចជាគ្រោះថ្នាក់ដែលតែងតែកើតមានឡើងជាញយៗ ។ ជាលទ្ធផល ក្រុមសិក្សាបានរៀបចំការប្រជុំជា ១១ក្រុម ដើម្បីពន្យល់ដល់ ក្រុមអ្នករើសសំរាមអំពីបទបញ្ជាពង្រាងនៃការរើសសំរាម និងការបែងចែកកន្លែងរើសអំពីតំបន់ដែលឡានចាក់ដើម្បីជៀសវាងគ្រោះថ្នាក់ ។ នៅក្នុងការប្រជុំនោះ គេបានរៀបចំសំរួលចុះឈ្មោះក្រុមអ្នករើសសំរាមជាលើកដំបូងដើម្បីទទួលបាននូវទិន្នន័យសរុបនៅទីលានចាក់សំរាម ។

ការចុះឈ្មោះចាប់ផ្តើមនៅថ្ងៃទី ១៧ ខែវិច្ឆកា ឆ្នាំ២០០៣ និងបានទទួលពាក្យចុះឈ្មោះចំនួន ២,៩០៧ នាក់ នៅថ្ងៃទី ១៧ ខែមករា ឆ្នាំ២០០៤ ។ ក្រុមសិក្សាបានរៀបចំប័ណ្ណអនុញ្ញាតឱ្យចូលរើស ហើយដែលត្រូវឳានចែកជូនដោយក្រុមការងារ រ.គ.ស.ភ ដល់អ្នករើសសំរាមណាដែលមកធ្វើការរាល់ថ្ងៃ ។ ជាងនេះទៀត ដើម្បីការពារការឆ្លងជំងឺបណ្តាលមកពិបរិស្ថានមិនស្អាតនោះ ក្រុមសិក្សាបានផ្តល់ការចាក់ថ្នាំបង្កាតេតាណុស និងអេប៉ាទីតបេ ជូនដល់អ្នករើសសំរាម ។ ដោយសារមានបញ្ហាជំលោះជាមួយម្ចាស់ដីក្នុងការសាងសង់ទីលាននោះ ការអនុវត្តន៏ផែនការបែងចែកការរើសសំរាមត្រូវពន្យារហូតដល់ថ្ងៃទី ២៩ ខែធ្នូ ។ ប៉ុន្តែទោះជាយ៉ាងណាក្តីទំនាស់ជាមួយម្ចាស់ដីនោះ នោះនៅតែបន្តរំខានដល់ការសាងសង់ ។

### c. ការកែលំអប្រតិបត្តិការណ៍

#### c.1 ប្រតិបត្តិការទីលាន

គេបានកំណត់រាល់ប្រភេទរថយន្ត អ្នកដឹកជញ្ជូន និងចំនួនរថយន្តដែលចូលមកទីលានជារៀងរាល់ថ្ងៃ ។

ក្រុមសិក្សា បានធ្វើបទដ្ឋានបច្ចេកទេសសំរាប់អោយរដ្ឋាករអាចមានលទ្ធភាពត្រួតពិនិត្យការងារជាប្រចាំរបស់អ្នកម៉ៅការទីលានដោយប្រើបទដ្ឋាននោះប្រកបដោយប្រសិទ្ធភាព ។ ក្រោយខែ សីហា ២០០៤ នៅពេលដែលមានការផ្លាស់អ្នកម៉ៅការ នោះការងារថែទាំផ្លូវបានប្រព្រឹត្តទៅជាប្រចាំ ។ បច្ចុប្បន្នក្រុមសិក្សាបានផ្តល់បច្ចេកទេសដោយផ្ទាល់ដល់មន្ត្រីរដ្ឋាករតាមរយះការផ្ទេរបច្ចេកវិទ្យា ដោយប្រើប្រាស់រថយន្តឈូសសំរាមប្រភេទធំ ដែលចាប់ផ្តើមជួលតាំងពីពាក់កណ្តាលខែវិច្ឆិកា ២០០៤។ ភារះសំខាន់គឺការថែរក្សាផ្លូវចូល និងទីតាំងចាក់សំរាម ឈូសឆាយសំរាមដែលទើបនឹងចាក់ពីឡាន ថែរក្សាទំនប់ ។ ការអនុវត្តនេះនឹងបន្តរហូតដល់ពាក់កណ្តាលខែ មិថុនា ឆ្នាំ ២០០៥ ។ មូលហេតុដែលជ្រើសរើសការប្រើប្រាស់រថយន្តរៀលឡូដដីនេះគឺថា វាមានលទ្ធភាពបត់បែនរហ័ស និងមានប្រយោជន៏ច្រើនបើប្រៀបធៀបទៅនិងប្រភេត ប៊ុលដូសេដែលប្រើបច្ចុប្បន្ន។ តាមការជីកយកសំរាមចាស់ គេឃើញមានដីធម្មជាតិនៅខាងក្រោម ដូច្នេះ គេអាចប្រើដីនេះ សំរាប់គ្រងលើសំរាម ។

#### c.2 វិធានការណ៏សំរាប់អ្នករើសសំរាម

ការសាកល្បងនេះធ្វើឡើងដើម្បីរកសុវត្ថភាព និងប្រសិទ្ធភាពប្រត្តិបត្តការទីលាន ដោយបែងចែកពេលរើសសំរាម និងពេលចាក់សំរាមអោយដាច់ពីគ្នា ។ ធ្វើយ៉ាងនេះបាន គឺបានជំរុញគុណភាពការងារទីលានរបស់រដ្ឋាករ ។ ព្រោះតែការសាកល្បងមានការពន្យាពេលនោះ (ចាប់ផ្តើមខែ ធ្នូ ២៩) និងជំលោះដីធ្លីជាមួយ ម្ចាស់ដីនោះ ធ្វើអោយស្ថានភាពកាន់តែលំបាក ដែលធ្វើអោយក្រុមសិក្សាពុំអាចមានពេលវេលាគ្រប់គ្រាន់សំរាប់ធ្វើ ការងានេះឡើយ ។ ជាលទ្ធផល ក្រុមសិក្សា និង រ.គ.ស.ភ មិនអាចបង្កើតប្រពន្ធ័នេះបានទេ ។

ដូច្នេះ ប្រព័ន្ធនៃការបែងចែកនេះត្រូវបានរៀបចំឡើងនៅតំណាច់ខែធ្នូ ឆ្នាំ ២០០៤ ហើយការចាប់អនុវត្តហាក់ដូចជាមិនមានបញ្ហាចំបង ។ រដ្ឋាករត្រូវរកកំលាំងនរគបានដើម្បីទប់ស្កាត់ហេតុការណ៏ដែលអាចបង្កដោយអ្នករើសសំរាម

រឹងក្រុមសន្តិសុខនឹងត្រូវជួយយាមកាម និងចាត់ចែងអ្នករើសសំរាមតាមគោលដៅ ។ ថវិកានេះនឹងទទួលបានពីមូនិធិជប៉ុនដើម្បីកាត់បន្ថយភាពក្រីក្រ (JFPR) ។ រដ្ឋាករបំរុងនឹងចាប់អនុវត្តពីតំណាច់ខែធ្នូ ២០០៤ តទៅ ។

### c.3 ការបង្កើតប្រព័ន្ធត្រួតពិនិត្រមួយដោយទៀងទាត់

មុនគំរោងសាកល្បងការកែលំអរទីលានចាស់នេះ ក្រសួងបរិស្ថាន និងមន្ទីរបរិស្ថានមិនដែលធ្វើការត្រួតពិនិត្របរិស្ថានទីលានទេ ។ ការត្រួតពិនិត្រដោយទៀងទាត់ដោយស្ថាប័នណាមួយពិតប្រាកដ វាជាការចាំបាច់ណាស់សំរាប់ការត្រួតពិនិត្រការបំពុល ។

ជាងនេះទៀត សំរាប់ការអភិវឌ្ឍន៍ទីលានដង្កោ ក្រុមសិក្សាបានផ្តល់អនុសាសន៍ថាត្រូវបង្កើតគណកម្មការត្រួតពិនិត្រការងារប្រត្តិបត្តការរបស់រដ្ឋាករ ។ ដើម្បីធានាអោយបានការត្រួតពិនិត្រសមស្របដោយគណកម្មការនោះ ក្រសួង និងមន្ទីរបរិស្ថានត្រូវរៀបចំប្រព័ន្ធត្រួតពិនិត្រមួយអោយទៀងទាត់ និងសមស្រប ។ ដូច្នេះហើយ តាមរយះគំរោងសាកល្បងនៅទីលានចាស់ ក្រុមសិក្សាបានសំរេចគាំទ្រដល់ក្រសួង និងមន្ទីរអោយត្រួតពិនិត្របរិស្ថានទីលាន ជាប្រចាំ ។

ដោយសារកង្វះខាតថវិការ ក្រសួង និងមន្ទីរស្ទើរតែមិនអាចត្រួតពិនិត្រការងារបានតាមផែនការ ។ ដូច្នេះហើយ ក្រុមសិក្សាបានដកចេញការងារខ្លះដែលក្រសួង និងមន្ទីរមិនមានលទ្ធភាពធ្វើ ។ ទោះបីថា ប្រព័ន្ធថ្មីដែលរៀបចំនោះមានលក្ខណធម្មតាមិនស្មុគស្មាញ តែក្រសួង និងមន្ទីរនឹងអាចទទួលបានការយល់ដឹង និងបទពិសោធន៍តាមរយះគំរោងសាកល្បងនេះ ដោយរួមមានការងារជាច្រើនដូចជា ការរើសសំណាក វិភាគ រៀបចំទិន្នន័យ និងវិភាគ ទិន្នន័យ ។ល។

## 4.2.2 លទ្ធផលការសិក្សា

### a. ទំនាស់ជាមួយម្ចាស់ដីក្នុងតំបន់ដែលត្រូវពង្រីក

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៤ គេបានរៀបចំកិច្ចសន្យារវាង រ.គ.ស.ភ និងម្ចាស់ដីខ្លះដើម្បីដកតំបន់ A2 (២,៤ហ.ត) ចេញពីផែនការពង្រីកសរុបដែលមាន ៦ហ.ត (A1+A2+B) ។ ផែនការកែលំអនោះត្រូវធ្វើការកែប្រែតាមទំហំដី ៣.៦ហ.ត វិញ។ ក្រុមសិក្សាបានជួបពិភាក្សា និងរាយការជូនសាលាក្រុងភ្នំពេញនាថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ ២០០៤ ហើយសាលាក្រុងបានឯកភាពទាំងស្រុងលើគំរោងការនោះ ។

<u>បញ្ហានានាដែលមាន</u> :

១. ទោះបីថាបញ្ហាដែលបានលើកឡើងខាងលើនោះជាបញ្ហានាពេលបច្ចុប្បន្ន ក៏ប៉ុន្តែទឹកសំអុយពីសំរាមនឹងត្រូវហូរចូលទៅក្នុងដី A2 (២,៤ហ.ត) ដែលអាចនឹងមានការតវ៉ាអំពីម្ចាស់នោះដីនាពេលអនាគត ។

២. ដោយយោងលើការកាត់បន្ថយនៃតំបន់ពង្រីកនោះមានលទ្ធភាពផ្ទុកនឹងថយចុះពី ២៨៤.០០០ម៣ មកត្រឹមតែចំណុះ ១៧០.០០០ម៣ ប៉ុណ្ណោះ ដែលស្មើប្រមាណមួយឆ្នាំថយចុះនៃអាយុរបស់ទីលាន ពោលគឺនៅត្រឹមឆ្នាំ ២០០៦ គឺមិនមែន ២០០៧ ទេ ។

<u>វិធានការនានាដែលមាន</u> :

- រាល់ការតវ៉ាអំពីម្ចាស់ដី រ.គ.ស.ភ គួរតែត្រូវមានភស្តុតាងគ្រប់គ្រាន់អំពីស្ថានភាពពិតដើម្បីពន្យល់ និងបន្តការកែលំអ ទីលាន ។
- រហូតដល់ទីលានថ្មីនឹងត្រូវបញ្ចប់ការសាងសង់ សំរាមគួរតែត្រូវចាក់ឱ្យខ្ពស់។ ក្នុងការងារគ្រប់គ្រងសំណល់រឹងបញ្ហាតែងកើតមានឡើងជាប្រចាំ ។ ប៉ុន្តែដោយសារការជួបប្រទះជាញឹកញាប់នេះ រ.គ.ស.ភ ខាន់ទទួល

នូវបទពិសោធន៍ជាច្រើនដូចជាការពិនិត្យប្លង់ ការចាត់វិធានការតាមការជាក់ស្តែង និងការប្រាស្រ័យជាមួយភាគីពាក់ព័ន្ធនានា ។




Figure 4-2: ការពង្រីកតំបន់ចាក់សំរាមស្ទឹងមានជ័យ

## b. ការកែលំអបរិក្ខារ

ចំពោះការកែលំអផ្លូវនៅក្នុងទីលាន តាមការស្ទង់មតិអំពីពេលវេលា និងសកម្មភាពនៃរថយន្តសំរាមដែលបានចាប់អនុវត្តពីថ្ងៃទី២៤ ខែមិនា រហូតដល់ថ្ងៃទី៦ ខែមេសា ឆ្នាំ២០០៣ យើងឃើញថាពេលវេលានៃការរង់ចាំចាក់សំរាមមានចាប់ពី ១៧នាទី រហូតដល់ ១ម៉ោង និង ១១នាទី ដែលជាមធ្យមមាន ៣២នាទី ។ ក្រោយពេលការកែលំអទីលានពីខែធ្នូ ឆ្នាំ២០០៣ មក ពេលវេលារង់ចាំជាមធ្យមថយមកត្រឹម ៩,៩នាទី ប្រមាណ១/៣ បើប្រៀបធៀបទៅពេលវេលាចាស់ដែលកត្តានេះបានបង្កើនលទ្ធភាពប្រមូលកាន់តែប្រសើរ ។ ដូចគ្នាផងដែរការកែលំអប្លុកគំរូនឹងសង្ឃឹមថា ត្រូវបានចាក់ដីគ្របជាបណ្តើរៗ ។

ផ្លូវចូលត្រូវបានធ្វើការកែលំអដោយក្រាលបន្ទះដែក ។ ផ្លូវនៅក្នុងទីលានត្រូវផ្លាស់ប្តូរជាញឹកញាប់ដោយសារផ្ទៃក្រាលនោះត្រូវបានចាក់អំពីសំរាម ។ មុនកែលំអ គេបានជញ្ជូនដីទៅដាក់ចូលការដ្ឋានសំរាប់ការងារនេះ ។ តំលៃសំរាប់ការថែរក្សាផ្លូវទាំងនោះគឺជាការចំណាយច្រើនជាងគេបង្អស់ទី ២ នៃប្រតិបត្តិការណ៍នៅទីលានបន្ទាប់ពីការចំណាយលើប្រេង សំរាប់គ្រឿងចក្រ ។

ទំនប់ការពារដើម្បីញែកទីលានចាក់សំរាម ហើយនឹងប្រព័ន្ធប្រមូលទឹកសំអុយក៏ត្រូវបានសាងសង់ក្នុងតំបន់ ពង្រីក ហើយប្រព័ន្ធចំរោះទឹកសំអុយនោះក៏ត្រូវបានតំលើងនៅកាច់ជ្រុងដីដែលជាកម្មសិទ្ធិរបស់សាលាក្រុងភ្នំពេញ ។ នៅក្នុងតំបន់ពង្រីក តំបន់ចាក់សំរាមត្រូវបានចែកដាច់ទាំងស្រុងពីដីនៅក្បែរនោះដើម្បីការពារការរាយប៉ាយសំរាម និង ការរាលដាលដោយភ្លើង ។

ប្លុកគំរូសំរាប់បញ្ចប់ការចាក់ដីត្រូវបានសង់ឡើងជិតច្រកចូលនៃទីលាន ។ មុនការកែលំអ ប្លុកគំរូនោះគ្រាន់តែជាភ្នំសំរាមតែប៉ុណ្ណោះ តែពេលនេះតំបន់នោះត្រូវបានគេគ្របដណ្តប់ដោយដី និងតំលើងប្រព័ន្ធប្រមូលឧស្ម័នដើម្បីបង្ហាញអំពីទំរង់នៃទីលានមួយដែលមានអនាម័យល្អ ។ តាមរយៈការងារនេះ ទិដ្ឋភាពក្បែរច្រកផ្លូវចូលភាពរាយប៉ាយនៃសំរាម

ហើយនិងក្លិនត្រូវបានកាត់បន្ថយស្ទើរតែទាំងស្រុង ។ ជាងនេះទៀត ទីលានត្រូវគេបានគិតថានឹងដើរតួនាទីសំខាន់សំរាប់ជាទិសដៅមួយក្នុងការគ្រប់គ្រងដោយ រ.គ.ស.ភ នាពេលអនាគត ។

## c. ការកែលំអរប្រត្តិបត្តិការ

ដើម្បីអោយប្រត្តិបត្តិការមានភាពប្រសើរ រដ្ឋាករ អ្នកម៉ៅការ និងក្រុមសិក្សាបានឯកភាពបង្កើតការត្រួតពិនិត្រ និងការប្រជុំប្រចាំសប្តាហ៍តាមផែនការដែលរៀបចំដោយក្រុមសិក្សា ។ ជាលទ្ធផល គេឃើញមានការកែលំអរដែលពីមុនជាទីលានចំហរហើយគ្មានអនាម័យ ។ ការងារប្រើប្រាស់វៀលឡូដឺ ត្រូវបានគេសំរួល ដោយសារតែថាការប្រើចូលគ្នារវាង អ៊ិចស្កាវ៉ាទ័រ និងប៊ុដូសើមានលក្ខណប្រសើរជាង ។ ដូច្នេះ បច្ចេកវិទ្យាដែលផ្តល់ដល់សមភាគីត្រូវបានកែសំរួលតាមពិសោធន៍នេះ ។

ចំពោះការព្យាយាមបេងចែកតំបន់រើសសំរាមនោះ គេបានសាកល្បងលើទីតាំងបែងចែក ២ និង ៣ទីតាំង ។ ការចល័តពេលដែលបានកំណត់គឺ ៦ ទៅ ៧ ម៉ោងចាពេលវេលាយូរពេក ដែលអ្នករើសសំរាមកំណត់យកតែ ៣០ ទៅ ៤០ នាទីប៉ុណ្ណោះ ។ ទោះបីជាមិនមានទិន្នន័យច្បាស់លាស់ តែការព្យាយាមបែងចែកនេះបានផ្តល់ចាប្រសិទ្ធភាពច្រើនដក់ការងារឈ្លូសឆាយ និងបង្អាប់សំរាម និងការចាក់សំរាម ។

ដោយសារតែការសាកល្បងនេះមានសភាបយឺតយ៉ាវ (ចាប់ផ្តើម ថ្ងៃ ២៩ ខែធ្នូ) ព្រមជាមួយបញ្ហាជាមួយនិងម្ចាស់ដី នោះក្រុមសិក្សាមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីបន្តការសាកល្បងទេ ។ ដូច្នេះ ក្រុមសិក្សា និងរដ្ឋាករមិនអាចកសាងប្រព័ន្ធមួយសំរាប់ការបែងចែកទីលានចាក់សំរាម និងអ្នករើសសំរាមទេ ។ ក្រោយមកគេរកឃើញថាមានបញ្ហាជាច្រើនដូចជា អ្នករើសអេតចាយបានទិញសំរាមពីអ្នកបើកបរ ឬក៏មានការគាបសង្កតដោយកំលាំងដល់អ្នករើសដ៏ទៃទៀត ដែលបញ្ហាមានផលប៉ះពាល់ដល់ការបែងចែក ។ ក្រុមសិក្សា និងរដ្ឋាករបានចាត់វិធានការណ៏ទប់ស្កាត់ដោយសហការណ៏ជាមួយសង្កាត់ និងភូមិ ។ ទោះបីជាការសាកល្បងមានរយះពេលខ្លី តែបានបង្ហាញថាមានប្រយោជន៏ច្រើនដល់អ្នករើសសំរាម ។ ដូច្នេះហើយការសាកល្បងម្តងទៀតនឹងចាប់ផ្តើមនាតំណាច់ខែធ្នូ ឆ្នាំ ២០០៤ ។

## d. លទ្ធផលនៃការកែលំអ

### d.1 ការវាយតំលៃលើលទ្ធផលនៃការកែលំអ

ដើម្បីធ្វើការវាយតំលៃចំពោះលទ្ធផលនៃការកែលំអ ក្រុមសិក្សាបានរៀបចំអោយមានការចូលរួមពីអ្នករស់នៅជិតខាង និងបុគ្គលិកនៃអង្គការក្រៅរដ្ឋាភិបាល ។ ក្រុមអ្នកចូលរួមទាំងនោះត្រូវបានរៀបចំឱ្យមានការទស្សនាទីលានមុននិងក្រោយការកែលំអ ជារួមគឺថ្ងៃទី ១០ ខែតុលា ឆ្នាំ២០០៣ និងថ្ងៃទី ៩ខែមិនា ឆ្នាំ២០០៤ ហើយលទ្ធផលនោះត្រូវខានធ្វើការវាយតំលៃតាមរយះសំនួរដោយប្រៀបធៀបលក្ខណមុន និងក្រោយគំរោង ។ ចំនួនអ្នកចូលរួមគឺមាន ២៥នាក់មុនការដើរពិនិត្រគំរោងសាកល្បង និង២១នាក់ ក្នុងពេលការដើរពិនិត្រគំរោងសាកល្បង ។ គំរោងសំនួររួមមានពី៣-១០ លើខ្លឹមសារការងារ ដូចជា ផលប៉ះពាល់បរិដ្ឋាន លក្ខណប្រតិបត្តិការណ៏ និងមុខងារនៃហេដ្ឋារចនាសម្ពន៍ ។ អ្នកចូលរួមបានវាយតំលៃសំនួរនិមួយៗតាមរយះលំអានពី ១ទៅ៣ គឺ ១-មិនអាចទទួលយកបាន ២-កណ្តាល និង ៣-អាចទទួលយកបាន ។ អត្រានៃផលប៉ះពាល់មុនគំរោងកែលំអគឺ ១.២៧ រីឯក្រោយការកែលំអមាន ២.០៥ ។ សំរាប់លក្ខណនៃការធ្វើប្រតិបត្តិការណ៏ អត្រាបានកើនពី ១.៣១ ទៅ ២.០៥ ដែលអ្នកចូលរួមទទួលស្គាល់អំពីលទ្ធផលនៃការងារកែលំអនេះ ហើយដែលការងារនេះតំរូវអោយមានបន្ត ។ ចំពោះហេដ្ឋារចនាសម្ពន័វិញ គេក៏បានទទួលស្គាល់ពសារប្រយោជន៏នៃការថ្លឹងសំរាមចូល និងការសំរួលផ្លូវចូល ប្រពន្ធ័យកឱស្ម័ន ការធ្វើប្រព្រិត្តកម្ម ទឹកសំអុយ បរិក្ខាសំអាតទឹកសំអុយ និងរោងចក្រធ្វើជីកំប៉ុស ក៏ត្រូវបានធ្វើការវាយតំលៃ ។ ម្យ៉ាងវិញទៀត ការអោយពិន្ទុលើការងារចែកពេលរើសសំរាមបានទទួលចំណាត់ថ្នាក់ទាបជាងពិន្ទុ២ ដូច្នេះការងារកែលំអនឹងត្រូវតែមានបន្ត ។

## d.2 ការពន្យារអាយុកាលនៃទីលាន

ក្នុងការកែលំអនេះ លទ្ធភាពសំណល់ត្រូវបានកើនឡើង ១៧០,០០០ម៣ ។ ដោយយោងទៅលើកំពស់ប្លុកគំរូទីលាននេះអាចប្រើប្រាស់ដល់ឆ្នាំ២០០៦ ។

## d.3 ការណែនាំអោយមានបទបញ្ជានៃការចាក់សំរាម

តាមរយៈនៃការបែងចែកកន្លែងរើសសំរាម ប្រសិទ្ធិភាពនៃប្រតិបត្តិការណ៍ទីលានត្រូវបានកែលំអ ក៏ដូចជាសុវត្ថិភាពសំរាប់អ្នករើសសំរាមផងដែរ ។ ទោះបីជាយ៉ាងណាក៏ដោយការព្យាយាមអនុវត្តផែនការនេះ នឹងអាចក្លាយជាបញ្ហានាពេលអនាគត ។

## d.4 ប្រត្តិបត្តការទីលានដោយប្រើរថយន្តឈូសសំរាមកង់កៅស៊ូ

ដោយសារតែគុណប្រយោជន៍នៃរថយន្តនេះ ក្រុមសិក្សាសំណូមពរអោយដាក់បញ្ចូលទៅក្នុងផែនការប្រត្តិបត្តទីលាន ។ ដូច្នេះ ទីលាននឹងអាចបិទដោយប្រសើរប្រសិនបើការងារកែលំអរត្រូវបានបន្តដោយបច្ចេកទេសសមស្រប ។

## d.5 ប្រយោជន៍នៃអាងប្រព្រឹត្តកម្ម

ជាទូទៅ ជាតិបំពុលមានចំរុះដោយសារធាតុជាច្រើន ជាពិសេសជាតិដែលរលាយបាន ។ មុខងាររបស់អាងប្រព្រឹត្តកម្មនេះគឺដើម្បីកាត់បន្ថយជាតិបំពុលលើទឹកដែលបូមចេញពីពំនូកសំរាមហើយដែលអាចហូរទៅតំបន់ក្បែរខាងវា ។ ដើម្បីវាយតំលៃប្រសិទ្ធភាពរបស់អាងនេះ គេបានយកសំណាកទឹកសំអុយ និងទឹកដែលបានធ្វើប្រព្រឹត្តកម្មរួចស្រេចមកវិភាគ ។

Table 4-2: ការវិភាគលើប៉ារ៉ាម៉ែត្រនីមួយ ៗ

| Analysis parameters | PH | BOD5 (mg/L) | COD-Cr (mg/L) | Oil & Grease (mg/L) | SS (mg/L) | Iron (mg/L) | Chloride (mg/L) | Flow (L/sec) |
|---|---|---|---|---|---|---|---|---|
| **Sampling 1 (26 July 2004)** | | | | | | | | |
| Inlet | 7.52 | 380 | 720 | 59* | 100 | 2.3 | 1,900 | 38 |
| Outlet | NO sampling due to a mechanical problem of pump in the facility | | | | | | | |
| Proportion(%) | N/A | | | | | | | |
| **Sampling 2 (20 August 2004)** | | | | | | | | |
| Inlet | 7.57 | 190 | 540 | 11 | 99 | 2..3 | 2,200 | 41 |
| Outlet | 8.26 | 300 | 640 | 7.8 | 1,100 | < 0.3 | 1,400 | |
| Proportion(%) | 109 | 158 | 119 | 71 | 1111 | 13 | 64 | |
| **Sampling 3 (10 September 2004)** | | | | | | | | |
| Inlet | 7.44 | 320 | 1,100 | 9.1 | 130 | 0.97 | 1,700 | 35 |
| Outlet | 8.40 | 180 | 570 | 5.3 | 375 | 0.45 | 1,200 | |
| Proportion(%) | 113 | 56 | 52 | 58 | 288 | 46 | 71 | |
| **Sampling 4 (22 September 2004)** | | | | | | | | |
| Inlet | 7.22 | 360 | 5,100* | 7.5 | 244 | 0.53 | 1,800 | 30 |
| Outlet | 8.76 | 110 | 590 | 4.8 | 195 | < 0.3 | 1,100 | |
| Proportion(%) | 121 | 31 | 12 | 64 | 80 | 57 | 61 | |
| **Sampling 5 (28 September 2004)** | | | | | | | | |
| Inlet | 7.36 | 410 | 760 | 9.7 | 138 | 0.52 | 950 | 32 |
| Outlet | 9.05 | 160 | 630 | 6.0 | 318 | < 0.3 | 1,100 | |
| Proportion(%) | 123 | 39 | 83 | 62 | 230 | 58 | 116 | |

** ទិន្នន័យដែលមានការសង្ស័យ

ចំនុចខាងក្រោមគួរត្រូវពិចារណាមុននិងថាយតំលៃលទ្ធផល ។

ជាតំបូង លទ្ធផលនៃសំនាក ២ នាថ្ងៃទី ២៦.០៧.០៤ បង្ហាញនិន្នាការផ្សេងពីសំនាកដ៏ទៃទៀត ។ មូលហេតុនេះដោយសារសកម្មភាពរបស់អ្នករើសសំរាមប៉ះពាល់ដល់អាងប្រព្រឹត្តកម្មទី ៣ ដូចជាការលាងថង់ផ្លាស្ទិច ការបង្កអោយមានកំណកបាតអាង និងការលាយបញ្ចូលគ្នានូវកាកសំណល់ ។ ជាលទ្ធផល មានបរិមាណ BOD និង COD ច្រើនហើយមានកំរិត ១០ដងច្រើនជាង SS ។ ទីពីរ ទិន្នន័យដែលមានសញ្ញា * នោះនៅមានភាពមិនច្បាស់លាស់ ។ ជាលទ្ធផលទូទៅ អាងនេះអាចជួយសំរួលគុណភាពទឹកសំអុយ ក៏ដូចជា BOD និង COD និង ក្លបានមួយកំរិតទៀត ។ រូបភាពនេះបានបង្ហាញភាពខុសគ្នារវាងគុណភាពទឹកនៅមាត់ច្រកចូល និងច្រកចេញ ។ តែសំរាប់ SS គេកត់សំគាល់ឃើញថាបរិមាណបំពុលមានច្រើននៅមាត់ចេញទៅវិញទោះបីជាមានការរំពឹងថានឹងថមថយក្រោយពេលធ្វើប្រព្រឹត្តកម្មក្តី ។ មូលហេតុនោះគឺថា SS ចេញពីសាធាតុសរីរាង្គមានជីវិតហើយងាយរលាយនៅក្នុងទឹកសំអុយ ។ តែសាធាតុសារាយបានកើតមានឡើងដោយសារថា មាពន្លឺព្រះអាទិត្យខ្លាំងនៅប្រទេសកម្ពុជា ។



Figure 4-3 The Picture of Samples



Figure 4-4: Algae grown in the treated leachate

### 4.2.3 បញ្ហាច្រកចូលទីតាំងចាក់ និងបញ្ហានានា

ការធានាអោយបាននូវស្ថានភាពផ្លូវចូលដ៏ប្រសើរសំរាប់អ្នកប្រើប្រាស់ ពោលគឺរថយន្តប្រមូលសំរាម ជាតួនាទីដ៏សំខាន់របស់រដ្ឋាករគ្រប់គ្រងសំនល់ ។ ជាទូទៅ រដ្ឋាករតែងតែមិនបានបំពេញតួនាទីនេះអោយបានត្រឹមត្រូវទេ ។ ជួនកាលរថយន្តប្រមូលសំនល់ត្រូវរង់ចាំយ៉ាងយូរដោយសារមានការជាប់គាំងផ្លូវចូលដោយមានភក់ និងពំនូកសំណល់ ។ ពេលខ្លះត្រូវរង់ចាំប្រមាណ ៥ ម៉ោងក៏ត្រូវសំរេចចិត្តចាក់សំណល់ចោកនៅតាមផ្លូវនានាក្នុងទីលាន ។ ការរង់ចាំយូរបណ្តាលអោយមានការខាតបង់ និងប៉ះពាល់ដល់ផ្នែករថយន្ត ហើយនេះជាក់ស្តែងជាកង្វះខាតផ្នែកគ្រប់គ្រងទីលាន ជាពិសេសគឺទីតាំងចាក់សំណល់ ។ វាកាន់តែមានបញ្ហាច្រើនពេលខែវស្សា ។

១. កង្វះគ្រឿងចក្រគ្រប់គ្រាន់សំរាប់ការងារប្រត្តិបត្តការ ។ ការពិត រដ្ឋាករមិនមានគ្រឿងចក្រណាមួយទាល់តែសោះ ។ ដោយសារតែបរិក្ខារទាំងឡាយជាកម្មសិទ្ធរបស់អ្នកម៉ៅការនោះ រដ្ឋាករមិនអាចធ្វើការងារឈូសឆាយផ្លូវដោយមិនមានការយល់ព្រមអោយព្រើប្រាស់គ្រឿងចក្រនោះទេ ។

២. មិនមានថវិការគ្រប់គ្រាន់សំរាប់ប្រតិបត្តការទីលាន ។ ការទូទាត់ប្រចាំខែចំនួន ៨,៥០០ ដុល្លាអោយអ្នកម៉ៅការនោះមិនគ្រប់គ្រាន់សំរាប់ប្រតិបត្តការប្រកបដោយគុណភាពទេ ។ តាមការវិភាគរបស់ក្រុមសិក្សា តំលៃ

ថវិកានោះបានត្រឹមតែការជួលប៊ុលដូសើប្រភេទ D7 ប៉ុណ្ណោះ ហើយអាចប្រតិបត្តិការជាប្រចាំរយះពេល ១២ ម៉ោង[១] ។

៣. អ្នកប្រតិបត្តការមិនមានជំនាញ និងអនុវត្តអោយត្រឹមត្រូវ ។ នេះក៏បណ្តាលមកពីការគ្រប់គ្រងរបស់រដ្ឋាករនៅមានកំរិត ។

៤. មិនមានផែនកាប្រចាំថ្ងៃ ប្រចាំឆ្នាំ និងប្រចាំខែ ។ ដោយយោងលើផែនការនេះ អ្នកម៉ៅការត្រូវកសាង ថែរក្សា និងជួសជុលផ្លូវក្នុងទីលាន និងទីតាំងចាក់សំរាម ។

## 4.2.4 កិច្ចការដែលត្រូវធ្វើដោយសាលាក្រុង និងរដ្ឋាករ

ក្រុមសិក្សាផ្តល់អនុសាសន៍មួយចំនួនដើម្បីដោះស្រាយបញ្ហានេះ ។

### a. ដំណោះស្រាយសំរាប់ផ្លូវចូល

ដោយសារថា ការថែទាំផ្លូវចូលជាតួនាទីរបស់រដ្ឋាករ ដូច្នេះរដ្ឋាករត្រូវធ្វើការងារខាងក្រោម ។

### a.1 បង្កើនប្រាក់ចំនូលពីអ្នកប្រើប្រាស់ទីលាន ហើយសំរាប់ទូទាត់អោយអ្នកម៉ៅការ

រដ្ឋាករត្រូវធ្វើការថែទាំផ្លូវចូល និងទីតាំងចាក់សំរាមអោយបានត្រឹមត្រូវ និងទៀងទាត់ ។ រដ្ឋាករត្រូវយល់ថាការងារនេះតំរូវអោយមានគ្រឿងចក្រ និងការចំនាយដ៏ទៃទៀតដូចជា ប្រេង កំលាំងពលកម្ម ជាដើម ។ល។ តាមការប៉ាន់ស្មានរបស់ក្រុមសិក្សា ការចំណាយលើការងារប្រតិបត្តកាមានប្រមាណ ២៥,៣០០ ដុល្លាក្នុងមួយខែដោយគិតទាំងការធ្វើជារាងទីលាន តែមិនរាប់បញ្ចូលការគ្របដីលើសំរាមទេ ។ តំលៃនេះស្មើនិងប្រមាណ ១,២០ដុល្លា/តោន បើគិតថាបរិមាណសំនល់ប្រចាំថ្ងៃគឺ ៧០០ តោននោះ ។ ដូច្នេះ រដ្ឋាករត្រូវចរចារជាមួយអ្នកប្រើប្រាស់ទីលាន គឺក្រុមហ៊ុនស៊ីនទ្រីជាពិសេស ដើម្បីបង្កើនតំលៃឈ្នួលការចាក់សំនលដើម្បីអោយការងារគ្រប់គ្រងនេះមានប្រសិទ្ធភាព ។ ទន្ទឹមនិងនេះ រដ្ឋាករត្រូវផ្តល់សេវាកម្មប្រសើរដល់អ្នកប្រើប្រាស់ទីលានវិញ ។ សំរាប់ការចរចារនេះ រដ្ឋាករគួរយល់ថា ដើម្បីកែលំអរទីលាន និងច្រកចូលចាក់សំនល់ចាដើមគឺទាមទារអោយមានថវិការប្រតិបត្តសមស្រប ហើយដែលការងារនេះនឹងផ្តល់ជាផលប្រយោជន៍ត្រឡប់ដល់អ្នកប្រើប្រាស់វិញ ព្រោះថាវានឹងសំរួលប្រសិទ្ធភាពរថយន្តពេលចូលទីលានជួយបង្កើនជើងរត់ ជាសវាងបានកំហូចរថយន្ត និងជារួមបានកាត់បន្ថយថ្លៃជួសជុល ។

ប្រសិនបើរដ្ឋាករជោគជ័យលើការតំឡើងថ្លៃទីលាន ហើយរដ្ឋាករនឹងអាចបង្កើនប្រាក់ប្រចាំខែអោយអ្នក ម៉ៅការព្រមគ្នានិងសំនូមពរអោយបង្កើនគ្រឿងចក្រ ។

### a.2 ផែនការ និងការត្រួតពិនិត្រប្រតិបត្តកាទីលាន

ទោះបីជាថា រដ្ឋាករនឹងអាចមានថវិកាសំរាប់ថែរក្សាទីលាន តែប្រសិនបើមិនមានផែនកាគ្រប់គ្រងត្រឹមត្រូវទេនោះ រដ្ឋាករនឹងមិនអាចធានាការងារនេះបានទេព្រោះថា ប្រតិបត្តការទីលានត្រូវបានផ្តល់អោយក្រុមហ៊ុនឯកជនទៅហើយ ។ ដូច្នេះ រដ្ឋាករត្រូវរៀបចំផែនការប្រតិបត្តប្រចាំថ្ងៃ អាទិត្យ ខែ សំរាប់ជំរុញប្រតិបត្តការមួយត្រឹមត្រូវ និងផ្តល់ការណែនាំដល់អ្នកម៉ៅការ ។ ដោយយោងលើផែនកានោះ រដ្ឋាករត្រូវត្រួតពិនិត្រ និងតាមដានការងាររបស់អ្នកម៉ៅការ ដូចខាងក្រោម :

- ថែទាំច្រកចូលចាក់សំរាប់រថយន្ត (ផ្លូវក្នុងទីលាន និងទីតាំងចាក់) អោយខ្ពស់ជាងតំបន់ដ៏ទៃដើម្បីជាងវាងបានផលប៉ះពាល់នារដូវវស្សា ។

[១] ជាទូទៅប៊ុលដូសើមិនអាចប្រតិបត្តការជាប្រចាំទេ ។

- រៀបចំលូបង្ហូរទឹកភ្លៀងសំរាប់ផ្លូវចូល និងទីតាំងចាក់សណល់ ។

- ធ្វើការថែទាំ និងជួសជុលដោយទៀងទាត់តាមការណែនាំរបស់ក្រុមសិក្សា ។

**b. ការត្រួតពិនិត្រទីលាន**

រដ្ឋាករជាម្ចាស់នៃទីលាន ហើយមានតួនាទីធ្វើការងារទីលានដូចខាងក្រោម :

- ការគ្រប់គ្រងទូទៅលើទីលាន
- សន្តិសុខទីលានដោយរាប់ទាំងការការពាររបស់ទ្រព្យដែលមាននៅទីលាន
- រៀបចំផែនការប្រត្តិបត្តការទីលាន និងផ្តល់ការណែនាំការងារដល់អ្នកម៉ៅការ
- ត្រួតពិនិត្រអ្នកម៉ៅការ អ្នកចាក់សំនល់ (រថយន្តចេញ និងចូល) អ្នករើសសំរាម ល ។ល
- ត្រួតពិនិត្រប្រត្តិបត្តការទីលានទូទៅដោយរាប់ទាំងការមើលពីលើប៉ុស្តិយាមផង
- ពង្រឹងបទបញ្ជាទីលានដូចជាត្រួតពិនិត្រភ្លើងឆេះ ប្រត្តិបត្តការមិនសមស្រប និងការចាក់សំរាម
- ការងារជញ្ជីង និងអាងប្រព្រឹត្តកម្ម
- ផ្តល់អគ្គសនី និងទឹក
- ផ្តល់ភ្លើងតាមផ្លូវសំខាន់ៗ និងទីតាំងចាក់សំរាមសំរាប់ការងារពេលយប់
- ថែរក្សាផ្លូវចូលចាក់ ម៉ូដែលប្លុក ទំនប់កាពារ និងប្រឡាយ

ដើម្បីបំពេញបានភាពទទួលខុសត្រូវខាងលើ រដ្ឋាករត្រូវរៀបចំបទបញ្ជាទីលានដោយផ្អែកលើពង្រាងបទបញ្ជាដែលរៀបចំដោយក្រុមសិក្សា ។ បន្ថែមលើនេះ រដ្ឋាករត្រូវបានស្នើរអោយត្រួតពិនិត្រឡើងវិញនូវកិច្ចសន្យាជាមួយអ្នកម៉ៅការ ដោយយោងលើបទដ្ឋានបច្ចេកទេសសំរាប់ការងារប្រត្តិបត្តការទីលានដែលជួយរៀបចំដោយក្រុមសិក្សា ។

**c. ការជីក និងយកសំរាមចាស់ចេញ**

មានផែនការកាយយកសំរាមចាស់ចេញពីទីលាន ដែលក្រុមសិក្សាយល់ថាវាមានប្រយោជន៏ចំពោះការបន្តអាយុកាលទីលានដោយផ្តល់អោយមានទំហំដីកាន់តែ ទូលាយនិងជាសវាងការកើនជាតំពស់ ហើយកាត់បន្ថយតំលៃសំរាប់ប្រត្តិបត្តការនៅទីលានដែរ ។ ក្រុមសិក្សាបានផ្តល់អនុសាសន៏ដល់រដ្ឋាករអោយបន្តការងារនេះ តែត្រូវយកចិត្តទុកដាក់ពិនិត្រលើករណីយខាងក្រោម :

- ការងារជីកត្រូវធ្វើឡើងតាមការងារណែនាំដូចមានក្នុងរូបភាពខាងក្រោម ។ ការជីកលើកទីមួយគឺត្រូវធ្វើលើចំនុច (១) និងបន្ទាប់មកគឺ (២) និង (៣) ដូចមានក្នុងរូបភាព ។ បើតំរូវការសំរាមមានច្រើនទៀតនោះ គេអាចបន្តជីកចំនុច (៤) ទៀត ។

- ផ្លូវចូលសំរាប់ជីកយកសំរាមក៏ត្រូវធ្វើតាមរូបភាពខ្សែផ្លូវខាងក្រោមនេះដែរ ។ រដ្ឋាករមិនត្រូវអោយរថយន្តដឹកសំរាមចាស់ទាំងនេះរត់លើផ្លូវជាមួយរថយន្តដឹកសំរាមពីក្នុងទីក្រុងមកទេដើម្បីជាសវាងបញ្ហាចរាចរ ។ ខ្សែរត់នោះក៏មិនត្រូវអោយប៉ះពាល់ទំនប់ការពារអាងប្រព្រឹត្តកម្មដែរ ។

- រដ្ឋាករមិនត្រូវបង្កអោយមានការជីកសំរាមចាស់ពីប្លុកគំរូរទេ ។




Figure 4-5: : សំណើរបួ្លង់ជីកសំរាមចាស់ និងផ្លូវចូល

## 4.3 ការកែលំអប្រព័ន្ធប្រមូលសំរាម

ការកែលំអរប្រព័ន្ធប្រមូលជាការចាំបាច់ណាស់ដើម្បីឆ្លុះបញ្ចាំងអំពីផែនកាមេដែលបានរៀបចំជាពិសេសលើតំបន់ដែលមិនមានសេវាកម្ម និងតំបន់ដែលមានសេវាកម្មតិចតួច ដើម្បីពង្រឹងសមត្ថភាពរបស់សាលាក្រុង និងវដ្ឋាករគ្រប់គ្រងសំនល់រាជធានីភ្នំពេញ ។ ប៉ុន្តែ តំបន់ទាំងនោះភាគច្រើនមិនអាចអោយរថយន្តសំរាមចូលដឹកបាន ។ ដោយហេតុនេះ នៅតំនាក់កាលទី ២ នៃការសិក្សា ក្រុមសិក្សាបានរៀបចំគំរោងសាកល្បងដោយប្រើប្រាស់ធុងសំរាមធំចំនួន ១០គ្រឿងដែលមានទំហំមួយគ្រឿងប្រមាណ ៥ ម៣ ដោយបង្កអោយមានការចូលរួមពីសង្កាត់ និងភូមិលើការប្រមូលប្រាក់ ។ នៅតំណាក់កាលទី៣ វដ្ឋាករបានធ្វើគំរោងសាកល្បងដោយពង្រីកសេវាកម្មប្រមូលសំណល់ទៅតំបន់ដ៏ទៃទៀតដោយប្រើប្រាស់គ្រឿងចក្រដែលមានស្រាប់ ។ តាមរយះគំរោងសាកល្បងនេះ ដោយមានការផ្ទេរតំបន់ពីក្រុមហ៊ុនស៊ីនទ្រីនោះ វដ្ឋាករបានធ្វើដំណោះស្រាយគ្រប់បែបយ៉ាងជាមួយអតិថិជនជំនួសអោយក្រុមហ៊ុននេះ ។

### 4.3.1 ការណែនាំប្រព័ន្ធប្រមូលដោយធុងសំរាមធំ

**a. ផែនកាកែលំអរ**

**a.1 ការពង្រីកសេវាកម្មប្រមូលសំរាមដោយប្រើប្រាស់ធុងកុងទែន័រ**

តំបន់សាកល្បងគង្គាផុស និងបឹងសាឡាង (១ និង២ ក្នុងរូបភាព៤-៥: ផែនទីទីតាំងនៃតំបន់សាកល្បង) គឺជាប្រភេទតំបន់ដែលមានប្រាក់ ចំណូលទាបនៅក្នុងទីក្រុងភ្នំពេញ ។ អាស្រ័យហេតុនេះហើយ ក្រុមសិក្សាបានប្រើប្រាស់ការប្រមូលដោយប្រើរទេះរុញ និង ការប្រមូលដោយប្រើធុងកុងទែន័រ ។

តំបន់ NIP នៅក្នុងខ័ណ្ឌចំការមន មានទំហំ ៨០០ម៉ែត្រពីកើតទៅលិច និង២០០ម៉ែត្រពីជើងទៅត្បូង ។ ពាក់កណ្តាលនៃផ្នែកខាងជើងស្ថិតនៅក្នុងសង្កាត់បឹងកេងកង ១ រីឯមួយផ្នែកទៀតភាគខាងត្បូង ស្ថិតនៅក្នុងសង្កាត់ បឹងកេងកង ២ ។ នៅក្នុងតំបន់NIP ដែលការប្រមូលដោយប្រើរទេះត្រូវបានប្រើប្រាស់នោះ សំរាមត្រូវបានប្រមូលដោយក្រុមជួយខ្លួនឯងហើយយកទៅមណ្ឌលកែច្នៃដើម្បីបែងចែក ។ តែដោយសារមណ្ឌលកែច្នៃស្ថិតនៅក្បែរ ចុងខាង ជើងនៃតំបន់ NIP នោះចំងាយរុញរទេះពីចុងខាងជើងមានរយៈចំងាយឆ្ងាយ ប្រមាណ១គីឡូម៉ែត្រហើយប្រសិទ្ធិភាពនៃការប្រមូលក៏មានកំរិត។ ដូច្នេះហើយដើម្បីបង្កើនប្រសិទ្ធិភាពនៃការប្រមូលក្រុមសិក្សា បានដាក់ទីតាំងធុងសំរាម បន្ថែមនៅផ្នែក

ខាងត្បូងគឺ បឹងកេងកង ២ ដើម្បីបន្ថយរយៈពេលរុញរបស់ក្រុមជួយខ្លួនឯង ។ ក្រុមសិក្សា ក៏បានដាក់ធុង តាមបណ្តោយប្រឡាយពីជើងទៅត្បូងក្នុងតំបន់ភាគខាងកើតនៃ NIP ដើម្បីកាត់បន្ថយពំនូកសំរាម និង ការចាក់សំរាមទៅក្នុងប្រឡាយ ។

### a.2 ការប្រមូលដោយការញែកសំរាម

ការព្យាយាមញែកសំរាមប្រភេទសំរាមសើម និងសំរាមស្ងួតត្រូវបានធ្វើឡើងដោយផ្តោតទៅលើគ្រួសារចំនួន ២០០ ក្នុងសង្កាត់បឹងកេងកង ២ ។

### a.3 ការបង្កើតប្រព័ន្ធនៃការប្រមូលថ្លៃសេវា

ការប្រមូលថ្លៃសេវាដោយមានការគាំទ្រពីសង្កាត់ត្រូវបានប្រើប្រាស់នៅតំបន់គង្គាផុស និងបឹងសាឡាងដែលជាកន្លែងផ្តល់សេវាកម្មប្រមូលសំរាមថ្មី ។

Table 4-3: : ខ្លឹមសារសំខាន់ៗនៃតំបន់គោលដៅនៃការសាកល្បង

| តំបន់ដែលជ្រើសរើស | ប្រព័ន្ធប្រមូលសំរាម | លក្ខណៈតំបន់ដែលបានជ្រើសរើស |
|---|---|---|
| គង្គាផុស សង្កាត់ទួលសង្កែ ខ័ណ្ឌទួលគោក | ការប្រមូលដោយរទេះរុញ និងដោយកុងទេន័រ | ជាផ្នែកមួយនៃសង្កាត់ទួលសង្កែ មានទីតាំងនៅជាយភាគខាងជើងនៃខ័ណ្ឌទាំង៤ ។ គ្រួសារតាមបណ្តោយផ្លូវ៥៩៨ ទទួល សេវាកម្មពីក្រុមហ៊ុនស៊ិនទ្រី លើកលេង ២៦៣ គ្រួសារទៀត ក្នុងតំបន់សាកល្បង ។ |
| ភូមិទី ១៤ សង្កាត់បឹងសាឡាង ខ័ណ្ឌទួលគោក | ការប្រមូលដោយរទេះរុញ និងដោយកុងទេន័រ | ភូមិនេះជាផ្នែកនៃសង្កាត់បឹងសាឡាងនាកាច់ជ្រុងប្រឡាយ ។ វាចាំបាច់ត្រូវកែលំអផ្លូវចង្អៀតនោះសំរាប់ការងារអនុវត្ត ។ មានគ្រួសារនៅក្នុងតំបន់នេះ ប្រមាណជា ១១៣ គ្រួសារ ។ |
| សង្កាត់បឹងកេងកង ១ និង ២ ខ័ណ្ឌចំការមន | ការប្រមូលដោយរទេះរុញ និងដោយកុងទេន័រ | ប្រមាណពាក់កណ្តាលនៃប្រជាពលរដ្ឋនៅក្នុងតំបន់ NIP ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់ រ.គ.ស.ភ ត្រូវបានជួយដោយក្រុម សិក្សា។ |
| សង្កាត់បឹងកេងកង ២ ចំការមន | ការប្រមូលញែកសំរាម | ផ្នែកមួយនៃ NIP ស្ថិតក្រោមសេវាកម្មរបស់ រ.គ.ស.ភ (២០០គ្រួសារ) |




Figure 4-6: **: ផែនទីទីតាំងនៃទំបន់សាកល្បងដែលបានជ្រើសរើស**

## b. លទ្ធផលនៃការសិក្សា

### b.1 ការបង្កើតប្រព័ន្ធប្រមូលដោយរទេះ

ដូចតំបន់នានាដែលគ្មានសេវាប្រមូលសំរាមដែរ តាមផ្លូវខ្សឿងហែង និងច្រករបៀងនានានៅតំបន់គង្គាផុស និងបឹងសាឡាងមានលក្ខណតូចចង្អៀត និងមិនរាបស្មើដែលបណ្តាលអោយការប្រមូលតាមរទេះមានការលំបាក ឬមិនអាចទៅរួច ។ បន្ទាប់មកក្រុមសិក្សាបានធ្វើការពង្រីក និងចាក់គ្រាលផ្លូវដោយផ្តល់សំភារៈដូចជាថ្ម និងស៊ីម៉ង់ត៍ ហើយដែលប្រជាពលរដ្ឋចូលរួមជាពលកម្ម ។

Table 4-4: **ការកែលំអផ្លូវចូលនៅក្នុងតំបន់សាកល្បង**

| តំបន់ដែលជ្រើសរើស | ផ្លូវមិនរាបស្មើ ( ម ) |
|---|---|
| ១. គង្គាផុស | 884 |
| ២. បឹងសាឡាង | 528 |

សំរាប់ការប្រមូលដោយរទេះរុញ អតីតអ្នករើសសំរាមបីនាក់ត្រូវបានគេរៀបចំឱ្យទៅជាក្រុមជួយខ្លួនឯង ក្រោមការសហការជាមួយអង្គការស្ការ៉ូ ហើយកំពុងផ្តល់សេវាកម្មនៅតំបន់គង្គាផុស និងបឹងសាឡាងក្នុងតំលៃ 0,៣ដុល្លាក្នុងមួយគ្រួសារក្នុងមួយផ្ទះដោយទំនាក់ទំនងផ្ទាល់ជាមួយរ.គ.ស.ភ ។ យោងតាមការសាកសួរមតិអំពីអ្នកប្រើប្រាស់សេវាក្រោយពេលសាកល្បងបានឱ្យឃើញថា ភាគច្រើននៃអ្នកប្រើប្រាស់ពេញចិត្តចំពោះសេវាកម្ម ។ ការប្រមូលថ្លៃសេវាលើកទីមួយ ពីអ្នកដែលទទួលសេវាដែលនឹងបង្ហាញខាងក្រោមគឺ ៨៩% នៅតំបន់គង្គាផុស និង ៨២% នៅបឹងសាឡាង ដែលនេះបញ្ជាក់ពីការពេញចិត្តចំពោះសេវាកម្ម ។

### b.2 ប្រសិទ្ធិភាពនៃការប្រមូលដោយធុងសំរាម

តាមការដាក់ធុងសំរាមនៅតាមតំបន់គ្មានសេវាកម្មសំរាមគំនរសំរាម ត្រូវបានប្រមូលព្រមជាមួយនឹងក្លិននៅតំបន់ជុំវិញក៏ត្រូវបានកាត់បន្ថយ ព្រមទាំងការចោលសំរាមដោយគ្មានរបៀប។ ជាងនេះទៀត ចំពោះការប្រមូលបឋម

ក៏មានប្រជាពលរដ្ឋដែលបានយកសំរាមមកដាក់ដោយផ្ទាល់នៅធុងសំរាមដែរ ។ ការប្រមូលដោយធុងសំរាមនេះបាន បង្ហាញអោយឃើញនូវប្រសិទ្ធភាព ហើយដែលគួរតែធ្វើការពង្រីកទៅតំបន់នានា ដែលពុំទាន់មានច្រកចូលប្រសើរ ។

ដោយដាក់ធុងសំរាមនៅតំបន់ NIP ចំងាយធ្វើដំណើររបស់រថយន្តពីភាគខាងត្បូងត្រូវបានកាត់បន្ថយដូច្នេះគឺបាន កាត់បន្ថយការងាររបស់ក្រុមជួយខ្លួនឯង ។ ចំពោះការកែឆ្នៃសំរាម ក្រុមជួយខ្លួនឯងបានព្យាយាមរើសយករបស់មាន តំលៃមុនធ្វើការចាក់ចូលទៅក្នុងធុងសំរាម ហើយយករបស់អស់នោះទៅដាក់នៅក្នុងមណ្ឌល ក៏ប៉ុន្តែបរិមាណនោះបាន ថយចុះ ។

## b.3 ទីតាំងនៃធុងសំរាម

ក្រុមសិក្សាបានរៀបចំការដាក់ធុងសំរាមដោយផ្អែកលើអត្រាបញ្ចេញសំរាមរបស់មនុស្សម្នាក់ៗ គឺ ៤៨៧ ក្រ. ក្នុង ម្នាក់ក្នុង មួយថ្ងៃដោយគិតផងដែរនូវក៏រិតនៃប្រាក់ចំណូល ។ ដូច្នេះធុងសំរាមមួយចំណុះ ៥ម$^{៣}$ ត្រូវបានរៀបចំសំរាប់ពី ៣៤០-៤៤០គ្រួសារ ។

មិនយូរប៉ុន្មានក្រោយពីការប្រមូលចាប់ផ្តើម បរិមាណសំរាមនៅតំបន់គង្គាផុស និងបឹងសាឡាងបានកើនឡើង ហួសពីការប៉ាន់ស្មាន ។ ជាពិសេសនៅតំបន់គង្គាផុស គេបានចាត់វិធានការណ៏បន្ថែមកុងទែន័រទីពីរ ជាបន្ទាន់ដោយសារ ធុងទីមួយពុំអាចទទួលបរិមាណច្រើនលើសលប់នេះ ។ បីថ្ងៃក្រោយមកស្ថានភាពត្រឡប់មកជាបីធុងវិញ ។ ការចាក់ សំរាមចោលនូវបរិមាណដ៏ច្រើនបែបនេះ ត្រូវបានគេសន្និដ្ឋានលើមូលហេតុថានៅពេលដែលមានទីតាំងចាក់សំរាមត្រឹម ត្រូវនោះប្រជាពលរដ្ឋព្យាយាមបានបញ្ចេញសំរាមដែលនៅសល់ឱ្យអស់ក្នុងពេលតែមួយ ។ ដោយឡែកនៅតំបន់ NIP នាពេលដំបូង ការប្រមូលបែបនេះមានលក្ខណៈប្រក្រតី ។

ប្រមាណពីរ ឬបីអាទិត្យក្រោយពីការសាកល្បង បរិមាណសំរាមខានកើនឡើងធ្វើឱ្យហួសពីចំណុះរបស់ធុងដែល អាចទទួលខាន ។ មូលហេតុនោះត្រូវបានគេគិតថា បណ្តាលមកពីការយកសំរាមមិនទៀងទាត់របស់ក្រុមហ៊ុន ស៊ិនទ្រី គឺជា ទូទៅ ៣ថ្ងៃក្នុងមួយសប្តាហ៏ គឺថ្ងៃសៅរ៏ អាទិត្យ និងថ្ងៃចន្ទ័ ហើយបរិមាណដែលពុំបានប្រមូល ត្រូវបានប្រជាពលរដ្ឋចាក់ ចូលក្នុងធុងសំរាមនៅតំបន់ NIP នេះតែម្តង ដោយមធ្យោបាយនានា ដូចជាឡានតូចៗ ឬរ៉ឺម៉ក។

## b.4 បញ្ហាជាមួយនិងការប្រមូលដោយធុង និងវិធានការណ៏ចាំបាច់

ប្រមាណពីរសប្តាហ៏ក្រោយការសាកល្បង គេឃើញមានសំរាមរាយប៉ាយនៅជុំវិញធុង ។ មូលហេតុចំបងគឺ បរិ-មាណសំរាម ដែលដឹកចូលមកពីខាងក្រៅតំបន់សាកល្បងមានច្រើនហួសពីការសន្និដ្ឋាន ហើយប្រជាពលរដ្ឋខ្លះពុំបានដាក់ សំរាមឱ្យចូលធុងខានត្រឹមត្រូវដែរ ។ ដើម្បីទប់ស្កាត់ឱ្យទាន់ពេលវេលានោះ ក្រុមសិក្សាខានសហការណ៏ជាមួយ រ.គ.ស.ភ បាន ស្នើសុំឱ្យក្រុមជួយខ្លួនឯងជួយសំអាតទីកន្លែងជុំវិញធុងសំរាម ហើយស្នើរអាជ្ញាធរសង្កាត់ចាត់វិធានការ ជួយទប់ស្កាត់សំរាមពីខាងក្រៅ ។ ប៉ុន្តែសំរាប់វិធានការយូរអង្វែងនោះ គេចាំខាច់ត្រូវណែនាំប្រជាជនតាមរយៈការអប់រំ ជាសាធារណ:។ ជាងនេះទៀត ការគ្រប់គ្រងប្រើប្រាស់ធុងសំរាមក៏ជាបញ្ហាដែរដែលតំរូវឱ្យពិចារណា អំពីការចូលរួម ថែរក្សាពីសហគមន៏ ។

## b.5 ប្រសិទ្ធិភាពនៃការញែកសំរាម

ការញែកសំណល់ចែកជាពីរផ្នែកគឺ សំណល់ស្ងួត និងសើម ។ ដោយមានណែនាំឱ្យមានការញែកសំរាមនោះ បរិមាណសំរាមដែលអាចធ្វើជីកំប៉ុស្តខានកើនឡើង ៧,៦ដង ពេលបែងចែកក្នុងមនុស្សម្នាក់ៗ ក្នុងមួយម៉ោង ហើយបរិមាណអេតចាយក៏បានកើនឡើង ៦,៨ដង លើសពេលមុន ។ ទោះបីជា យ៉ាងណាក្តី បរិមាណរបស់ កែច្នៃបាននោះបានថយចុះដោយសារប្រជាជនបានលក់អេតចាយ សំរាប់កំរៃផ្ទាល់ទៅឱ្យដេប៉ូជៀសជាងទុកក្នុងធុង

សំរាប់ក្រុមជួយខ្លួនឯង ។ ទោះបីថាវាជាសញ្ញាមិនល្អសំរាប់ក្រុមជួយខ្លួនឯង និងសំរាប់ការប្រមូលសំរាមជារួមក្តី តែក៏អាចជាចំណុចល្អដែរព្រោះថាប្រជាពលរដ្ឋានទឹងកំពុងចាប់អារម្មណ៍លើការកែច្នៃសំរាម ។

### c. ប្រពន្ធ័នៃការប្រមូលថ្លៃសេវាសំរាម

ចំពោះការប្រមូលថ្លៃសេវាសំរាម រ.គ.ស.ភ ជាស្ថាប័នចេញវិក័យបត្រ័ ឯអាជ្ញាធរសង្កាត់ជាអ្នកប្រមូលថវិកាប្រគល់ជូនទៅ រ.គ.ស.ភ វិញ ។ ដើម្បីជាការលើកទឹកចិត្ត រ.គ.ស.ភ បានផ្តល់កំរៃជើងសារ ១0% ទៅអាជ្ញាធរសង្កាត់ជាការតបស្នងថ្លៃសេវា ។ ដើម្បីឱ្យការប្រមូលថ្លៃសេវាដំណើរការខាន ក្រុមសិក្សាបានរៀបចំការប្រជុំជាមួយអង្គការដោយពន្យល់អំពីប្រព័ន្ធ និងមូលហេតុនៃការប្រមូល ។ មុនពេលការចាប់ផ្តើមនៃការសាកល្បង ការជួបជុំពន្យល់ដោយ រ.គ.ស.ភ ត្រូវបានធ្វើឡើងជាមួយប្រជាពលរដ្ឋ ហើយពួកគេបានជ្រាបថាពួកគាត់ត្រូវធ្វើកិច្ចសន្យាទទួលសេវាកម្មជាមួយ រ.គ.ស.ភ និងព្រមបង់ថ្លៃសេវាជារៀងរាល់ខែ ។ ការប្រមូលត្រូវបានធ្វើឡើង ជាដំបូង នាខែមករា ឆ្នាំ២00៤ ។

តាមរយៈតារាងខាងក្រោម គេឃើញមានការចូលរួម និងមូលមតិពីអតិថិជនភាគច្រើន ។

Table 4-5: : លទ្ធផលនៃការប្រមូលថ្លៃសេវា (ខែមករា ២00៤)

| តំបន់ដែលជ្រើសរើស | ចំនួនគេហដ្ឋាន | ថវិកាដែលប៉ាន់ស្មានថានឹងទទួលបាន (ដុល្លា) | ចំនួនគេហដ្ឋានដែលបានបង់ប្រាក់ | ថវិកាដែលទទួលបានពិតប្រាកដ (ដុល្លា) |
|---|---|---|---|---|
| គង្គាផុស | ២៦៣ | ២៩៤ | ២៦១ (៩៩.២%) | ២៦១.0 (៨៨.៧%) |
| បឹងសាឡាង | ១១៣ | ១២៥ | ១0១ (៨៩.៣%) | ១0១.៦ (៨១.៣%) |

អត្រាប្រមូលប្រាក់ជាមធ្យមក្នុងកំឡុងពាក់កណាលឆ្នាំគឺប្រមាណ ៨២ ភាគរយ ដូចមានក្នុងរូបភាពខាងក្រោម ។ ដូច្នេះបញ្ជាក់ថាការប្រមូលប្រាក់ជាមួយសង្កាត់គឺអាចមានកំរៃបាន ។




Figure 4-7: : អត្រាប្រមូលប្រាក់

## 4.3.2 ការពង្រីកសេវាកម្មប្រមូលសំរាម

### a. ផែនការនៃគំរោងសាកល្បង

រដ្ឋាករ និងក្រុមសិក្សាបានជ្រើសរើសយកបេក្ខភាពតំបន់សាកល្បង ៤ កន្លែងដែលមិនមានសេវាកម្មប្រមូលសំនល់ដោយប្រើប្រាស់បទពិសោធន៏ដែលបានពីការសាកល្បងនៅតំបន់ក្នុងខណ្ឌ ៣ នាជាយក្រុងក្នុងតំនាក់កាលទី ២ នៃការសិក្សា ។ បនទាប់មករដ្ឋាករបានស្នើរដល់ស៊ីនទ្រីដើម្បីឯកភាពលើការសាកល្បងនេះ ។ តែក្រុមហ៊ុនស៊ីនទ្រីបានស្នើរដល់

រដ្ឋាករអោយមានការដោះដូរតំបន់បេក្ខភាពទាំងបួនជាមួយនិងតំបន់សាកល្បងចាស់របស់រដ្ឋាករគឺ តំបន់ទីប និងបឹងសាលាងដែលរដ្ឋាករបានធ្វើគំរោងសាកល្បងនាតំណាក់កាលទី ២នោះ ។ សាលាក្រុង និងរដ្ឋាករបានឯកភាពលើសំណើរដោះដូរនេះដើម្បីបន្តគំរោងសាកល្បង ។

## a.1 ផែនការប្រមូលសំរាម

### (១) តំបន់គំរោងសាកល្បង និងចំនួនអតិថិជន

តំបន់គំរោងនេះមានប្រជាជនប្រមាណ ៨៨,៩០២ នាក់នាឆ្នាំ ២០០៣ ស្មើ ៧.៥ ភាគរយនៃប្រជាពលរដ្ឋនៅតំបន់នេះ ។ សូមមើលរូបភាព 4-7 ។ អតិថិជនដែលត្រូវផ្តោតសេវាកម្មមុនបំផុតគឺចំពោះអ្នកដែលធ្លាប់បានទទួលសេវាប្រមូលពីស៊ីនទ្រី ។ រដ្ឋាករ និងក្រុមសិក្សាបានធ្វើការប្រមូលទិន្នន័យពីសង្កាត់ទាំង ៤ ដោយ សហការជាមួយសង្កាត់ និងភូមិ ។ យោងលើទិន្នន័យនោះចំនួន អតិថិជនមាន ៦,៣១៤នាក់ ដូចមានក្នុងតារាងខាងក្រោម ។ មិនមានការបញ្ជាក់ណាមួយពីចំនួនអតិថិជនដែលទទួលសេវាកម្មពីស៊ីនទ្រីទេ ។



Figure 4-8: តំបន់គំរោងសាកល្បង

Table 4-6: តំបន់ និងចំនួនប្រជាពលរដ្ឋ ២០០៣

| អង្គាធរ | | តំបន់ | ប្រជាពលរដ្ឋ |
|---|---|---|---|
| ខណ្ឌ | សង្កាត់ | ($Km^2$) | (Person) |
| មានជ័យ | ច្បារអំពៅ ១ | 0.49 | 12,053 |
| ឫស្សីកែវ | ទួលសង្កែ | 2.76 | 30,773 |
| ឫស្សីកែវ | Phnom Penh ថ្មី | 20.55 | 25,844 |
| ឫស្សីកែវ | ជ្រោយចង្វារ | 9.62 | 20,232 |
| សរុប | | 33.42 | 88,902 |

Table 4-7: ចំនួនអតិថិជនតាមសង្កាត់

| | | ច្បារអំពៅ ១ | ជ្រោយចង្វា | Phnom Penh ថ្មី | ទួលសង្កែ | សរុប |
|---|---|---|---|---|---|---|
| គេហដ្ឋាន | សរុប | 1245 | 2465 | 3168 | 4159 | 11037 |
| | ក្នុងតំបន់សេវាកម្ម | 1150 | 1849 | 345 | 2074 | 5418 |
| ភោជនីយដ្ឋាន | សរុប | 9 | 49 | 7 | 17 | 82 |
| | ក្នុងតំបន់សេវាកម្ម | 9 | 24 | 3 | 10 | 46 |
| ហាងទំនិញ | សរុប | 113 | 127 | 59 | 624 | 923 |
| | ក្នុងតំបន់សេវាកម្ម | 113 | 69 | 20 | 400 | 602 |

| | | ច្បារអំពៅ ១ | ជ្រោយចង្វា | Phnom Penh ថ្មី | ទួលសង្កែ | សរុប |
|---|---|---|---|---|---|---|
| ការិយាល័យ | សរុប | 4 | 2 | 9 | 1 | 16 |
| | ក្នុងតំបន់សេវាកម្ម | 4 | 2 | 3 | 1 | 10 |
| ស្នាក់នៅ | សរុប | | 50 | 24 | 651 | 725 |
| | ក្នុងតំបន់សេវាកម្ម | | 21 | 10 | 194 | 225 |
| រោងចក្រ | សរុប | | 2 | 18 | 33 | 53 |
| | ក្នុងតំបន់សេវាកម្ម | | | 3 | 4 | 7 |
| ទីផ្សារ | សរុប | | 2 | 1 | 2 | 5 |
| | ក្នុងតំបន់សេវាកម្ម | | | 1 | 1 | 2 |
| ប្រភេទពេទ្យ | សរុប | | 1 | | | 1 |
| | ក្នុងតំបន់សេវាកម្ម | | | | | - |
| សាលារៀន | សរុប | | 13 | 5 | 4 | 22 |
| | ក្នុងតំបន់សេវាកម្ម | | | 2 | | 2 |
| សាធារណ | សរុប | | 3 | 1 | | 4 |
| | ក្នុងតំបន់សេវាកម្ម | | | | | - |
| សរុប | សរុប | | | | | |
| | ក្នុងតំបន់សេវាកម្ម | | | | | 6,314 |

ខាងលើ : សរុបទិន្នន័យ និងខាងក្រោម: អតិថិជនក្រោមសេវាកម្មស៊ីនទ្រី

## (២) បរិមាណសំណល់ដែលមានទីសដៅ

ទីសដៅ និងបរិមាណសំនល់ដែលនឹងប្រមូលគឺត្រូវបានប៉ាន់ស្មានតាមរយះទិន្នន័យដែលផ្តល់ដោយសង្កាត់ ។

### Table 4-8: បរិមាណសំនល់ដែលត្រូវប្រមូលតាមតំបន់

| ប្រទេភ | Chba Ampov I | Chroy Changva | Phnom Penh Thmey | Toul Sangke | សរុប |
|---|---|---|---|---|---|
| គេហដ្ឋាន | 3.22 | 5.18 | 0.97 | 5.81 | 15.17 |
| ភោជនីយដ្ឋាន | 0.14 | 0.77 | 0.05 | 0.32 | 1.28 |
| ហាង | 0.51 | 0.31 | 0.09 | 1.80 | 2.71 |
| ការិយាល័យ | 0.01 | 0.01 | 0.01 | 0.00 | 0.04 |
| ប្រទេភស្នាក់នៅ | 0.00 | 0.07 | 0.04 | 0.68 | 0.79 |
| រោងចក្រ | 0.06 | | 1.50 | 2.72 | 4.28 |
| ផ្សារ | | | 0.60 | 3.00 | 3.60 |
| មន្ទីរពេទ្យ | | | | | |
| សាលារៀន | | | 0.15 | | 0.15 |
| ទីសាធារណ | | | | | |
| សរុប | 3.95 | 6.34 | 3.40 | 14.33 | 28.02 |

### (៣) រថយន្តប្រមូលដែលជាកម្មសិទ្ធរបស់រដ្ឋាករ

រដ្ឋាករមានរថយន្ត៤ ប្រភេទ គឺរថយន្តកុំប៉ាក់ទ័រចំនួន ៤ និងរថយន្តស្ទូចធុងសំរាម ១ដោយមានធុងចំនួន ១០ មានចំនុះ ៥ម៣ ក្នុងធុងនីមួយ ៗ ។



Skip loader truck with 5m$^3$ container
Compactor truck 4m$^3$
Compactor truck 18m$^3$
Compactor truck 4.5m$^3$

Figure 4-9: រថយន្តប្រមូលដែលជាកម្មសិទ្ធរបស់រដ្ឋាករ

### (៤) ផែនការប្រមូលលើកទីមួយ

ជាមូលដ្ឋាន ការប្រមូលសំរាប់គេហដ្ឋានធម្មតាគឺ ៣ដងក្នុងមួយថ្ងៃ និងតាមអាជីវិកម្មត្រូវធ្វើជារៀងរាល់ថ្ងៃ ។ ដោយគិតលើលទ្ធភាពរបស់រថយន្ត និងចំនួនជើងប្រមូល នោះរដ្ឋាករ និងក្រុមសិក្សាបានធ្វើការប៉ាន់ស្មានបរិមាណសំនល់អតិបរមាដូចតារាង ៤.៩ ខាងក្រោម ។ តែតាមការពិតបរិមាណលើការដ្ឋានមានតិចជាងការប៉ាន់ស្មាន ដោយសារគេបានគិតលំអិតលើបញ្ហាចរាចរ បុណ្យផ្សេង ៗ ជាដើម ។

Table 4-9: លទ្ធភាពប្រមូលសំណល់របស់រដ្ឋាករ

| តំបន់ | រថយន្ត | លទ្ធភាព | ផែនការ | ត្រូវប្រមូល |
|---|---|---|---|---|
| | | Ton/trip | trip/day | ton/day |
| ទួលសង្កែ | Compactor Daewoo (01) | 9.6 | 2 | 19.2 |
| | Skip Loader (05) | 1.2 | 6 | 7.2 |
| ច្បារអំពៅ ១ | Compactor hiroshima (03) | 2 | 3 | 6 |
| ជ្រោយចង្វារ | Compactor Laterday (02) | 2.7 | 2 | 5.4 |
| | Compactor hiroshima (03) | 2 | 1 | 2 |
| ភ្នំពេញថ្មី | Compactor hiroshima (04) | 2 | 2 | 4 |
| សរុប | | | 16 | 43.8 |

### (៥) កាលវិភាគអនុវត្ត

ដោយយោងលើកិច្ចសន្យាជាមួយស៊ីនទ្រី ការចាប់ផ្តើមការងារប្រមូលគឺថ្ងៃ ១៥.០៩.២០០៤ ។ រដ្ឋាករបានធ្វើការជួប និងពន្យល់ដល់សង្កាត់ ធ្វើកិច្ចសន្យាជាមួយប្រជាជន ជ្រើសរើសអ្នកបើកបរ និងកម្មករព្រមទាំងផ្តល់ការបណ្តុះបណ្តាលមុលពេលធ្វើការ ។

Table 4-10: កាលវិភាគ

| Items | Jul. | Aug. | Sep. | Oct. |
|---|---|---|---|---|
| Agreement between MPP and CINTRI | | ■ | | |
| Customer Data Collection | ■ | | | |
| Detail Collection Planning | ■ | ■ | | |
| Agreement with Sangkat | ■ | ■ | | |
| Service agreement with Customers | | ■ | ■ | |
| Preparation of the vehicle depot | | ■ | | |
| Preparation of the maintenance facility | | ■ | | |
| Recruit new staffs | | ■ | | |
| Purchase tools and materials | | ■ | ■ | |
| Training staff | | | ■ | |
| Implementation of the collection service | | | ■ | ■ |

## a.2 សកម្មភាពដែលបានធ្វើដោយសាលាក្រុង និងរដ្ឋាករ

### (១) ថវិការវិនិយោគ

រដ្ឋាករបានប៉ាន់ស្មានថានឹងមានតំរូវការថវិការប្រមាណ ១៣,០០០ ដុល្លាសំរាប់ការវិនិយោគ ៦ អាទិត្យតំបូងចំពោះ សង្កាត់ទាំងបួន ។ ថវិការនេះរាប់បញ្ចូលការចំណាយលើបុគ្គលិក បណ្តុះបណ្តាល ប្រេងរថយន្ត ជាដើម ។ល។ រដ្ឋាករបានស្នើរថវិការនេះ ហើតសាលាក្រុងបានគាំទ្រនាខែ កញ្ញា ២០០៤ ។

### (២) ដីសំរាប់រោងជាង និងការជួសជុល

រដ្ឋាករមានរថយន្តប្រាំគ្រឿងតែមិនមានរោងជាងជួសជុលទេ ។ ការរៀបចំរោងជាងជាការចាំបាច់ណាស់ ។ ដូច្នេះ សាលាក្រុង និងរដ្ឋាករបានយករថយន្តទៅដាក់ទុកក្នុងមណ្ឌលអប់រំអ្នករើសសំរាមចាបណ្តោះអាសន្ន ដែលបានសាងសង់ដោយគំរោង JFPR ។ បន្ទាប់មកក៏បាននឹងកំពុងរៀបចំរោងជាងថ្មីនៅជាប់ការិយាល័យការដ្ឋានសំនង់ទីលានតែម្តង ។

## b. លទ្ធផលនៃការសិក្សា

## b.1 បរិមាណប្រមូល

រដ្ឋាករបានប្រមូលសំនល់ដុចតារាងខាងក្រោមក្នុងរយះពេល ២.៥ ខែ ចាប់ពីខែ កញ្ញា ២០០៤ មក។ គេឃើញមានសំនល់ជាច្រើនត្រូវបានប្រមូលនៅសង្កាត់ទួលសង្កែនាតែពាក់កណ្តាលខែតំបូង ដោយមូលហេតុថាគេបានធ្វើការប្រមូលពំនូកចាស់ ៗ ដែលបានចាក់ចោលដោយពាសវាលពាសកាល មុននិងចាប់ផ្តើមសេវាកម្ម ។ ដូចគ្នាដែរ បរិមាណសំរាមនៅទួលសង្កែ និងជ្រោយចង្វារដែលបែរមុខមកច្រាំងទន្លេក៏មានច្រើនដែរដោយសារពិធីបុណ្យអ៊ុំទូក ។

បរិមាណប្រមូលក្នុងខែតុលាមាន ៣២.២ តោនក្នុងមួយថ្ងៃ ដែលលើសការប៉ាន់ស្មានប្រមាណ ៤ តោន ។ សរុបទិន្នន័យនេះ គឺស្មើប្រមាន ៧៤ភាគរយនៃលទ្ធភាពរបស់រដ្ឋាករនាពេលបច្ចុប្បន្ន ។

Table 4-11: បរិមាណសំណល់នៅ ៤ សង្កាត់

| សង្កាត់ | September, 2004 | | | October, 2004 | | | November, 2004 | | |
|---|---|---|---|---|---|---|---|---|---|
| | trips | ton/m | ton/day | trips | ton/m | ton/day | trips | ton/m | ton/day |
| ទួលសង្កែ | 121 | 543.7 | 36.2 | 171 | 649.2 | 21.6 | 196 | 708.8 | 23.6 |
| ជ្រោយចង្វារ | 38 | 99.4 | 6.6 | 58 | 158.2 | 5.3 | 58 | 597.7 | 19.9 |
| Phnom Penh ថ្មី | 14 | 34.3 | 2.3 | 28 | 65.2 | 2.2 | 15 | 57.5 | 1.9 |
| ច្បារអំពៅ ១ | 15 | 36.5 | 2.4 | 33 | 94.0 | 3.1 | 42 | 108.6 | 3.6 |
| សរុប | 188 | 713.9 | 47.6 | 290 | 966.6 | 32.2 | 311 | 1,472.6 | 49.1 |

ចំណាំ : សេវាកម្មប្រមូលចាប់ផ្តើមថ្ងៃ ១៥.០៩.០៤

**b.2 ការងារគ្រប់គ្រងគ្រឿងចក្រ**

រថយន្តពីរគ្រឿង គឺ ១៨ម៣ និង៤.៥ ម៣ ត្រូវបានខូចខាតជាញឹកញាប់ ហើយដែលគេបានប្រើរថយន្តពីរគ្រឿងទៀតដើម្បីជំនួស ។ បញ្ហានេះមិនមែនជារឿងថ្មីទេដែលថារថយន្តទាំងពីរនេះចាស់ ប៉ុន្តែរដ្ឋាករបានគ្រប់គ្រងដោយមិនអោយមានសេវាកម្មអាក់ខានដល់អតិថិជនឡើយ ។ រដ្ឋាករបានបំពាក់រថយន្តដោយវិទ្យុទាក់ទង ហើយដែលអាចអោយរថយន្តចល័តទីតាំងខ្សែរត់បានយ៉ាងងាយទៀតផង ។ តែទោះបីយ៉ាងណាក្តី រថយន្តដែលជំនួសនោះវាតូច ហើយក៏មិនប្រាកដថាអាចដោះស្រាយបញ្ហាជានិរន្តទេ ។ ការជំនួសដោយរថយន្តថ្មីជាការចាំបាច់ណាស់ ។

**b.3 ចំនួនអតិថិជន និងការប្រមូលលុយ**

ចំនួនអតិថិជន និងចំនួនទឹកប្រាក់សរុបដែលប្រមូលបាននាខែ វិច្ឆិកា ២០០៤ មានក្នុងតារាងខាងក្រោម ។ ការប្រមូលបានតែប្រមាន ៥៨ ភាគរយ ហើយរដ្ឋាករបានពន្យល់ថាហេតុអ្វីបានជាកិច្ចសហការជាមួយសង្កាត់នៅមានកំរិត ហើយអតិថិជនខ្លះមិនបង់ប្រាក់ ។ រដ្ឋាករបានធ្វើយុទ្ធនាការអប់រំសាធារណនៅក្នុងខែធ្នូកន្លងមក ។

Table 4-12: ចំនួននៃអតិថិជន កិច្ចសន្យា និងបរិមាណប្រមូល

| | កិច្ចព្រមព្រៀង | | លុយដែលប្រមូល | |
|---|---|---|---|---|
| | អតិថិជន | US$ | អតិថិជន | US$ |
| ទួលសង្កែ | 2,301 | 4,338.50 | 1,334 | 2,094.90 |
| ជ្រោយចង្វារ | 305 | 892.20 | 65 | 418.80 |
| Phnom Penh ថ្មី | 193 | 362.50 | 22 | 151.00 |
| ច្បារអំពៅ ១ | 1,052 | 1,471.25 | 811 | 1,192.50 |
| សរុប | 3,851 | 7,064.45 | 2,232 | 3,857.20 |

ប្រភព : ទិន្នន័យរដ្ឋាករ ខែធ្នូ ២០០៤

**b.4 វិធានការណ៍ជាបន្ទាន់**

មានគ្រោះថ្នាក់ចរាចរមួយកើតឡើងនាកំឡុងពេល ២.៥ ខែនេះ ។ រថយន្ត ដេរ៉ូ ១៨ម៣ បានប៉ះជាមួយរឺម៉កដឹកមនុស្សពេញនាថ្ងៃ ១៦.១១.០៤ ។ តែមានតែមនុស្ស ២ នាក់ប៉ុណ្ណោះដែលមានរបួសស្រាល រីឯអ្នកដ៏ទៃនិងរឺម៉ក មិនមានបញ្ហាទេ ។ ក្នុងករណីយនេះ អ្នកបើកបរបានបញ្ជូនអ្នករងរបួស ទៅមន្ទីរពេទ្យតាមដែលបទដ្ឋានសង្គ្រោះបន្ទាន់ដែលរៀបចំដោយក្រុមសិក្សា ។ រដ្ឋាករបានធ្វើការអប់រំដល់អ្នកបើករ ហើយនឹងអាចឈានដល់ការបណ្តេញចេញប្រសិនបើមានការធ្វេសប្រហែសទៀត ។

# 4.4 ការអប់រំជាសាធារណ

## 4.4.1 ផែនការគំរោង

### a. ទីសដៅនៃគំរោង

ទីសដៅសំខាន់គឺកាសំអាតទីក្រុង ជាពិសេសសំអាតពំនូកសំរាមដែលមាននៅតាមតំបន់គេហដ្ឋាន និងអាជីវកម្ម ដែលមានប្រជាជនច្រើនដោយធ្វើការណែនាំបទដ្ឋានចាក់សំនល់ ក្រោមការសហការពីប្រជាជន និ្យងអជ្ញាធរមូលដ្ឋាន ។ វាមានសារះសំខាន់ណាស់សំរាប់មន្ទីរបរិស្ថានដើម្បីបង្កើនការយល់ដឹងជាសាធារណ និងជំរុញការចូលរួមពីប្រជាជនដើម្បីធ្វើការណែនាំពីបទដ្ឋាននោះដោយប្រសិទ្ធភាព ។ ដូច្នេះ គំរោងនេះមានសារះដើម្បីជួយស្តារលទ្ធភាពរបស់មន្ទីរ ។

### b. ទីតាំងគំរោង

ដោយសារថា បញ្ហាសំរាមមានកើតច្រើនត្រង់តំបន់មានមនុស្សកកកុញ នោះការជ្រើសរើសគំរោងគឺ : (១) ប្រជុំអាគារធំ ៧ ដែលមានចាប់ពី ២០០ ទៅ ៣០០គ្រួសារ ដែលចាក់សំណល់នៅចំនុចតែមួយ (២) តំបន់ដែលមានលាយឡំដោយគេហដ្ឋាន និង (៣) តំបន់ផ្សា ។ ដោយយោងលើលក្ខណវិនិច្ឆ័យនេះ មន្ទីរជ្រើសរើសតំបន់មួយចំនួន ហើយក្រុមសិក្សាបានជ្រើសរើសតំបន់ក្នុងសង្កាត់មនោរម្យដូចមានក្នុងរូប ៤.៩ ខាងក្រោម ។ ជាងនេះទៀត ដោយយោងលើណើររបស់ស៊ីនទ្រី គេក៏បានជ្រើសរើសតំបន់មួយទៀតនាសង្កាត់បឹងត្របែកដែលមានតែអាគារពីរជាន់ និងមនុស្សតិច ។ នៅមុនការចាប់ផ្តើមគំរោង កម្មកររបស់ស៊ីនទ្រមានការលំបាកក្នុងការយកសំនល់នៅសងខាងប្រឡាយ ។




Figure 4-10: Project Site in Sangkat Monorom




Figure 4-11: Project Site in Sangkat Boeung Trabek

### c. ការកសាងការយោគយល់ (កាបង្កើតក្រុមការងារ)

ប្រជាជនកម្ពុជាធម្មតាមួយចំនួនមិនយល់ពីមូលដ្ឋានច្បាប់សង្គមទេ ។ ដូច្នេះ ដើម្បីធ្វើកាណែនាំបទដ្ឋាន ចាក់សំណល់អោយបានប្រសើរ វាចាំបាច់ត្រូវកសាងការជឿជាក់ និងឯកភាពដ៏ទូលំទូលាយមួយជាមួយអតិថិជន និងអាជីវកម្ម ហើយត្រូវចំណាយពេលដើម្បីអោយគេអាចយល់ដឹងពីបទដ្ឋាននោះអោយច្បាស់លាស់ ។

ក្នុងកិច្ចការនេះ ក្រុមសិក្សាបានស្នើរអោយមានការសហការពីអាជ្ញាធរ តំណាងប្រជាជន អាជីវករ និងក្រុមហ៊ុនស៊ីនទ្រី ដើម្បីអោយអ្នកទទួលផលទាំងអស់អាចជួបគ្នាជាញឹកញាប់ដើម្បីចែករំលែកការយល់ដឹង និងមតិលើបទដ្ឋាននោះ ។ ក្រុមសិក្សាក៏បានអញ្ជើញអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធនិងបញ្ហាបរិស្ថានអោយធ្វើជាអ្នកសង្កេតការណ៍ ។

ក្រុមអ្នកចូលរួមមាន :

- ក្រុមសិក្សា JICA
- មន្ទីរបរិស្ថាន (សាលាក្រុង)
- ក្រុមហ៊ុនប្រមូលសំរាម (ស៊ីនទ្រី)
- អាជ្ញាធរតំបន់របស់គំរោង
- តំណាងប្រជាពលរដ្ឋ និង NGOs

រាល់មាតិការសំខាន់ ៗ នៃបទដ្ឋាននោះត្រូវបានសំរេចដោយការប្រជុំ ។

## 4.4.2 គំហើញនៃការសិក្សា

ប្រជាពលរដ្ឋដែលនៅចំកណ្តាលទីប្រជុំជននាទីក្រុងភ្នំពេញ ជាពិសេសត្រង់តំបន់មានសណល់រាយប៉ាយ និងពំនូកធំ ៗ មានការចាប់អារម្មណ៏ចង់សំអាតទីកន្លែងរបស់គេ ។ ទោះបីចាថាប្រជាជនមិនយល់មូលដ្ឋានច្បាប់របស់សង្គម ដូចជាការគោរពច្បាប់ចរាចរ ជាដើមតែពួកគេនៅតែអាចចាប់យល់អំពីបទដ្ឋាននៃការគ្រប់គ្រងសំនល់ប្រសិនបើអ្នកជំនាញព្យាយាមពន្យល់អោយប្រជាជនយល់ច្បាស់អំពីអត្ថប្រយោជន៏នៃបទដ្ឋាននោះ។
មូលដ្ឋានសំខាន់នៃជោគជ័យមានបង្ហាញក្នុងផ្នែកនេះ រួមទាំងដំណោះស្រាយសំរាប់ពង្រីកតំបន់អប់រំក៏មានសង្ខេបស្រាប់ ។

### a. ចំនុចសំខាន់

#### (១) ការយល់ដឹងជារួមលើបញ្ហា

ដើម្បីណែនាំបទដ្ឋានអោយបានលទ្ធផលល្អ វាចាំបាច់ថាប្រជាពលរដ្ឋត្រូវយល់ទាំងអស់គ្នាពីផលវិបាកពីការចាក់សំនល់មិនត្រឹមត្រូវ ។ តាមរយះគំរោងសាកល្បង ជាពិសេសការប្រជុំក្រុមការងារ និងសហគមន៏ ទាំងមន្ទីរបរិស្ថាន ក្រុមសិក្សា និងស៊ីនទ្រីបានកសាងការយល់គ្នាជារួមមួយលើគំរោងការគ្រប់គ្រងសំនល់រឹង ជាមួយអាជ្ញាធរ និងប្រជាជន ។ ការយល់ពីបញ្ហានេះ បានជុំរុញអោយមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋាន ។ ជាងនេះទៀត ការបង្ហាញរូបភាពជាក់ស្តែងតាមរយះខ្សែវីដេអូដែលបានថតពីតំបន់នោះមុនគំរោងសាកល្បងការអប់រំ បានយកមកបញ្ចាំងហើយបង្កអោយមានការយល់យ៉ាងច្បាស់ពីស្រទាប់មហាជន។

#### (២) កត្តាដឹកនាំរបស់អាជ្ញាធរមូលដ្ឋាន

នៅក្នុងសង្កាត់មនោរម្យ ការដឹកនាំពូកែរបស់ចៅសង្កាត់បាននាំមកនូវជោគជ័យ ។ ក្រោមការដឹកនាំរបស់គាត់ មេភូមិទាំងឡាយបានចូលរួមហើយផ្សព្វផ្សាយពីបទដ្ឋានដែលទើបតែរៀបចំនោះដល់ប្រជាពលរដ្ឋ ហើយក៏បានបញ្ចុះបញ្ចូលពួកគេអោយចូលរួមលើការងារគ្រប់គ្រងសំណល់រឹង ។ ពេលនោះ គេបានសាងជំនឿក្នុងចំនោមមហាជនថាអ្នកដ៏ទៃច្បាស់ជាគោរពច្បាប់ ដូច្នេះខ្ញុំក៏ត្រូវតែគោរពដែរ ។ ដូច្នេះ ជាបន្តវាចាំបាច់សំរាប់មន្ទីរបរិស្ថានក្នុងការសហការជាមួយនិងខណ្ឌ សង្កាត់ជាបន្តដើម្បីពង្រីកតំបន់អប់រំ ។

#### (៣) ផលប្រយោជន៏ដ៏ច្បាស់

ដើម្បីការអនុវត្តដោយរលូន មន្ទីរត្រូវបង្ហាញផលប្រយោជន៏ពីគំរោង ក៏ដូចជាការណែនាំអោយច្បាស់អំពីថាតើត្រូវទុកដាក់ និងចាក់សំរាមយ៉ាងណា ។ កត្តាជោកជ័យនេះ អាចយកទៅបង្ហាញនៅតំបន់ដ៏ទៃទៀតពេលមន្ទីរបរិស្ថានត្រូវការពង្រីកការងារ ។

### b. បញ្ហាត្រូវដោះស្រាយសំរាប់ការពង្រីកតំបន់ការងារ

**(១) ចែកព័តមានដល់ទីក្រុងទាំងមូល**

ក្នុងគំរោងសាកល្បង លក្ខណវិនិច្ឆ័យសំខាន់មួយ គឺស្មារតីរបស់អជ្ញាធរក្នុងការសំអាតមូលដ្ឋានរបស់គេ ។ សំរាប់ការពង្រីកតំបន់ មន្ទីរគួរតែសហការអប់រំជាមួយថ្នាក់ ខណ្ឌ និងសង្កាត់ ដូច្នេះសង្កាត់ដ៏ទៃទៀតនឹងព្យាយាមចូលរួម ។ មន្ទីរក៏ត្រូវរៀបចំបទដ្ឋានដ៏ទូលំទូលាយមួយដើម្បីឲ្យទូលាយមួយដើម្បីច្បាមយកការយល់ដឹងលើផ្ទៃធំជាងនេះ ដោយប្រើប្រាស់ប្រព័ន្ធផ្សាយ ដូចជា ទូរទស្សន៍ វិទ្យុ និង កាសែត ។

**(២) ហាមមិនអោយយកសំរាមចេញទៅចាក់ក្រៅតំបន់**

ការសិក្សាបង្ហាញថា ប្រជាជនខ្លះចាក់សំរាមនៅពំនូកជិតផ្ទះ ឬនៅតាមផ្លូវទៅធ្វើការ ឬទៅផ្សារ ។ ទោះបីជាគំរោងសាកល្បងនេះមានការរីកចំរើន តែប្រជាជនមួយចំនួននៅតែមានទម្លាប់ចាក់សំរាមនៅតំបន់អ្នកជិតខាង ។ ដូច្នេះ មន្ទីរគួរតែធ្វើការហាមប្រាមមិនអោយយកសំនល់ទៅចាក់ចោលនៅតាមតំបន់ក្បែរខាង ហើយបំរាមនេះត្រូវតែផ្សព្វផ្សាយទូទាំងរាជធានី ។

**(៣) ដំណោះស្រាយជាមួយអ្នកលក់តាមផ្លូវ**

ការសិក្សាក៏បានបង្ហាញថា អ្នកលក់តាមផ្លូវដូចជា ដូង អំពៅ ជាដើម ដែលចល័តពេញទីក្រុងបាន ចាក់ចោលសំនល់ជាច្រើន ។ បច្ចុប្បន្ន ពួកគេចាក់សំនល់គ្រប់កន្លែងដែលគេចង់ធ្វើ ជាពិសេសលើដីតែម្តង ។ វាជាការលំបាកណាស់សំរាប់មន្ទីរបរិស្ថានដើម្បីធ្វើការគ្រប់គ្រងពួកគេ ពេលពង្រីកសេវាទូទាំងរាជធានី ។

# 4.5 ការអភិវឌ្ឍន៍ និងការបង្កើនទីផ្សារជីកំប៉ុស្ត

## 4.5.1 ចំណុចសំខាន់ៗ នៃការសិក្សា

ក្រុមសិក្សាបានអនុវត្តសកម្មភាពខាងក្រោម :

| ចំណុចសិក្សា | អធិប្បាយ |
|---|---|
| ១.ការវិភាគអំពីសមាសភាពជីកំប៉ុស្ត | សមាសភាពជីកំប៉ុស្តដែលធ្វើឡើងដោយ COMPED និង CSARO ត្រូវបានធ្វើការវិភាគ (C/N ratio, PH, N, $P_2O_5$, $K_2O_5$, ភាពមិនស្អាត កែវ លោហៈផ្សេងៗ) ។ |
| ២. ការសិក្សាទៅលើទីផ្សារ | ការសិក្សាទីផ្សារធ្វើឡើងចំពោះ៥០គ្រួសារ ដែលមានចំងាយ ២០ម៉ាយ ពីផ្ចិតនៃទីក្រុងភ្នំពេញ (១០ភូមិ x ៥គ្រួសារ) ។ |
| ៣. ការសាកល្បងនៅវាលស្រែ | ការពិសោធន៍នៅវាលស្រែ (២ ប្រភេទ) ត្រូវបានធ្វើឡើងដោយកសិករ៤រូបមកពីខេត្តស្វាយរៀង ក្រោមការណែនាំរបស់ក្រុម IVY ដោយធ្វើការប្រៀបធៀបទិន្នផលដែលប្រើ និងមិនប្រើជីកំប៉ុស្ត។ |
| ៤.ការពិនិត្យវាលស្រែដើម្បីតាមដានការសាកល្បង | ការចុះពិនិត្យត្រូវបានរៀបចំសំរាប់កសិករដែលមកពីខេត្តស្វាយរៀង និងទីក្រុងភ្នំពេញដើម្បីធ្វើការបង្ហាញប្រសិទ្ធិភាពនៃការធ្វើជីកំប៉ុស្ត ព្រមទាំងការផ្តល់មេរៀនអំពីមូលដ្ឋាននៃការធ្វើកំប៉ុស្ត ។ |
| ៥. ការបង្កើតវីដេអូផ្សព្វផ្សាយ | បានធ្វើវីដេអូផ្សព្វផ្សាយផ្គត់ពត៌មាន និងផ្ទាំងប៉ាណូរូបភាពអំពីការធ្វើជីកំប៉ុស្ត និងការសាកល្បងនៅវាលស្រែ ។ |

* IVY: ក្រុមស្ម័គ្រចិត្តអន្តរជាតិនៃ Yamagata និងអង្គការក្រៅរដ្ឋាភិបាលដែលមានមូលដ្ឋាននៅខេត្តស្វាយរៀង

### 4.5.2 លទ្ធផលនៃការសិក្សា

យោងតាមលទ្ធផលនៃការវិភាគលើសមាសភាពជីកំប៉ុស្តផលិតពីសំណល់ទីក្រុង ដោយអង្គការ COMPED និង CSARO នៅទីក្រុងភ្នំពេញបង្ហាញឱ្យឃើញថាបរិមាណ ph និងភាពមិនស្អាត០ានកើនលើសពីជីកំប៉ុសដែលផលិតនៅប្រទេសថៃ ។ តែបញ្ហានេះអាចដោះស្រាយតាមរយះការកែលំអដំណើការផលិត ។ ហេតុដូច្នេះជីកំប៉ុស្តអាចនឹងមានទីផ្សារខាន ។

លទ្ធផលសាកល្បងដែលធ្វើឡើងនៅខេត្តស្វាយរៀង បានបង្ហាញថា ការប្រើប្រាស់ជីកំប៉ុស្តទីក្រុងបានជួយបង្កើនទិន្នផល ។ ក្រុមសិក្សាបានរៀបចំផលិតខ្សែវីដេអូអំពីដំណើរការនៃការធ្វើជីកំប៉ុស្ត និងការសាកល្បងនៅលើវាលស្រែ ។ នៅសិក្ខាសាលាលើកទីពីរក្រុមសិក្សាបានបង្ហាញនូវខ្សែវីដេអូ នោះជូនដល់អ្នកចូលរួមជាមួយនិងការធ្វើបទបង្ហាញពីជីកំប៉ុស្តដោយប្រើប៉ាណូដើម្បីបង្ហាញប្រសិទ្ធិភាពនៃការប្រើប្រាស់ជីកំប៉ុស្ត ។ ខ្សែវីដេអូក៏ត្រូវបានអនុញ្ញាតឱ្យអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានប្រើប្រាស់ដើម្បីកែលំអ និងបង្កើនទិន្នផល ។ ឆ្លងតាមការសំភាសន៍ជាមួយប្រជាពលរដ្ឋនៅទីនោះផ្ទាល់ ពួកគាត់បានគាំទ្រ និងកោតសរសើរចំពោះការប្រើប្រាស់ជីសរីរាង្គ ។ ប៉ុន្តែការផ្គត់ជីកំប៉ុស្តពុំទាន់មានស្ថេរភាពដូច្នេះការ ប្រើប្រាស់ជីគីមីនៅតែមានរិមាណច្រើនដ៏ដែល ។

លក្ខណៈនេះបង្ហាញថា កាលណាការផ្គត់ផ្គង់ជីមានស្ថេរភាពជាមួយនិងតំលៃសមរម្យ នោះតំរូវការទីផ្សារប្រាកដជាមាន ។ ចំពោះការសាកល្បងនៅលើវាលស្រែ ដើម្បីផលិតអោយបានស្រូវ ៣000គ.ក្រ នោះ គេត្រូវការជីគីមី ៥0គ.ក្រ និង១0,000គ.ក្រ នៃជីកំប៉ុស្តដែលជីគីមីមានតំលៃពី ៩00៛ ទៅ ១២00៛/គ.ក្រ រីឯជីកំប៉ុស្តមានតំលៃតែ ២00 ទៅ ៥00៛/គ.ក្រ ។ ដូច្នេះហើយដើម្បីផលិតបានទិន្នផលដូចគ្នានោះ ជីកំប៉ុស្តទទួលបានផលចំណេញពី ៤៥ទៅ ៨0ដងច្រើនជាង ។ ទោះបីជាថាជីគីមីផ្តល់ប្រសិទ្ធិភាពដល់ការបង្កើនគុណភាពដីក៏ដោយ ក៏ប៉ុន្តែបើតំលៃមិនចុះនៅត្រឹម១ភាគ១0នៃតំលៃបច្ចុប្បន្ននោះទេ នោះកសិករគ្មានជំរើសក្រៅពីការប្រើប្រាស់ជីគីមីឡើយ ។

COMPED លក់ជីកំប៉ុស្តក្នុងតំលៃ២00៛/គ.ក្រ ឱ្យទៅកសិដ្ឋាន និងកសិករជាច្រើនដែលធ្វើកសិកម្មនៅក្បែរៗក្រុងភ្នំពេញនៅពេលដែល CSARO លក់ក្នុងតំលៃ ៣៥0៛/គ.ក្រ សំរាប់សួនច្បារគេហដ្ឋាន និងថ្នាលបណ្តុះ ។ ទោះបីជាអង្គការទាំងពីរបំរើទីផ្សាខ្នាតតូចប៉ុន្តែសំរាប់តំរូវការបែបនេះគេលក់ចេញច្រើន ។ ហេតុដូច្នេះហើយទោះបីជាតំលៃជីកំប៉ុស្តពុំអាចប្រៀបធៀបបាននឹងជីគីមី ប៉ុន្តែសំរាប់ទិន្នផលអតិបរមានោះគេប្រាកដជាមាន សុទិដ្ឋិនិយម ។

## 4.6 ការអភិវឌ្ឍន៏ការគ្រប់គ្រងប្រព័ន្ធទិន្នន័យរបស់ រ.គ.ស.ភ

### 4.6.1 ចំនុចសំខាន់ៗនៃការអភិវឌ្ឍន៏

ក្រុមសិក្សាបានរៀបចំការគ្រប់គ្រងប្រព័ន្ធទិន្នន័យសំរាប់រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ ដែលបានបង្ហាញក្នុងតារាងខាងក្រោមនេះហើយធ្វើការបណ្តុះបណ្តាលដល់បុគ្គលិកទាំងអស់អំពីប្រតិបត្តិការណ៏នៃប្រព័ន្ធ នោះ ។

| ការអភិវឌ្ឍន៏ប្រព័ន្ធ | អធិប្បាយ |
|---|---|
| ១. ប្រព័ន្ធគ្រប់គ្រងការនាំសំរាមទៅទីលាន | អភិវឌ្ឍន៏ទិន្នន័យនៃជញ្ជីង និងប្រព័ន្ធដែលបូកសរុបទិន្នន័យ |
| ២. ប្រព័ន្ធគ្រប់គ្រងបញ្ជីអតិថិជន | ប្រព័ន្ធគ្រប់គ្រងបញ្ជីអតិថិជនបានប្រើប្រាស់នៅតំបន់ NIP ត្រូវបានកែលំអដែលអាចត្រូវបានប្រើប្រាស់នៅតំបន់ផ្សេងៗទៀតនោះរាប់បញ្ចូលទាំងទិន្នន័យអតិថិជននិងមុខងារសំរាប់បញ្ចេញវិក័យប័ត្រ ។ |
| ៣. ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីអតិថិជន | ប្រព័ន្ធនេះគ្រប់គ្រងព័តមានអ្នករើសសំរាមដែលធ្វើការនៅទីលាន និងធ្វើប័ណ្ណសំគាល់ខ្លួន |
| ៤. ការអភិវឌ្ឍន៏វែបសាយ | គេហទំព័រត្រូវបានរៀបចំនៅវែបសាយរបស់សាលាក្រុងភ្នំពេញអំពីការគ្រប់គ្រងកាកសំណល់រឹងនៅរាជធានីភ្នំពេញ ។ |

## 4.6.2 លទ្ធផលការសិក្សា

### a. ការត្រួតពិនិត្រសំរាមចូលទីលាន

បរិមាណដែលទទួលបានអំពីជញ្ជីងថ្លឹងនៅក្នុងដំណាក់កាលទីមួយនៃការសិក្សា បានបង្ហាញថាទីលានចាក់សំរាមស្ទឹងមានជ័យបានទទួលចំនួនរថយន្តប្រមាណ ១៦០គ្រឿងក្នុងមួយថ្ងៃស្មើនឹងប្រមាណ៧០០តោនសំរាម ។ តាមរយៈប្រព័ន្ធនេះគេអាចធ្វើការបូកសរុបឬបែងចែកទិន្នន័យជាប្រភេទក្រុមហ៊ុនដឹកសំរាមតំបន់ដែលបានជញ្ជូន និង ប្រភេទ សំរាម ហើយដែលការបញ្ចូលទិន្នន័យចាំបាច់ត្រូវបានរៀបចំឡើងសំរាប់ រ.គ.ស.ភ ។

### b. ប្រព័ន្ធប្រមូលថវិការ

រ.គ.ស.ភ បានប្រើប្រាស់ទិន្នន័យដែលបានរៀបចំឡើងដោយ អង្គការ NORAD ដែលហៅថា **ប្រព័ន្ធវិក័យប័ត្រប្រើប្រាស់សេវា** សំរាប់ការប្រមូលថវិកាពីថ្លៃសេវា ។ **ប្រព័ន្ធវិក័យប័ត្រប្រើប្រាស់សេវា** នេះបានប្រើប្រាស់នៅតំបន់ NIP អស់រយៈពេលប្រមាណពីរឆ្នាំមកហើយ។ដែល រ.គ.ស.ភ មានភាពស្ទាត់ជំនាញ ជាមួយប្រពន្ធ័នេះ ។ ប៉ុន្តែចំនុចលំបាកនោះគឺថាប្រពន្ធ័ត្រូវបានរៀបចំពីកម្មវិធីស្មុគ្រស្មាញដែលពុំមែនសំរាប់ការប្រើប្រាស់ទូទៅ ។ ដូច្នេះដើម្បីដំណើរការប្រព័ន្ធថ្មីអោយមានភាពរលូននោះ គេទាមទារពេលវេលាច្រើនដែលក្នុងរយៈពេលសិក្សានេះពុំអាចធ្វើបានច្រើន ។ ដូច្នេះហើយបានជាក្នុងគំរោងសាកល្បងការប្រមូលសំរាម ក្រុមសិក្សាបានធ្វើការកែសំរួល **ប្រព័ន្ធវិក័យបត្រ័ប្រើប្រាស់សេវា** នេះសំរាប់ការប្រើប្រាស់ក្នុងការសាកល្បងដ៏ទៃទៀតនៅ គង្គាផុស ភូមិ ១៤ និងសង្កាត់ទាំងបួន ។ បច្ចុប្បន្ននេះ រ.គ.ស.ភ មាន បញ្ជីឈ្មោះអតិថិជន ក្នុងតំបន់សាកល្បង ហើយបុគ្គលិកពីរនាក់ជាអ្នកគ្រប់គ្រងការចេញវិក័យប័ត្រ និងវិក័យប័ត្រ ។ គេក៏បានរៀបចំផង ដែរអំពីប្រព័ន្ធសំរាប់ទទួលការយល់ដឹងតំលៃ ដែលនឹងអាចទទួលបាននឹងតំលៃពីការផ្តល់សេវាកម្មពិតប្រាកដ ។

ទោះបីយ៉ាងណាក្តី ប្រព័ន្ធដែលរៀបចំសំរាប់គ្របដណ្តប់លើចំនួនអតិថិជនច្រើននាតំបន់របស់រដ្ឋាករ និងមាន មានបញ្ហាខ្លះ ៗ ដូចតទៅ :

១- ការកែសំរួលប្រព័ន្ធនេះអាចធ្វើបានចំពោះតែវិស្វករដែលមានជំនាញលើ Clarion software ប៉ុណ្ណោះ ដែលគេមិនអាចធ្វើការកែលំអរទូទាំងប្រទេសទេ ។

២- USB មិនអាចប្រើលើ network បានទេ ។ ដូច្នេះ គេមិនអាចធ្វើជំរឿន ឬបញ្ចេញវិក័យបត្រពេលមានបរិមាណច្រើននាពេលអនាគតទេ ។

៣- ព្រោះថា ទិន្នន័យមិនអាចបញ្ចេញមកក្រៅ ដូច្នេះ គេក៏មិនអាចធ្វើរបាយការណ៏បានក្រៅពីទិន្នន័យបញ្ចេញដោយ USB ទេ ។ ជាងនេះទៀត គេមិនអាចចែករំលែកទិន្នន័យជាមួយសង្កាត់បានទេនាពេលអនាគត ។

ប្រសិនបើរដ្ឋាករត្រូវពង្រីកសេវាទៅដល់តំបន់ដែលមិនមានសេវាកម្មនាខណ្ឌជនបទទាំងបីនោះ គេត្រូវរៀបចំប្រព័ន្ធទិន្នន័យមួយដែលអាចប្រើបានទូ ទាំងប្រទេស ។

### c. ប្រព័ន្ធគ្រប់គ្រងការចុះបញ្ជីអ្នករើសំរាម

ជាងនេះទៀតដើម្បីជាការកែលំអទីលានចាក់សំរាមស្ទឹងមានជ័យ ក្រុមសិក្សាបានណែនាំប្រព័ន្ធនៃការចុះបញ្ជីអ្នករើសសំរាមហើយនឹងបានចុះបញ្ជីសរុប ២៩០៧ នាក់ ។ តាមរយៈពិតមានទទួលបាននេះ គេអាចយល់ដឹងអំពីអ្នករើសសំរាមរួមមាន ចំនួនខ្នងផ្ទះ អាយុ ចំនួនអ្នករើសសំរាមពីតំបន់ផ្សេង ។ល។ ដើម្បីពង្រីកប្រព័ន្ធ រ.គ.ស.ភ ពិតមានអាចត្រូវបានប្រើប្រាស់សំរាប់រៀបចំក្រុមអ្នករើសសំរាមអោយទៅជាអ្នកសំអាត ឬជាក្រុមជួយខ្លួនឯង ។

### d. ការរៀបចំគេហទំព័រ

គេហទំព័រស្តីពីការគ្រប់គ្រងសំណល់រឹងត្រូវបានបង្កើតក្នុងវែបសាយរបស់សាលាក្រុងភ្នំពេញ ដែលអ្នកសិក្សាស្រាវជ្រាវអាចផ្តល់អនុសាសន៏ ឬមតិយោបល់នៅក្នុងនោះ ។ តាមរយៈការជូនពិតមានជាចំហរស្តីពីការគ្រប់គ្រងសំណល់រឹងជូនដល់សាធារណៈជន និងការទទួលបាននូវយោបល់ផ្សេងៗពីប្រជាជនវិញ គេហទំព័រនេះត្រូវបានគេសង្ឃឹមថានឹងមានផលប្រយោជន៏ក្នុងការបង្កើតប្រព័ន្ធគ្រប់គ្រងសំណល់រឹងមួយតាមរយៈការចូលរួមពីមហាជន ។

# 5 ការកសាងសមត្ថភាព

## 5.1 គោលបំណងនិងវិធីសាស្ត្រ

### 5.1.1 គោលបំណង

ដើម្បីអនុវត្តផែនការមេនេះអោយមានប្រសិទ្ធភាព គេចាំបាច់ត្រូវការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ (ICB) ដល់មន្ត្រីនៃមន្ទីរសាធារណការ និងដឹកជញ្ជូន រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ និងមន្ទីរបរិស្ថាន ។ ដូចគ្នាផង ដែរក្រុមសិក្សា JICA ក៏បានអនុវត្តការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធដែលបានបកស្រាយខាងលើ ដូចខាងក្រោម នេះ ។

### 5.1.2 វិធីសាស្ត្រ

ប្រព័ន្ធនៃការគ្រប់គ្រងកាកសំណល់រឹងនៅរាជធានីភ្នំពេញត្រូវបានបែងចែកទៅជាមូលដ្ឋាន២ គឺប្រព័ន្ធនៃការប្រមូលសំរាម( រាប់បញ្ចូលទាំងការសំអាតផ្លូវសាធារណៈ) និងការចាក់ចោលនៅទីលាន ។ ប្រព័ន្ធនៃការគ្រប់គ្រងរឹងនៅរាជធានី ភ្នំពេញត្រូវបានអនុវតដោយមន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីបរិស្ថាន និងរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ ។ ប៉ុន្តែភាគច្រើននៃសេវាកម្មប្រមូលសំរាមនិងការសំអាតផ្លូវ និងការប្រមូលថ្លៃសេវាកម្មត្រូវបានធ្វើឡើងដោយក្រុមហ៊ុនឯកជនតែមួយប៉ុណ្ណោះ ។ ដើម្បីពង្រឹងការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធនៃ ស.ក.ភ.ព មន្ទីរបរិស្ថាន និង រដ្ឋាករ គ្រប់គ្រងសំណល់រាជធានីភ្នំពេញ ក្រុមសិក្សា JICA បានអនុវត្តកម្មវិធីដូចខាងក្រោម ៖

១- **ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ (ICB) តាមរយៈការអនុវត្តគំរោងសាកល្បង** (PPs)៖
ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលក្នុងពេលអនុវត្តការងារ តាមរយៈការអនុវត្តផ្ទាល់នូវសេវាកម្មនៃការគ្រប់គ្រងកាកសំណល់រឹង នៅរាជធានីភ្នំពេញក្រុមសិក្សាបានរៀបចំការកែលំអប្រព័ន្ធនៃការប្រមូលសំរាមនិងការចាក់ចោលនៅទីលាន និងការអប់រំសាធារណ ដោយសហការជាមួយស្ថាប័នជាដៃគូរ ។

២- **ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ (ICB) តាមរយៈសិក្ខាសាលាជាដើម** ៖ ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ (ICB) តាមរយៈការពន្យល់នៅក្នុងអង្គប្រជុំអំពីរបាយការណ៍នានា ការប្រជុំប្រចាំសប្តាហ៍ និងវគ្គបណ្តុះបណ្តាលដល់ស្ថាប័នជាដៃគូ ។

## 5.2 កសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធតាមរយៈការអនុវត្តន៍គំរោងសាកល្បង

### 5.2.1 ការកែលំអទីលានចាក់សំរាមស្ទឹងមានជ័យ

#### a. ចំណុចសំខាន់នៃការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ

ការរៀបចំផែនការសំរាប់ការកែលំអទីលានចាក់សំរាមស្ទឹងមានជ័យបានធ្វើឡើងក្នុងខែ មេសា ឆ្នាំ ២០០៣ ហើយបានបញ្ចប់ជាស្ថាពរក្នុងខែវិច្ឆិកា ឆ្នាំ២០០៤ ។ តាមរយៈគំរោងសាកល្បងនេះការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធត្រូវបានគេធ្វើឡើងសំរាប់ផែនការប្រត្តិបត្តិការណ៍ និងការងារគ្រប់គ្រងនៃប្រព័ន្ធចាក់សំរាមនៅទីលានដូចដែលបានបង្ហាញក្នុងតារាងខាងក្រោម ។

Table 5-1: ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធតាមរយៈគំរោងសាកល្បងដើម្បីកែលំអទីលាន

| ប្រភេទ | ការងារ | អធិប្បាយ |
|---|---|---|
| ការធ្វើផែនការ | កំណែទំរង់ផែនការកែលំអរ | - បានផ្តល់វគ្គបណ្តុះបណ្តាលវិធីសាស្ត្រធ្វើផែនកាតាមរយៈការប្រជុំសប្តាហ៍ |
| | ការរៀបចំសំរាប់ការអនុវត្តនៃផែនការកែលំអរ | - បានផ្តល់ការធ្វើការចចារដើម្បីធានាអោយមានដីពង្រីកសំរាប់ទីលាន<br>- បទបញ្ជាទៅទីលានចាស់ត្រូវបានរៀបចំ និងអនុវត្តន<br>- កិច្ចសន្យាប្រត្តិបត្តការណទីលានត្រូវបានកែលំអរ<br>- បានផ្តល់ការត្រួតពិនិត្យការងារសាងសង់<br>- បានណែនាំការចុះបញ្ជីអ្នករើសសំរាម |
| ប្រតិបត្តិការណ៍ | កំណែទំរង់ផែនការកែលំអរ | - បានផ្តល់វគ្គបណ្តុះបណ្តាលវិធីសាស្ត្រធ្វើផែនកាតាមរយៈការប្រជុំសប្តាហ៍ |
| | ការអនុវត្តផែនការ | - បានរៀបចំផែនការប្រតិបត្តិការណ៍ចាក់ដីប្រចាំថ្ងៃ<br>- រៀបចំប្រព័ន្ធតាមដាន និងត្រួតពិនិត្រទឹកសំអុយ<br>- ផ្តល់ការណែនាំដល់អ្នកបើកបររថយន្តសំរាម អ្នកគ្រប់គ្រងគ្រឿងចក្រ និងអ្នករើសសំរាមទៅលើទីតាំងការងារ និងការពង្រឹងបទបញ្ជា |
| ការគ្រប់គ្រង | ត្រួតពិនិត្យសំរាមចូល | - បានពិនិត្យនិងគ្រប់គ្រងរថយន្តនិងសំរាមចូល<br>- បានថ្លឹងរថយន្តសំរាមនិងបញ្ចូលទិន្នន័យសំរាម<br>- អនុវត្តនិងថែទាំផ្លូវក្នុងទីលាន |
| | ត្រួតពិនិត្យការងារប្រតិបត្តិការណ៍ | - ត្រួតពិនិត្យអ្នករើសសំរាម<br>- ប្រតិបត្តការណ៍និងការថែទាំទីកន្លែងការងារ |

## b. លទ្ធផល និងបញ្ហា

### b.1 លទ្ធផល

ទិន្នផលចំបងគឺរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ បានបង្កើតប្រព័ន្ធគ្រប់គ្រង ( ប្រតិបត្តិការណ៍ និងការថែទាំតំបន់ដែលត្រូវចាក់សំរាម រៀបចំប្រព័ន្ធតាមដាន និងត្រួតពិនិត្រទឹកសំអុយ កំណត់ព្រំប្រទល់ទីលាន ចុះបញ្ជី និងពិនិត្យក្រុមអ្នករើសសំរាម ។ល ។) អោយសមស្រប ទៅនឹងស្ថានភាពទីលានស្ទឹងមានជ័យដែលមុនពេលគំរោងសាកល្បងទីលាននេះគ្រាន់តែជាទីលានចំហរសាមញ្ញតែ ប៉ុណ្ណោះដោយគ្មានបទបញ្ជា និងការគ្រប់គ្រង ។ ស្របពេលនោះដែររដ្ឋាករបានសំរេចបញ្ឈប់កិច្ចសន្យារបស់អ្នកប្រត្តិបត្តការណចាស់ចោលដោយសារថា គេមិនបានគោរពតាមការណែនាំ ។

ជាងនេះទៀតក្រុមសិក្សាបានបង្កើតប្រព័ន្ធត្រួតពិនិត្យសំរាម និង រថយន្តសំរាមដែលចូលមកទីលានដោយតំលើងជញ្ជីងថ្លឹង ។ ដូច្នេះគេបានកត់ត្រាបរិមាណសំរាម និងប្រភពសំរាមបានយ៉ាងប្រាកដ ប្រព័ន្ធនៃការគ្រប់គ្រងក៏ត្រូវបានពង្រីកតាមលក្ខណៈរូបសាស្ត្រ ។ ចំនួនបុគ្គលិករបស់រដ្ឋាករគ្រប់គ្រង សំណល់រាជធានីភ្នំពេញបានបង្កើនពីម្នាក់មុនពេលគំរោងសាកល្បងរហូតដល់បួននាក់ ។ លើសពីនេះទៀត អភិបាលរងម្នាក់ក្នុងចំណោមអភិបាលរងពីរនាក់ត្រូវបានចាត់ចែងអោយទទួលការខុសត្រូវនៃប្រតិបត្តិការណ៍ទីលាន ។ រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញក៏បានចាត់ចែងបុគ្គលិកម្នាក់ទៀតអោយគ្រប់គ្រងទិន្នន័យពីជញ្ជីងនៅការិយាល័យទីលានជាប្រចាំ ។

**b.2** បញ្ហានានា

ទោះបីជាប្រព័ន្ធគ្រប់គ្រងដែលត្រូវបានបង្កើតឡើងដោយរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញទៅតាមក៏រិតមួយក៏ដោយ គេត្រូវការចាំបាច់ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ បន្ថែមដូចខាងក្រោមដើម្បីអោយមានប្រព័ន្ធចាក់ចោលសំណល់មួយដ៏ត្រឹមត្រូវ :

១- ការកសាងសមត្ថភាពបន្ថែមចំពោះបុគ្គលិកដើម្បីបង្កើតប្រព័ន្ធចាក់សំរាមចោលត្រឹមត្រូវមួយ ការចុះបញ្ជីអ្នករើស សំរាម និងការគ្រប់គ្រងបរិស្ថាន ។

២- ការពង្រឹងប្រព័ន្ធប្រតិបត្តិការណ៍ និងថែទាំគ្រឿងចក្រ និងរថយន្តដើម្បីធានាអោយបានការចាក់សំរាមត្រឹមត្រូវមួយ ។

៣- ការពង្រឹងប្រព័ន្ធត្រួតពិនិត្យបរិស្ថាន ដូចជាការត្រួតពិនិត្យទឹកសំអុយចេញពីសំរាម ។

## 5.2.2 ការកែលំអប្រព័ន្ធប្រមូលសំរាម

### a. ចំណុចសំខាន់ៗនៃការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ

គោលដៅចំបង គឺត្រូវបានរៀបចំឡើងដើម្បីលុបបំបាត់ចោលនូវតំបន់ទាំងឡាយដែលពុំមានសេវាកម្មប្រមូលសំរាម ឬក៏សេវាកម្មដែលពុំមានលក្ខណៈសមស្របនៅក្នុងរាជធានីភ្នំពេញ នៅក្នុងតំណាក់កាលទីពីរនៃការសិក្សា ។ ការធ្វើផែនការចាប់ផ្តើមឡើងនៅក្នុង ខែឧសភា ឆ្នាំ២០០៣ ។ ក្រុមសិក្សា JICA និងរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញបាននឹងកំពុងអនុវត្តគំរោងការសាកល្បងលើការងារពង្រីកសេវាកម្មប្រមូលសំណល់នាសង្កាត់ទាំងបួនដោយប្រើប្រាស់គ្រឿងចក្រដែលមានស្រាប់ ។ ការងារនោះមានរាប់បញ្ចូលតាំងពីការចុះស្រង់ស្ថិតិអតិថិជន ការផ្តល់សេវាកម្ម និងការប្រមូលថវិកា ។ ដូច្នេះហើយ បច្ចុប្បន្ន រដ្ឋាករកំពុងបន្តការងារនេះ ។

Table 5-2: ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធតាមរយៈគំរោងសាកល្បងដើម្បីកែលំអប្រព័ន្ធប្រមូលសំរាម

| ប្រភេទ | ការងារ | អធិប្បាយ |
|---|---|---|
| ផែនការ | កំណែទំរង់នៃគំរោងកែលំអរ | - បណ្តុះបណ្តាលលើវិធីសាស្ត្រធ្វើផែនការតាមរយៈការប្រជុំសប្តាហ៍<br>- ការប្រជុំជាសាធារណត្រូវបានធ្វើឡើង និងកំណែទំរង់ផែនការកែលំអរដែលឆ្លុះបញ្ចាំងនូវ សំណើរនិងមតិនៃមហាជន |
| | រៀបចំសំរាប់អនុវត្តន៍ផែនការកែលំអ | - កម្មករប្រមូលសំរាបបឋមត្រូវបានរៀបចំជាមួយនឹងការចរចាលើកិច្ចសន្យាការងារ<br>- បានធ្វើការចរចារជាមួយសង្កាត់<br>- បានធ្វើការចុះបញ្ជីនិងត្រួតពិនិត្យអតិថិជន<br>- បានធ្វើកិច្ចព្រមព្រៀងផ្តល់សេវាកម្មជាមួយអតិថិជន<br>- យុទ្ធនាការអប់រំសាធារណត្រូវបានរៀបចំ និងអនុវត្ត |
| ប្រតិបត្តិការណ៍ | កំណែទំរង់ផែនការប្រតិបត្តិការណ៍ | - បណ្តុះបណ្តាលលើវិធីសាស្ត្រធ្វើផែនការតាមរយៈការប្រជុំប្រចាំសប្តាហ៍<br>- រៀបចំ និងពន្យល់ពីប្រត្តិបត្តកាពេលមានភាពងាសន្ន ដោយមានផ្តល់ជាខិតបណ្ណ |
| | ការអនុវត្តន៍ផែនការប្រតិបត្តិការណ៍ | - រៀបចំផែនទីនៃខ្សែប្រមូលសំរាប់សរថយន្តនិង កម្មករ |

| ប្រភេទ | ការងារ | អធិប្បាយ |
|---|---|---|
| | | - ផ្តល់ការណែនាំដល់អ្នកបើកបរនិងកម្មករ<br>- ផ្តល់ការពន្យល់ពីផ្លូវរត់ និងប្រតិបត្តិការដោយផ្ទាល់ដល់អ្នកបើកបរ និងកម្មករ<br>- ការប្រមូលនិងគ្រប់គ្រងតំលៃសេវា |
| ការគ្រប់គ្រង | ការគ្រប់គ្រងអតិថិជន<br>(អ្នកទទួលផលអំពីសេវាកម្ម) | - បង្កើតក្រុមទំនាក់ទំនងអតិថិជន និងផ្តល់វគ្គបណ្តុះបណ្តាល<br>- ចុះ និងគ្រប់គ្រងនៃកិច្ចសន្យាសេវាកម្ម<br>- ដោះស្រាយបណ្តឹងសាធារណ<br>- រៀបចំនិងបន្តកែសំរួលបញ្ជីអតិថិជន |
| | ធ្វើប្រតិបត្តិការណ៍ និងការគ្រប់គ្រង | - ប្រតិបត្តិការណ៍និងថែរក្សារថយន្តនិងធុងសំរាម<br>- ប្រតិបត្តិការណ៍និងថែរក្សាការទុកដាក់ធុងសំរាម<br>- ត្រួតពិនិត្យកម្មករប្រមូលតាមរទេះរុញ |

## b. ទិន្នផល និងបញ្ហា

### b.1 ទិន្នផល

ទិន្នផលសំខាន់ គឺប្រព័ន្ធប្រមូលថ្លៃសេវាដ៏ចាំបាច់មួយ ពីអ្នកប្រើប្រាស់ទាំងឡាយត្រូវបានបង្កើតឡើងទៅតាមកំរិតសមស្របមួយ ។ នោះគឺរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ បានធ្វើកិច្ចសន្យាជាមួយអតិថិជន និងចេញវិក័យប័ត្រ ហើយអាជ្ញាធរសង្កាត់ជាអ្នកប្រមូលថ្លៃសេវា ។ ជាងនេះទៀតសេវាកម្មប្រមូលសំរាមដោយរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញដែលជាអាទិភាពសំរាប់ការអនុវត្តទីគំរោងសាកល្បងគ្រាន់តែជាការប្រមូល និងចាក់សំរាមនៅទីលានយ៉ាងសាមញ្ញបំផុត និងការបង្កើនគុណភាពសេវាតែក្រោយមកត្រូវបានពង្រីកទៅរកគុណភាពនៃសេវាកម្មដែលសព្វថ្ងៃនេះរដ្ឋាករគ្រប់គ្រងសំណល់រាជធានី ភ្នំពេញត្រូវដោះស្រាយរាល់ការទាមទារ ឬតវ៉ារបស់អតិថិជន ប្រតិបត្តិការណ៍និងការថែទាំកន្លែងដាក់ធុងសំរាម ការគ្រប់គ្រងការងារប្រមូលតាមរទេះ ។ល។ អ្នកបើកបររថយន្តរបស់រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ និងកម្មករ ប្រមូលសំរាមក៏ត្រូវថែទាំរថយន្ត និងគ្រឿងចក្រដែលពីមុនមកកម្រនឹងអនុវត្តនោះគឺពួកគេត្រូវពិនិត្យគ្រឿងចក្រ មុនពេលចាប់ផ្តើមការងារលាងរថយន្ត និងធុងសំរាម ។ល។

### b.2 បញ្ហាទាំងឡាយ

ទោះបីជាប្រព័ន្ធគ្រប់គ្រងត្រូវបានបង្កើតនូវក្នុងកំរិតមួយក៏ដោយ ដើម្បីអភិវឌ្ឍន៍ប្រព័ន្ធប្រមូលសំរាមមួយដែលនឹងលុបបំបាត់តំបន់គ្មានសេវាកម្ម ឬក៏សេវាកម្មមិនគ្រប់គ្រាន់ នោះការ កសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធត្រូវការចំណុចបន្ថែមនានាដូចខាងក្រោម :

១. ការកសាងសមត្ថភាពបន្ថែមនៃបុគ្គលិករបស់រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ ដើម្បីឱ្យយល់ពីការ ពង្រីកសេវាកម្មប្រមូលសំរាមដូចដែលស្នើឡើងនៅក្នុងផែនការមេ ។

២. ត្រូវការចាំបាច់ការពង្រឹងទំនាក់ទំនងជាមន្ត្រីពាក់ព័ន្ធដូចជាសង្កាត់និងកម្មករប្រមូលបឋម សំរាប់ការពង្រីកសេវាកម្មប្រមូលគឺគេត្រូវពង្រីកនិងពង្រឹងទំនាក់ទំនងក្នុងចំណោម រ.គ.ស.ភ មន្ទីរបរិស្ថាន សង្កាត់ និង ប្រជាពលរដ្ឋដើម្បីអនុវត្តការប្រមូលថ្លៃសេវាសំរង់បញ្ជីអតិថិជនហើយនឹងត្រួតពិនិត្យសេវាកម្មប្រមូលសំរាម ។

៣. បង្កើតកិច្ចសហការជាមួយប្រជាពលរដ្ឋ អតិថិជនដើម្បីការពារការរាយប៉ាយនៃសំរាម ប្រតិបត្តិការណ៍ និង ការថែទាំ ទីតាំងដាក់ធុងសំរាមទាំងឡាយ និងលុបបំបាត់ការប្រើប្រាស់ដោយមិនបង់ថ្លៃសេវា ។

៤. រៀបចំជាបន្ទាន់នូវសំភារះសំរាប់ថែទាំគ្រឿងចក្រ ។

## 5.2.3 យុទ្ធនាការអប់រំសាធារណៈ

### a. ចំណុចសំខាន់ៗនៃការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ

ដូចដែលបានបញ្ជាក់នៅក្នុងផ្នែកនៃគំរោងសាកល្បង មន្ទីរបរិស្ថានមានតួនាទីផ្តល់ និងបង្កើនការយល់ដឹងជាសាធារណៈ និងជំរុញការចូលរួមពីមហាជនដែលពីមុនមកមិនធ្លាប់មានបទពិសោធនទេ គឺគ្រាន់តែធ្វើតាមបែបដឹកនាំចលនាការងារជាសាធារណៈ ។ តាមទំលាប់នោះគឺថា មន្ទីរបរិស្ថានបានបង្កអោយមានការសំអាតតែម្តង តែមិនបានអប់រំប្រជាពលរដ្ឋអំពីរបៀបនៃការចាក់សំរាម ឬការរៀបចំប្រព័ន្ធអប់រំ និងកែលំអរប្រពន្ធ័ប្រមូលសំរាមទេ ។ ជាលទ្ធផលការអប់រំបានបញ្ចប់ដោយពុំទទួលបានផ្លែផ្កាទេ ។

តាមរយះគំរោងការសាកល្បង មន្ទីរបរិស្ថានត្រូវបានរំពឹងថានឹងទទួលបានចំណេះដឹង និងបទពិសោធនដើម្បីដោះស្រាយបញ្ហាទាំងនេះដូចជា ភាពរាយប៉ាយសំណល់ និងក្លិនដោយគ្រាន់តែប្រើប្រាស់បទបញ្ជាអប់រំសាមញ្ញ ។

Table 5-3: ការកសាងសមត្ថភាពតាមរយះគំរោងសាកល្បងលើការអប់រំសាធារណៈ

| ប្រភេទ | ការងារ | អធិប្បាយ |
|---|---|---|
| ផែនការ | កែទំរង់មូលដ្ឋានយុទ្ធសាស្ត្រ និងផែនកា | - សិក្សាពីមូលដ្ឋាននៃបញ្ហា និងការវិភាគបញ្ហា<br>- ជួបជុំអ្នកទទួលផល និងពិភាក្សារកចំនុចរួម<br>-កំនត់យុទ្ធសាស្ត្រជាមូលដ្ឋានដោយសហការណជាមួយអ្នកទទយលផលដទៃទៀត (ដោយកំនត់អោយបានច្បាស់នូវតួនាទី និងការ ទទួលខុសត្រូវ) ។<br>-កែទំរង់បទដ្ឋានចាក់សំនល់ ដោយយោងលើភាពសមស្របពីការអនុវត្តការប្រមូលសំនល់នាពេលបច្ចុប្បន្ន |
| | រៀនចំសំរាប់អនុវត្តផែនកា | -រៀបចំសំភារះងប់រំដោយសហការជាមួយអជ្ញាធរ និងអ្នកប្រ មូលសំនល់<br>- ចែកចាយព័តមាន<br>- ផ្តល់ការណែនាំលើការទុកដាក់សំរាមដល់អតិថិជន និងអជ្ញាធរ<br>- ផ្តល់ការណែនាំដល់អ្នកផ្តល់សេវាកម្មបើចាំបាច់ |
| អនុវត្តដោយផ្ទាល់ | អនុវត្តបទដ្ឋានចាក់សំណល់ | - ត្រួតពិនិត្រចរិកអតិថិជន និងអ្នកឆ្លងកាត់តំបន់<br>- ត្រួតពិនិត្រអ្នកផ្តល់សេវាកម្មប្រមូលសំនល់<br>- ផ្តល់ការណែនាំដល់អ្នកផ្តល់សេវាកម្មបើចាំបាច់<br>- ធ្វើកាកែលំអរបទដ្ឋានបើចាំបាច់ |

### b. ទិន្នផល និងបញ្ហាដែលត្រូវដោះស្រាយ

#### b.1 ទិន្នផល

តាមរយៈគំរោងសាកល្បង មន្ទីរបរិស្ថានបានទទួល និងយល់ដឹងអំពីសារសំខាន់នៃបទដ្ឋានចាក់សំរាម ទោះបីជាថាបទដ្ឋានដែលបានប្រើប្រាស់សំរាប់គំរោងសាកល្បងនោះមានលក្ខណមិនគ្រប់គ្រាន់ក្តី ។ មន្ទីរបានទទួលនូវបទពិសោធនដើម្បីកែលំអរបទដ្ឋានចាក់សំនល់តាមបែបសាមញ្ញដោយសហការជាមួយអ្នកទទួលផលនានា ផ្តល់ការចែកចាយព័តមានណែនាំប្រជាពលរដ្ឋ និងអាជីវកម្ម ។

មន្ទីរបានចាប់ផ្តើមគំរោងប្រហាក់ប្រហែលគ្នានេះនៅតាមតំបន់នានាក្នុងក្រុងភ្នំពេញ ដោយមានការគាំទ្រផ្នែកថវិកាពីធនាគារអភិវឌ្ឍអាស៊ី និង UNDP ។ ព្រមជាមួយគ្នា មន្ទីរបានទទួលថវិការគាំទ្រពីកម្មវិធី SEILA ផងដែរដើម្បីពង្រីកបទដ្ឋានចាក់សំនល់ ។

## b.2 បញ្ហាដែលត្រូវដោះស្រាយ

### (១) បន្តសហការជាមួយអជ្ញាធរតាមតំបន់ និងអ្នកផ្តល់សេវាកម្ម

វាជាកាកត្តាបន្ទាន់សំរាប់មន្ទីរក្នុងការពង្រីកការយល់ដឹងលើការចាក់សំណល់នាទូទាំងរាជធានី ។ ប៉ុន្តែថវិកា និងធនធនាមនុស្សរបស់មន្ទីរមានក៏រិតនៅឡើយ ហើយការដែលពង្រីកដោយខ្លួនឯងនោះពិតជានៅមានការលំបាក ។ តែការសហការជិតស្និតជាមួយអជ្ញាធរវាជាការចាំបាច់បំផុតសំរាប់ភាពជោគជ័យ ។ មន្ត្រីរបស់មន្ទីរដែលទទួលបន្ទុកការងារតាមខណ្ឌនីមួយ ៗ នឹងមានតួនាទីសំខាន់ក្នុងការពង្រីកសេវាកម្មទូទាំងរាជធានី ។ ជាងនេះទៀត គំរោងសាកល្បងបង្ហាញថា ការយល់ដឹងជាសាធារណ ចូលរួមជួយអោយការប្រមូលសំរាមកាន់តែមានប្រសិទ្ធភាពមួយក៏រិតទៀត ។ មុនពេលគំរោងសាកល្បង គេសង្កេតឃើញមានការសហការការងារតិចតួចរវាងស៊ីនទ្រី និងមន្ទីរ ។ តែនៅពេលដែលពួកគេចាប់ផ្តើមពិភាក្សាលើបទដ្ឋានចាក់សំរាម នោះក្រុមហ៊ុន ស៊ីនទ្រីបង្កអោយមានភាពសហការជាបន្ត ។ យកល្អ សាលាក្រុងគួរតែកំនត់អោយច្បាស់ពីអ្នកប្រមូលសំរាមដល់អតិថិជន ក្នុងពេលធ្វើការអប់រំជាសាធារណ ។

### (២) ផ្តល់ព័តមានទៅទូទាំងរាជធានីភ្នំពេញ

លទ្ធផលពីគំរោងសាកល្បងបង្ហាញថា វាមិនមែនជាការពិបាកទេដែលថាប្រជាជនមិនចង់ចូលរួមក្នុងការអនុវត្តន៏បទដ្ឋានចាក់សំណល់នោះ តែវាជាកាលំបាកបំផុតក្នុងការគ្រប់គ្រងការចាក់សំណល់ដោយអ្នកជិតខាង និងអ្នកដែលយកសំណល់តាមរទេះមកចាក់នៅទីតាំងនោះ ។ ដំណោះស្រាយចាំបាច់គឺថា មន្ទីរត្រូវតែធ្វើការផ្សព្វផ្សាយអោយទូលំទូលាយទៀតតាមរយៈទូរទស្សន៏ និងបណ្តាព័តមានដ៏ទៃទៀតអោយដល់ស្រទាប់មហាជននាទូទាំងរាជធានីភ្នំពេញ ។

### (៣) ភាពចាំបាច់សំរាប់បន្តកាអប់រំជាសាធារណ

ដូចដែលបានបពាជាក់ខាងលើស្រាប់ថា បទដ្ឋានដែលបានរៀបចំសំរាប់គំរោងសាកល្បងនោះ វាគ្រាន់តែជាការអប់រំសំរាប់សហគមន៏តូច ៗ ប៉ុណ្ណោះ ។ បច្ចុប្បន្ន ប្រជាជនព្យាយាមសំអាតផ្ទះផងខ្លួន និងជុំវិញ តែពួកគាត់មិនចងចូលរួមសំអាតទីកន្លែងសាធារណទេ ។ ជាលទ្ធផល ប្រព័ន្ធប្រមូលតាមសហគមន៏បែបនេះមិនអាចធានាភាពស្អាតបានទេព្រោះថាមិនមានការធានាការបោះសំរាមចូលក្នុងធុងដែលបានបង្កអោយមានភាពរាយប៉ាយ ។ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅជិតបំផុតទៅនិងធុងដាក់សំរាម មានការតវ៉ាយឡាងតឹងតែងមិនអោយដាក់ធុងក្បែរផ្ទះរបស់ពួកគេ ទោះបីថា ប្រព័ន្ធប្រមូលបែបនេះមានតំលៃថោកក្តី ។ តាមរយៈនេះ គេនឹងអាចប្រើប្រាស់ប្រព័ន្ធប្រមូលផ្សេង ៗទៀតព្រមជាមួយនិងបទដ្ឋានដែលមានភាពលំអិតបន្ថែមទៀត ដែលនេះជាបន្ទុករបស់បន្ទីរបរិស្ថានត្រូវបន្តការអប់រំសាធារណ។

## 5.2.4 ការបង្កើតប្រព័ន្ធត្រួតពិនិត្រជាប្រចាំ (ក្រោមគំរោងសាកល្បងនៃការកែលំអរទីលានស្ទឹងមានជ័យ)

មុនគំរោងសាកល្បងការកែលំអរទីលានចាស់នេះ ក្រសួងបរិស្ថាន និងមន្ទីរបរិស្ថានមិនដែលធ្វើការត្រួតពិនិត្របរិស្ថានទីលានទេ ។ ការត្រួតពិនិត្រដោយទៀងទាត់ដោយស្ថាប័នណាមួយពិតប្រាកដ វាជាការចាំបាច់ណាស់សំរាប់ការត្រួតពិនិត្រការបំពុល ។

ជាងនេះទៀត សំរាប់ការអភិវឌ្ឍន៍ទីលានដង្កោ ក្រុមសិក្សាបានផ្តល់អនុសាសន៍ថាត្រូវបង្កើតគណកម្មកាត្រួតពិនិត្រការងារប្រត្តិបត្តការរបស់រដ្ឋាករ ។ ដើម្បីធានាអោយបានការត្រួតពិនិត្រសមស្របដោយគណកម្មការនោះ ក្រសួង និងមន្ទីរបរិស្ថានត្រូវរៀបចំប្រព័ន្ធត្រួតពិនិត្រមួយអោយទៀងទាត់ និងសមស្រប ។ ដូច្នេះហើយ តាមរយះគំរោងសាកល្បងនៅទីលានចាស់ ក្រុមសិក្សាបានសំរេចគាំទ្រដល់ក្រសួង និងមន្ទីរអោយត្រួតពិនិត្របរិស្ថានទីលានជាប្រចាំ ។

ដោយសារកង្វះខាតថវិការ ក្រសួង និងមន្ទីរស្ទើរតែមិនអាចត្រួតពិនិត្រការងារបានតាមផែនការ ។ ដូច្នេះហើយ ក្រុមសិក្សាបានដកចេញការងារខ្លះដែលក្រសួង និងមន្ទីរមិនមានលទ្ធភាពធ្វើ ។ ទោះបីថា ប្រព័ន្ធថ្មីដែលរៀបចំនោះមានលក្ខណធម្មតាមិនស្មុគស្មាញ តែក្រសួង និងមន្ទីរនឹងអាចទទួលបានការយល់ដឹង និងបទពិសោធន៍តាមរយះគំរោងសាកល្បងនេះ ដោយរួមមានការងារជាច្រើនដូចជា ការរើសសំណាក វិភាគ រៀបចំទិន្នន័យ និងវិភាគ ទិន្នន័យ ។ល។

## 5.3 ការកសាងសមត្ថភាពតាមរយះសិក្ខារសាលា ជាដើម...

សូមពិនិត្រលំអិតក្នុងតារាងខាងក្រោម ។

Table 5-4 ការកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធតាមរយ:ការធ្វើសិក្ខាសាលា

| ការងារ | ការងារបន្ទាប់ | រយ:ពេល | មាតិកាសិក្សា | អ្នកចូលរួម |
|---|---|---|---|---|
| **វគ្គបណ្តុះបណ្តាលស្ថាប័នដៃគូរ** | វគ្គបណ្តុះបណ្តាលនៅឡាវ និងវៀតណាម | ២៩.០៩.០៣ ដល់ ០៣.០១.០៤ | យល់អំពីមតិណែនាំនៅក្នុងផែនការមេ ( ប្រព័ន្ធនៃកាប្រមូលដោយធុងសំរាម ការប្រមូលថវិកា និងប្រព័ន្ធនៃកាគ្រប់គ្រងអតិថិជន ប្រព័ន្ធ សំរាប់ប្រតិបត្តិការណ៍ទីលាន និងការគ្រប់គ្រង សំរាមដឹកចូលទីលាន ។ល។ | អ្នកចូលរួមសរុប ៩នាក់ មក ពី : ក្រ.ប.ស្ថ សាលាក្រុង ស.ក.ភ.ព ម.ប.ស្ថ.ភ និង រ.គ.ស.ភ |
| | វគ្គបណ្តុះបណ្តាលនៅកម្ពុជា | ២៩.១២.០៣ ដល់០២.០១.០៤ | វគ្គបណ្តុះបណ្តាលធ្វើឡើងដើម្បីផ្សព្វផ្សាយលទ្ធផលនៃការសិក្សានៅទូទាំងប្រទេស ។ គោលបំណងគឺជួយដល់មន្ត្រីពាក់ព័ន្ធនៅក្នុងជួររដ្ឋាភិបាលដើម្បីទទួលចំណេះដឹងនិងពិតមានចាំបាច់ដើម្បីកែសំរួលផែនការមេ ។ | ២៩នាក់ មកពីទីរួមខេត្ត ១៦ មកពី សាលាក្រុង និង ៦នាក់ មកពី ស្ថាប័នរដ្ឋាភិបាល |

| ការងារ | ការងារបន្ទាប់ | រយៈពេល | មាតិកាសិក្សា | អ្នកចូលរួម |
|---|---|---|---|---|
| **សិក្ខាសាលាផ្ទេរបច្ចេកវិទ្យា** | សិក្ខាសាលាផ្ទេរបច្ចេកវិទ្យាទី ១ | ០៦.១០.០៣ | ការពន្យល់អំពីខ្លឹមសារនៃផែនការមេស្តីពីការគ្រប់គ្រងសំណល់រឹង (ពង្រាង) ។ ការបង្ហាញពីគំរោងអាទិភាព ។ ការបង្ហាញពីខ្លឹមសារនៃគំរោងសាកល្បង ។ | សរុប ៥៣នាក់ : សាលាក្រុង ៣៨រូប ភ្នាក់ងាររដ្ឋាភិបាល ២ NGO ១នាក់ អង្គការអន្តរជាតិ ៤នាក់ ក្រុមហ៊ុនឯកជន ២នាក់ ប្រព័ន្ធផ្សព្វផ្សាយ ៨រូប |
| | សិក្ខាសាលាលើកស្ទួយដល់កម្មវិធី 3Rs | ០៨.០១.០៤ ដល់ ០៩.០១.០៤ | នៅជំហានទី១ក្នុងការលើកកំពស់ការយល់ដឹងសាធារណៈលើ 3Rs ចំណេះដឹង និងពិតមានពីការគ្រប់គ្រងសំណល់រឹង និង 3Rs ត្រូវបានផ្តល់ឱ្យ NGO និងស្ថាប័នរដ្ឋាភិបាលដែលនឹងដើរតួជាអ្នកដឹកនាំ ។ | សរុប៤១នាក់ : NGO ១៤នាក់ ស្ថាប័នរដ្ឋាភិបាល ៨នាក់ និងសាលាក្រុង ១៩នាក់ |
| **ការពន្យល់ និងការពិភាក្សា** | របាយការណ៍ដំបូង | ២៥.០២.០៣ ដល់១០.០៣.០៣ | ពន្យល់និងពិភាក្សាពីគោលបំណង វិធីសាស្ត្រ... នៃការសិក្សា | សរុប ៣៣នាក់ |
| | របាយការណ៍វិវឌ្ឍន៍ លើក ទី ១ | ០៣.០៧.០២ | ពន្យល់និងពិភាក្សាអំពីគោលគំនិតនៃផែនការមេ លទ្ធភាពសិក្សា និងគំរោងសាកល្បង | សរុប ៤១នាក់ |
| | រ.ប.អ | ២៣.០៩.០៣ | ពន្យល់និងពិភាក្សាពង្រាង ផ.ម និង គ.ស | សរុប ៣៣នាក់ |
| | របាយការណ៍វិវឌ្ឍន៍ លើក ទី ២ | ១៣.០១.០៤ | ពន្យល់ និងពិភាក្សាអំពីវិធីសាស្ត្រដើម្បីបន្តនូវពង្រាងនៃ ល.ស និង គ.ស | សរុប ៣០នាក់ |
| | ការប្រជុំប្រចាំសប្តាហ៍ | ២៨.០២.០៣ ដល់២៧.០៦.០៣ ០៣.១០.០៣ ដល់១៦.០១.០៤ | ពន្យល់ និងពិភាក្សាអំពីកាលវិភាគការងារ គោលបំណង និងខ្លឹមសារនៃការសិក្សា | ៥-១០ នាក់ មកពី -ស.ក.ភ.ព -ម.ប.ស្ថ.ភ និង -រ.គ.ស.ភ |
| | ការប្រជុំប្រចាំសប្តាហ៍នៅស្ទឹងមានជ័យ | ១២.១០.០៣ ដល់១២.០១.០៤ | ពន្យល់ និងពិភាក្សាអំពីកាលវិភាគការងារ គោលបំណង និងខ្លឹមសារនៃការសិក្សា | ២-៨នាក់ មកពីស្ថាប័នជាដៃគូ |
| **សិក្សាលក្ខណ្ឌ មានស្រាប់** | សិក្សាអំពីប្រភេទ និងបរិមាណសំរាម | ២៣.០៣.០៣ ដល់៣០.០៣.០៣ ២១.១០.០៣ ដល់២៨.១០.០៣ | ពន្យល់ និងពិភាក្សាអំពីកាលវិភាគការងារ គោលបំណង និងខ្លឹមសារនៃការសិក្សា អនុវត្តការស្រង់នៅទីលាន (វិធីសាស្ត្ររើសគំរូ វិធីសាស្ត្រវិភាគ) វិភាគនិងគ្រប់គ្រងទិន្នន័យ | ២-៣នាក់ មកពីស្ថាប័នជាដៃគូ |
| | ការសិក្សាពីពេលវេលា និងសកម្មភាពរថយន្ត | ២៤.០៣.០៣ ដល់០៦.០៤.០៣ ១២.១១.០៣ ដល់១៦.១១.០៣ ០១.១២.០៣ ដល់០៨.១២.០៣ | រៀបចំសំរាប់ការសំរង់ (គ្រប់គ្រងទិន្នន័យនៃរថយន្តដឹកសំរាម បែងចែកប្រព័ន្ធប្រមូលសំរាម) អនុវត្តការ សិក្សា រៀបចំ និងវិភាគលទ្ធផលនៃការ ស្រាវជ្រាវ | ២នាក់ មកពីស្ថាប័នជាដៃគូរ |

| ការងារ | ការងារបន្ទាប់ | រយៈពេល | មាតិកាសិក្សា | អ្នកចូលរួម |
|---|---|---|---|---|
| | សិក្សាលើគុណភាពទឹក | ២៣.០៤.០៣ ដល់២៩.១១.០៣ | ពន្យល់ និងពិភាក្សាអំពីកាលវិភាគការងារ គោលបំណង និងខ្លឹមសារនៃការសិក្សា និង សិក្សានៅទីលាន (បណ្តុះបណ្តាលវិធីសាស្ត្រជ្រើសរើសគំរូ) | ១-២ នាក់មកពីស្ថាប័នជាដៃគូ |
| ការជួបជុំពន្យល់ដល់អ្នកជិតខាង | ការស្ទង់មតិសាធារណៈលើកទី ១ | ២០.១០.០៣ | ពន្យល់អំពីគំរោងកែលំអទីលានចាក់សំរាមដង្កោ(ពង្រាង១) និងសំរង់ EIA និងបន្ទាប់មកអំពី Q និង A | ប្រមាណ១០០នាក់ រួមមាន ស.ភ សាលាក្រុង រ.គ.ស.ភ សង្កាត់ ខ័ណ្ឌ និងប្រជាពលរដ្ឋ |
| | ការស្ទង់មតិសាធារណៈលើកទី ២ | ២៥.១២.០៣ | ពន្យល់អំពីគំរោងកែលំអទីលានចាក់សំរាមដង្កោ (ពង្រាង២) និងលទ្ធផល EIA និងបន្ទាប់មក អំពី Q និង A | ប្រមាណ ៣៥០នាក់ រួមមាន ស.ភ សាលាក្រុង រ.គ.ស.ភ និង ក្រ.ប.ស្ថ ខ័ណ្ឌ សង្កាត់ និងប្រជាពលរដ្ឋ ។ |

# 6 ការសិក្សាពីលទ្ធភាពនៃគំរោង

## 6.1 ការជ្រើសរើសគំរោងអាទិភាព

គំរោងបីខាងក្រោមនេះគឺជាគំរោងអាទិភាពដែលត្រូវបានជ្រើសរើសសំរាប់ការអនុវត្តជាបន្ទាន់នៅក្នុងដំណាក់កាលទីមួយនៃផែនការមេដោយយោងទៅលើភាពចាំបាច់លក្ខ័ណហិរញ្ញវត្ថុ និងប្រសិទ្ធិភាពនៃគំរោង។ អាស្រ័យហេតុនេះបានជាការសិក្សាជំហានដំបូងត្រូវចាប់ផ្តើម ។

- ផែនការអភិវឌ្ឍន៍ទីលានចាក់សំរាមដង្កោ
- គំរោងពង្រីកសេវាកម្មប្រមូលសំរាម
- ការបិទទីលានចាក់សំរាមស្ទឹងមានជ័យ

## 6.2 ផែនការអភិវឌ្ឍន៍ទីលានចាក់សំរាមដង្កោ

### 6.2.1 គោលគំនិតរៀបចំ

ផែនការអភិវឌ្ឍន៍ទីលានដង្កោនេះធ្វើឡើងដើម្បីសាងសង់ទីលានចាក់សំរាមមួយ ដែលមានលទ្ធភាពអាចចាក់សំរាមបានរយៈពេល ៥ឆ្នាំ នៅលើផ្ទៃដី ៣១.៤ ហ.ត ដែលត្រូវបានធានាដោយសាលាក្រុងភ្នំពេញនៅក្នុងដំណាក់កាលទីមួយនៃការសិក្សា ។ ទីលានដាក់សំរាមដង្កោនឹងក្លាយជាទីលានទីមួយនៅក្នុងប្រទេសកម្ពុជាដែលមានប្រព័ន្ធសំរាប់ធ្វើប្រព្រឹត្តិកម្មទឹកស្អុយ និងមធ្យោបាយត្រួតពិនិត្យការបំពុលបរិស្ថានមួយដ៏ត្រឹមត្រូវ ។ ក្រុមសិក្សាបានសំរេចបញ្ចូលមធ្យោបាយដូចខាងក្រោមសំរាប់ដំណើរការក្នុងការអភិវឌ្ឍន៍ផែនការដោយសហការជាមួយសមភាគីការងារ ។

- ផ្នែករដ្ឋបាល ( ការិយាល័យ រ.គ.ស.ភ ជញ្ជីងថ្លឹង ។ល។)
- ផ្នែកទីលានចាក់សំរាម និងប្រព័ន្ធត្រួតពិនិត្យទឹកសំអុយ
- រោងចក្រធ្វើជីកំប៉ុស្ត ( សំណល់សរីរាង្គពីទីផ្សារគឺជាគោលដៅចំបង)
- រោងជាងជួសជុល និងរោងឡានសំរាម ( សំរាប់រថយន្តសំរាម និងគ្រឿងចក្រនានានៅទីលាន) ។

### 6.2.2 បរិស្ថានធម្មជាតិនៃទីតាំងគំរោងនៅដង្កោ

អាកាសធាតុនៅតំបន់ដង្កោដែលជាទីតាំងគ្រោងធ្វើទីលានចាក់សំរាមថ្មី ទទួលឥទ្ធិពលខ្យល់មូសុងនារតី និងព្យុះសាន។ ខែដែលមានសីតុណ្ហភាពក្តៅបំផុតនោះគឺក្នុងខែមេសា ហើយខែដែលត្រជាក់ជាងគេនោះគឺខែមករា ហើយភ្លៀងធ្លាក់ប្រចាំឆ្នាំ៧០% ចាប់ពីខែឧសភាដល់ខែតុលា។ ផ្ទៃដីទីតាំងគំរោងភាគច្រើនគឺជាស្រែ និងវាលដែលមានដើមឈើខ្លះៗនិងត្រពាំងជាច្រើន។ គ្មានផ្លូវនៅទីតាំងរបស់គំរោងទេ តែមានផ្លូវជាតិលេខ ៣០៣នៅក្បែរនោះ។ ត្រពាំងលើកលែងតែត្រពាំងធារាសាស្ត្រចេញដែលឋិតនៅចុងខាងលិច គឺជាស្រះដែលកើតឡើងការជីកយកដី។ មានប្រឡាយធារាសាស្ត្រដែលលាតសន្ធឹងពីលិចទៅកើតនិងប្រលាយតូចមួយលាតសន្ធឹងខាងជើងនៃប្រឡាយមេ។

ស្ទឹងព្រែកត្នោតដែលហូរចាក់ទៅទន្លេបាសាក់ លាតសន្ធឹងពីលិចទៅកើតគឺឋិតនៅភាគខាងត្បូងទីតាំងគំរោង។ ប្រជាជនដែលរស់នៅតាមបណ្តោយស្ទឹងនេះប្រើប្រាស់ទឹកស្ទឹងសំរាប់បរិភោគចិញ្ចឹមជីវិត។ ប្រជាជនភាគច្រើនរស់នៅរាយប៉ាយក្នុងខ័ណ្ឌដង្កោប្រើប្រាស់ទឹកអណ្តូងសំរាប់បរិភោគ។ ទីតាំងគំរោងឋិតនៅភាគខាងលើដែលលាតសន្ធឹងទៅទិសខាងលិចនៃទន្លេមេគង្គហើយគ្របដណ្តប់ទៅដោយដីឥដ្ឋល្បាប់កំរាស់ពី១០ទៅ១៥ម៉ែត្រ។ រុក្ខជាតិ និងសត្វដែលត្រូវអភិរក្ស នោះមានតិចតួចដោយសារតំបន់នោះមិនមែនជាតំបន់ព្រៃឈើ។

## 6.2.3 ការរៀបចំចំណុចសំខាន់ៗ

### a. លក្ខខណ្ឌក្នុងការរៀបចំ

### a.1 កាលវិភាគការងារ

ការងារនៃដំណាក់កាលទីមួយ : ប្រតិបត្តិការណ៍ទីលាននឹងចាប់ផ្តើមនៅ ខែមករាឆ្នាំ ២០០៧ ។

ការងារនៃដំណាក់កាលទីពីរ : ប្រតិបត្តិការណ៍ទីលាននឹងចាប់ផ្តើមនៅ ខែមករាឆ្នាំ ២០១៣ ។

### a.2 បរិមាណសំរាមដែលត្រូវចាក់នៅទីលានថ្មី

សំរាមដែលត្រូវចាក់នៅទីលានថ្មី គឺជាប្រភេទសំរាមទីក្រុងដែលប្រមូលពីភ្នំពេញលើកលែងតែសំរាមដែលមានគ្រោះថ្នាក់ដល់សុខភាព ។ តារាងខាងក្រោមនេះបង្ហាញពីបរិមាណនៃសំណល់ តាមការប្រយោលលើចំនួនប្រជាជនដែលរំពឹងថានឹងត្រូវចាក់ចោលនៅ ទីលានថ្មីនេះ បន្ទាប់ពីវានឹងចាប់ផ្តើមអោយដំណើរការ (តារាង ៦-១ ខាងក្រោម) ។

បរិមាណនៃការចាក់ ត្រូវបានគិតដោយផ្អែកលើចំនួនប្រជាពលរដ្ឋដោយ NIS ដែលនឹងមានប្រមាណ ១១០,០០០តោន (៤.៥%)ច្រើននៅក្នុងតំនាក់កាលទីមួយ ជាងការគិតរបស់ក្រុមសិក្សា ។ នេះស្មើទៅនិងបរិមាណចាក់ ៣.៣ ខែ (ប្រមាណ ១.០ម កើនលើកំពស់ទីលាន ជាមួយនិងលទ្ធភាពទីលាន ០.៨ តោន/ម៣) ដែលនេះនឹងអាចមានផលប៉ះពាល់ខ្លះលេការធ្វើផែនការទីលាន ។

Table 6-1: បរិមាណចាក់ដែលបានប៉ាន់ស្មាន

| ឆ្នាំ | បរិមាណសំរាមដែលត្រូវចាក់ | |
|---|---|---|
| | បរិមាណប្រចាំឆ្នាំ (តោន/ឆ្នាំ) | បរិមាណកើនឡើង (តោន) |
| ២០០៧ | ៣៣៧,១៥១ | ៣៣៧,១៥១ |
| ២០០៨ | ៣៦១,៣៥០ | ៣៩៨,៥០១ |
| ២០០៩ | ៣៨៨,៦១៦ | ១,០៨៧,១១៧ |
| ២០១០ | ៤១៦,៣១៩ | ១,៥០៣,៤៣៦ |
| ២០១១ | ៤៣៩,៨២៥ | ១,៩៣៤,២៦១ |
| ២០១២ | ៤៧៤,៩៣៨ | ២,៤១៨,១៩៩ |
| ២០១៣ | ៤៩៨,៩៥៥ | ២,៩១៧,១៥៤ |
| ២០១៤ | ៥២៤,៦៨៨ | ៣,៤៤១,៤៨២ |
| ២០១៥ | ៥៦១,៩៥១ | ៤,០០៣,៨៣៣ |

### b. ផែនការសាងសង់ហេដ្ឋារចនាសម្ព័ន៍លើទីលានថ្មី

ទីតាំងបំពាក់មធ្យោបាយនានានៅក្នុងទីលាននេះមានបង្ហាញដូចខាងក្រោម ។




Figure 6-1: ប្លង់ផែនការរៀបចំទីលានចាក់សំរាមថ្មីដង្កោ (ដំណាក់កាលទី 1)

ដើម្បីពង្រីកទំហំដីសំរាប់ចាក់សំរាមឱ្យធំទូលាយនោះ ការសាងសង់ហេដ្ឋារចនាសម្ពន័នានាត្រូវបង្រួមតូច ។ តំបន់ដែលបានរៀបចំសំរាប់ជាទីលានថ្មីនោះមានទំហំសរុប ២៣.៥ហ.ត ហើយសមត្ថភាពផ្ទុកមានរហូតដល់ ២,៣ លានម៉ែត្រគូបដោយមានសាងសង់ខ្ទង់ផ្លូវទប់ជុំវិញ ។ ដូចបានអធិប្បាយក្នុងជំពូក១.២ ហេដ្ឋារចនាសម្ពន័ទាំងនោះត្រូវរៀបចំឡើងដោយផ្អែកលើលទ្ធផលការអង្កេត ភូមិសាស្ត្រដែលបានធ្វើឡើងក្នុងជំហានទី២នៃការសិក្សា។ ដូច្នេះ ការសិក្សាអង្កេតភូមិសាស្ត្រត្រូវបានធ្វើឡើងសំរាប់ការ រៀបចំផ្ទៃដីទីលានចាក់សំរាម អគាររដ្ឋបាល ដេប៉ូនិងរោងជាងរថយន្តដែលចិតនៅភាគខាងជើងនៃប្រព័ន្ធធារាសាស្ត្រ។

Table 6-2: ផ្ទៃហេដ្ឋារចនាសម្ព័នតាមផ្នែកដែលត្រូវសាងសង់

| ហេដ្ឋារចនាសម្ព័ន្ធ | ទំហំ (ហ.ត) |
|---|---|
| ផ្នែករដ្ឋបាល | ០.៧ |
| ផ្នែកទីលាន និងប្រព្រឹត្តិកម្មទឹកសំអុយ | ១៧,០ |
| រោងចក្រជីកំប៉ុស្ត | ១,១ |
| រោងជាងជួសជុល និងដេប៉ូឡាន | ១.២ |
| ផ្សេងៗ (តំបន់ទ្រនាប់ ។ល។) | ១១,៤ |
| សរុប | ៣១,៤ |

### c. ផែនការរៀបចំគ្រឿងចក្រ

គ្រឿងចក្រនានាត្រូវបានរៀបចំដូចខាងក្រោមតាមគំរោង :

Table 6-3: តារាងគ្រឿងចក្រសំរាប់ទីលាន

| គ្រឿងចក្រ | បទដ្ឋាន | ចំនួន | ការប្រើប្រាស់ |
|---|---|---|---|
| ១ រថយន្តឈូសសំរាម | ២១ តោន | ៤ | សំរាប់គៀរនិងបង្ហាប់សំរាម |
| ២ រថយន្តចូកសំរាម | ១.២ ម៉ែត្រ$^{៣}$ | ១ | សំរាប់គៀរសំរាមនិងថែរក្សាផ្លូវ |
| ៣ ឡានទឹក | ៦,000 លីត្រ | ១ | ថែរក្សាផ្លូវនិងពលត់ភ្លើង |
| ៤ ឡានបែន | ១១ តោន | ២ | សំរាប់ដឹកដី |
| ៥ ឡាន Pickup | 4 WD | ២ | សំរាប់ពិនិត្យការដ្ឋាន |
| ៦ រថយន្តដឹកដី | 0.៧ ម$^{៣}$ | ២ | សំរាប់ដឹកដី និងសំអាតលូ |

ការពិនិត្យ និងជួសជុលតូចតាចប្រចាំថ្ងៃត្រូវធ្វើនៅរោងជាងក្នុងការដ្ឋាន រីឯការជួសជុលទ្រង់ទ្រាយធំត្រូវធ្វើដោយក្រុមជាងដែលទទួលម៉ៅការ ។ ការលំអិតអំពីរោងជាងនានាមានបង្ហាញក្នុងតារាងផែនការជួសជុលរថយន្តដឹកសំរាម ។

### d. រចនាសម្ព័ន្ធគ្រប់គ្រង និងប្រពន្ធ័គ្រប់គ្រង

ការងារប្រតិបត្តិការនៅទីលានក្រោមការគ្រប់គ្រងរបស់ រ.ក.ស.ភ គឺការទទួលខុសត្រូវលើការងារចាក់សំរាម ។ មន្ត្រីនៅ ទីលានត្រូវបានរៀបចំដូចខាងក្រោមតាមគំរោង ។

Table 6-4: : តារាងបុគ្គលិកប្រតិបត្តិការណ៍ទីលាន

| ផ្នែក | ពេលបច្ចុប្បន្ន | ២00៧ | ២0១២ | ២0១៥ |
|---|---|---|---|---|
| ១- នាយក | | ១ | ១ | ១ |
| ២. ប្រធានផ្នែក | ១ | ១ | ១ | ១ |
| ៣. វិស្វករ | - | ១ | ១ | ១ |
| ៤. ស្មៀន | - | ២ | ២ | ២ |
| ៥. អ្នកថ្លឹងជញ្ជីង | ២ | ៣ | ៣ | ៣ |
| ៦. អ្នកត្រួតពិនិត្យ | - | ៤ | ៤ | ៤ |
| ៧. អ្នកបើកបរ | - | ២២ | ២៥ | ២៩ |
| ៨. កម្មករ | ១ | ១២ | ១២ | ១២ |
| សរុប | ៤ | ៤៥ | ៤៨ | ៥២ |

តារាងបុគ្គលិកសំរាប់ប្រតិបត្តិការណ៍ធ្វើដីកំប៉ុស្តនៅឆ្នាំ ២00៧ បានស្នើរមានដូចរៀបរាប់ខាងក្រោម ។

Table 6-5: តារាងបុគ្គលិកប្រតិបត្តិការណ៍ធ្វើដីកំប៉ុស្ត

| ផ្នែក | ចំនួន |
|---|---|
| ១. ប្រធានផ្នែក | ១ |
| ២. ប្រចាំការនៅការិយល័យ | ១ |
| ៣. អ្នកត្រួតពិនិត្យ | ២ |
| ៤. អ្នកបើកបរ | ២ |
| ៥. កម្មករ | ២៥ |
| សរុប | ៣១ |

### e. ការត្រួតពិនិត្យ និងប្រព័ន្ធគ្រប់គ្រងព័ត៌មាន

ការត្រួតពិនិត្យតទឹកក្រោមដី ទឹកនៅផ្ទៃលើ ឧស្ម័នពីទីលាន សម្លេង ការស្រុតដី ភ្លើង និងក្លិនត្រូវបានធ្វើឡើងនៅទីតាំងដូចរូបភាព៦-២ ខាងក្រោម ។ រង្វាស់សារធាតុដែកនិងសារធាតុមានគ្រោះថ្នាក់មានសារៈសំខាន់ណាស់ក្នុងការត្រួតពិនិត្យ ប៉ុន្តែការវាស់ដូច្នេះត្រូវចំណាយលុយច្រើនណាស់។ ដោយគិតលើស្ថានភាពហិរញ្ញវត្ថុរបស់សាលាក្រុងភ្នំពេញ-រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ ក្រុមសិក្សាបានផ្តល់អនុសាសន៍តែពីរបីមុខប៉ុណ្ណោះសំរាប់ត្រួតពិនិត្យមានដូចជា : H, EC, Cl ជាដើម។ ទោះជាយ៉ាងនេះក្តី ការចំណាយក្នុងការវាស់សារធាតុទាំងបីនេះអស់ថវិកាតិច នោះរដ្ឋាករគ្រប់គ្រងសំណល់នឹងមានលទ្ធភាពក្នុងការការពារទឹកស្អុយមិនអោយជ្រាប។ ពីព្រោះសារធាតុទាំងនេះត្រូវបានផ្លាស់ប្តូរគួរអោយកត់សំគាល់នៅពេលដែលទឹកស្អុយជ្រាបចូលទឹកដែលយើងយកមកពិនិត្យនោះ។ ប្រសិនបើបំរែបំរួលត្រូវបានដឹងនោះរដ្ឋាការត្រូវវាស់គុណភាពទឹកដោយរួមបញ្ចូលទាំងសារធាតុដែក ហើយចាត់វិធានការដើម្បីដោះស្រាយបញ្ហានោះអោយបានលឿន។

ការត្រួតពិនិត្យជាប្រចាំអោយបានច្រើនដងដែលធ្វើឡើងដោយមន្ទីរបរិស្ថាន-រដ្ឋាករគ្រប់គ្រងសំណល់ ត្រូវបានគ្រោងធ្វើជារៀងរាល់ខែ ហើយនិងចូលរួមក្នុងការត្រួតពិនិត្យជាមួយគណៈកម្មការត្រួតពិនិត្យក្រោយពីការត្រួតពិនិត្យនោះមកពីរដងក្នុងមួយឆ្នាំ ។




Figure 6-2: ចំណុចត្រួតពិនិត្យ

មុខការនិងពេលវេលាដែលត្រូវត្រួតពិនិត្យបានបង្ហាញក្នុងតារាងខាងក្រោម

Table 6-6: Monitoring Plan of Dang Kor Disposal Site

| មុខការ | ហេដ្ឋារចនាសម្ព័ន្ធ និង ឧបករណ៍ | មុខការដែលត្រូវវាស់ | ដំណាក់កាល | | |
|---|---|---|---|---|---|
| | | | ការសាងសង់ | ប្រតិបត្តិការ | ពេលបិទទីលាន |
| ទឹកក្រោមដី | អណ្តូងដែលត្រូវត្រួតពិនិត្យ | ការចំលងអគ្គីសនី, Cl⁻, pH | | √ | √ |
| ទឹកលើផ្ទៃ | សំណាកទឹក | ការចំលងអគ្គីសនី, Cl⁻, pH | | √ | √ |
| ឧស្ម័នចេញពីទីលាន | បំពង់បង្ហុយឧស្ម័ន | មេតាន កាបូនិច ទឹក សីតុណ្ហភាព | | √ | √ |
| សំលេង | ឧបករណ៍វង្វាស់សំលេង | ក្លិន សំលេង | √ | √ | |
| ភាពស្រុត | ក្តារវាស់ភាពស្រុត | កំរិតស្រុត | | √ | √ |
| ភ្លើងឆេះ | ត្រួតពិនិត្យដោយមនុស្ស | ភ្លើងឆេះទីលាន | | √ | √ |
| ក្លិនស្អុយ | ត្រួតពិនិត្យដោយមនុស្ស | ក្លិនស្អុយ | | √ | √ |
| ហៀរចេញ | ត្រួតពិនិត្យដោយមនុស្ស | ទឹកហៀរចេញពីអាងប្រព្រឹត្តកម្មទឹកស្អុយ | | √ | √ |

### e.1 គណកម្មការត្រួតពិនិត្យ

ដើម្បីពង្រឹងប្រព័ន្ធត្រួតពិនិត្យ គណៈកម្មការត្រួតពិនិត្យរួមមានសាលាក្រុង ក្រ.ប.ស្ថ មន្ទីរបរិស្ថាន គណកម្មការអភិវឌ្ឍភូមិ និងអង្គការក្រៅរដ្ឋាភិបាលនឹងត្រូវបានគេបង្កើតឡើង។ គណកម្មការនោះមានតួនាទីដូចខាងក្រោម:

- សមាជិកគណៈកម្មការត្រូវចូលរួមការត្រួតពិនិត្យនិងអង្កេតពីលក្ខខ័ណ្ឌបរិស្ថានរបស់ទីលាន និងតំបន់ដែលនៅជុំវិញទីលាន
- ប្រសិនបើប្រតិបត្តិការត្រូវបានសង្ស័យថាធ្វើអោយមានផលប៉ះពាល់ដល់លក្ខខ័ណ្ឌបរិស្ថាន សមាជិកគណៈកម្មការត្រូវធ្វើសំណើរការស្ទាបស្ទង់ហើយនិងចូលរួមការត្រួតពិនិត្យទីលាន
- ដើម្បីអោយប្រតិបត្តិការទីលានបានល្អ គណៈកម្មការត្រូវធ្វើការពិភាក្សានៅពេលណាដែលចាំបាច់។

ក្រសួងបរិស្ថាន សាលាក្រុង-មន្ទីរបរិស្ថាន និងរដ្ឋាការគ្រប់គ្រងសំណល់បានធ្វើការត្រួតពិនិត្យទីលានជាលក្ខណៈផ្ទៃក្នុងរួចទៅហើយ ហើយបន្ទាប់មកការត្រួតពិនិត្យនឹងមានដំណើរការយ៉ាងរលូន ហើយគណៈកម្មការត្រួតពិនិត្យមួយដូចបាននិយាយខាងលើនឹងត្រូវបង្កើតឡើង។

ដូច្នេះ ការលំអិតស្តីពីការត្រួតពិនិត្យនិងគណៈកម្មការត្រួតពិនិត្យនឹងត្រូវសិក្សាឡើងវិញជាលំអិតនៅក្នុងដំណាក់កាលរៀបចំ។

### f. តំលៃវិនិយោគគំរោង

សរុបតំលៃនៃគំរោងដោយរាប់បញ្ចូលទាំងតម្លៃប្រតិបត្តិការណ៍ និងថែទាំត្រូវបានរំពឹងថានឹងមានបង្ហាញដូចខាងក្រោមលើកលែងតែការសាងសង់ទីលានជួសជុល ។

Table 6-7: ផែនការតម្លៃដើមគំរោងទីលានចាក់សំរាមដង្កោ (១,000ដុល្លាសហរដ្ឋ)

| | | ២០០៥ | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្នែករដ្ឋបាល | វិនិយោគ | ៩៥ | ១៦៥៣ | 0 | 0 | 0 | 0 | ៤ | ៧៥ | 0 | 0 | 0 | ១៨២៧ |
| | ប្រតិ.និងថែ. | 0 | 0 | ១៣២ | ១៣២ | ១៣២ | ១៣២ | ១៣៧ | ១៣៤ | ១៩២ | ១៣៩ | ១៣៩ | ១២៦៩ |
| ផ្នែកទីលាន | វិនិយោគ | ៣១៦ | ៦៨២៦ | 0 | 0 | 0 | ១៧៥ | ១៩៣ | ៣៣៤៩ | ១៧២៤ | 0 | 0 | ១២៥៨៣ |
| | ប្រតិ.និងថែ. | 0 | 0 | ១៣២២ | ១៣០៤ | ១៣០៤ | ១៣០៤ | ១៣៤៤ | ១៣៣៤ | ១៣៤២ | ១៣៥៧ | ១៤៦៨ | ១២០៧៩ |
| កន្លែងធ្វើជីកំប៉ុស្ត | វិនិយោគ | ៥៩ | ១១៣៥ | 0 | 0 | 0 | 0 | 0 | 0 | ១១០ | 0 | 0 | ១៣០៤ |
| | ប្រតិ.និងថែ. | 0 | 0 | ៥៦ | ៥៦ | ៥៦ | ៥៦ | ៦២ | ៥៨ | ៦១ | ៦៣ | ៦៣ | ៥៣១ |
| រោងជាង | វិនិយោគ | ៧៦ | ១៤៩៨ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | ១៤៥៨ |
| | ប្រតិ.និងថែ. | 0 | 0 | ១២១ | ១២១ | ១២១ | ១២១ | ១៣៧ | ១៣០ | ១៣៨ | ១៤៨ | ១៤៨ | ១១៨៥ |
| សរុប | វិនិយោគ | ៥៤៦ | ១១១១២ | 0 | 0 | 0 | ១៧៥ | ១៩៧ | ៣៤២៤ | ១៨៣៤ | 0 | 0 | ១៥៧១៤ |
| | ប្រតិ.និងថែ. | 0 | 0 | ១៦៣១ | ១៦១៣ | ១៦១៣ | ១៦១៣ | ១៦៨០ | ១៦៥៦ | ១៧៣៣ | ១៧០៧ | ១៨១៨ | ១៣៨៧៩ |

## 6.2.4 ការវាយតំលៃគំរោង

### a. ការវាយតំលៃបច្ចេកទេស

លទ្ធផលនៃការពិសោធន៍ដីបានបង្ហាញថា ទីតាំងដែលគ្រោងធ្វើជាទីលានចាក់សំរាមថ្មីនោះ ត្រូវបានគ្របដណ្តប់ក្នុងជំរៅប្រហែលជា១០ម៉ែត្រដោយស្រទាប់ដីឥដ្ឋ ហើយមានស្រទាប់ដីខ្សាច់ដែលមានកំរិតជ្រាបទឹក ១x១០$^{-៣}$ cm/s ដែលឋិតនៅភាគខាងកើតទីតាំងគំរោង ចន្លោះរវាងពី៣ទៅ៤ម៉ែត្រពីផ្ទៃក្រោម។ ស្រទាប់ដីឥដ្ឋមានកំរិតជ្រាបទឹកត្រឹមតែ ១០$^{-៦}$ cm/s ដែលតួលេខនេះទាបល្មមក្នុងការបញ្ឈប់ទឹកស្អុយជ្រាបចូលទឹកក្រោមដី។ (នៅប្រទេសជប៉ុន ស្រទាប់ដីឥដ្ឋត្រូវមានកំរិតជ្រាបទឹក ១x១០$^{-៦}$ cm/s ហើយមានកំរាស់៥០សង់ទីម៉ែត្រឬច្រើនជាងនេះតាមស្តង់ដា)។ ផ្ទៃទីលាននឹងត្រូវជីកយកដីដែលមានជំរៅ ៩ម៉ែត្រដើម្បីធ្វើអោយសមត្ថភាពផ្ទុករបស់ទីលានមានកំរិតអតិបរមា និងដើម្បីកាត់បន្ថយការចំណាយប្រតិបត្តិការទីលានអោយមានកំរិតអប្បបរមាដោយការជីកយកដីលក់។ ទោះបីជាយ៉ាងនេះក្តី គ្រោះថ្នាក់មួយអាចនឹងកើតឡើង ដោយស្រទាប់ដីជ្រាបទឹកដែលឋិតនៅក្រោមបាតទីលានដែលត្រូវកាយយកនោះប្រហែលជានឹងពង្រីកដោយកាត់បន្ថយសំពាធ ហើយដោយហេតុដូច្នេះទឹកស្អុយនឹងជ្រាបចូលទឹកក្រោមដី។ ជាមួយគ្នានេះផងដែរ ស្រទាប់ដីខ្សាច់ដែលបានរៀបរាប់ពីខាងលើប្រហែលជានឹងរីកធំឡើង៧ផងដែរ។ ដូច្នេះ ក្រុមសិក្សាសូមផ្តល់អនុសាសន៍អោយធ្វើការអង្កេតពិសោធន៍ពីលក្ខណៈភូមិសាស្ត្របន្ថែមទៀតសំរាប់ការរៀបចំអោយបានលំអិត។ មានការព្រួយបារម្ភមួយគឺថាទឹកស្អុយនឹងជ្រាបតាមរយៈផ្ទែកដែលត្រូវពន្លឺថ្ងៃនៃស្រទាប់ដីខ្សាច់ ដូច្នេះចាំបាច់ត្រូវយកស្រទាប់ដីឥដ្ឋដែលបាននិយាយពីខាងលើមកចាក់គ្របពីលើ។ វិធានការនេះគឺគ្រប់គ្រាន់នឹងបញ្ឈប់ទឹកស្អុយជ្រាបចូលទឹកក្រោមដី។ ផែនការអភិវឌ្ឍបានប្រើប្រាស់លក្ខខ័ណ្ឌក្នុងស្រុកនានានៃទីតាំងនិងសំរេចជោគជ័យក្នុងការធ្វើអោយការចំណាយមានកំរិតអប្បបរមា។ ទោះជាយ៉ាងនេះក្តី ដើម្បីបង្ការការប្រេះស្រាំក្នុងកំឡុងពេលសាងសង់ ចាំបាច់ត្រូវធ្វើការត្រួតពិនិត្យសារជាតិសំណើមនិងត្រួតពិនិត្យកំរាស់នៃស្រទាប់ដីឥដ្ឋ ។ល។

អ្នករស់នៅក្បែរនោះបានប្រើប្រាស់ទឹកស្ទឹងដោយច្រោះទុកអោយរងនិងដាំសំរាប់បរិភោគ។ ដូច្នេះ ដែលទឹកសំអុយដែលនឹងធ្វើប្រព្រឹត្តកម្មនោះមិនអាចបង្ហូរចូលប្រភពទឹកបានទេ ។ ដើម្បីដោះស្រាយបញ្ហានេះ ទឹកសំអុយត្រូវរំហួតដោយកំដៅថ្ងៃ ហើយនិងត្រូវបង្ហូរត្រឡប់ទៅទីលានវិញនារដូវភ្លៀងដើម្បីធ្វើការលាយច្របល់ជាមួយទឹកសំអុយថ្មី ។ នេះជាប្រពន្ធ័មួយ ដែលមិនអនុញ្ញាតអោយបង្ហូរទៅក្រៅទីលាន ។ ជាងនេះទៅទៀត វិធានការទប់ស្កាត់ការបង្ហូរទឹកសំអុយចេញ ទីតាំងទីលានត្រូវបានគ្រោងធ្វើទំនប់ព័ទ្ធជុំវិញដែលមានកំពស់ ១០.២ម៉ែត្រលើកំពស់ទឹកសមុទ្រ ហើយកំពស់នេះខ្ពស់ជាងកំរិតកំពស់ទឹកជំនន់ដល់ទៅ៣០សង់ទីម៉ែត្រដែលកើតមាននៅតំបន់នេះកាលពីពេលមុន។ ទោះជាយ៉ាងនេះក្តី យើងមិនអាចសន្និដ្ឋានថានេះជាផែនការល្អដែលអាចទប់ទល់នឹងគ្រោះធម្មជាតនោះទេ តែវិធានការកាត់បន្ថយទឹកស្អុយអោយមានកំរិតស្របតាមស្តង់ដានឹងត្រូវរៀចំឡើងដើម្បីបន្ថយផលប៉ះពាល់អោយមានកំរិតអប្បបរមាដល់តំបន់ដែលនៅជុំវិញនោះ។

ទំហំបញ្ចេញសំណល់ពីឆ្នាំ ២០០៧-២០១៥ ដែលធ្វើការសន្និដ្ឋានលើចំនួនប្រជាពលរដ្ឋដោយការិយាល័យជំរឿនមាន៩% ដែលច្រើនជាងការសិក្សា ។ ទីលានដែលធ្វើការសិក្សា នឹងមានសមត្ថភាពរហូតដល់ ៦ឆ្នាំ ចាប់ពី ២០០៧-២០១២ ។ ប្រសិនបើចំនួនប្រជាពលរដ្ឋនឹងមានកំនើនដូច្នោះមែន នោះអាយុទីលាននឹងត្រូវបន្ថយអស់ ៣.៣ ខែដែរនោះនឹងមិនប៉ះពាល់ការងារនៅដំណាក់កាលទីមួយទេ ។ តែនៅដំណាក់កាលទីពីរ គេចាំបាច់ត្រូវពិនិត្យបរិមាណហូរចូលនិងស្ថិតិ ប្រជាពលរដ្ឋដោយប្រៀបធៀបទៅនិងគំរោងបួង់ ។ កាលវិភាគនៃគំរោងត្រូវតែផ្លាស់ប្តូរជានិច្ច ។

### b. ការវាយតំលៃសង្គម

ការប៉ះពាល់ដែលនឹងអាចបណ្តាលមកពីទីលានថ្មី មានរៀបរាប់ខាងក្រោម ។ ផលប៉ះពាល់អវិជ្ជមាន :

- ការកើនឡើងចំពោះថ្លៃសេវា

- បាត់បង់ប្រាក់ចំណូលចំពោះប្រជាកសិករនៅក្បែរទីលានចាក់សំរាម
- មានការបាត់បង់ប្រាក់ចំណូលចំពោះអ្នករើសសំរាមនៅទីលានចាស់

ដើម្បជាវិធានការណ៍សំរាប់កាត់បន្ថយការកើនឡើងនៃការប្រមូលតំលៃសេវានេះក្រុមសិក្សាបានស្នើរអោយលក់ដីដែលនឹងជីក ។ ជាងនេះទៀត ប្រពន្ធ័នៃការកំណត់ថ្លៃសេវាគួរត្រូវផ្លាស់ផ្តូរទៅច្បាមយកគេហដ្ឋានដែលមានរបររកស៊ីដែលបញ្ហានេះអាចជួយបន្ថយទម្ងន់ចំពោះគេហដ្ឋានធម្មតា ។ វីធវិធានកាណ៍ចំពោះការបាត់បង់ប្រាក់ចំណូលរបស់ប្រជាកសិករនៅក្បែរទីលាននោះ ទីលានថ្មីអាចផ្តល់ការងារខ្លះចំពោះពួកគាត់ដូចជាធ្វើការនៅទីលាន និងការផលិតជីកំប៉ុស ។

អ្នករើសសំរាម នឹងមិនអនុញ្ញាតអោយចូលរើសសំរាមនៅទីលានថ្មីឡើយដែលនឹងក្លាយជាផលវិបាកចំពោះការបាត់បង់ប្រាក់ចំណូលដោយសារការបិទទីលានចាស់ ។ ការងារនេះមិនអាចដោះស្រាយបានតាមតែរយះសកម្មភាពប្រមូលសំរាមតែឯងនោះទេ ។ ការពង្រីកសេវាកម្មប្រមូលសំរាមនឹងត្រូវការបន្ថែមនូវបុគ្គលិករបស់ រ.គ.ស.ភ និងក្រុមប្រមូលបថម ដែលក្រុមសិក្សាលើកទឹកចិត្តអោយជ្រើសរើសអ្នករើសសំរាមដើម្បីជួយកាត់បន្ថយផលប៉ះពាល់ ។

យុទ្ធវិធីមូលដ្ឋាននានាក្នុងការដោះស្រាយជាមួយអ្នករើសសំរាមដែលនឹងត្រូវបាត់បង់ប្រាក់ចំណូលត្រូវបានសង្ខេបក្នុងរង្វាយតំលៃគំរោង" ការបិទទីលានចាក់សំរាមស្ទឹងមានជ័យ" ក្នុងជំពូក ៦.៤.៣ ។

### c. ការវាយតំលៃបរិស្ថាន

#### c.1 សន្និដ្ឋាន

ផ្អែកលើលទ្ធផលនៃការពិនិត្យដោយយកចិត្តទុកដាក់លើ ការសិក្សាគំរោងធនធានធម្មជាតិ ការវិភាគលើហេតុប៉ះពាល់បរិស្ថាន លទ្ធផលស្ទង់មតិសាធារណៈ វិធីកាត់បន្ថយផលប៉ះពាល់បរិស្ថាន ការវិភាគលើជំរើសនានា ផែនការគ្រប់គ្រងបរិស្ថាន និងសមត្ថភាពរបស់ស្ថាប័នពាកព័ន្ធ នោះគេរំពឹងថាផលប៉ះពាល់អវិជ្ជមានទាំងនោះ នឹងត្រូវបានត្រួតពិនត្យ និងកាត់បន្ថយបានច្រើន ។ ការសិក្សាលំអិតលើផ្នែកនីមួយៗមានអធិប្បាយខាងក្រោម ។

#### c.2 គំរោង

គំរោងនេះរៀបចំឡើងសំរាប់ការអភិវឌ្ឍន៍ទីលានចាក់សំរាមថ្មីនៅដង្កោ ហើយសាលាក្រុងភ្នំពេញគឺជាម្ចាស់គំរោង ។ វាមានសារៈសំខាន់ណាស់សំរាប់ការគ្រប់គ្រងសំណល់រឹងនៅរាជធានីភ្នំពេញ និងបន្តផ្តល់សេវាកម្មប្រមូលសំរាមដល់ប្រជាពលរដ្ឋ នៅពេលដែលទីលានចាស់នឹងត្រូវបិទជាស្ថាពរនៅឆ្នាំ២០០៧ ។ ការអនុវត្តន៍គំរោងនឹងផ្តល់ប្រយោជន៍ជាសាធារណៈ ដល់ប្រជាពលរដ្ឋរាជធានីភ្នំពេញ ព្រមទាំងជួយវិភាគទានដល់ការគ្រប់គ្រងសំណល់រឹង និងថែរក្សាបរិស្ថានស្អាតមួយ ។ គំរោងនេះគ្របដណ្តប់លើផ្នែកជាច្រើនពោលគឺ ដំណាក់កាលនៃការសាងសង់ ការបើក និងបិទទីលាន ជាមួយនិងការគិតគូរយ៉ាងខ្លាំងលើការថែទាំបរិស្ថាន ។ ការជ្រើសរើសទីតាំង ទំហំដី និងវិធីសាស្ត្រនៃការចាក់សំរាមត្រូវបានគេគិតដល់ការថែទាំបរិស្ថាន ព្រមជាមួយនិងផែនការគ្រប់គ្រងបរិស្ថានមួយត្រឹមត្រូវ ។ មិនត្រឹមតែវិធានការនោះទេ តែគេក៏បានគិតដល់ការបង្កើតគណកម្មការសំពប់គំរោង និងការបណ្តុះបណ្តាលដល់មន្ត្រីនានា ។

#### c.3 ដំណាក់កាលនៃការធ្វើ EIA

គំរោងនេះតំរូវឱ្យធ្វើ EIA ដោយយោងលើអនុក្រឹត្យស្តីអំពីដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថាននៅកម្ពុជា ។ ដោយ តំរូវការនេះហើយ ការធ្វើ IEE ដំបូងត្រូវបានរៀបចំឡើងហើយដាក់ជូនក្រសួងបរិស្ថាន ។

EIA ដំបូង ត្រូវបានរៀបចំឡើងអាស្រ័យលើលទ្ធផលនៃ IEE ដែលបានគ្របដណ្តប់លើគ្រប់ជ្រុងនៃបរិស្ថានដែលបានអនុម័តឱ្យធ្វើ តាំងពីថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០០៣ ។ ដើម្បីអោយក្រសួងបរិស្ថានអនុម័តយល់ព្រមលើ EIA សាលាក្រុងភ្នំពេញដែលជាម្ចាស់គំរោងបានដាក់របាយការIEE និង EIA ហើយនឹងបានធ្វើវេទការសារធារណៈលើកទី3 ។ ជាពិសេស សាលាក្រុងភ្នំពេញនិងរដ្ឋាករគ្រប់គ្រងសំណល់បានដើរតួនាទីក្នុងការពន្យល់ពីគំរោងដល់រាល់អ្នកពាក់ព័ន្ធទាំង

អស់នៅក្នុងវេទការសាធារណៈលើកទី៣។ ក្រុមសិក្សាគ្រាន់តែជួយសាលាក្រុងភ្នំពេញដើម្បីអោយទទួលបានការយល់ព្រមពីក្រសួងបរិស្ថានលើ EIA តាមរយៈការប្រតិបត្តិការអង្កេតបរិស្ថាននិងការរៀបចំនៃពង្រាងផែនការអភិវឌ្ឍដែលជាការលំបាករបស់សាលាក្រុងភ្នំពេញ។

## c.4 ការចូលរួមពីសាធារណៈ (វេទិកាសារធារណៈ)

ជាផ្នែកមួយនៃការធ្វើ EIA វេទការសាធារណៈត្រូវបានរៀបចំឡើងចំនួនបីលើក្ប ចំណុចសំខាន់ៗនៃវេទការសារធារណៈបានសង្ខេបដូចខាងក្រោមៈ

### c.4.1. ចំណុចសំខាន់ៗនៃវេទការ សារធារណៈ

**(១) គោលបំណង**

គោលបំណងចំបងរបស់វេទការសារធារណៈគឺដើម្បីបង្កើតនូវការយល់ព្រមឯកភាពរវាងអ្នកពាក់ព័ន្ធនិងគំរោងទាំងអស់។

វេការសារធារនៈលើកទី១បានធ្វើឡើងមុនពេលចាប់ផ្តើមក្នុងការធ្វើF/ ។ ដើម្បីឆ្លុះបញ្ចាំងពីគំនិតយោបល់និងរិះគន់ពីរាល់អ្នកចូលរួមទាំងអស់នៅក្នុងផែនការF/និងផែនការអភិវឌ្ឍចុងក្រោយក៏ជាគោលបំពងយ៉ាងសំខាន់ផងដែរ។

**(២) តំបន់គោលដៅចំបងៗ និងអ្នកចូលរួមវេទការសារធារណៈ**

តំបន់ទាំងបីខាងក្រោមត្រូវបានជ្រើសរើសដោយសារជាតំបន់ដែលអាចនឹងទទួលផលប៉ះពាល់ខ្លាំងជាងគេបំផុតៈ តំបន់ដែលឋិតក្នុងរង្វង់កាំ១គ.មពីចំណុចអ័ក្សនៃទីតាំងគ្រោងធ្វើជាទីលាន តាមបណ្តោយផ្លូវជាតិលេខ ៣០៣ និងតាមបណ្តោយពាក់កណ្តាលនៃដងស្ទឹងព្រែកត្នោត។ (ចុងខាងក្រោមបំផុតនៃស្ទឹង ទឹកស្ទឹងមិនត្រូវបានប្រើប្រាស់សំរាប់បរិភោគឬចិញ្ចឹមជីវិតឡើយ)។ តំបន់ដែលឋិតនៅក្នុងរង្វង់កាំ១គ.មពីទីលានសំរាមថ្មី រាល់ផ្ទះដែលរស់នៅក្នុងតំបន់នោះត្រូវបានចាត់ទុកថាជាអ្នកពាក់ព័ន្ធ ចំណែកអាជ្ញាធរវិញត្រូវបានអញ្ជើញអោយចូលរួមពីតំបន់ពីរទៀត។

ជាប់តាំងពីវេទការសារធារណៈលើកទី១មក រាល់ផ្ទះដែលឋិតនៅក្នុងរង្វង់នោះត្រូវបានអញ្ជើញអោយចូលរួម។ ភាគីជាដៃគូបានទទូចអោយប្រាប់ដល់រាល់អាជ្ញាធរភូមិនិងសង្កាត់ក្នុងខ័ណ្ឌដង្កោជាមុនសិន ដូច្នេះហើយអាជ្ញាធរទាំងនោះត្រូវបានអញ្ជើញអោយចូលរួមជាលើកទី១។ ចុងក្រោយបំផុត គ្រប់សង្កាត់និងភូមិដែលពាក់ព័ន្ធត្រូវបានអញ្ជើញអោយចូលរួម ចំណែកឯប្រជាជនវិញមានតែតំណាង (ប្រធានក្រុម)ប៉ុណ្ណោះត្រូវបានអញ្ជើញអោយចូលរួម ដោយសារតែទីតាំងប្រជុំមានកំរិត។

អ្នករើសសំរាមនៅទីលានស្ទឹងមានជ័យមិនត្រូវបានអញ្ជើញអោយចូលរួមក្នុងវេទការសារធារណៈទេពីព្រោះគ្មានតំណាងអ្នករើសសំរាមទេ។ ផ្ទុយមកវិញ ការអង្កេតបរិស្ថានសង្គមក្នុងដំណាក់កាលទី១បានព្យាយាមដើម្បីទទួលបានគំនិតយោបល់និងផែនការអនាគតបន្ទាប់ពីទីលានស្ទឹងមានជ័យត្រូវបិទនោះ។ ជាងនេះទៅទៀត រដ្ឋាករគ្រប់គ្រងសំណល់និងក្រុមសិក្សាបានបានរៀបចំការប្រជុំដោយអញ្ជើញអង្គការក្រៅរដ្ឋាភិបាល ប្រធានសហគមន៍នានាដែលពាក់ព័ន្ធយ៉ាងសកម្មជាមួយនិងបញ្ហាអ្នករើសសំរាម ដើម្បីមកផ្លាស់ប្តូរយោបល់ថាតើត្រូវជួយអ្នករើសសំរាមដោយរបៀបណាដើម្បីអោយពួកគេផ្លាស់ប្តូរការងារ។ ជាការចាំបាច់ណាស់សំរាប់សាលាក្រុងភ្នំពេញ-រដ្ឋាករគ្រប់គ្រងសំណល់ក្នុងការរៀបចំការប្រជុំជាប្រចាំរបៀបនេះចាប់តាំងពីពេលនេះទៅនិងដើម្បីបង្កើនទូវយន្តការតាមរយៈដែលអ្នករើសសំរាមអាចទាក់មករដ្ឋាករបានយ៉ាងងាយស្រួល ។

### c.4.2. ការស្ទាបស្ទង់បញ្ជាក់

ទោះបីជាមានវិវត្តសំនួរនិងចំលើយក្នុងវេទិកាសាធារណៈនីមួយៗហើយក៏ដោយ គេរំពឹងថាភាគច្រើននៃអាជ្ញាធរមូលដ្ឋាននិងប្រជាជនមានការលំបាកក្នុងការយល់ពីមាតិការនៃបទបង្ហាញដោយសារតែកំរិតចំណេះដឹងស្តីពីការគ្រប់គ្រងសំណល់រឹងនៅមានកំរិត ហើយប្រជាពលរដ្ឋភាគច្រើនមិនហ៊ានបញ្ចេញមតិយោបល់នៅចំពោះមុខអាជ្ញាធរ។ ដូច្នេះក្រុមសិក្សាបានធ្វើការស្ទាបស្ទង់បញ្ជាក់ឡើងវិញបន្ទាប់ពីវេទិការសារធារណៈនីមួយៗ ដើម្បីចង់ដឹងកំរិតយល់លើបទបង្ហាញនិងដើម្បីទទួលបាននូវគំនិតយោបល់និងការផ្តល់មតិស្តីពីផែនការអភិវឌ្ឍ ។

ភាពលំអិតនៃវេទិការសារធារណៈទាំងបីនិងលទ្ធផលនៃការស្ទាបស្ទង់បញ្ជាក់ត្រូវបានបង្ហាញនៅសេចក្តីបន្ថែម ១៥ (វេទការសារធារណៈលើកទី១និងទី២) និងសេចក្តីបន្ថែម ១៨ (លើកទី៣) ក្នុងរបាយការណ៍ជំនួយ ។

### c.4.3. បញ្ហានានាដែលត្រូវដោះស្រាយ

វេទកាសាធារណៈទាំងបីលើកត្រូវបានរៀបចំឡើងដើម្បីបង្កើតនូវការឯកភាពយល់ស្របគ្នារវាងអ្នកពាក់ព័ន្ធទាំងអស់ និងឆ្លុះបញ្ចាំងនូវមតិយោបល់និងសំនួរស្តីពីផែនការគំរោង ។ វេទកាសាធារណៈផ្តល់នូវឳកាសដល់ទាំងម្ចាស់គំរោងនិងអាជ្ញាធរមូលដ្ឋាននិងប្រជាពលរដ្ឋផ្លាស់ប្តូរយោបល់គ្នា ប៉ុន្តែដោយសារកំរិតចំណេះដឹងស្តីពីការគ្រប់គ្រងសំណល់រឹងរបស់ អាជ្ញាធរមូលដ្ឋាន ប្រជាជន និងអង្គការក្រៅរដ្ឋាភិបាលនៅមានកំរិត អ្នកចូលរួមខ្លះមិនអាចយល់នូវបទបង្ហាញបានទាំងស្រុងទេនៅពេលវេទកាសារធារណៈ ដូចលទ្ធផលនៃការស្ទាបស្ទង់បញ្ជាក់បានបង្ហាញនៅក្រោយពេលវេទកាសារធារណៈនីមួយៗ។ ជាការចាំបាច់ណាស់សំរាប់រដ្ឋាករគ្រប់គ្រងសំណល់ និងសាលាក្រុងភ្នំពេញក្នុងការរៀបចំការប្រជុំរបៀបនេះដើម្បីពង្រីកចំណេះដឹងអោយកាន់តែស៊ីជំរៅថែមទៀតស្តីពីការគ្រប់គ្រងសំណល់រឹងនិងការយល់ដឹងពីផែនការអភិវឌ្ឍ។

ការអភិវឌ្ឍនូវសំភារៈអប់រំតាមរយៈរូបភាពស្តីពីការគ្រប់គ្រងសំណល់រឹងដល់ប្រជាជនគឺជាវិធានការមួយដែលអាចសំរេចបាន។ (គំរូនៃសំផារៈអប់រំដើម្បីពន្យល់ថាតើកន្លែងណាជាកន្លែងត្រូវចាក់សំរាមត្រូវបានបង្កើតឡើងអោយល្អប្រសើររួចមកហើយ)។ វិធីសាស្រ្តនៃបទបង្ហាញ និងស្ទីលគួរតែធ្វើអោយប្រសើរផងដែរ។ កំនិតដែលអាចទៅរួចសំរាប់បុគ្គលិករដ្ឋាករគ្រប់គ្រងសំនល់និងសាលាក្រុងភ្នំពេញក្នុងការទស្សនកិច្ចតាមភូមិនីមួយៗហើយរៀបចំការប្រជុំតូចមួយដើម្បីផ្តល់ពត៌មានចាំបាច់ព្រមតាំងសំភារៈអប់រំមុនពេលដែលការអភិវឌ្ឍត្រូវបានបញ្ចប់ ។

## c.5 សមត្ថភាពរបស់ម្ចាស់គំរោង

ម្ចាស់គំរោងគឺសាលាក្រុងភ្នំពេញ ។ ស្ថាប័នដែលនៅក្រោមការដឹកនាំរបស់សាលាក្រុងភ្នំពេញគឺ រ.គ.ស.ភ និង ម.ប.ស ទទួលខុសត្រូវលើការធ្វើប្រតិបត្តិការណ៍និងត្រួតពិនិត្យគំរោងនិមួយ ៗ ។ ដើម្បីកសាងសមត្ថភាពមន្រ្តីរបស់រ.គ.ស.ភ និងម.ប.ស ក្នុងការងារអនុវត្តគំរោង នោះពួកគេបានទទួលការបណ្តុះបណ្តាលតាមរយះការកែលំអទីលានស្ទឹងមានជ័យ ដែលធ្វើឡើងដោយក្រុមសិក្សា JICA ។

## c.6 ចំណុចដែលត្រូវពិចារណាដោយយកចិត្តទុកដាក់

តាមរយៈលទ្ធផលពីការសិក្សា ហេតុប៉ះពាល់របស់គំរោងលើបរិស្ថានជុំវិញ ត្រូវបានចាត់វិធានការឬអាចកាត់បន្ថយបាន ឬលប់បំបាត់ចោលតាមរយៈវិធីកាត់បន្ថយ និងគំរោងផ្សេងៗទៀតដែលរំពឹងថានឹងត្រូវបានអនុវត្តជាជំនួស ។ ក៏ប៉ុន្តែ ចំណុចពិចារណាជាពិសេសត្រូវតែបានដោះស្រាយដូចខាងក្រោម ។

### c.6.1. ការអនុវត្តន៍ត្រឹមត្រូវ

ទោះបីជាផែនការការរៀបចំ និងការសាងសង់ទីលានដែលបានស្នើនោះ នឹងត្រូវបានបញ្ចប់ក្តីតែការត្រួតពិនិត្យប្រតិបត្តិការណ៍ និងការបិទទីលាន គឺជាការចាំបាច់សំរាប់ធានាឱ្យបាននូវទីលានមួយដែលមានបរិស្ថានល្អ និងអនាម័យ ។ ដូច្នេះក្នុងពេលសាងសង់ ការអនុវត្តន៍ និងការបិទទីលាន ការពិនិត្យជាប់ជាប្រចាំលើការបំពុលឬជ្រាបលើទឹកផ្ទៃទឹក

និងទឹកក្រោមដី ក្លិនបំពុល និងផ្សែងចេញពីទីលានត្រូវតែរៀបចំ។ ខាងក្រោមនេះគឺជាចំនុចសំខាន់ៗ សំរាប់ពិនិត្យលើបរិស្ថាន ។

ដើម្បីបង្កើតនូវប្រព័ន្ធត្រួតពិនិត្យ គេបានស្នើឱ្យមានគណកម្មការត្រួតពិនិត្យគំរោង ។ សមាជិកគណកម្មការត្រូវចូលរួមត្រួតពិនិត្យ និងអង្កេតលក្ខណ្ឌបរិស្ថាននៅទីលាន និងជុំវិញ ។ គណកម្មការនេះអាចមានសមាសភាពមកពី :

- សាលាក្រុងភ្នំពេញ
- ក្រសួងបរិស្ថាន
- មន្ទីរបរិស្ថាន
- អង្គការក្រៅរដ្ឋាភិបាល
- តំណាងពីប្រជាពលរដ្ឋ និងអាជ្ញាធរ

សំរាប់កំឡុងពេលធ្វើការអង្កេត ការអង្កេតផ្ទៃក្នុងដែលធ្វើដោយ រ.គ.ស.ភ ត្រូវអនុវត្តជារៀងរាល់ខែ ឯការងារអង្កេតដែលធ្វើឡើងដោយគណកម្មការចំរុះត្រូវពិនិត្យជារៀងរាល់ពីរដងក្នុងមួយឆ្នាំ ។

### c.6.2. ការកែលំអផ្លូវ

យោងលើការប្រមូលនិងដឹកជញ្ជូនសំរាមដែលចែងក្នុងផែនការមេនេះរថយន្តប្រមូលនឹងត្រូវធ្វើចរាចរណ៍ ៣២២ ជើងក្នុងឆ្នាំ ២០០៧។ ដូច្នេះចំនួនជើងដែលបានប្រមូលដោយរថយន្ត មិនជាច្រើនប៉ុន្មានទេ ក៏ប៉ុន្តែផ្លូវមានសភាពទ្រុឌទ្រោមខ្វះការថែទាំ ។ ចំនុចមួយចំនួនលើផ្នែកបរិស្ថានអាចប៉ះពាល់ :

- សំឡេង
- ស្ទះចរាចរ
- ផ្សែងបំពុល

សំរាប់ការចាត់វិធានការ គឺការចាក់ក្រាលផ្លូវឱ្យបានស្អាតដែលក្នុងនោះ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងអភិវឌ្ឍន៍គំរោងអភិវឌ្ឍន៍ទេសចរណ៍ទន្លេមេគង្គ ។ ផ្លូវជាតិ៣០៣ នឹងត្រូវកែលំអដោយភ្ជាប់ពីភ្នំពេញទៅតំបន់ប្រល័យពូជសាសន៍ជើងឯក ។ កំណាត់ផ្លូវចូលដល់ច្រកទីលាន ក៏នឹងត្រូវកែលំអផងដែរដោយគំរោង ។ ដូច្នេះបញ្ហាសំឡេងចរាចរនិងផ្សែងបំពុលនឹងត្រូវបានដោះស្រាយ ។

### c.6.3. វិធានការសំរាប់អ្នកដែលបានលក់ដីមកអោយគំរោង

ម្ចាស់ដីនឹងត្រូវបាត់បង់ដីដែលប្រើប្រាស់សំរាប់កសិកម្មដោយការលក់ដីនោះមកអោយគំរោង។ ម្ចាស់ដីទាំងនោះត្រូវបានអនុញ្ញាតិអោយបន្តការដាំដុះរហូតដល់ការងារសាងសង់នឹងត្រូវចាប់ផ្តើម ប៉ុន្តែមិនអនុញ្ញាតអោយក្រោយពេលការអភិវឌ្ឍទេ។ ដូច្នេះ សាលាក្រុងភ្នំពេញត្រូវស្នើអោយរៀបចំការងារដូចជា កម្មករសំណង់ក្នុងពេលសាងសង់ កម្មករទីលានចាក់សំរាមក្នុងដំណាក់កាលប្រតិបត្តិ។

## d. ការវាយតំលៃលើហិរញ្ញកិច្ច និងសេដ្ឋកិច្ច

### d.1 ចំណុចសំខាន់ៗ

ទីលានស្ទឹងមានជ័យដែលនាពេលបច្ចុប្បន្នកំពុងនឹងបានប្រមូលកាកសំណល់រឹងពីទីក្រុងភ្នំពេញ នឹងត្រូវបញ្ចប់ជីវិតនៃការចាក់សំរាមយ៉ាងឆាប់ខាងមុខ។ ដូច្នេះវាមានសារៈសំខាន់ណាស់ដែលគេត្រូវធ្វើការអភិវឌ្ឍន៍ទីលានថ្មីក្នុង ពេលពីរឬបីឆ្នាំខាងមុខនេះ។

ដើម្បីឆ្លើយតបទៅនិងបញ្ហានេះ គំរោងមួយត្រូវបានរៀបចំដើម្បីអភិវឌ្ឍន៍ និងធ្វើប្រតិបត្តិការណ៍ ទីលានចាក់សំរាមថ្មីដែលមានផ្ទៃក្រឡាសរុប ១០០ ហ.ត នៅតំបន់ដង្កោហើយដែលនឹងត្រូវប្រើប្រាស់ក្នុង រយះពេល ២០ឆ្នាំចាប់តាំងពីឆ្នាំ ២០០៧តទៅ ។ ការសិក្សានេះបានវិភាគទៅលើលទ្ធភាពហិរញ្ញកិច្ច និងសេដ្ឋកិច្ចលើការអភិវឌ្ឍគំរោងលើផ្ទៃដី៣១.៤ហិចតាក្នុងដំណាក់កាលទី១នៃទីលានថ្មីនេះ។

### d.2 ការវាយតម្លៃលើផ្នែកហិរញ្ញវត្ថុ

### d.2.1. បុរេលក្ខ័ណ្ឌក្នុងការវាយតម្លៃលើផ្នែកហិរញ្ញវត្ថុ

ការវាយតំលៃលើផ្នែកហិរញ្ញវត្ថុលើការងារអភិវឌ្ឍន៍ និងប្រតិបត្តិការណ៍ទីលានដង្កោនេះត្រូវបានធ្វើឡើងដោយផ្អែកលើបុរេលក្ខ័ណ្ឌមួយចំនួន ។

Table 6-8: បុរេលក្ខ័ណ្ឌសំរាប់ការវាយតំលៃលើផ្នែកហិរញ្ញវត្ថុរបស់គំរោង

| | |
|---|---|
| **ស្ថាប័នអនុវត្តគំរោង** | រ.គ.ស.ភ |
| **ដំណាក់កាលនៃគំរោង** | ១១ឆ្នាំចាប់តាំងពីឆ្នាំ២០០៥ ដល់ ២០១៥ (តែទោះជាយ៉ាងណាក៏អាយុកាលនៃទីលាន មានតែ២០ឆ្នាំចាប់តាំងពី ២០០៧ទៅ) ។ |
| **ប្រាក់ចំនូលពីគំរោង** | • ការប្រមូលថ្លៃចាក់សំរាមនៅទីលានដែលបានមកពីអតិថិជនពីឆ្នាំ ២០០៧ ដល់ឆ្នាំ ២០១៥ (ប្រសិទ្ធិភាពនៃការប្រមូលថ្លៃត្រូវបានកំណត់ ១០០%) ។<br>• ចំណូលបានមកពីការជីកអាចម៍ដីលក់ដែលប្រមាណ ៣ដុល្លាក្នុងមួយម៉ែត្រគូប (ចំណូលប្រចាំឆ្នាំប្រមាណ២៧៥,០០០ដុល្លាត្រូវបានគេប៉ាន់ស្មានក្នុងរយៈពេល ២០០៧-២០១៥ ។<br>• ចំណូលពីការលក់ជីកំប៉ុស្តដែលមានតំលៃប្រមាណ២០០/គ.ក្រ (ចំណូលប្រចាំឆ្នាំ ប្រមាណ ៦១,២៥០ដុល្លា ក៏ត្រូវបានគេធ្វើការប៉ាន់ស្មានពី ២០០៧-២០១៥) ។ |
| **តំលៃវិនិយោគ** | ការវិនិយោគដំបូងដូចខាងក្រោមនេះនឹងត្រូវធ្វើនៅឆ្នាំ ២០០៥ ដល់ ២០០៦:<br>២០០៤ : ការទិញដី ៣១,៤ហ.ត<br>២០០៥ ដល់២០០៦: រៀបចំ និងការសាងសង់ទីលាននិងកន្លែងធ្វើជីកំប៉ុស្ត ការអភិវឌ្ឍន៍ដំណាក់កាលទីពីរនៃការងារទីលាននឹងចាប់ផ្តើមនៅឆ្នាំ ២០១២ សំរាប់ការងារ អនុវត្តនាឆ្នាំ ២០១៣។ |
| **តំលៃប្រតិបត្តិការណ៍ និងថែរក្សា** | តំលៃប្រតិបត្តិការណ៍ និងថែរក្សាត្រូវបានគិតសំរាប់រាល់ឆ្នាំពី ២០០៧ ដល២០១៥ ដោយយោងលើតំលៃឯកតា និងបរិមាណដែលបានកំណត់ ។ ការធ្វើជីកំប៉ុស និងតំលៃទីលានក៏ត្រូវបានបញ្ចូលដែរ ។ |
| **តំលៃរំលោះ** | តំបន់សំរាប់ការប្រើប្រាស់ជារួមនោះ ដូចជាផ្លូវ អាគាររដ្ឋបាល ការយកឧស្ម័ន និង បរិក្ខាចំរោះនឹងត្រូវរំលោះក្នុរយះពេល២០ឆ្នាំ។ សំរាប់ទីលានផ្ទាល់នោះ ដំណាក់កាលទីមួយនឹងត្រូវបានរំលោះទាំងស្រុងក្នុងរយះពេល ៦ឆ្នាំព្រមទាំងដំណាក់កាលទីពីរនោះក្នុងតែរយៈពេល ៣ឆ្នាំប៉ុណ្ណោះនៅក្នុងការអភិវឌ្ឍន៍នៅដំណាក់កាលទីពីរ ។ ចំពោះការងារធ្វើជីកំប៉ុស គេនឹងត្រូវ បានរំលោះគ្រឿងបរិក្ខាក្នុងពេល ១៥ឆ្នាំ ហើយនិងគ្រឿងចក្រ (wheel loader and trommel) ក្នុងរយះពេល ៧ឆ្នាំក្នុងតំលៃកំហាតប្រមាណ ១០% ។ |
| **ថ្លៃទីផ្សារ** | តំលៃប៉ាន់ស្មានទាំងអស់គឺយោងតាមអត្រាថ្លៃទីផ្សារបច្ចុប្បន្នឆ្នាំ ២០០៤មិនគិតបញ្ចូលថ្លៃបំប៉ោងទេ ។ |
| **អត្រាបញ្ចុះតម្លៃ** | ១០% (ដូចគំរោងប្រមូលសំណល់រឹង និងគំរោងអភិវឌ្ឍន៍ខាងលើដែរ) ។ |

ចំណាំ : ១- រយៈពេលទីលាន គឺអាស្រ័យលើ រយៈពេលនៃសមត្ថភាពដែលអាចផ្ទុក

២- តំលៃដែលនៅសល់សំរាប់ហេដ្ឋារចនាសម្ពន្ធ័ក្រោយ ១៥ឆ្នាំ ក៏រាប់បញ្ចូលជាផលចំណេញ

### d.2.2. ការវាយតំលៃលើហិរញ្ញកិច្ច

ចំពោះការវាយតំលៃផ្នែកហិរញ្ញកិច្ចនៃគំរោងផែនកាមេនោះ គេបានពិនិត្រលើសេណារីយ៉ូពីរសំខាន់ៗ : ជាមួយនិងការមិនមានផ្តល់ជំនួយគ្មានសំណង និងកាផ្តល់ជំនួយគ្មានសំណង ។

#### ១) - ករណីយមិនមានផ្តល់ជំនួយគ្មានសំណង

ការសិក្សាបានពិនិត្រថា តើប្រាក់ថ្លៃទីលានគួរត្រូវយកកំរិតណាជាមូលដ្ឋានដើម្បីអោយទទួលបាន FIRR ១០%ឬច្រើនជាងនេះ ជាមួយនិងអត្រាចុះតំលៃដូចគ្នាទៅនិងការវាយតំលៃហិរញ្ញកិច្ចសំរាប់ផែនកាមេដែរ ។

Table 6-9: អត្រាថ្លៃចាក់សំរាមនៅទីលាន និងលទ្ធភាពនៃហិរញ្ញវត្ថុ

| អត្រាថ្លៃទីលាន (ដុល្លាក្នុង១តោន) | តំលៃពិតប្រាកដនាពេលបច្ចុប្បន្ន (ដុល្លា) | អត្រាហិរញ្ញវត្ថុដែលនឹងទទួលបានវិញ (%) |
|---|---|---|
| ១ | -១០.00២.២៣៤ | -១៣,១៥ |
| ២ | -៧.៩៦៧.៦៨៩ | -៧,៨១ |
| ៣ | -៥.៩៣៣.១៤៣ | -២,៨៣ |
| ៤ | -៣.៨៩៨.៥៩៨ | ១,៨២ |
| ៥ | -១.៨៦៤.0៥៣ | ៦,២0 |
| ៦ | ១៧0.៤៩៣ | ១0,៣៤ |

ចំណាំ: អត្រាចុះថ្លៃត្រូវបានកំណត់ ១0%

ដូចបានបង្ហាញនៅតារាងខាងលើ ថ្លៃសេវាទីលានត្រូវការប្រមាណ៥,៩២ដុល្លា/មួយតោនសំរាម ដើម្បីទទួលបាននូវអត្រាចំនួលដែលនឹងទទួលបានវិញ ១0%នោះ (EIRR) ។ យោងតាមតំលៃនេះ តំលៃប្រតិបត្តិការណ៍ទីលាននាពេលបច្ចុប្បន្នមានតិចជាង១ដុល្លាប៉ុណ្ណោះ ។ សព្វថ្ងៃនេះ រ.គ.ស.ភ ក៏រិតតែប្រមាណ 0.៥៦ដុល្លា ប៉ុណ្ណោះពីក្រុមហ៊ុនស៊ិនទ្រី ហើយដែលតំលៃនឹងត្រូវទទួលបានគឺប្រមាណ ១១ដង ច្រើនជាងតំលៃបច្ចុប្បន្ន។ មានន័យថា ទីលានថ្មីនឹងមិនមានកំរៃដូចជាការវិនិយោគតាមបែបឯកជននោះ ប្រសិនបើគ្មានជំនួយពីខាងក្រៅ។

#### ២) - ករណីយមានផ្តល់ជំនួយគ្មានសំណង

ការសិក្សាបានពិនិត្យថាតើប្រាក់ថ្លៃទីលានគួរត្រូវបានចុះបន្ថយប្រសិនបើការវិនិយោគតំបូងចាប់តាំងពីឆ្នាំ២00៤-២00៦ ដោយរាប់បញ្ចូលទាំងការទិញដី (ដែលនឹងត្រូវបានធានាដោយរដ្ឋាភិបាល) ត្រូវបានរាប់រងដោយជំនួយគ្មានសំណង ។ ស្ថេរភាពហិរញ្ញកិច្ចនៃគំរោងអាចធានាបាន លុះណាតែគេអាចធានាធនគ្រប់គ្រានសំរាប់រាប់រងតំលៃវិនិយោគសរុប (តំលៃរំលោះ តំលៃវិនិយោគលើគ្រឿងចក្របន្ថែម និងតំលៃប្រតិបត្តិការណ៏) ក្នុងកំឡុងពេលគំរោងទាំងមូល ។ ក្រាភិចខាងក្រោមបង្ហាញអំពីនិន្នាការនៃគំរោងដោយយោងលើមូលដ្ឋានបញ្ចុះតំលៃ [១] ក៏ដូចជាការចំណាយពិតប្រាកដក្នុងករណីមានជំនួយគ្មានសំណង ។

ដូចបញ្ជាក់ខាងលើការវិនិយោគលើគំរោងត្រូវបានបង្កើនល្បឿនយ៉ាងខ្លាំងចាប់ពីឆ្នាំ ២0១១-២0១៣ នៅពេលដែលតំណាក់កាលទីពីរនៃការអភិវឌ្ឍន៏ទីលានចាប់ផ្តើមដំណើរការ ។ម្យ៉ាងវិញទៀតតាមតំលៃរំលោះ នឹងត្រូវបាន

---

[១] តំលៃគំរោងក្នុងឆ្នាំនិមួយៗដោយផ្អែកលើមូលដ្ឋានបញ្ចុះតំលៃ រួមមានការចំណាយដោយបញ្ចុះថ្លៃ ថ្លៃរបតិបត្តិកាណ៏និងថែទាំ និងថ្លៃវិនិយោគលើសំភារះបន្ថែមនៅពេលដែលថ្លៃគំរោង ទៅលើការចំណាយបានបញ្ជាក់ពីការចំណាយពិតប្រាកដ សំរាប់ឆ្នាំនិមួយៗ ។

ដោះស្រាយតាមឆ្នាំនិមួយៗ ដូចគ្នាតាមតំលៃដែលបានកំណត់ ដូច្នេះការកើនឡើងនៃកំរៃពីវិនិយោគគឺពិតជាមានសន្ទុះ ។ តែទោះជាយ៉ាងណាក្តី ការវិភាគបង្ហាញថានៅក្នុងការវិនិយោគពិតប្រាកដវាចាំបាច់ត្រូវធានានូវប្រាក់ចំណូលសំរាប់តំណាក់កាលទីពីរនៃការអភិវឌ្ឍន៍ទីលានពីឆ្នាំ ២០១២ ដល់២០១៣ ។

ដើម្បីអោយគំរោងមានស្ថេភាពលើថវិកា នោះប្រាក់ចំនូលបានពីគំរោងត្រូវតែឆ្លើយតបចំនុចខាងក្រោម :

- ប្រាក់ប្រចាំឆ្នាំ គឺលើសអំពីតំលៃដែលបានគិតលើមូលដ្ឋានរំលោះ និង
- ប្រាក់បំរុងសំរាប់គំរោង (កំនើនពិតប្រាកដ) ត្រូវលើសតំលៃតំរូវការសំរាប់តំលៃដែលបានធ្វើការប៉ាន់ស្មានលើមូលដ្ឋានចំណាយពិតប្រាកដ ។

លទ្ធផលនៃការវិភាគបង្ហាញថា តំលៃទីលានសមស្របមួយដែលនឹងកំរិតលើមូលដ្ឋាននៃទំងន់សំរាមដែលនឹងឆ្លើយតបទៅនិងលក្ខណទាំងពីរខាងលើគឺ ៤.៤០ ដុល្លាសំរាប់មួយតោន (ជាប្រាកដគឺ ៣.៣៦ ដុល្លា) ។

ថ្លៃទីលានដែលស្មើនិង៤.៤០ដុល្លា/តោននៃសំរាមគឺស្មើនិង៨ដងនៃតំលៃចាក់សំរាមនាឆ្នាំ ២០០២។ ដែលក្នុងនោះទាំងស៊ិនទ្រី និង រ.ក.ស.ភ ត្រូវតែរ៉ាប់រងតំលៃសំរាប់ទីលានមួយដែលមានបច្ចេកទេសសមស្រប ។ កំនើននៃតំលៃចាក់នៅទីលាននឹងប៉ះពាល់ដល់ការប្រមូលកំរៃសេវាកម្មដែលបានផ្តល់សេវាកម្មដោយស៊ីនទ្រីនិងរដ្ឋាករ។

## d.3 ការវាយតម្លៃលើផ្នែកសេដ្ឋកិច្ច

ការវិភាគលើបែបសេដ្ឋកិច្ចអំពីប្រសិទ្ធភាពនៃតំលៃនៃការអភិវឌ្ឍន៍ទីលានដង្កោ រាប់បញ្ចូលចំនុចខាងក្រោម ។

- ការវិភាគបរិមាណអំពីប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនៃការអភិវឌ្ឍន៍ការងារធ្វើជីកំប៉ុស ។
- ការវិភាគបរិមាណអំពីប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនៃគំរោងទាំងមូល ។

ទោះបីជាថាការវិភាគលើហិរញ្ញវត្ថុកិច្ច និងផលប្រយោជន៍នោះ មានលទ្ធផលប្រសើក្តី ប៉ុន្តែប្រយោជន៍ពីទីលានដង្កោ ជាពិសេសលើការកែលំអរ សុខភាព និងអនាម័យនៃប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជិតខាង និងការកាត់បន្ថយផ្សែងបំពុល និងការជ្រាបទឹក មិនស្អាតពីក្រោមដីជាការលំបាកសំ រាប់ការថ្លឹងថ្លែងលើផលនៃគំរោង អោយទៅជាតំលៃមួយពិតប្រាកដ និងមានភាពត្រឹមត្រូវជាបរិមាណដោយមានទិន្នន័យ និងវិធីសាស្រពិតប្រាកដ ។

### d.3.1. ការវិភាគបរិមាណអំពីប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនៃការអភិវឌ្ឍន៍ការងារធ្វើជីកំប៉ុសនៅទីលានដង្កោ

### ១) បុរេលក្ខណសំរាប់ការវិភាគទៅលើប្រសិទ្ធភាពសេដ្ឋកិច្ចនៃការធ្វើជីកំប៉ុស

ដើម្បីធ្វើការសិក្សា ក្រុមសិក្សាបានបង្កើតបុរេលក្ខណសំរាប់ធ្វើការការសន្និដ្ឋានដូចខាងក្រោម ។

Table 6-10: បុរេលក្ខ័ណ្ឌសំរាប់ការវាយតំលៃលើផ្នែកហិរញ្ញវត្ថុរបស់គំរោង

| | |
|---|---|
| ស្ថាប័នអនុវត្តគំរោង | រ.គ.ស.ភ |
| តំណាក់កាលនៃគំរោង | ១០ឆ្នាំ ចាប់តាំងពីឆ្នាំ២០០៥ ដល់ ២០១៥ ។ |
| ប្រាក់ចំនូលពីគំរោង | • ចំណូលបានមកពីការលក់ជីកំប៉ុសនៅកន្លែងផលិតមានប្រមាណ១០០-៥០០ រៀល/គ.ក្រ (បរិមាណផលិតក្នុងមួយឆ្នាំមាន ប្រមាណ ១,២២៥ ត)។<br>• ការបញ្ចុះតំលៃចាក់សំរាមនៅទីលានគឺអាស្រ័យលើទំហំនៃការផលិតជីកំប៉ុស ។ ការចុះថ្លៃមានប្រមាណ៦៦៨៣.៥ដុល្លា/ឆ្នាំ ដែលតំលៃនៃការចាក់សំរាមក្នុងមួយ តោន (៥.២៦ដុល្លា/ត ដើម្បីសំរេចអោយបាន ១០% នៃ IRR ក្នុងករណីយមិនមាន |

| | |
|---|---|
| | ជំនួយ) គុណនិង ១.២២៥ត នៃសំរាមដែលបានប្រែក្លាយជាជីកំប៉ុស ។ |
| **តំលៃវិនិយោគ** | • ការវិនិយោគដំបូងដូចខាងក្រោមនេះនឹងត្រូវធ្វើនៅឆ្នាំ ២០០៥ ដល់ ២០០៦: តំលៃរៀបចំហេដ្ឋារចនាសម្ពន័ : ៧០,០០០ដុល្លា(២០០៥: ៤២,០០០, និង ២០០៦: ២៨,០០០ ដុល្លា)<br>• តំលៃសាងសង់ហេដ្ឋារចនាសម្ពន័ : ៦៩៨,០០០ ដុល្លា (២០០៦)<br>• តំលៃទិញគ្រឿងចក្រ : ១១០,០០០ ដុល្លា (២០០៦) |
| **តំលៃប្រតិបត្តិការណ៍ និងថែរក្សា** | តំលៃប្រតិបត្តិការណ៍ និងថែរក្សាត្រូវបានគិតសំរាប់រាល់ឆ្នាំពី ២០០៧ ដល់ ២០១៥ ដោយយោងលើតំលៃឯកតា និងបរិមាណដែលបានកំណត់ ។ |
| **តំលៃរំលោះ** | គ្រឿងបរិក្ខារទាំងឡាយនឹងត្រូវរំលោះទាំងស្រុងក្នុងរយះពេល ១៥ ហើយនិង៧ឆ្នាំសំរាប់គ្រឿងចក្រជាមួយនិងតំលៃកំហាតបង់ ១០% ហើយត្រូវជំនួសដោយវិនិយោគនៅឆ្នាំទី៧ ក្រោយពីការចាប់ផ្តើម ។ |
| **ថ្លៃទីផ្សារ** | តំលៃប៉ាន់ស្មានទាំងអស់គឺយោងតាមអត្រាថ្លៃទីផ្សារបច្ចុប្បន្នឆ្នាំ២០០៤។ មិនគិតបញ្ចូលថ្លៃបំប៉ោងទេ ។ |

## ២) លទ្ធផលនៃការវិភាគលើប្រសិទ្ធភាពសេដ្ឋកិច្ច

យោងលើការបុរេលក្ខណខាងលើ EIRR ត្រូវបានគិតជាមួយនិង តំលៃលក់ជីកំប៉ុសចាប់ពី ១០០-៥០០ រៀល។ លទ្ធផលមានដូចខាងក្រោម ។

Table 6-11: EIRR នៃគំរោងធ្វើជីកំប៉ុស

| តំលៃកំប៉ុស រ/គ.ក្រ | ចំណូលប្រចាំឆ្នាំ (ដុល្លា/ឆ្នាំ) | EIRR (%) |
|---|---|---|
| ១០០ | ៣៧,៦២៨ | -១០.៥១ |
| ២០០ | ៦៧,៨៩៣ | -៥.៨៥ |
| ៣០០ | ៩៨,៥១៨ | -១.៣៦ |
| ៤០០ | ១២៩,១៤៣ | ២.៩៨ |
| ៥០០ | ១៥៩,៧៦៨ | ៧.១៨ |

ដូចមានបង្ហាញក្នុងតារាងខាងលើ ដើម្បីទទួលបាននូវតំលៃវិជ្ជមានពី EIRR គេត្រូវលក់ជីកំប៉ុសក្នុងតំលៃលើ ៣០០រ/គ.ក្រ។ បើគេអាចលក់បាន ៤០០រ/គ.ក្រ EIRR (តំលៃគំរោង) នឹងមានប្រមាណ ៣% ។

### d.3.2. ការវិភាគបរិមាណអំពីកំរៃនៃគំរោង

បន្ថែមទៅលើកំរៃជាបរិមាណនៃជីកំប៉ុស ដែលបានធ្វើការគិតគូរកន្លងមកការអនុវត្តន៏លើទីលានដង្កោនឹងផ្តល់មកនូវផលចំណេញជាច្រើនដល់ទីក្រុងភ្នំពេញទោះបីជាមាការលំបាកនឹងគិតជាតំលៃបរិមាណក្តី ។

- **ការការពារពីផលប៉ះពាល់លើបរិដ្ឋានជុំវិញដោយសារការយឺតយ៉ាវលើការបិទទីលានស្ទឹងមានជ័យ**

ទីលានស្ទឹងមានជ័យនឹងត្រូវបានគេគិតថានឹងត្រូវចាក់បំពេញពេញនៅកំឡុងពេលពីរឬបីឆ្នាំខាងមុខ ។ ប្រសិនបើការងារអភិវឌ្ឍន៍ទីលានដង្កោមិនមានដំណើរការប្រសើរទេ នោះទីលានចាស់នឹងត្រូវបានគេប្រើអោយហួសកំរិត ។ ការប្រើប្រាស់ទីលានដែលមិនមានវិធានការណ៍សមស្របនេះ នឹងបណ្តាលអោយមានការបាក់និងការហូរចំរោះដី និងសំរាមព្រមទាំងការហូរជ្រាបនៃទឹកសំអុយទៅតំបន់ជុំវិញដែលបណ្តាលមកពីភ្លៀង ។ កត្តានេះនឹងមិនគ្រាន់តែប៉ះពាល់សុវត្ថភាព និងអនាម័យបរិដ្ឋានទេ តែក៏មានផលប៉ះពាលអវិជ្ជមានយ៉ាធ្ងន់ធ្ងរទៅលើសុខភាព និងសេដ្ឋកិច្ចរបស់ប្រជាជន និងកសិករក្នុងតំបន់ក្បែរនោះ ។ ការអភិវឌ្ឍន៍ និងប្រតិបត្តការសមស្របនៃទីលានអនាម័យថ្មីនឹងនាំទៅកាន់ការទប់ស្កាត់ទាំងនោះ ។

- **ការទប់ស្កាត់ការចាក់សំរាមដោយអនាធិតេយ្យ**

បន្ថែមលើការប្រើប្រាស់ទីលានហួសពីសមត្ថភាពនោះការពន្យារការសាងសង់ទីលានថ្មីនឹងនាំមកនូវការចាក់សំរាមគ្មានរបៀប ដែលបណ្តាលរអាយមានការបាត់បង់ទីលានមួយដែលត្រឹមត្រូវតាមបច្ចេកទេស ។ ដូចដែលបានឃើញនៅតំបន់ខ្លះក្នុងក្រុងភ្នំពេញ ការចាក់សំរាមបែបនោះនឹងបណ្តាលអោយមានការប៉ះពាល់លើបរិដ្ឋានទឹកដោយសារការបង្ហូរទៅក្នុងទន្លេ និងបរិដ្ឋានជុំវិញ ក៏ដូចជាការប៉ះពាល់ដល់ប្រភពម្ហូបអាហារសំរាប់ប្រជាពលរដ្ឋ ។ ជាងនេះទៀតការចាក់ សំរាមដោយអនាធិបតេយ្យនឹងបណ្តាលអោយមានការរីករាលដាលការបំពុលបរិដ្ឋាន និងបាត់បង់សំរស់ទីក្រុង ។ ការ អភិវឌ្ឍន៍ទីលានថ្មីនឹងធ្វើអោយមានកាកាត់បន្ថយការចាក់សំរាមពាសវាលពាសកាល ។

- **ការកែលំអរការចាប់អារម្មណ៏សោភ័ណភាពទីក្រុងភ្នំពេញតាមរយៈការយល់ដឹងពីបរិដ្ឋានទីក្រុងស្អាត**

ការអភិវឌ្ឍន៍ និងការធ្វើប្រតិបត្តិការណ៏សមស្របនៅទីលានថ្មី នឹងនាំមកនូវការកែលំអរបរិដ្ឋាន និងសំរស់ទីក្រុងព្រមទាំងដើរតួរនាទីសំខាន់ក្នុងការកែលំអរលទ្ធភាពរ និងមុខមាត់របស់ទីក្រុង ។ សំរាប់ការផ្តល់ជាជំហានតំបូងដល់ប្រទេសកម្ពុជា និងទីក្រុងភ្នំពេញលើការងារអភិវឌ្ឍន៏សេដ្ឋកិច្ចប្រកបដោយនិរន្តរភាព គេត្រូវរៀបចំអោយមានបរិដ្ឋានទីក្រុងមួយដែលសមស្របដែលនេះជាកត្តាសំខាន់បំផុតដើម្បីធ្វើអោយមានសកម្មភាពសេដ្ឋកិច្ច តាមរយៈការវិនិយោគបរទេស និងទេសចរណ៏ ជាដើម ។ លើបញ្ហានេះ កំរៃដែលនឹងបានមកពីការងារអភិវឌ្ឍនទីលាន ពិតជាមិនតិចតទួចទេ ។

- **ការជុំរុញសកម្មភាពសេដ្ឋកិច្ចដែលអាចពាក់ពន្ធ័**

ទីលានដង្កោផ្តល់មិនត្រឹមតែការគ្រប់គ្រងកាកសំនល់រឹងដោយទីលានអនាម័យប៉ណ្ណោះទេ តែក៏មានសកម្មភាពបរិស្ថានផ្សេងៗទៀតដូចជាកាផលិតជីកំប៉ុសនឹងត្រូវផលិតនៅនិងកន្លែង ។ ទោះបីជាមានតំរូវការបន្ថែមនូវតំលៃសំរាប់វិនិយោគក្តី តែការព្យាយាមនេះនឹងជួយបង្កើតបច្ចេកវិទ្យាថ្មី ដែលមិនធ្លាប់មានកន្លងមក (ដូចជាការយកឧស្ម័នមេតានពីទីលាន) ការអភិវឌ្ឍន៏ធនធានមនុស្ស និង ការធ្វើអោយមាន សកម្មភាពឧស្សាហកម្ម និងសេដ្ឋកិច្ច ។ ទោះបីជាកំរៃខាងលើមានការលំបាកនឹងធ្វើការប៉ាន់ស្មាន ជាបរិមាណតែវាត្រូវបានគេគិតគួរថា កត្តានេះនឹងអាចធ្វើការទូទាត់បានជាមួយនិងតំលៃអនុវត្តគំរោង ។

# 6.3 គំរោងពង្រីកសេវាកម្មប្រមូលសំរាម

## 6.3.1 គោលគំនិតរៀបចំ

ដោយយោងលើផែនការមេ សាលាក្រុងភ្នំពេញ និងរដ្ឋាករត្រូវព្យាយាមលុបបំបាត់តំបន់ដែលមិនមានសេវាកម្ម និងតំបន់ដែលមានសេវាកម្មតែមិនទាន់សមស្របនោះ ដោយសហការណ៏ជាមួយក្រុមហ៊ុនឯកជន ។ អ្វីដែលសាលាក្រុងត្រូវធ្វើគឺផ្តល់សេវាកម្មដល់តំបន់ដែលក្រុមហ៊ុន ស៊ីនទ្រីមិនបានធ្វើដែលជាតំបន់ដែលមិនមានកំរៃ

ផ្នែកសេដ្ឋកិច្ចនៅតាមខណ្ឌជាយក្រុងទាំងបី ។ គំរោងនេះ ត្រូវបង្កើតប្រព័ន្ធប្រមូលសំនល់សំរាប់រដ្ឋាករដែលជាស្ថាប័នប្រតិបត្ត ដើម្បីមានលទ្ធភាពពង្រីកសេវាកម្មទៅតំបន់ទាំងនោះជាបន្ត ។

## 6.3.2 ការរៀបចំចំណុចសំខាន់ៗ

### a. លក្ខណ្ឌនៃផែនការ

#### a.1 ឆ្នាំគោលដៅ

សេវាកម្មប្រមូលដោយ រ.គ.ស.ភនឹងចាប់នៅឆ្នាំ ២០០៧ ។

#### a.2 តំបន់ទិសដៅនៃសេវាកម្មប្រមូលសំរាម :

រដ្ឋាករត្រូវផ្តល់សេវាកម្មដល់តំបន់ដែលមិនមានសេវាកម្ម ។ តែទោះជាយ៉ាងណាក្តី វាអាស្រ័យលើការចរចាររវាងសាលាក្រុង និងក្រុមហ៊ុនឯកជនអោយបានចប់ជាស្ថាពរនាចុងខែ កុម្ភៈ ២០០៥។ ក្រុមសិក្សារៀបចំគំរោងនេះ ដោយយោងលើបរិមាណសំនល់ដែលធ្វើការប៉ាន់ស្មាន ដូចបានបង្ហាញក្នុងតារាងខាងក្រោម ។

#### a.3 បរិមាណប្រមូលដែលបានធ្វើផែនការ

ក្រុមសិក្សាបានធ្វើការប៉ាន់ស្មានបរិមាណសំនល់សំរាប់រដ្ឋាករ គឺអាស្រ័យទៅលើការសិក្សាលើតំបន់ និងទិន្នន័យពីជញ្ជីងនៅឯទីលាន ហើយធ្វើការសន្និដ្ឋានដូចខាងក្រោម ។

- ការប្រមូលសំនល់ប្រចាំថ្ងៃរបស់ក្រុមហ៊ុនឯកជន គឺជាបរិមាណសំនល់ដែលនាំចូលទីលាននាខែ តុលា និងវិច្ឆិកា ២០០៥ ។
- ការប្រមូលសំនល់ដោយក្រុមហ៊ុនឯកជន នឹងមានកំណើនប្រមាណ ១០ ភាគរយនៅតាមខណ្ឌទាំងបីជារាងរាល់ឆ្នាំក្រោយឆ្នាំ ២០០៤ ។
- បរិមាណដែលនឹងប្រមូលដោយរដ្ឋាករ នឹងមានការខុសគ្នាពីបរិមាណដែលស្នើរដោយផែនការ មេ និងបរិមាណដែលនឹងប្រមូលដោយក្រុមហ៊ុនឯកជន ។

Table 6-12: បរិមាណប្រមូលដែលមានធ្វើផែនការ

| បរិមាណ | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|---|---|
| Households | 82.6 | 100.2 | 116.7 | 132 | 145.9 | 158.5 | 188.2 | 216.2 | 242.1 |
| Commercial-Restaurants | 8.1 | 8.5 | 9.3 | 9.9 | 9.9 | 13.3 | 13.5 | 13.6 | 17.5 |
| Commercial-Others | 20.6 | 22.1 | 24.5 | 26.5 | 26.7 | 36.3 | 37.2 | 38.1 | 49.1 |
| Markets | 14.1 | 15 | 16.5 | 17.8 | 17.9 | 24.2 | 24.7 | 25.2 | 32.4 |
| Hotels | 0.4 | 0.5 | 0.5 | 0.6 | 0.6 | 0.8 | 0.8 | 0.8 | 1 |
| Offices | 0.1 | 0.2 | 0.2 | 0.2 | 0.2 | 0.3 | 0.3 | 0.3 | 0.4 |
| Schools | 1.4 | 1.4 | 1.6 | 1.7 | 1.7 | 2.3 | 2.3 | 2.3 | 3 |
| Factories | 15.9 | 16.5 | 17.9 | 19 | 18.8 | 25.1 | 25.4 | 25.6 | 32.8 |
| Hospitals | 2.7 | 2.8 | 3 | 3.2 | 3.1 | 4.2 | 4.3 | 4.3 | 5.5 |
| Slaughter House | 1.9 | 2 | 2.1 | 2.2 | 2.2 | 2.9 | 2.9 | 2.9 | 3.7 |
| Unidentified source | 8.4 | 9.2 | 10 | 10.9 | 11.8 | 12.7 | 13.7 | 15 | 16.2 |
| Street Sweeping | 0.3 | 0.3 | 0.4 | 0.4 | 0.4 | 0.5 | 0.5 | 0.5 | 0.7 |
| TOTAL | 156.5 | 178.7 | 202.7 | 224.4 | 239.2 | 281.1 | 313.8 | 344.8 | 404.4 |

### a.4 ការថែរក្សាគ្រឿងចក្រ

ការថែរក្សាគ្រឿងចក្រត្រូវបានធ្វើឡើងនៅរោងជាងដែលមាននៅទីលាន ។ ការជួសជុលក្នុងទ្រង់ទ្រាយធំត្រូវធ្វើការម៉ៅការឱ្យក្រុមហ៊ុន ។

### b. ការធ្វើផែនការលើគ្រឿងចក្រ

គ្រឿងចក្រដែលចាំបាច់សំរាប់សេវាកម្មប្រមូលសំរាម គួរត្រូវប្រើប្រាស់អោយអស់លទ្ធភាព តាមប្រពន្ធ័បច្ចេកទេស ដែលបានណែនាំនៅក្នុងផែនការមេ ។ ការប្រើប្រាស់គ្រឿងចក្រជារួមទាំងអស់មានបង្ហាញនៅក្នុងតារាង ៦-១១ ខាងក្រោម ។

Table 6-13: ការប្រើប្រាស់គ្រឿងចក្រ និងវិធីសាស្ត្រប្រមូលសំរាម

| ប្រភពនៃសំរាម | | **វិធីសាស្ត្រប្រមូល** | **គ្រឿងចក្រ** | **ចំនួនជើង** |
|---|---|---|---|---|
| **គេហដ្ឋាន** | តំបន់មានផ្លូវចេញចូលពិបាក | ប្រមូលបថម និងធុងសំរាម | រថយន្ត ធុងសំរាម៥ម៉ែត្រគូប មណ្ឌលកែច្នៃ និងរទេះរុញ | ៣ដងក្នុងមួយសប្តាហ៍ |
| | | ការប្រមូលដោយធុង | រថយន្ត និងធុង ៥ម$^{៣}$ | ៣ដងក្នុងមួយសប្តាហ៍ |
| | តំបន់មានផ្លូវចេញចូល | មុខផ្ទះ ឬកណ្តឹង | ឡាន compactor ១៥,៨ម$^{៣}$ | ៣ដងក្នុងមួយសប្តាហ៍ |
| **អាជីវកម្ម** | ទំហំតូច | មុខផ្ទះ ឬកណ្តឹង | ឡាន compacto ១៥,៨ម$^{៣}$ | រៀងរាល់ថ្ងៃ |
| | ទំហំធំ | ការប្រមូលដោយធុងសំរាម (ធុងជួល) | រថយន្ត និងធុង៥ម$^{៣}$ | ពេលណាក៏បាន |
| | ផ្សេងៗ | ការប្រមូលដោយធុង | រថយន្ត និងធុង៥ម$^{៣}$ | ពេលណាក៏បាន |
| **ការសំអាតផ្លូវ** | | ការប្រមូលនៅមុខផ្ទះ | រថយន្តបែន | ២ដងក្នុងមួយសប្តាហ៍ |
| **សួនសាធារណ** | | ការប្រមូលដោយធុង | រថយន្តនិងធុង៥ម៉ែត្រគូប | ២ដងក្នុងមួយសប្តាហ៍ |

បរិមាណគ្រឿងចក្រក្នុងពេលអនុវត្តន៏គំរោងមានបង្ហាញក្នុងតារាងខាងក្រោម ។

Table 6-14: គ្រឿងចក្រប្រមូលសំរាមសំខាន់

| Equipment | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|---|---|
| Compactor truck 15m3 | 8 | 9 | 10 | 12 | 12 | 14 | 16 | 17 | 19 |
| Compactor truck 8m3 | 3 | 3 | 3 | 3 | 4 | 4 | 5 | 5 | 6 |
| Compactor truck 4m3 | 3 | 4 | 4 | 5 | 5 | 5 | 6 | 7 | 8 |
| Skip loader truck | 5 | 6 | 7 | 7 | 7 | 8 | 9 | 10 | 11 |
| Container（5m3） | 37 | 45 | 51 | 51 | 52 | 61 | 67 | 74 | 86 |
| Dump truck | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| Wheel loader | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| Pick-up truck | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 |

### c. ប្រព័ន្ធស្ថាប័ន និងការងារគ្រប់គ្រង

Table 6-15: បុគ្គលិកដែលត្រូវការសំរាប់សេវាកម្មប្រមូល

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|---|---|
| ប្រធានផ្នែក | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| វិស្វករប្រមូលសំរាម | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| មេការ | 2 | 2 | 2 | 2 | 2 | 3 | 3 | 3 | 3 |
| សេវ្រនៃ | 3 | 3 | 3 | 3 | 3 | 4 | 4 | 4 | 5 |
| អ្នកបើកបរ | 22 | 25 | 27 | 30 | 31 | 34 | 39 | 42 | 47 |
| អ្នកបញ្ជាម៉ាស៊ីន | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| កម្មករ | 43 | 49 | 53 | 59 | 61 | 69 | 78 | 84 | 95 |
| កម្មករការិយាល័យ | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 |
| អ្នកបោសសំអាត | 25 | 32 | 32 | 38 | 38 | 44 | 44 | 50 | 50 |
| TOTAL | 103 | 119 | 125 | 140 | 143 | 162 | 176 | 191 | 208 |

### d. ផែនការហេដ្ឋារចនាសម្ព័ន្ធ

ការត្រួតពិនិត្យនិងជួសជុលជាប្រចាំដល់រថយន្តប្រមូលនឹងត្រូវអនុវត្តក្នុងរោងជាងជួសជុលរថយន្តដែលបានសាងសង់ឡើងក្នុងទីលានចាក់សំរាមថ្មី ។ ក្នុងករណីជួសជុលច្រើនដូចជាពុះម៉ាស៊ីន រដ្ឋាករអាចយកទៅអោយគេធ្វើផ្សេងបាន ។

### d.1 គ្រឿងបរិក្ខា

រោងជាងប្រើសំរាប់ទុកដាក់គ្រឿងបរិក្ខារសំរាប់ធ្វើការតាមដាននិងជួសជុលគ្រឿងចក្រទាំងនោះ ។

- គ្រឿងបរិក្ខារសំរាប់ជួសជុល
- គ្រឿងបរិក្ខារសំរាប់លាងរថយន្ត




Figure 6-3: ប្លង់រោងជាងជួសជុល

### d.2 សំភារៈរោងជាង

ក្រុមសិក្សាបានរៀបចំសំភារៈរោងជាងសំខាន់ៗសំរាប់ការងារជួសជុលនិងពិនិត្យឱ្យខានទៀងទាត់ ដើម្បីរក្សាបាននូវស្ថានភាពគ្រឿងចក្រ ។

- ការងារត្រួតពិនិត្យទ្បើងទាត់ និងជួសជុលទូទៅ
- ពិនិត្យ និងជួសជុលសំបកកង់
- អាគុយ និងការងារផ្សារ
- ឃ្លាំងគ្រឿងបន្លាស់
- ការិយាល័យ
- កន្លែងលាងរថយន្ត

មន្ត្រីដែលត្រូវការចាំបាច់សំរាប់ការងារប្រតិបត្តិតំហែទាំងគ្រឿងចក្រមានសង្ខេបក្នុងតារាងខាងក្រោម ។

Table 6-16: មន្ត្រីត្រូវការសំរាប់ការងារប្រមូលសំរាម

| មន្ត្រី | 2007 | 2012 | 2015 |
|---|---|---|---|
| នាយក | 1 | 1 | 1 |
| ប្រធានមេកានិច | 2 | 2 | 2 |
| ជាងមេកានិច | 6 | 8 | 9 |
| ស្មៀន | 5 | 5 | 5 |
| សរុប | 12 | 14 | 15 |

### e. ការប្រមូលថ្លៃសេវា ការគ្រប់គ្រងទិន្នន័យ និងប្រព័ន្ធត្រួតពិនិត្យ

នៅតារាងខាងក្រោម រ.គ.ស.ភ រៀបចំការចេញវិក័យបត្រប្រចាំខែតាមរយះការប្រើប្រាស់ប្រពន្ធ័ទិន្នន័យនៃអ្នកប្រើប្រាស់សេវា ដែលត្រូវបានគេអភិវឌ្ឍន៏ដោយបានធ្វើការចះកិច្ចសន្យាជាមួយអ្នកប្រើប្រាស់ ។ សង្កាត់ជាអ្នកចែកចាយ វិក័យបត្រ ប្រចាំខែនោះទៅអោយអតិថិជនព្រមទាំងប្រមូលថ្លៃសេវា ហើយប្រគល់ជូន រ.គ.ស.ភ ។ ជាមួយគ្នានោះ សង្កាត់ត្រូវទទួលបានថ្លៃកំរៃជើងសារ ។

ចំពោះប្រពន្ធ័ទិន្នន័យនៃអ្នកប្រើប្រាស់សេវា សង្កាត់ត្រូវធ្វើការកត់ត្រាការចេញ និងចូលនៃប្រជាពលរដ្ឋនៅតំបន់នោះ នៅពេលដេលខ្លួនធ្វើការប្រមូលថ្លៃសេវាហើយរាយការណ៏ជូន រ.គ.ស.ភ រាល់ការប្រែប្រួលនានា ។ យោងតាមព័តមាន នោះ រ.គ.ស.ភ នឹងធ្វើការផ្លាស់ផ្តូរកិច្ចសន្យាជូនអ្នកមកថ្មី ហើយកែតំរូវប្រពន្ធ័ទិន្នន័យអោយទាន់ហេតុការណ៏។

ចំពោះការគ្រប់គ្រងប្រពន្ធ័ទិន្នន័យនៃអតិថិជនសង្កាត់ជួយតាមដានការប្រមូលសំរាមដែលធ្វើឡើងដោយរ.គ.ស.ភ ក្នុងពេលខ្លួនប្រមូលថ្លៃសេវាដោយស្តាប់ការប្តឹងផ្តល់ និងរាល់ការស្នើរបស់អតិថិជនដើម្បីអោយកែលំអសេវានិងរាយការណ៏ជូន រ.គ.ស.ភ និងម.ប.ស្ថ.ភ។

រ.គ.ស.ភ នឹងធ្វើការកែសំរួលផែនការការងាររបស់ខ្លួនតាមសំណូមពរនោះ ដោយយោងតាមការអនុម័ត្រពី ម.ប.ស្ថ.ភ ។ ប្រសិនបើ រ.គ.ស.ភ មិនធ្វើការដាក់ជូនដល់ ម.ប.ស្ថ.ភ ក្នុងរយះពេល ២សប្តាហ៏ទេ ម.ប.ស្ថ.ភ ត្រូវជំរុញ រ.គ.ស.ភ អោយរួសរាន់ ហើយរាយការណ៏ជូន ស.ក្រ.ភ ។




Figure 6-4: ប្រពន្ធ័ប្រមូលថ្លៃសេវា

## f. ថ្លៃដើមគំរោង

### f.1 តំរូវការធនធានសំរាប់ការវិនិយោគ

ថវិការចាំបាច់សំរាប់ការទិញគ្រឿងចក្រមានបញ្ចោងក្នុងតារាងខាងក្រោម ។

Table 6-17: ការវិនិយោគធនធានដែលត្រូវការសំរាប់ការពង្រីកសេវាកម្មប្រមូលសំរាម (១,០០០ដុល្លា)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|---|---|---|
| a. គ្រឿងចក្រ | 1,746 | 193 | 140 | 195 | 59 | 219 | 320 | 1,601 | 521 | 144 |
| សាងសង់ហេដ្ឋារចនាសម្ព័ន | 58 | 2 | 1 | 2 | 1 | 1 | 2 | 3 | 2 | - |
| Total | 1,804 | 195 | 141 | 197 | 60 | 220 | 322 | 1,604 | 523 | 144 |

### f.2 តំលៃសំរាប់ការធ្វើប្រតិបត្តិការណ៍និងតំហែទាំ

តំលៃទាំងនោះរួមមាន : ការចំណាយលើប្រេង បុគ្គលិក គ្រឿងបន្លាស់ សំលៀកបំពាក់ ។ល។ ចំពោះតំលៃប្រតិបត្តិការណ៍ និងការគ្រប់គ្រងមានការថែរក្សារោងជាង បុគ្គលិក និងបរិក្ខាផ្សេងៗ មានក្នុងតារាងខាងក្រោម ។

Table 6-18: តំលៃប្រតិបត្តិការណ៍ និងការគ្រប់គ្រង (១,០០០ដុល្លា)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|---|---|
| Fuel | 169 | 191 | 207 | 220 | 225 | 248 | 275 | 298 | 332 |
| បុគ្គលិក | 83 | 94 | 99 | 110 | 112 | 127 | 138 | 149 | 163 |
| ផ្សេង ៗ | 3 | 3 | 4 | 4 | 4 | 5 | 5 | 5 | 6 |
| Maintenance | 61 | 71 | 77 | 83 | 86 | 97 | 108 | 118 | 133 |
| TOTAL ($US) | 316 | 359 | 386 | 417 | 428 | 475 | 527 | 569 | 634 |

### f.3 តំលៃសំរាប់ការប្រមូលសំរាម

Table 6-19: តំលៃសំរាប់ការប្រមូលសំរាម( ១,០០០ដុល្លា)

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014* | 2015 | Total |
|---|---|---|---|---|---|---|---|---|---|---|
| O&M Cost | 286 | 325 | 352 | 379 | 390 | 434 | 485 | 524 | 588 | 3,763 |
| រំលោះ | 178 | 203 | 221 | 245 | 253 | 281 | 322 | 210 | 369 | 2,281 |
| សរុប | 464 | 528 | 573 | 624 | 643 | 715 | 807 | 734 | 957 | 6,044 |

តំលៃនៃការប្រមូលសំរាមក្នុងមួយតោនក្នុងឆ្នាំ ២០០៧ ដល់ ២០១៥ មានក្នុងតារាងខាងក្រោម ។ តំលៃឯកតាមធ្យម គឺ ៧,៧៤ ដុល្លាក្នុងមួយតោន ។

Table 6-20: តំលៃក្នុងមួយឯកតា

| | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 * | 2015 | Total |
|---|---|---|---|---|---|---|---|---|---|---|
| ប្រមូលរាល់ថ្ងៃ (ton/day) | 156.2 | 178.4 | 202.3 | 224 | 238.8 | 280.6 | 313.3 | 344.3 | 403.7 | |
| ប្រមូលរាល់ឆ្នាំ (ton/year) | 57,017 | 65,120 | 73,850 | 81,760 | 87,169 | 102,430 | 114,358 | 125,673 | 147,358 | 854,735 |
| តំលៃកតា ($US/ton) | 8.14 | 8.10 | 7.76 | 7.64 | 7.37 | 6.98 | 7.05 | 5.84 | 6.50 | 7.07 |

* ចំណាំ: ថ្លៃរំលោះក្នុងឆ្នាំ ២០១៤ ត្រូវបានសំរួលដោយការលក់ចេញរថយន្តចាស់ៗដែលនឹងមានការធ្លាក់ចុះយ៉ាងខ្លាំងនូវតំលៃឯកតាសំរាប់ឆ្នាំនោះ ។

## 6.3.3 ការវាយតំលៃគំរោង

### a. ការវាយតំលៃលើបច្ចេកទេស

### a.1 ប្រព័ន្ធប្រមូល និងដឹកជញ្ជូនសំរាម

ផ្លូវមួយចំនួននៅតាមជនបទមានការថែទាំបានត្រឹមត្រូវតែតំបន់ជាច្រើន ដែលរថយន្តពុំអាចចូលបាន ។ ដូច្នេះផែនការគ្រឿងចក្រត្រូវបានធ្វើឡើងសំរាប់ការប្រមូលនៅតាមចញ្ចើមផ្លូវដោយរថយន្ត compactor ចំពោះផ្លូវដែលមានការថែទាំ ហើយការប្រមូលដោយធុងសំរាម និងរថយន្តស្ទូច សំរាប់តំបន់ដែលពិបាកចូល ។

រ.គ.ស.ភ មានបទពិសោធន៏ចំពោះការប្រមូលតាមចញ្ចើមផ្លូវដោយរថយន្ត compactor ដូច្នេះនឹងមិនមានបញ្ហាផ្នែកបច្ចេកទេសទេ ។ បើតាមការងារប្រតិបត្តិកាណ៏ ការងារប្រមូលនិងចាក់ចោលសំរាម គឺជាចំនុចសំខាន់របស់រ.គ.ស.ភ ដែលស្ថាប័នអនុវត្តនេះគួរតែទទួលបាននូវការសហការណ៏ពីសាធារណ ក្រោមការជ្រោមជ្រែងពី ម.ប.ស.ភដើម្បីបង្កើតនូវប្រពន្ធ័នៃការប្រមូលមួយដ៏សមស្រប ។

ចំពោះការប្រមូលដោយធុងសំរាម គេបានដោះស្រាយបញ្ហាបច្ចេកទេសជាស្រាច់ ទោះបីការងារនេះហាក់ដូចជាថ្មីសំរាប់ភ្នំពេញក្តី ។ ទោះជាយ៉ាងណា ក្នុងការងាររកកន្លែងដាក់ធុងសំរាម គេតែងជួបការតវ៉ាពីប្រជាពលរដ្ឋដែលនៅក្បែរនោះ ដូច្នេះចាំបាច់ត្រូវធ្វើការដោះស្រាយជាមុនក្រោមការសហការណ៏ពីសង្កាត់ ជាដើម ។ ជាងនេះទៀតការរៀបចំការប្រមូល នឹងត្រូវការអ្នកបើកបរនិងអ្នកប្រមូលសំរាមច្រើន ។ ចំពោះការអនុវត្តប្រពន្ធ័តាមធុងសំរាមនេះគេចាំបាច់ត្រូវការការគិតគូរល្អិតល្អន់ចំពោះផែនការប្រើប្រាស់បុគ្គលិក និងវគ្គបណ្តុះបណ្តាលដែលនឹងត្រូវកែសំរួលហើយនឹងអនុវត្តនាឆ្នាំ២០០៦ ។

**a.2 ការអនុវត្តន៍ និងការថែរក្សាគ្រឿងចក្រ**

រោងជាងជួសជុលគ្រឿងចក្រត្រូវដែលនឹងត្រូវសាងសង់នោះ គឺគ្រប់គ្រាន់សំរាប់ការថែរក្សារថយន្ត ។ ដើម្បីអនុវត្តន៍ប្រពន្ធ័ការងារថែទាំនេះ ចាំបាច់ត្រូវប្រើប្រាស់អ្នកបច្ចេកទេសដែលមានការបណ្តុះបណ្តាលល្អ ហើយចេះរៀបចំផែនការសំរាប់រាល់គ្រឿងបន្លាស់ ។ វិធានការណ៍ថវិកាសមស្របនានា ក៏ជាការចាំបាច់សំរាប់ការងារផ្គត់ផ្គង់ចំពោះរាល់គ្រឿង បន្លាស់អោយបានសមស្រប និងគ្រប់គ្រាន់ ។

**b. ការវាយតំលៃពីសង្គម**

ការពង្រីកសេវាកម្មប្រមូលសំរាម នឹងអាចបណ្តាលអោយមានការប៉ះពាល់ទៅលើការងារកែឆ្នៃសំរាមខ្នាតតូចនានា។ ដូច្នេះ ចាំបាច់ត្រូវចែកចាយព័តមានជាមួយអ្នកធ្វើការងារកែឆ្នៃសំរាម ជាដើមហើយត្រូវធានាថាថ្ងៃប្រមូល នឹងមិនជាន់គ្នាជា មួយថ្ងៃដែលរើសសំរាមកែឆ្នៃ ដូច្នេះគេមិនធ្វើអោយខាតបង់ដល់សកម្មភាពនេះទេ ។ នៅក្នុងផែនកាដើម្បីពង្រីកសេវាកម្មប្រមូលសំរាម គេចាំបាច់ត្រូវជ្រើសរើសកម្មករច្រើនដែលកត្តានេះគេត្រូវការអ្នករើសសំរាមជាច្រើនដែលធ្វើការនៅទីលានចាស់ ។ ទោះបីយ៉ាងណាក្តី ការចុះបញ្ជីអ្នករើសសំរាមដែលបានរៀបចំក្នុងការសិក្សានេះ គួរតែមានលក្ខណះសមស្របដើម្បី ធានាអោយបាននូវភាពរលូនចំពោះការងារជ្រើសរើស ។

**c. ការវាយតំលៃលើបរិស្ថាន**

គេបានធ្វើការប៉ាន់ស្មានថា រថយន្តប្រមូលនឹងចរាចរណ៍ប្រមាណ ៣២២ ជើងក្នុងមួយថ្ងៃ នាឆ្នាំ ២០០៧។ ជាលទ្ធផលនោះ រថយន្តទាំងនោះនឹងបង្កអោយមានសំឡេង និងភាពញ័រនៅតាមដងផ្លូវដែលទៅកាន់ទីលាន។ កំរិតនៃរំញ័រនិងសំឡេងគឺ អាស្រ័យលើចរិកលក្ខណៈនៃអ្នកបើកបរ។ ដូច្នេះ ចាំបាច់ត្រូវធ្វើការអប់រំអោយបើកបរត្រឹមត្រូវដើម្បីជៀសវាងផលប៉ះពាល់។ រថយន្តចាក់សំរាម ក៏អាចបង្កអោយមានការធ្លាក់ចុះរាយប៉ាយនៃសំរាម ដូច្នេះតោងតែមានក្រណាត់ ឬស្បៃគ្របពេលធ្វើដំណើរ ។ ចំណែកឯគ្រឿងចក្រដ៏ទៃទៀតដូចជា compactor truck និង រថយន្តបិទជិត គេត្រូវចាត់វិធានការណ៍ចាំបាច់នានាដើម្បីកុំអោយអ្នករើសសំរាមតាមរើសនៅពេលធ្វើដំណើរ។

**d. ការវាយតំលៃលើហិរញ្ញកិច្ច និងសេដ្ឋកិច្ច**

**d.1 ចំណុចសំខាន់ៗ**

ផែនការមេដែលបានរៀបចំនៅក្នុងការសិក្សាផ្តល់អនុសាសន៍ថា ស៊ិនទ្រីដែលជាក្រុមហ៊ុនឯកជនប្រមូលនិងដឹកជញ្ជូនសំណល់ គួរផ្តល់សេវាកម្មប្រមូលក្នុងខ័ណ្ឌទីប្រជុំជនចំនួន៤ ដែលមានប្រជាជនពលរដ្ឋនិងសកម្មភាពសេដ្ឋកិច្ចក្នុងស្ថានភាពចំនេញថវិកា ហើយរដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញដែលជាភ្នាក់ងាររដ្ឋនោះនិងក្រុមហ៊ុនស៊ិនទ្រីត្រូវចែករំលែកតំបន់ពាក់កណ្តាលទីប្រជុំជនចំនួន៣ខ័ណ្ឌ ដែលខ័ណ្ឌទាំងនោះមិនសូវបជាជនពលរដ្ឋនិងសកម្មភាពសេដ្ឋកិច្ចក្នុងស្ថានភាពចំនេញថវិកាឡើយ។ ហេតុដូច្នេះ សេវាកម្មសាធារណៈជាមូលដ្ឋានគួរតែត្រូវផ្តល់ដោយស្មើភាពទៅប្រជាពលរដ្ឋគ្រប់រូបក្នុងទីក្រុងភ្នំពេញ ។

ការវាយតំលៃលើហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៅក្នុងរបាយការណ៍នេះ គឺមានគោលបំណងចំពោះផែនការមេគ្រប់គ្រងសំណល់រឹង និងសេវាកម្មដឹកជញ្ជូនក្នុងតំបន់ដែលនឹងប្រមូលសំនល់ដោយរដ្ឋាករប៉ុណ្ណោះ ។

**d.2 បុរេលក្ខខ័ណ្ឌនៃការវាយតម្លៃលើហិរញ្ញកិច្ច**

ការវាយតម្លៃលើហិរញ្ញកិច្ចនៅទីនេះ យោងទៅលើសេណារីយោចំនួន២ ។

### d.2.1. បុរេលក្ខខ័ណ្ឌនៃការវាយតម្លៃហិរញ្ញវត្ថុ

Table 6-21: បុរេលក្ខខ័ណ្ឌនៃការវាយតម្លៃហិរញ្ញវត្ថុ

| ស្ថាប័នអនុវត្តគំរោង | រ.គ.ស.ភ |
|---|---|
| **រយៈពេលនៃគំរោង** | ១០ ឆ្នាំពី ២០០៦ ដល់ ២០១៥ |
| **ប្រាក់ចំណូលនៃគំរោង** | ការប្រមូលថ្លៃសេវាពីឆ្នាំ ២០០៧ ដល់ ២០១៥ប្រសិទ្ធភាពនៃថ្លៃប្រមូលបានកំណត់ត្រឹម ៨០%សំរាប់គេហដ្ឋានធម្មតា និង ១០០% សំរាប់ផ្ទះធ្វើអាជីវកម្ម |
| **ធនធានវិនិយោគ** | ការិនិយោគដំបូងធ្វើនៅឆ្នាំ ២០០៦ សំរាប់គោលបំណងដូចខាងក្រោម :<br>(ការទិញរថយន្ត)<br>- រថយន្តបង្ហាប់ (ចំណុះ ៤ម៣ មិង ១៥ម៣)<br>- រថយន្តស្ទូច<br>- ធុងស្ទូច<br>- រទេះរុញ<br>- រថយន្តភីកអាប់<br>- រថយន្តបែន<br>(ការសាងសង់)<br>- ទីតាំងធុងសំរាម<br>- រោងជាងថែរក្សារថយន្ត<br>រថយន្តប្រមូលនិងដឹកសំរាម និងគ្រឿងចក្រ នឹងត្រូវបានទិញអាស្រ័យទៅលើកំណើនអ្នកប្រើប្រាស់សេវាកម្ម និងការពង្រីកនៃតំបន់ប្រមូលដែលរថយន្តចាស់នឹងត្រូវបានជំនួសថ្មី ។ |
| **តំលៃប្រតិបត្តិការណ៍ និងការគ្រប់គ្រង** | ត្រូវបានប៉ាន់តំលៃសំរាប់ឆ្នាំនិមួយៗពីឆ្នាំ២០០៧ ដល់ ២០១៥ ដោយយោងទៅលើបរិមាណនិងតំលៃឯកតាដែលបានកំណត់ ។ |
| **តំលៃរំលោះ** | រយៈពេលរំលោះត្រូវបានកំណត់តាមប្រភេទអាគារ គ្រឿងចក្រនិងរថយន្ត ក្នុងរយៈពេល២០ ១៥ និង៧ឆ្នាំ តាមលំដាប់លំដោយ។ តំលៃផ្សេងៗត្រូវបាន កំណត់ត្រឹម ១០% សំរាប់រថយន្ត នឹងគ្រឿងចក្រទាំងអស់នៅពេល អាគារ ទាំងឡាយត្រូវបានគេសន្និដ្ឋានថាបានទទួលការខូចខាត ។ |
| តំលៃទីផ្សារ | តំលៃទាំងអសល់ដែលត្រូវបានប៉ានស្មានខាងលើគឺអាស្រ័យទៅលើតំលៃទីផ្សារឆ្នាំ២០០៣ ។ ពុំមានតំលៃកើនឡើងត្រូវបានរាប់បញ្ចូលឡើយ ។ |
| អត្រាចុះតំលៃ | ដោយគិតទៅលើអាត្រាអតិផរណាបច្ចុប្បន្ន និងតំរូវការនៃថវិកាបំរុងក្នុងឆ្នាំដំបូងសំរាប់ការផ្លាស់ប្តូររថយន្ត និងគ្រឿងចក្រ (បន្ទាប់ពីប្រតិបត្តិការណ៍រយៈពេល៧ឆ្នាំ អាត្រាបញ្ចុះតំលៃកំណត់ត្រឹម ១០% ។ |

## d.2.2. ការវាយតម្លៃលើហិរញ្ញកិច្ច ( សេណារីយោទី២ )

### ១- ករណីមិនមានជំនួយ

ដោយសន្និដ្ឋានថា ប្រសិនបើ IFRR ត្រូវកំរិតក្នុង ១០%នោះ ការសិក្សាបានវិភាគការកំណត់ថ្លៃសំណល់តាមទំងន់តោននៃសំរាម ។ លទ្ធផលនៃការវិភាគមានបង្ហាញក្នុងតារាងខាងក្រោម ។

Table 6-22: លទ្ធភាពហិរញ្ញកិច្ច និងអត្រាថ្លៃសេវា

| Fee Rate | Net Present Value | FIRR |
|---|---|---|
| 10 | - 1,370,578 | - 5.08 |
| 11 | - 1,022,691 | - 1.06 |
| 12 | - 674,807 | 2.83 |
| 13 | - 326,920 | 6.59 |
| 14 | 20,968 | 10.22 |
| 15 | 368,854 | 13.72 |

ចំណាំ: អត្រាចុះថ្លៃគឺ ១០%

ដូចតារាងខាងលើ អត្រាត្រូវកំរិតក្នុង ១១ ដុល្លា/ត នៃសំណល់ដែលបានប្រមូល (ឬជាប្រាកដគឺ១៣.៩៤ ដុល្លា/ត)ដើម្បីទទួលបាន IRR ១០% ដែលជាអត្រាតិចបំផុតសំរាប់ជាកំរៃនៃគំរោង ។ បើករណីប្រើប្រាស់អត្រាបែបនេះ អត្រាជាមធ្យមសំរាប់គេហដ្ឋាន មានដូចខាងក្រោម ។

Table 6-23: អត្រាប៉ាន់ស្មានសំរាប់គេហដ្ឋាន

| | Unit | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|---|---|---|
| បរិមាណសំរាម | គ.ក្រ/ខែ/ផ្ទះ | 102 | 107 | 113 | 118 | 124 | 113 | 119 | 125 | 113 |
| អត្រាតំលៃ | ដុល្លា/ខែ/ផ្ទះ | 1.42 | 1.49 | 1.58 | 1.64 | 1.73 | 1.58 | 1.88 | 1.74 | 1.58 |

ចំនាំ: ការថយចុះនៃបរិមាណប្រមូលនាឆ្នាំ២០១២ និង២០១៥ បណ្តាលមកពីការថយសំណល់បញ្ចេញនៅនិងកន្លែង និងដោយសារការចេះកែឆ្នៃ ។ល។ ដែលបានសន្មតក្នុងផែនការមេ ។

ដូចមាននៅក្នុងតារាងខាងលើ អត្រាតំលៃសំរាប់គេហដ្ឋានមានចាប់ពី ១.៤២ ដល់ ១.៧៤ ដុល្លាខែ/ផ្ទះ ក្នុងពេល អនុវត្តគំរោង ។ ការប៉ាន់ស្មាននេះមានប្រមាណ ១.៧ ទៅ ២.០ ដង នៃថ្លៃបច្ចុប្បន្ន ដែលមានប្រមាណតែពី ០.៨ ទៅ១.០ ដុល្លាប៉ុណ្ណោះ។ ដោយពិចារណាលើឆន្ទៈ និងការបង់ថ្លៃនៃគេហដ្ឋានក្នុងតំបន់ពាក់កណ្តាលទីប្រជុំជនទាំងនោះ ការតំឡើងថ្លៃនេះអាចជាការលំបាក ។

### ២- ករណីមានជំនួយ

ការសិក្សាបានវិភាគអត្រានៃការប្រមូលដោយប្រើប្រាស់ករណីមានជំនួយគ្មានសំណង ដើម្បីការចាប់ផ្តើមការវិនិយោគនាឆ្នាំ ២០០៥ និង ២០០៦ ។ សំរាប់ការវិនិយោគដែលនឹងមាននាឆ្នាំ ២០០៥ និង ២០០៦ ។ លទ្ធភាពនៃថវិការនៃគំរោងអាចធានាបាន លុះណាតែគេអាចរកចំណូលបានគ្រប់គ្រាន់ដើម្បីគ្របដណ្តប់លើការចំណាយទាំងស្រុងរួមមាន រំលោះ ការទិញ សំភារះបន្ថែម និងការចំណាយផ្សេង ៗ លើការងារប្រតិបត្តិការក្នុងពេលអនុវត្តគំរោង។

ដូច្នេះ ប្រាក់ចំនូលបានមកពីគំរោង ត្រូវឆ្លើយតបនូវលក្ខណនានាដូចខាងក្រោម ដូច្នេះហើយ ស្ថានភាពហិរញ្ញវត្ថុអាចថិតថេរទៅបាន:

- ចំនូលមួយឆ្នាំតែងតែលើសពីថ្លៃគំរោងដែលបានស្មានដោយយោងលើមូលដ្ឋានរំលោះ និង
- ប្រាក់បំរុងសំរាប់គំរោង (កំនើនប្រាក់ចំនូល) តែងតែលើសតំលៃតំរូវការសំរាប់តំលៃដែលបានធ្វើការប៉ាន់ស្មានលើមូលដ្ឋាននៃការចំណាយពិតប្រាកដ ។

លទ្ធផលនៃការវិភាគបង្ហាញ ថាអត្រាតំលៃទីលានសមស្របមួយដែលអាចឆ្លើយតបនិងលក្ខណខាងលើ គឺ ១១.៦១ ដុល្លាសំរាប់មួយតោន ។

អត្រាតំលៃ ១១.៦១ ដុល្លាក្នុងសំរាមមួយតោន គឺប្រហែលជា១.៦ ទៅ ១.៧ ដងនៃអត្រាតំលៃបច្ចុប្បន្ននៃ៧ដុល្លាក្នុង ឆ្នាំ ២០០២ និង២០០៣។ អត្រាតំលៃថយប្រមាណ ១៧ ភាគរយប្រសិនបើមានជំនួយ។

Table 6-24: ការប៉ាន់ប្រមាណអត្រាតំលៃនៃការប្រមូលសំណល់សំរាប់គេហដ្ឋាន

| | ឯកត្តា | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|---|---|---|
| បរិមាណសំរាម | គ.ក្រ/ខែ/ផ្ទះ | 102 | 107 | 113 | 118 | 124 | 113 | 119 | 125 | 113 |
| អត្រាតំលៃ | ដុល្លា/ខែ/ផ្ទះ | 1.18 | 1.24 | 1.31 | 1.37 | 1.44 | 1.31 | 1.38 | 1.45 | 1.31 |

ដូចបានបង្ហាញក្នុងតារាងខាងលើ អត្រាតំលៃសំរាប់គេហដ្ឋានមានចន្លោះពី ១,១៨ ទៅ ១,៤៥ ដែលខ្ពស់ជាងប្រហែលជា ១,២ ទៅ ១,៥ ដងនៃ អត្រាតំលៃបច្ចុប្បន្នដែលមានត្រឹមតែ ០,៨ ទៅ ១,០ ដុល្លាក្នុងមួយគេហដ្ឋានក្នុងមួយខែ។ ទោះជាតំលៃត្រូវបានកាត់បន្ថយដោយមានជំនួយក្តី តែគេក៏ត្រូវចាត់វិធានការន៍សំរាប់កាត់បន្ថយតំលៃតាមគេហដ្ឋាន ។

### d.3 ការវាយតម្លៃលើសេដ្ឋកិច្ច

សេវាកម្មប្រមូលសំណល់តាមផែនការមេដែលផ្តល់ដោយរដ្ឋាករគ្រប់គ្រងសំណល់ដែលបានគ្រោងនាពេលបច្ចុប្បន្ននៅក្នុងផែនការមេ គឺមានគោលបំណងផ្តល់នូវសេវាកម្មសារធារណៈជាមូលដ្ឋានដល់តំបន់ដែលគ្មានសេវាកម្មក្នុងទីក្រុងភ្នំពេញ។ ទោះបីជាតំរូវអោយមានការវិនិយោគបន្ថែមទៀត នេះជាកាតួកិច្ចមូលដ្ឋានដែលសាលាក្រុងភ្នំពេញត្រូវផ្តល់សេវាកម្មប្រមូលសំណល់អោយដល់ប្រជាជនពលរដ្ឋគ្រប់រូបក្នុងទីក្រុងភ្នំពេញ។

ផែនការនាពេលបច្ចុប្បន្នស្តីពីសេវាកម្មប្រមូលសំណល់ក្នុងខ័ណ្ឌជាយក្រុងទាំងបីគឺជាលទ្ធផលនៃការត្រួតពិនិត្យលើការចំណាយដ៏មានប្រសិទ្ធភាពបំផុតនៃវិធីសាស្ត្រប្រមូលនឹងដឹកជញ្ជូនសំណល់តាមរយៈការសិក្សា ដូច្នេះហើយការចំណាយបន្ថែមដែលកើនឡើងពីគំរោងត្រូវបានកាត់បន្ថយជាអប្បបរមាកាន់តែប្រសើរ។

ម្យ៉ាងវិញទៀត ការផ្តល់សេវាកម្មប្រមូលសំណល់ដល់ខ័ណ្ឌជាយក្រុងទាំងបីត្រូវបានរំពឹងទុកថាបង្កើតនូវផលប្រយោជន៍ដូចខាងក្រោម ទោះបីជាមានការលំបាកក្នុងការកម្រិតនូវតំលៃចំណេញក៏ដោយ ។

- **ការកែលំអសុខភាព អនាម័យ និង បរិស្ថាន**

ដោយសារគ្មានសេវាកម្មនៃការប្រមូលកាកសំណល់ សំណល់ត្រូវបានចាក់ក្នុងទន្លេ តាមដងផ្លូវ ឬក៏ដុតចោល។ មានការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរជាច្រើនដែលបណ្តាលមកពីការចាក់សំណល់ទាំងនេះលើបញ្ហាសុខភាពកើតមានឡើងចំពោះប្រជាជន អនាម័យនិងបរិដ្ឋានជុំវិញ ដែលមិនត្រឹមតែកើតមានក្នុងតំបន់ដែលគ្មានសេវាកម្មប្រមូលសំណល់ទេ គឺវាកើតឡើងចំពោះទីក្រុងទាំងមូលតែម្តង។ ការអនុវត្តគំរោងនេះ នឹងផ្តល់នូវការការពារពីការបំពុលទាំងនោះព្រមទាំងកែរលំអឡើងវិញនូវបរិស្ថានរស់នៅរបស់ទីក្រុង ។

- **ជំរុញអោយមានការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅតំបន់នោះ**

ការកែលំអសុខភាព អនាម័យនិង បរិស្ថានរស់នៅនឹងជួយបង្កើនតំលៃសន្ទះសកម្មភាពសេដ្ឋកិច្ច និង សង្គមកិច្ច ផងដែរ ។ ទោះបីជាមានគំលាតខុសគ្នាខ្លាំងរវាងខ័ណ្ឌជាយក្រុងទាំងបីនិងខណ្ឌទីប្រជុំជនទាំងបួនក្តី ការផ្តល់សេវាកម្មប្រមូលសំរាមនឹងបង្កើនសក្តានុពលភាពចំពោះខណ្ឌទាំងបី អោយទៅជាតំបន់សំរាប់អភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ទីក្រុង ។

- **ការបង្កើនការយល់ដឹងអំពីបរិស្ថាន**

ទោះជាការអោយបង់ថ្លៃសេវាសំរាប់គេហដ្ឋានទាំងបីអាចនឹងមានប្រតិកម្មពីប្រជាពលរដ្ឋនៅខណ្ឌជាយក្រុងទាំងបី តែវានឹងជួយបង្កើនការយល់ដឹងលើបរិស្ថាន ប្រសិនបើគេយល់អំពីការប្រថុយប្រថានផលវិបាកចំពោះការចាក់កាកសំនល់ដោយពុំមានការត្រួតពិនិត្រត្រឹមត្រូវនោះ ហើយដែលអាចនឹងប៉ះពាល់ដល់សុខភាព ។ ការបង្កើនការយល់ដឹងនេះនឹងបានជួយកាត់បន្ថយការបញ្ចេញ សំរាមតាមរយះការបែងចែក ការប្រើប្រាស់ឡើងវិញ និង ការកែឆ្នៃ ។

រាល់ការរំពឹងទុកទាំងនេះនៃប្រសិទ្ធិភាពគំរោងខាងលើ នឹងផ្តល់នូវផលប្រយោជន៍គ្រប់គ្រាន់គ្របដណ្តប់ទៅលើការចំណាយដែលត្រូវការសំរាប់ការអនុវត្តគំរោង ។

# 6.4 គំរោងបិទទីលានស្ទឹងមានជ័យ

## 6.4.1 គោលគំនិតក្នុងការរៀបចំ

ការបិទទីលានបានគិតបញ្ចូលនូវបញ្ហាមួយចំនួនដូចខាងក្រោម :

១- ការផ្ទេរដោយមានភាពរលូនពីទីតាំងចាស់ទៅទីតាំងថ្មី

២- ការងារចាំបាច់សំរាប់បិទទីលានស្ទឹងមានជ័យ

៣- ផែនការត្រួតពិនិត្យបន្ទាប់ពីការបិទទីលាន

៤- ផែនការប្រើប្រាស់ដីនាពេលអនាគត

## 6.4.2 ការរៀបចំចំណុចសំខាន់ៗ

### a. លក្ខ័ណ្ឌនៃការរៀបចំ

### a.1 កាលវិភាគនៃការបិទទីលាន

ទីលានបច្ចុប្បន្ននឹងត្រូវបិទនៅចុងឆ្នាំ ២០០៦ ។

### a.2 ផ្ទៃដីគោលដៅនៃផែនការបិទទីលាន

ផែនការនោះគឺដីដែលកាន់កាប់ដោយសាលាក្រុងមានទំហំ៧.៥ហ.ត (រាប់បញ្ចូលទាំងផ្លូវនានា) និងដីឯកជនទំហំ ៣.៦ហ.ត ដែលបានពង្រីកក្រោមគំរោងសាកល្បង (A-1:1.6ha, b-2:2.0ha) ។ យោងទៅតាមកិច្ចសន្យាជួល តំបន់ពង្រីកនឹងត្រូវប្រគល់ឱ្យម្ចាស់ដីវិញនៅពេលដែលកំពស់នៃកន្លែងចាក់នោះឡើងដល់ ៤ម ខ្ពស់ជាងផ្លូវជុំវិញ ។ ដីនោះគួរតែនៅក្រោមការគ្រប់គ្រងរបស់ រ.គ.ស.ភ ដោយយោលទៅលើកត្តាបរិស្ថានព្រោះថាទឹកសំអុយ និងឧស្ម័ននៅតែកកើត ដូច្នេះផែនការបិទទីលានត្រូវបានគេរំពឹងថាសាលាក្រុងភ្នំពេញនឹងបន្តការជួលដីនោះក្រោយពីពេលបិទជាស្ថាពរ ។

**b. ផែនការអន្តរកាលនៃការផ្ទេរទៅទីលានថ្មី**

ដើម្បីធានាអោយបាននូវការផ្ទេរប្រកបដោយភាពរលូនពីទីលានចាស់ទៅទីលានថ្មី ដោយពុំអោយមានការប៉ះពាល់ដល់ការងារចាក់សំរាមនោះវិធានការមួយចំនួនត្រូវធ្វើឡើង ។

- បង្កើនប្រព័ន្ធគ្រប់គ្រងរបស់ រ.គ.ស.ភ ។ វាចាំបាច់សំរាប់ រ.គ.ស.ភ ដើម្បីរៀបចំបុគ្គលិកនិងគ្រឿងចក្រ និងផ្តល់នូវវគ្គបណ្តុះបណ្តាលមុននឹងចាប់ ផ្តើមទីលានថ្មី ។
- កែលំអផ្លូវចូល ។ សាលាក្រុងភ្នំពេញគួរតែធានាថាការសាងសង់ផ្លូវជាតិលេខ៣០៣ ដែលផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី នឹងត្រូវបញ្ចប់មុនការចាប់ផ្តើមទីលានថ្មី ។
- រៀបចំផែនការផ្ទេរ ។ រ.គ.ស.ភ គួរតែបែងចែកផែនការលំអិតសំរាប់ធ្វើការផ្លាស់ផ្តូរទីតាំងពីទីលានចាស់ទៅថ្មីនៅពាក់កណ្តាលឆ្នាំ២០០៦ ដោយយោងតាមផែនកាបណ្តោះអាសន្នដែលរៀបចំដោយក្រុមសិក្សា ។

**c. ផែនការរៀបចំគ្រឿងចក្រ**

បន្ទាប់ពីបញ្ចប់ប្រតិបត្តិការណ៍ទីលានការងារសំណង់ខាងក្រោមនឹងត្រូវសាងសង់នៅទីលានស្ទឹងមានជ័យ ។

- សាងសង់កន្លែងចាក់សំរាម
- សាងសង់ប្រព័ន្ធលូទឹកភ្លៀងដែលបែងចែកទឹកសំអុយពីទឹកភ្លៀងនិងទឹកចេញពីផ្ទះបាយ និងដាក់ម៉ូទ័របូមនិង គ្រឿងចក្រដ៏ទៃទៀត ។
- តម្លើងបំពង់យកឧស្ម័ន
- លប់គ្របទីលានដោយប្រើអាចម៍ដី



Figure 6-5: ទ្រង់ទ្រាយចុងក្រោយនៃទីលានស្ទឹងមានជ័យ

ក្រុមសិក្សាបានស្នើថា រ.គ.ស.ភ ត្រូវជួលទីលានចាក់សំរាមនោះឱ្យទៅជាកន្លែងវិនិយោគពាណិជ្ជកម្ម ឬអង្គការក្រៅរដ្ឋាភិបាលដែលមានការចាប់អារម្មណ៏លើការប្រើប្រាស់ឧស្ម័នទីលាន ។

## d. ផែនការត្រួតពិនិត្យ

រ.គ.ស.ភ គួររក្សាប្រព័ន្ធត្រួតពិនិត្យរហូតដល់ទីលានមានលំនឹង ( ប្រមាណ១៥ឆ្នាំ) ។ ចំនុចសំរាប់ត្រួតពិនិត្យមានក្នុងតា រាងខាងក្រោម ។ ការវាស់សារធាតុធ្ងន់និងសារធាតុដែលមានគ្រោះថ្នាក់ជារឿងសំខាន់ណាស់ក្នុងការត្រួតពិនិត្យ តែវាចំនាយខ្ពស់ណាស់។ ដោយគិតលើស្ថានភាពថវិការបស់សាលាក្រុងភ្នំពេញ-រដ្ឋាករគ្រប់គ្រងសមណល់រាជធានីភ្នំពេញ ក្រុមសិក្សាបានស្នើអោយត្រួតពិនិត្យ pH, EC, Cl តែប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ការវាស់សារធាតុទាំងនេះគឺមានភាពសម័ញ្ញហើយមានតំលៃថោកដែលយើងអាចការពារការជ្រាបទឹកស្អុយព្រោះថាលទ្ធផលនៃការត្រួតពិនិត្យនេះនឹងបំរែបំរួលគួរអោយកត់សំគាល់នៅពេលដែលយកមកធ្វើជាសំណាកដោយរួមទាំងទឹកស្អុយផងដែរ។ រដ្ឋាករគ្រប់គ្រងសំណល់គួរតែធ្វើការពិសោធន៍គុណភាពទឹករួមមានសារធាតុធ្ងន់ហើយត្រូវមានវិធានការជាបន្ទាន់បើមានករណីជ្រាបនេះ។ ការត្រួតពិនិត្យបែបនេះញឹកញាប់ដោយមន្ទីរបរិស្ថាន-រដ្ឋាករគ្រប់គ្រងសំណល់គួរតែធ្វើក្នុងមួយខែម្តង ហើយគណកម្មការត្រួតពិនិត្យវិញត្រូវធ្វើពីរដងក្នុងមួយឆ្នាំ។

ក្រសួងបរិស្ថននិងមន្ទីរបរិស្ថានំាទចាប់ផ្តើមត្រួតពិនិត្យទីលានស្ទឹងមានជ័យជាប្រចាំចាប់តាំងពីខែ កក្កដា ឆ្នាំ ២០០៤ មក។ នៅពេលដែលការត្រួតពិនិត្យចេះតែបន្តទៅ ប្រព័ន្ធត្រួតពិនិត្យនឹងត្រូវពង្រឹងឡើងដោយគណៈកម្មការត្រួតពិនិត្យដែលបានបង្កើតឡើង។ សកម្មភាពត្រួតពិនិត្យនេះមិនត្រឹមតែជាការថែរក្សាបរិស្ថានរបស់ទីលានស្ទឹងមានជ័យប៉ុណ្ណោះទេ តែវាក៏បានជួយបង្កើតនូវគណៈកម្មការត្រួតពិនិត្យសមរាប់ទីលានដង្កោផងដែរ។

| ប្រភេទការងារ | ការលិអិត |
|---|---|
| ១. គំហើញពីខាងក្រៅនៃទីលាន | ចំណុចដែលត្រូវអង្កេត :<br>លក្ខ័ណ្ឌដី (ដីគ្របចុងក្រោយ)<br>លក្ខ័ណនៃប្លុកគំរូរ (ការស្រុត ការកែទំរង់រូបរាងជាដើម)<br>ការថែទាំប្រព័ន្ធលូ និងប្រព័ន្ធចំរោះទឹកសំអុយ<br>ផ្សេង១ |
| ២. ទឹកក្រោមដី | ការត្រួតពិនិត្យដោយទ្បេងទាត់នូវគុណភាពទឹកនៃអណ្តូងត្រួតពិនិត្យ |
| ៣. ទឹកសំអុយ | ការត្រួតពិនិត្យបំពង់ហូរចូលនិងបំពង់ហូរចេញនៃបរិក្ខាប្រព្រឹត្តកម្ម |
| ៤. ឧស្ម័នពីទីលាន | ការវិភាគដោយទ្បេងទាត់នូវសារធាតុនៃឧស្ម័នពីទីលាន |
| ៥.ភ្លើងឆេះ | ត្រួតពិនិត្យភ្លើងឆេះទីលានជាប្រចាំ |
| ៦.សំលេង | ត្រួតពិនិត្យសំលេងជាប្រចាំ |
| ៧.ក្លិនស្អុយ | ត្រួតពិនិត្យក្លិនស្អុយដែលកើតនៅទីលានជាប្រចាំ |
| ៨. ការស្រុតចុះនៃប្លុកគំរូ | ការវាស់វែងដោយទ្បេងទាត់រាល់ការស្រុតចុះទាំងឡាយ |
| ៩.សត្វចង្រៃ (សត្វល្អិត កណ្តុរ។ល។) | ត្រួតពិនិត្យការកកើតសត្វល្អិតក្នុងទីលាន |
| ១០.ប្រតិបត្តិការទីលាន | ត្រួតពិនិត្យការប្រតិបត្តិទីលាន |
| ១១.សំរាមរាយប៉ាយ | ត្រួតពិនិត្យសំរាមរាមប៉ាយក្រៅទីលាន |

## e. ផែនការប្រើប្រាស់ដីធ្លីទៅថ្ងៃអនាគត

### e.1 ដីដែលជាកម្មសិទ្ធរបស់ក្រុង

- សួនសាធារណៈដោយមានកន្លែងសំរាប់សង្កេតមើល : ដើម្បីសាងសង់កន្លែងសំរាប់សង្កេតមើលដោយទាញយកផលប្រយោជន៍ពីរយៈកំពស់នៃប្លុកគំរូនេះ ។

- គ្រឿងបរិក្ខាសំរាប់ប្រើប្រាស់ឧស្ម័នពីទីលាន : ដើម្បីផលិតធ្យូងដោយប្រើឧស្ម័នពីទីលាន ។

**e.2 ដីឯកជន ( តំបន់ពង្រីក)**

- ត្រូវប្រគល់ទៅម្ចាស់ដីវិញបន្ទាប់ពីបានគ្របដីជិតរួច
- យោងទៅលើការជួល ត្រូវប្រគល់ទៅឱ្យម្ចាស់ដីនៅពេលដែលកន្លែងចាក់នោះមានកំពស់ ៤ម៉ែត្រ ។ វាចំណាយពេលវេលាយូរមុននឹងឈានដល់ការិតស្ថេរភាព និងមានការប្រថុយប្រថានជាមួយនឹងការស្រុតចុះ និង ការផ្ទុះដោយឧស្ម័នដែលចេញពីសំរាម ។ ដូច្នេះ ដើម្បីឱ្យមានលក្ខណៈល្អប្រសើរដីនោះត្រូវគ្រប់គ្រងដោយ រ.គ.ស.ភ ហើយនឹងបន្តរយៈពេលជួលឬក៏ទិញបន្ថែមទៀត។ ប្រសិនបើម្ចាស់ដីត្រូវការឱ្យប្រគល់ត្រលប់វិញនោះ សាលាក្រុងភ្នំពេញត្រូវតែធ្វើបទបញ្ជាអំពីបំរើបំរាស់ដីនោះ ហើយម្ចាស់ដីត្រូវសុំការអនុញ្ញាតពីក្រុង។
- ហេដ្ឋារចនាសម្ព័ន្ធដោយពុំមានអាគារធំៗ
- ក្រុមសិក្សាផ្តល់អនុសាសន៍ថាដីនោះនឹងត្រូវប្រើប្រាស់ជាសួនសាធារណៈឬ ប្រើជាកន្លែងបង្ហាត់វាយកូនគោល

  ដែលពុំមានការប្រឈមនឹងភាពប្រថុយប្រថានដែលបណ្តាលមកពីការស្រុត និងឧស្ម័ន ។

**f. តំលៃគំរោង**

ថ្លៃដើមគំរោងរាប់បញ្ចូលទាំង ថ្លៃសាងសង់ និងថ្លៃលើការងារអង្កេតចាំបាច់មួយចំនួន បន្ទាប់ពីការបិទទីលាន ។

Table 6-25: **តំលៃគំរោងនៃការបិទទីលានស្ទឹងមានជ័យ ( ១,000ដុល្លា)**

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | 2013 | 2014 | 2015 |
|---|---|---|---|---|---|---|---|---|---|---|
| ទុនដំបូង | 75 | 745 | | | | | | | | |
| តំលៃប្រតិ. និងគ្រប់គ្រង | | 24 | 14 | 14 | 24 | 14 | 14 | 24 | 14 | 14 |
| Total | 75 | 769 | 14 | 14 | 24 | 14 | 14 | 24 | 14 | 14 |

## 6.4.3 ការវាយតំលៃគំរោង

### a. ការវាយតំលៃបច្ចេកទេស

ផែនការបិទទីលានពុំមានការវិធានការណ៍លើការបំពុល ចាប់តាំងពីការបើកនាឆ្នាំ ១៩៦០ ។ ជាផលវិបាកនោះគឺថាផ្ទៃបាតនៃទីលានបានប៉ះពាល់ផ្ទាល់ជាមួយនិងប្រភពទឹកក្រោមដី ដែលគេមិនអាចបញ្ឈប់ការហូរនេះបានទេ ។ នាពេលបច្ចុប្បន្ននេះ មានតែវិធីគ្របដីប៉ុណ្ណោះ ដែលជាវិធីសាស្ត្រប្រសើរបំផុត ដេលវាអាចជួយបន្ថយ ប្រមូលសំអាតទឹកសំអុយអោយអស់ពីលទ្ធភាព ព្រមជាមួយការប្រមូលឧស្ម័នទីលាន ហើយប្រើប្រាសអោយសមស្រប ។

### b. ការវាយតំលៃសង្គម

ផលប៉ះពាល់លើសង្គមអំពីការបិទទីលានមានសង្ខេបខាងក្រោម ។

**១ ផលប៉ះពាល់អវិជ្ជមាន**

- បាត់បង់ប្រភពប្រាក់ចំណូលសំរាប់អ្នករើសសំរាម

- ការខូចខាតចំពោះឧស្សាហកម្មកែច្នៃនៅតំបន់ស្ទឹងមានជ័យ

**២ ផលប៉ះពាល់វិជ្ជមាន**

- ការកែលំអលក្ខ័ណ្ឌបរិស្ថាន និងអនាម័យជុំវិញទីលាន
- បង្កើតនូវមុខរបរថ្មីដើម្បីប្រើប្រាស់ឱ្យមានប្រសិទ្ធិភាពនៅឧស្ម័នពីទីលាន

### b.1 យុទ្ធវិធីមូលដ្ឋានក្នុងការធ្វើអោយផលប៉ះពាល់អវិជ្ជមានមានកំរិតអប្បបរមា

អ្នករើសសំរាមគឺជាក្រុមមួយដែលទទួលផលប៉ះពាល់ខ្លាំងជាងគេនៅពេលទីលានស្ទឹងមានជ័យបិទ ។ដោយគិតទៅលើចំនួនអ្នករើសសំរាម ជាការសំខាន់ណាស់ដែលសាលាក្រុង-រដ្ឋាករគ្រប់គ្រងសំណល់ចាត់វិធានការសមស្របក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានអោយមានកំរិតត្រឹមតែអប្បបរមា ។ ចាំបាច់ត្រូវចាត់វិធានការកាន់តែឆាប់កាន់តែល្អក្នុងការសហប្រតិបត្តិការជាមួយរាល់ស្ថាប័នពាក់ព័ន្ធទាំងអស់ ។

ក្រុមសិក្សាបានធ្វើការសិក្សាលើការអង្កេតបរិស្ថានសង្គមក្នុងជំនាក់កាលទី១ ។ ទោះជាយ៉ាងនេះក្តី ស្ថានភាពជុំវិញអ្នករើសសំរាមបានផ្លាស់ប្តូរកាលពីឆ្នាំមុន ដូច្នេះជាការចាំបាច់ណាស់ដែលត្រូវសង្ខេបពីបំរែបំរួលដែលបានកើតឡើងកាលពីឆ្នាំកន្លងទៅ ។

#### (១) ស្ថានភាពបច្ចុប្បន្នរបស់អ្នករើសសំរាម

លទ្ធផលនៃការសិក្សាបង្ហាញថាមានចំនួនអ្នកចូលមកនិងចេញទៅវិញក៏ច្រើនដែរ ហើយមានអ្នកខ្លះទៀត ផ្លាស់ប្តូរទីតាំងពីទីលានចាក់សំរាមទៅទីក្រុងជាញឹកញយ ។ បន្ទាប់ពីការសាកល្បងគំរោងបែងចែកតំបន់បានបញ្ចប់ ទៅកាលពីដើមឆ្នាំ ២០០៤ អ្នករើសសំរាមជាច្រើនបានមករើសសំរាមតាមដងផ្លូវក្នុងទីក្រុងភ្នំពេញដោយសារតែ ល័ក្ខខ័ណ្ឌទីលានកាន់តែយ៉ាប់យ៉ឺនដែលបណ្តាលមកពីការប្រតិបត្តិ និង គ្រប់គ្រងទីលានមិនបានល្អរបស់រដ្ឋាករគ្រប់ គ្រងសំណល់ ។ ជាងនេះទៅទៀត កន្លែងកែច្នៃដែលប្រតិបត្តិដោយក្រុមហ៊ុនឯកជនបានសហការជាមួយក្រុមហ៊ុន ស៊ីនទ្រីបានជួលអ្នករើសសំរាមប្រហែលជា ១០០នាក់អោយធ្វើការក្នុងកន្លែងកែច្នៃនោះកាលពីខែសីហាកន្លងទៅ ។ ជាលទ្ធផល ចំនួនអ្នករើសសំរាមបានថយចុះគួរអោយកត់សំគាល់កាលពីប៉ុន្មានខែមុននេះដូចបានបង្ហាញក្នុងតារាងខាង ក្រោម :

Table 6-26: ចំនួនអ្នករើសសំរាមនៅទិលានតាមការសង្កេត

| កាលបរិច្ឆេទ | ក្មេងរើសសំរាម | មនុស្សពេញវ័យ | សរុប |
|---|---|---|---|
| 2003 | | | |
| ៣០ ឧសភា (ព្រឹក) | 112 | 290 | 402 |
| ២ មិថុនា (រសៀល) | 161 | 360 | 521 |
| ៥ មិថុនា (ព្រឹក) | 144 | 369 | 513 |
| 2004 | | | |
| ១៨ តុលា | 45 | 149 | 204 |
| ២២ វិច្ឆិកា | 18 | 179 | 197 |
| ១ ធ្នូ | 78 | 196 | 274 |

ចាប់តាំងពីប្រតិបត្តិការនិងការគ្រប់គ្រងទីលានត្រូវបានកែលំអ គេរំពឹងថានឹងមានអ្នករើសសំរាមជាច្រើនទៀតនឹងវិលត្រលប់មកកាន់ទីលានចាប់តាំងពីពេលនេះទៅ ។

ការអង្កេតកាលពីលើកមុនក៏បានបង្ហាញដែរថាមានអ្នកចូលមកទីលាននិងអ្នកចាកចេញពីទីលានច្រើនដូចគ្នា ។ ជាប់ពីឆ្នាំ ២០០៤មក រដ្ឋាករគ្រប់គ្រងសំណល់បានចាប់ផ្តើមបន្តការងារចុះឈ្មោះអ្នករើសសំរាមដែលមកថ្មី ។ ផ្អែកលើទិន្នន័យចុះឈ្មោះនាពេលថ្មីៗនេះ មានអ្នករើសសំរាមដែលមកថ្មីប្រហែលជា២០-៣០នាក់ជារៀងរាល់ខែ ។

អ្នករើសសំរាមនៅតែគ្មានអ្នកដឹកនាំឬអង្គការចាត់តាំងគ្រប់គ្រងឡើយ ទោះបីជាអង្គការមិនមែនរដ្ឋាភិបាលនានាបានខិតខំប្រឹងប្រែងក៏ដោយ ។ គេរំពឹងថាសាលាក្រុងភ្នំពេញ-រដ្ឋាករគ្រប់គ្រងសំណល់នឹងប្រឈមមុខនឹងផលលំបាកជាច្រើនក្នុងការចរចារជាមួយអ្នករើសសំរាមក្នុងគោលបំណងគិតគូរពីវិធានការចាំបាច់នានា ។

**(២) យុទ្ធវិធីមូលដ្ឋាន**

ពីព្រោះថាថវិកានិងមន្ត្រីរបស់សាលាក្រុងភ្នំពេញអាចចាត់ចែងបានមានកំរិតនោះ សំខាន់ណាស់ដែលសាលាក្រុង — រដ្ឋាករគ្រប់គ្រងសំណល់ដើរតួនាទីនិងទទួលខុសត្រូវក្នុងការបង្កើតផែនការដោយសហការជាមួយអង្គការពាក់ព័ន្ធនានានោះ ។ យុទ្ធវិធីមូលដ្ឋានដែលក្រុមសិក្សាចាយកាស្នើដល់សាលាក្រុងភ្នំពេញត្រូវបានសង្ខេបដូចខាងក្រោមក្នុងផ្នែកនេះ ។

**១) -ការបង្ហាញមនុស្សដែលជាគោលដៅ**

ផ្អែកលើលទ្ធផលនៃការសិក្សាបរិស្ថានសង្គម អ្នករើសសំរាមនៅទីលានស្ទឹងមានជ័យខុសៗគ្នាទៅតាមអាយុ ប្រាក់ចំណូល ស្ថានភាពរស់នៅនិងស្ថានភាពការងារ ។ មានអ្នករើសសំរាមជាច្រើនដែលរើសសំរាមនៅទីលានមិនប្រាកដប្រជា គឺនៅពេលនៅពេលផុតរដូវកសិកម្ម ហើយអ្នករើសសំរាមខ្លះទៀត ដែលរស់នៅជិតទីលានរើសសំរាមតែនៅចុងសប្តាហ៍គ្រាន់តែជាប្រាក់ចំណូលបន្ថែមតែប៉ុណ្ណោះ ។

នៅពេលដែលរដ្ឋាករគ្រប់គ្រងសំណល់ចាប់ផ្តើមចុះឈ្មោះអ្នករើសសំរាមនៅចុងឆ្នាំ២០០៣ អ្នករើសសំរាមជាច្រើនដែលមិនរើសសំរាមនៅទីលានស្ទឹងមានជ័យពិតប្រាកដតែបានចុះឈ្មោះយកកាតរើសសំរាម ។ ក្រោយពេលត្រួតពិនិត្យអ្នករើសសំរាមនៅទីលានមួយរយៈពេលខ្លី រដ្ឋាករគ្រប់គ្រងសំណល់បានចេញកាតសំគាល់ខ្លួនដល់អ្នកទាំងឡាយណាដែលត្រូវបានត្រួតពិនិត្យដោយបុគ្គលិករដ្ឋាករគ្រប់គ្រងសំណល់ច្រើនជាងបីដង ។ នៅខែតុលា ឆ្នាំ ២០០៤ ចំនួនអ្នកដែលមានកាតរើសសំរាមមាន ១.៥៥៨ (ក្នុងចំណោមអ្នកដែលមានកាតរើសសំរាម ២.៩៦៧នាក់) ។ ទោះជាយ៉ាងនេះក្តីនៅមានចំនួនអ្នករើសសំរាមដែលមានកាតសំគាល់តែលែងរើសសំរាមនៅទីលានស្ទឹងមានជ័យ ។ ជាការសំខាន់សំរាប់សាលាក្រុង-រដ្ឋាករគ្រប់គ្រងសំណល់ដែលត្រូវជ្រើសរើសដោយប្រយ័ត្នប្រយែងនូវអ្នកដែលត្រូវជួយពិតប្រាកដ ។

ក្រុមសិក្សាចាយកាសូមផ្តល់នូវលក្ខណៈវិនិច្ឆ័យដូចខាងក្រោមក្នុងការរើសអ្នកដែលត្រូវជួយ ។

- ជាអ្នករើសសំរាមនៅទីលានចាក់សំរាមយូរមកហើយ (ជាអាទិភាពត្រូវផ្តល់អោយអ្នកដែលបានចុះឈ្មោះទទួលកាតមុនគេកាលពីដើមឆ្នាំ ២០០៤ ។ អ្នកទើបមកថ្មីមិនមែនជាអ្នកដែលត្រូវជួយឡើយ ។ នេះអាចកាត់បន្ថយការលើកទឹកចិត្តដល់ប្រជាជនក្នុងតំបន់ជនបទអោយមកទីលានស្ទឹងមានជ័យ ។
- ជាអ្នកធ្វើការពេញម៉ោងនៅទីលានស្ទឹងមានជ័យ (ហាមយកអ្នកធ្វើការមិនពេញពេល)
- ជាអ្នករើសសំរាមអចិន្ត្រៃយ៍នៅទីលាន (ហាមអ្នកមកពីជនបទមកពីតំបន់ជនបទ)
- ជ្រើសរើសអ្នករើសសំរាមដោយផ្អែកលើគេហដ្ឋាន (ដើម្បីពង្រីកអ្នកត្រូវជ្រើសរើសអោយបានច្រើនចាំបាច់ត្រូវជ្រើសរើសម្នាក់ក្នុងមួយគ្រួសារប្រសិនបើចំនួនការងារដែលបង្កើតឡើងមានកំណត់)

ដោយសារតែចំនួនអ្នករើសសំរាមដែលកំពុងរើសសំរាមនៅទីលានស្ទឹងមានជ័យនាពេលតលូវនេះមានចំនួន

តិចជាងអ្នកដែលមានកាតរើសសំរាម សាលាក្រុង-រដ្ឋការត្រូវសំគាល់ថាតើអ្នកណាជាអ្នករើសសំរាមជាប្រចាំនោះ។ ក្រុមសិក្សាចាយកាសូមស្នើដល់រដ្ឋាករគ្រប់គ្រងសំណល់អោយត្រួតពិនិត្យកាតសំគាល់ខ្លួនអ្នករើសសំរាមក្នុងមួយខែម្តង។

## ២) បង្កើតកិច្ចសហប្រតិបត្តិការជិតស្និតជាមួយរាល់ស្ថាប័នពាក់ព័ន្ធទាំងអស់

នៅទីលានស្ទឹងមានជ័យ អង្គការក្រៅរដ្ឋាភិបាលនានាបានធ្វើការយ៉ាងសកម្មពាក់ព័ន្ធនឹងការជួយគាំទ្រអ្នករើសសំរាមកាលពីសត្សវត្សកន្លងទៅ។ អង្គការទាំងនោះមានកម្មវិធីរបស់ខ្លួនក្នុងការគាំទ្រអ្នករើសសំរាមអោយផ្លាស់ប្តូរការងារ។ ពេលដែលសាលាក្រុង-រដ្ឋាករគ្រប់គ្រងសំណល់គិតគូរពីកម្មវិធីគាំទ្ររបស់ខ្លួន សំខាន់បំផុតត្រូវជៀសវាងជំលោះជាមួយសកម្មភាពរបស់អង្គការទាំងនោះ។

ជាការចាំបាច់ណាស់ សំរាប់សាលាក្រុងភ្នំពេញ-រ.គ.ស.ភ បង្កើនទនូវយន្តការដែលក្នុងនោះសាលាក្រុងភ្នំពេញអាចពិភាក្សាពីវិធានការចាំបាច់នានាជាមួយស្ថាប័នពាក់ព័ន្ធដទៃទៀតជាប្រចាំ។ ក្នុងគោលបំណងនេះ ក្រុមសិក្សា និង រ.គ.ស.ភ បានរៀបចំការប្រជុំមួយនៅចុងខែកញ្ញា ឆ្នាំ២០០៤ ដោយអញ្ជើញអង្គការ និងអង្គការសាសនាដែលគាំទ្រអ្នករើសសំរាម។ នៅពេលប្រជុំ ក្រុមសិក្សា និងរ.គ.ស.ភ បានពន្យល់ពីផែនការទីលាននិងកម្មវិធីបន្ទាប់បន្សំ ហើយអង្គការនានាបង្ហាញពីផែនការសកម្មភាពនាពេលបច្ចុប្បន្ននិងអនាគត។ ក្រុមសិក្សាសូមស្នើសាលាក្រុងភ្នំពេញ-រ.គ.ស.ភ អោយបន្តចាត់ចែងការប្រជុំនេះជាប្រចាំ ក្នុងគោលបំណងផ្លាស់ប្តូរគំនិត និងពត៌មាន។ ការប្រជុំលើកក្រោយគួរអញ្ជើញអាជ្ញាធរមូលដ្ឋានចូលរួមដែរ។

## ៣) ស្នើសុំអោយអង្គការនានាជួយគាំទ្រការទំនាក់ទំនងជាមួយអ្នករើសសំរាម

ជាផ្នែកមួយនៃការអង្កេតសង្គមនិងបរិស្ថាន ក្រុមសិក្សាបានធ្វើការសំភាសន៍ជាមួយអ្នករើសសំរាម និងរៀបចំការប្រជុំជាក្រុម។ នៅពេលធ្វើការអង្កេតផែនការអភិវឌ្ឍន៍នៃទីលានចាក់សំរាមថ្មីនៅតែមិនទាន់បានដឹងពិតប្រាកដ ហើយអ្នកសំភាសន៍ភាគច្រើនមិនបានយល់ពីផែនការបិទទីលានស្ទឹងមានជ័យទេ ដូច្នេះសាលាក្រុងភ្នំពេញ-រ.គ.ស.ភ ត្រូវពិភាក្សាជាបន្ទាន់ពីផែនការបិទទីលានជាមួយអ្នករើសសំរាម។

ទោះជាយ៉ាងនេះក្តី សាលាក្រុងភ្នំពេញ-រ.គ.ស.ភ មិនអាចអញ្ជើញអ្នករើសសំរាមអោយចូលរួមក្នុងវេទិកាសាធារណៈបានទេ ដោយសារតែអ្នករើសសំរាមគ្មានអ្នកដឹកនាំ។ ដោយសារតែអ្នករើសសំរាមជាច្រើនបានទទួលការជួយគាំទ្រពីអង្គការ ជាការប្រសើរណាស់ត្រូវស្នើអង្គការអោយសុំជួយធ្វើការទំនាក់ទំនងជាមួយអ្នករើសសំរាម។

ពេលដែលសាលាក្រុងភ្នំពេញបានធ្វើការសំរេចចិត្តអនុវត្តផែនការអភិវឌ្ឍន៍ទីលានដង្កោ សាលាក្រុងភ្នំពេញ-រ.គ.ស.ភ គួរតែចាប់ផ្តើមពិភាក្សាជាមួយអ្នករើសសំរាមពីបំលាស់ប្តូរការងារហើយប្រាប់ពីលក្ខណៈវិនិច្ឆ័យនៃអ្នករើសសំរាមដែលត្រូវជ្រើសរើសអោយធ្វើការ។

## ៤) ការផ្សព្វផ្សាយពត៌មានអោយបានទូទៅអំពីផែនការបិទ( ទូទាំងប្រទេសកម្ពុជា)

សាលាក្រុងភ្នំពេញ/រ.គ.ស.ភ លំបាកក្នុងការគ្រប់គ្រងចំពោះចំនួនអ្នករើសសំរាមចំណូលថ្មីណាស់។ ដើម្បីកាត់បន្ថយ ចំនួនអ្នកចំណូលថ្មី ចាំបាច់ត្រូវបង្កើតផែនការផ្សព្វផ្សាយអំពីទីលានចាក់សំរាមស្ទឹងមានជ័យអោយបានទូលំទូលាយនិងបង្ហាញអោយបានច្បាស់ពីលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសសំរាប់គាំទ្រក្នុងគំរោង តាមរយៈប្រព័ន្ធផ្សព្វផ្សាយ ដូចជា ទូរទស្សន៍ វិទ្យុ កាសែត។

(៣) កម្មវិធីគាំទ្រដែលសាលាក្រុងអាចធ្វើបាន

១) ក្រោមគំរោងសាលាក្រុង

ទៅអនាគតសំរាប់គំរោងដែលទាក់ទងនឹងការគ្រប់គ្រងសំណល់រឹង សាលាក្រុងភ្នំពេញ/រ.គ.ស.ភ អាចបង្កើតអោយមានការងារដូចខាងក្រោម ។ អ្នករើសសំរាមដែលជាគោលដៅនឹងអាចផ្តល់អត្តិភាពអោយទទួល បានការងារដែលទើបបង្កើតថ្មីទាំងនេះ ជាមួយគ្នានិងអ្នកដែលបានលក់ដី រឺនឹងលក់ដីរបស់ពួកគេសំរាប់សាងសង់ទីលានដង្កោ ។ ទោះជាយ៉ាងណា ចំនួនការងារដែលបង្ហាញខាងក្រោមគឺនៅក្នុងផែនការជាមូលដ្ឋាននិងកំនត់ប៉ុណ្ណោះ ។ ដូច្នេះសាលាក្រុងភ្នំពេញ/រ.គ.ស.ភ ត្រូវ តែពិចារណារកវិធានការដទៃទៀតដោយសហការជាមួយអង្គការផ្សេងៗទៀត ។

កម្មករនៅទីលានដង្កោ( ផ្តល់អទិភាពដល់អតីតម្ចាស់ដី)

| ឆ្នាំ | ការងារ | ចំនួន |
|---|---|---|
| 2007 | កម្មករសំរាប់ប្រតិបត្តិការនៅទីលានបច្ចេកទេស | 12 |
| 2007 | កម្មករសំរាប់ផលិតជីកំប៉ុស្ត | 25 |

កម្មករសំរាប់ការប្រមូលសំណល់និងសកម្មភាពសំអាតផ្តល់ដោយ រ.គ.ស.ភ

| ឆ្នាំ | ការងារ | ចំនួន |
|---|---|---|
| 2007 | កម្មករប្រមូលសំណល់ | 48 |
| 2007 | អ្នកបោសថ្នល់ | 25 |

ដោយសារតែមានគំរោងសាងសង់រោងដាក់រថយន្តនៅទីលានចាស់ពេលដែលនឹងត្រូវបិទ នោះអ្នករើសសំរាមដែលនឹងមាន ការងារជាអ្នកប្រមូលសំរាមតាមរថយន្ត មិនចាំបាច់ត្រូវដូរទីលំនៅទេ ។

២) ការគាំទ្រ NGOs

ការជួយគាំទ្រដល់អង្គការក្រៅរដ្ឋាភិបាលអោយបន្តប្រតិបត្តការណ៍ដោយមានភាពរលូននោះ ជាតួនទីដ៏សំខាន់ដែលរដ្ឋាករ និងសាលាក្រុងត្រូវធ្វើ ។ សព្វថ្ងៃ អង្គការនានាមានតួនាទីដោយឡែកពីគ្នា តែការងារមួយចំនួនមានលក្ខណជាន់គ្នា ។ រដ្ឋាករ និងសាលាក្រុងគួររៀបចំទីតាំងដើម្បីអាចអោយបណ្តាស្ថាប័នទាំងនោះអាចជួប និងដោះដូរព័ត មានគ្នាបាន ។

b.1.2. វិធានការន៍ដើម្បីដោះស្រាយដល់ការខូចខាតលើឧស្សាហកម្មកែឆ្នៃនៅទីលានចាស់

ការងារដែលពាក់ព័ន្ធនិងសកម្មភាពកែឆ្នៃ និងការទិញសំណល់មានការរីកចំរើននៅទីលានជាពិសេសនៅជុំវិញទីលាន តែម្តង ។ ពួកគេតែងតែទិញសំណល់កែឆ្នៃពីអ្នករើសសំរាមដែលសកម្មភាពនេះមានលក្ខណសកម្ម ហើយជួយសំរួលដល់អត្រាកែឆ្នៃ របស់សាលាក្រុង ។

ដោយសារតែថា ទីលានថ្មីនឹងមិនអោយអ្នករើសសំរាមចូលធ្វើការនោះ គេប្រមាណថាបរិមាណកែឆ្នៃនឹងចុះមួយរយះក្រោយ ពេលបិទទីលានចាស់ ។ រដ្ឋាករគួរតែចាត់វិធានការន៍យ៉ាងណាដើម្បីកុំអោយមានការបាត់បង់ ឬប៉ពាល់ដល់មុខរបររបស់ពួកគេ ។ ធ្វើបានយ៉ាងនេះគឺពួកគេអាចបន្តអត្រាកែឆ្នៃ និងកាត់បន្ថយសំណល់ចូលទីលាន ។

សាលាក្រុងគួរតែមានការជួបជុំ ឬធ្វើសិក្ខាសាលា លើរបរកែឆ្នៃនេះ ដើម្បីអោយសាលាក្រុងអាចរកវិធានការន៏ប្រសើរជាងនេះ ។

## c. ការវាយតំលៃលើបរិស្ថាន

### c.1 ទូទៅ

ទីលានចាក់សំរាមស្ទឹងមានជ័យ ពុំមានវិធានការត្រួតពិនិត្យការវិពុលពុលទេចាប់តាំងពីការប្រើប្រាស់នៅឆ្នាំ ១៩៦០ ។ ការ គ្រប់ដីនៅដំណាក់កាលចុងក្រោយរបស់ទីលាន ពុំអាចការពារចំពោះការកាត់បន្ថយបរិស្ថានបានទាំងស្រុងនោះឡើយ ។ ដូច្នេះ ចាំបាច់ ពិនិត្យឱ្យល្អិតល្អន់លើទឹកក្រោមដីដើម្បីការពារបញ្ហាបរិស្ថាន ។ ជាងនេះទៀត ចាំបាច់សំរាប់សាលាក្រុងភ្នំពេញដើម្បីធ្វើបំរាមអំពី ការប្រើប្រាស់ទឹកក្រោមដី ដែលជាទឹកសំរាប់បរិភោគ ។

ចំពោះការប្រើប្រាស់ដីធ្លីឧស្ម័នពីទីលានអាចមានការប្រថុយប្រថានខ្លះ ។ វាចាំបាច់សំរាប់សាលាក្រុងភ្នំពេញផ្តល់ការណែនាំ លើការប្រើប្រាស់ដីនាពេលអនាគតនៃទីលាន ។ ក្រុមសិក្សាសន្និដ្ឋានភាពចាំបាច់នៃរយៈពេលត្រួតពិនិត្យ យ៉ាងហោចណាស់១៥ឆ្នាំ ។ រ.គ.ស.ភ និងសាលាក្រុងភ្នំពេញត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យដើម្បីធ្វើប្រតិបត្តិការណ៍ក្នុង រយៈពេល ១៥ឆ្នាំ ។

### c.2 ប្រព័ន្ធត្រួតពិនិត្យ

ប្រព័ន្ធត្រួតពិនិត្យដែលត្រូវបានបង្កើតឡើងក្រោមគំរោងសាកល្បងនិងត្រូវបន្តប្រើប្រាស់រហូតដល់ទីលាននោះមានស្ថេរ ភាព (១៥ឆ្នាំ) ។ វាចាំបាច់ដើម្បីធានាថា រ.គ.ស.ភ អាចធ្វើការត្រួតពិនិត្យក្នុងរយៈពេលយូរ ។ ដូច្នេះ ការងារត្រួតពិនិត្យទីលានស្ទឹងមានជ័យគួរតែជាផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងនៅទីលានដង្កោ ។ កត្តានេះអាចធ្វើឱ្យ រ.គ.ស.ភ ប្រើប្រាស់បុគ្គលិក និងគ្រឿងចក្រចាំបាច់សំរាប់ការត្រួតពិនិត្យទីលានស្ទឹងមានជ័យ ។ ការគ្រប់គ្រងទីលានចាក់សំរាម ស្ទឹងមានជ័យ ក្រោយការបិទទាំងស្រុងនោះ មានការងារជាច្រើនដូចជា ចាប់តាំងពីការពិនិត្យរូបរាងខាងក្រៅ រហូតដល់ការងារប្រតិបត្តិ និងគ្រប់គ្រងប្រព័ន្ធប្រព្រឹត្តិកម្មទឹកសំអុយ ។ បុគ្គលិកម្នាក់នៃទីលានដង្កោ នឹងធ្វើការដើរពិនិត្យការងារទាំង នោះជាប្រចាំ ។ ប្រសិនបើចាំបាច់វិស្វករ ឬកម្មករមួយចំនួននឹងត្រូវបញ្ជូនសំរាប់ការងារទាំងនោះដូចជា ជួសជុស និង ចាត់វិធានការ ។ គោលដៅនៃការត្រួតពិនិត្យតាមរយៈការអង្កេតមានបង្ហាញដូចខាងក្រោម :

- លក្ខណ្ឌនៃដី និងស្មៅ (ការគ្របលប់ដីបង្ហើយ) ។
- លក្ខណ្ឌនៃប្លុកចាក់សំរាម (ការស្រុត ការប្រែប្រួលរូបរាងជាដើម) ។
- ការថែរក្សាប្រព័ន្ធលូបង្ហូរ និងប្រព័ន្ធប្រព្រឹត្តិកម្មទឹកសំអុយ ។

### c.3 ការបំពុលទឹក

ទឹកសំអុយនៅតែបន្តហូរចេញពីសំរាមនៅទីលានដែលបានបិទ ទោះបីជាសមត្ថភាព និងអត្រាវាត្រូវបានថយចុះបន្តិចម្តង ៗទៅតាមពេលវេលាក៏ដោយ ។ ហេតុនេះចាំបាច់ត្រូវធ្វើការពិចារណាលើបញ្ហាតាំងនេះ ។

គំនិតជាសំខាន់នៃផែនការ គឺត្រូវគិតលើ ការបែងចែកឱ្យដាច់ស្រឡះរវាងទឹកសំអុយ និងទឹកភ្លៀង ។ ទឹកស្អុយ និងទឹក ភ្លៀងនេះត្រូវធ្វើការត្រួតពិនត្យទៅតាមវិធីសាស្ត្រដូចខាងក្រោម ។

- ទឹកសំអុយត្រូវបានប្រមូលតាមប្រអប់លូដែលត្រូវបានគេសាងសង់នៅតាមទីរាបស្មើ ហើយនិងនៅកន្លែងខ្ពស់ជាងគេ នៃប្លុក ។ ទឹកសំអុយដែលបានប្រមូលនោះត្រូវបានបូមឡើងទៅកាន់អាងប្រព្រឹត្តិកម្មដែលត្រូវបានសង់ឡើងក្នុងពេលធ្វើគំរោងសាកល្បង ។
- ក្រុមសិក្សា បានសាងសង់លូចំហរជុំវិញទីលានសំរាប់បង្ហូរជាមួយទឹកភ្លៀងដែលលាយជាមួយទឹកប្រើប្រាស់ដែលចេញ ពីគេហដ្ឋាន ។ ទឹកភ្លៀង និងទឹកហូរចេញពីគេហដ្ឋានហូរដោយទំនាញ ។ លូនោះត្រូវបានសង់នៅក្នុងតំបន់ពង្រីកនៅ ក្នុងពេលធ្វើគំរោងសាកល្បងនៅទីលានស្ទឹងមានជ័យ ប៉ុន្តែនៅតែផ្នែកខ្លះប៉ុណ្ណោះ ។ គេចាំបាច់ត្រូវសង់បន្ថែមនៅ ក្នុងតំបន់ដីទៃទៀត ។

### c.4 ឧស្ម័ននៅទីលាន

គេត្រូវគិតពីឧស្ម័នដែលបន្តកកើតសាយភាយ ទោះជាទីលានត្រូវបិទ ហើយទោះជាសមត្ថភាពកកើត និងបរិមាណថយចុះ ទៅតាមពេលវេលាក៏ដោយ ។ ហេតុនេះ បញ្ហាឧស្ម័ននេះត្រូវតែមានការពិចារណាដូចខាងក្រោមនេះ ។

ឧស្ម័នដែលកកើត ត្រូវបានត្រួតពិនិត្យតាមរយៈការតម្លើងបំពង់ផ្តេក និងបញ្ឈរស្រូបឧស្ម័ន ។

- ចំនុចល្អគេត្រូវតម្លើងបំពង់ដែលបញ្ឈរសំរាប់ស្រូបយកឧស្ម័នពីទីលាន ។ វាចាំបាច់សំរាប់ រ.គ.ស.ភ តម្លើងបំពុងឧស្ម័នតាមចំណុចដែលបានកំណត់មុនពេលការធ្វើប្រតិបត្តិការណ៍ទីលាន ។
- រីឯបំពង់ស្រប និងនឹងត្រូវបានតម្លើងមុនពេលចាក់ដីលប់ ។ នៅលើប្លុកគំរូដែលបានសាងសង់នៅទីលានចាស់ គេបានតម្លើងបំពង់បញ្ឈររួចហើយ ដូច្នេះបំពង់ថ្មីនឹងត្រូវតភ្ជាប់ទៅនឹងបំពង់ចាស់ ។
- យកល្អ គេគួរតំលើងបំពង់យកឧស្ម័ននៅក្នុងតំបន់ដែលបានពង្រីក ដោយហេតុថាបំពង់ឧស្ម័នអាចបង្កឱ្យមាន

ផលលំបាកដល់ដំណើរការធ្វើឱ្យមានស្ថេរភាពនៃទីកន្លែងចាក់សំរាម ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ វាអាស្រ័យលើការប្រើដីនាពេលអនាគតហើយដែលម្ចាស់ដីនឹងកំណត់ថាតើបំពង់ទាំងនោះគួរអនុញ្ញាតឱ្យតម្លើងឬទេ ។

## d. ការវាយតំលៃផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

មានជំរើស ២ សំរាប់ធ្វើការស្នើសុំជំនួយសំរាប់ការថែរក្សាបរិស្ថាន និងការបិទទីលានស្ទឹងមានជ័យ ប្រកបដោយសុវត្ថិភាព ។ ទី១ គឺពីការចាត់ចែងថវិកាពីសាលាក្រុងភ្នំពេញ និងទី២ គឺជាខ្ទាក់ចំណូលដែលទទួលបានពីការប្រើប្រាស់ទីលានថ្មីនៅដង្កោ ។ ការសិក្សាខាងក្រោមបានធ្វើការប៉ាន់ស្មានលើការថែរក្សាបរិស្ថាន និងការបិទទីលានស្ទឹងមានជ័យប្រកបដោយសុវត្ថិភាព ហើយនិង ផលប៉ះពាល់របស់វាទៅលើការបង់ថ្លៃជួលសេវាទីលាននៅដង្កោរ ប្រសិនបើប្រាក់ចំណូលរបស់ទីលានថ្មីនេះត្រូវបានគេចាត់ចែង សំរាប់ការបិទទីលានស្ទឹងមានជ័យ ។

### d.1 តំលៃនៃការថែរក្សាបរិស្ថាន និងការបិទទីលានស្ទឹងមានជ័យប្រកបដោយសុវត្ថិភាព

មានចំនុចពីរដែលត្រូវធ្វើការតំឡើងតំលៃទីលានចាក់សំនល់ ដើម្បីងាចធ្វើការបិទទីលានដោយមានសុវត្ថភាព ក៏ដូចជា ការថែទាំបរិស្ថានផងដែរ ។ ទីមួយគឺការចាត់ចែងថវិការពីសាលាក្រុង និងមួយទៀតគឺការលៃលកថវិការពីប្រតិបត្តការណ៍ ទីលានថ្មីនៅដង្កោ ។ ការសិក្សានេះ ធ្វើការប៉ាន់ស្មានដោយយោងលើសុវត្ថភាពបរិស្ថានជាចំបងនាពេលធ្វើការបិទទីលានស្ទឹងមានជ័យនេះ ។

### d.2 ការប្រើប្រាស់ប្រាក់ចំណូលពីប្រតិបត្តិការណ៍ទីលានដង្កោ និងផលប៉ះពាល់លើថ្លៃចាក់នៅទីលាន

ការសិក្សាបានធ្វើការវិភាគទៅលើផលប៉ះពាល់ចំពោះថ្លៃចាក់ដែលនឹងត្រូវកំណត់សំរាប់ប្រតិបត្តិការណ៍នៅទីលានថ្មី ដង្កោក្នុង ករណីដែលចំណូលនេះត្រូវបានបែងចែកសំរាប់ធ្វើការបិទទីលានស្ទឹងមានជ័យ ។ ដូចបានបញ្ជាក់ក្នុងចំណុច ១.១.២ ខាងលើចាំបាច់ ត្រូវយកថ្លៃសេវាជួលទីលាន ៥ដុល្លាក្នុងមួយតោនសំរាម ដើម្បីទទួលបាននូវស្ថេរភាពនៃហិរញ្ញវត្ថុនៃទីលានដង្កោដែលក្នុងនោះ ប្រាក់កំរៃដែលបានមកវិញគឺ១០% ។ នៅក្នុងករណីដែលចាត់ចែងថវិកាសំរាប់ការបិទទីលាន ចាស់អំពីប្រាក់ចំណូលពីទីលានថ្មីនេះ នោះតំលៃសេវាទីលានត្រូវបានប៉ាន់ស្មានប្រមាណ៥.០៧ដុល្លាក្នុងមួយតោនសំរាម ចាក់ ។ អត្រាកំណើននៃថ្លៃសេវាចាក់នៅទីលាន ០,០៧ដុល្លាក្នុងមួយតោនគ្រាន់តែជាការប្រែប្រួលដ៏តិចតួចប៉ុណ្ណោះ សំរាប់ទីលានដង្កោប្រសិនបើវាត្រូវបានគេអនុវត្តប្រកបដោយស្ថេរភាពផ្នែកហិរញ្ញវត្ថុ ។

# 7 ការសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## 7.1 ការសន្និដ្ឋាន

### 7.1.1 បញ្ហាផ្សេងៗលើការគ្រប់គ្រងសំណល់រឹងនាទីក្រុងភ្នំពេញនាពេលបច្ចុប្បន្ន

#### a. តំបន់ដែលមិនទាន់មានសេវាកម្មនិងមានសេវាកម្មមិនគ្រប់គ្រាន់

ស៊ីនទ្រីគឺជាក្រុមហ៊ុនប្រមូលសំណល់ឯកជនមួយ ដែលមានសិទ្ធប្រមូលសំណល់ និងកំរៃសេវាកម្មនៅក្នុងទូទាំងទីក្រុងភ្នំពេញលើកលែងតែតំបន់ខ្លះៗ យោងទៅលើកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខានៅថ្ងៃទី ២១មិនា ឆ្នាំ២០០២។ កិច្ចសន្យាបានបញ្ជាក់ថា ក្រុមហ៊ុនស៊ីនទ្រីមិនចាំបាច់ផ្តល់សេវាកម្មប្រមូលសំណល់នៅតំបន់ដែលមិនមានផលចំណេញសេដ្ឋកិច្ចនោះទេ ហើយក៏បានបញ្ជាក់ទៀតថា សាលាក្រុងភ្នំពេញនឹងមិនអនុញ្ញាត្តអោយភាគីទីបីណាមួយ រឺសាលាក្រុងផ្ទាល់ផ្តល់សេវាកមប្រមូលសំណល់នេះនៅក្នុងទីក្រុងដែរ។

លទ្ធផលនៃសិក្សាបានបញ្ជាក់ថា អត្រាផ្តល់សេវាកម្មប្រមូលសំណល់នៅក្នុងខ័ណ្ឌទីប្រជុំជន ទាំងបួនមានប្រមាណ ៩៥% និង៤០% នៅក្នុងខ័ណ្ឌជាយក្រុងទាំងបី ប៉ុន្តែទោះបីជាយ៉ាងនេះក្តី មានតំបន់ជាច្រើននៅក្នុងទីក្រុងដែលគ្មានសេវាកម្ម និង មានសេវាកម្មតែមិនទាន់គ្រប់គ្រាន់។ សំណល់នៅក្នុងតំបន់ទាំងនោះត្រូវបានគេចាក់ចោលតាមទីធ្លា រឺតាមបណ្តាញលូ។ សំណល់ទាំងនោះធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថានទីក្រុង ហើយសំណល់ដែលគេចាក់តាមលូដែលបង្កអោយស្ទះបណ្តាញលូ និងឈានទៅដល់មានទឹកជំនន់។

#### b. ការចាក់សំណល់ដោយចំហរ

ទីលានចាក់សំរាមស្ទឹងមានជ័យត្រូវបានប្រើប្រាស់តាំងពីឆ្នាំ ១៩៦០មកម្ល៉េះ ហើយវាគឺជាទីលានចាក់សំរាមតែមួយគត់នៅក្នុងទីក្រុងក្រុងភ្នំពេញ។ នគរូបនីយកម្មបានរីករាលដាលឆាប់រហ័សរហូតដល់ទីលានស្ទឹងមានជ័យ និងមានគេហដ្ឋានជាច្រើនក៏កើតនៅជុំវិញតំបន់នោះ ។ ដោយសារតែប្រតិបត្តិការទីលានមិនសមស្របធ្វើអោយទីលានស្ទឹងមានជ័យក្លាយជាទីលានចាក់សំនល់បែបចំហរនិង ប៉ះពាល់ដល់បរិស្ថានដូចជា មានភ្លើងឆេះកើតឡើងជារៀងរាល់ថ្ងៃធ្វើអោយមានផ្សែង និងក្លិនអាក្រក់ និងការកើតមាន សត្វរុយ និងសត្វល្អិតចង្រៃនានា។ ទោះបីជាមានការកែលំអរជាច្រើននៅក្នុងគំរោងសាកល្បងក្នុងការសិក្សានេះក៏ដោយ ក៏នៅតែមានបញ្ហាជាច្រើនដូចជាមិនមានលទ្ធភាពគ្របដណ្តប់លើសំរាមដោយសារតែថវិកាមិនគ្រប់គ្រាន់ (ថវិការទទួលបានសព្វថ្ងៃគឺតិចជាង 0.៥ ដុល្លាក្នុង១តោន)។ បន្ថែមលើបញ្ហាបរិស្ថានដែលបានបញ្ជាក់ខាងលើទៀតនោះ គឺតាមការប៉ាន់ស្មានទីលានចាក់សំរាមស្ទឹងមានជ័យអាចចាក់សំរាមបានតែក្នុងរយៈពេល ២ឆ្នាំទៀតប៉ុណ្ណោះគិតចាប់ចុងឆ្នាំ ២០០៤តទៅ។ ដូច្នេះហើយ ការអភិវឌ្ឍន៍ទីលានថ្មីជាបន្ទាន់គឺជាកត្តាចាំបាច់មិនអាចខានបាន។

#### c. គំនរសំរាម និងការរ៉ាយប៉ាយនៃសំរាមក្នុងទីក្រុង

នៅទីក្រុងភ្នំពេញនាពេលបច្ចុប្បន្ន ទោះបីជានៅក្នុងមជ្ឈមណ្ឌលកណ្តាលដែលមានសេវាកម្មគ្រប់គ្រាន់ក៏គេនៅឃើញមានគំនរសំរាម និងភាពរាយប៉ាយគ្រប់ទីកន្លែងដោយសារតែខ្វះនូវបទបញ្ជា។ ហើយវាមិនគ្រាន់តែបង្កអោយមានការថយចុះលើផ្នែកបរិស្ថានអនាម័យប៉ុណ្ណោះទេក៏ប៉ុន្តែបានធ្វើអោយមានផលប៉ះពាល់អវិជ្ជមានលើវិស័យ ឧស្សាហ-កម្ម ទេសចរណ៍ ដោយសារតែទិដ្ឋភាពដែលត្រូវបានបំពុល។ ទោះបីជាទិដ្ឋភាពតាមផ្លូវសំខាន់ត្រូវបានសំអាតដោយសេវាកម្ម បោសផ្ទល់ក៏ដោយ ដើម្បីបំបាត់គំនរសំរាមនិងសំណល់រ៉ាយប៉ាយទាំងអស់នោះ គឺគួរតែមានការកែលំអរជាបន្ទាន់តាមរយៈការបង្កើតនូវបទបញ្ជាចាក់សំរាមដោយសហការជាមួយសាធារណជន។

**d. ភាពទន់ខ្សោយនៃប្រព័ន្ធកិច្ចការសាធារណៈ**

ដោយសារតែវិស័យឯកជនជាអ្នកទទួលខុសត្រូវលើសកម្មភាពសំអាតជាយូរមកហើយនោះ ធ្វើអោយសមត្ថភាពសំអាតរបស់ស្ថាប័នសាធារណៈមានភាពទន់ខ្សោយដូចពេលបច្ចុប្បន្ននេះ។ ជាលទ្ធផល សាលាក្រុងភ្នំពេញមិនអាចឆ្លើយតបទៅនឹង សំណើអោយមានការទទួលសេវាកម្មស្មើ ៗភាពគ្នាបានទេអំពីសំណាក់ប្រជាពលរដ្ឋរស់នៅក្នុងតំបន់ដែលគ្មានសេវាកម្ម។

## 7.1.2 ផែនការមេ

ផែនការមេ ត្រូវបានបង្កើតឡើងយោងទៅលើលក្ខខ័ណ្ឌបច្ចុប្បន្ននៃការគ្រប់គ្រងសំណល់រឹងដែលបានបញ្ជាក់ខាងលើក្នុងគោលបំណងដើម្បី "បង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ប្រកបដោយនិរន្តរភាពមួយក្នុងទីក្រុងភ្នំពេញនៅឆ្នាំគោលដៅគឺ ២០១៥" ។ ប្រសិនបើផែនការមេត្រូវបានសំរេច បរិមាណបញ្ជូនសំណល់ក្នុងឆ្នាំ២០១៥ នឹងមានដូចខាងក្រោម ។

(ឯកតា: តោនក្នុងមួយថ្ងៃ តំលៃនៅក្នុងរង្វង់ក្រចកគឺជាប្រភាគនៃសំណល់ដែលបានបញ្ចេញ)

| ឆ្នាំ | បរិមាណបញ្ចេញ | បរិមាណដែលចាក់ចោលមិនសមស្របពីកន្លែងដែលបញ្ចេញ | បរិមាណប្រមូល | បរិមាណដែលធ្វើប្រព្រឹត្តកម្មនៅកន្លែងធ្វើជីកំប៉ុស | បរិមាណចាក់ចោលនៅទីលាន | បរិមាណកែច្នៃ |
|---|---|---|---|---|---|---|
| ២០០៤ | ៩៧៨ (១០០) | ៦៨ (៦.៩) | ៧១៧ (៧៣.៣) | ៥.៣ (០.៥) | ៦៩៣ (៧០.៨) | ៩៣ (៩.៥) |
| ២០១៥ | ១,៧៣៩ (១០០) | ០ (០) | ១,៥៩៨ (៩១.៨) | ៣៣.៣ (១.៩) | ១,៤៦១ (៨៤) | ២៤២ (១៣.៩) |

នៅក្នុងផែនការមេ វិធានការកែលំអរដើម្បីដោះស្រាយបញ្ហាផ្សេងៗ ដែលបានបង្ហាញខាងលើដោយផ្អែកបច្ចេកទេស និងស្ថាប័ន ត្រូវបានគេគ្រោងទុក។

**a. វិស័យបច្ចេកទេស**

**a.1 ការពង្រីកសេវាកម្មប្រមូលសំណល់ដើម្បីលុបបំបាត់តំបន់គ្មានសេវាកម្ម**

- ក្រុមហ៊ុនឯកជន (ស៊ីនទ្រី) ផ្តល់សេវាកម្មប្រមូលសំណល់នៅក្នុងតំបន់ទាំងអស់នៃខ័ណ្ឌទាំងបួន និងនៅក្នុងខ័ណ្ឌជាយក្រុងទាំងបីចំពោះតែតំបន់ណាដែលមានផលចំណេញសេដ្ឋកិច្ចប៉ុណ្ណោះ។
  សាលាក្រុងភ្នំពេញ/ រ.គ.ស.ភ អាចផ្តល់សេវាកម្មប្រមូលសំណល់នៅតំបន់សេសសល់នៅក្នុងខ័ណ្ឌទាំងបីដែលជាកន្លែងមិនមានផលចំណេញខាងសេដ្ឋកិច្ចសំរាប់ក្រុមហ៊ុនឯកជនបាន គឺតាមរយៈទទួលជំនួយឥតសំណងបរទេស។
- សាលាក្រុងភ្នំពេញ/មន្ទីរបរិស្ថានគួរដឹកនាំ និងត្រួតពិនិត្យលើសេវាកម្មប្រមូលសំណល់ដែលផ្តល់ដោយរ.គ.ស.ភ និងក្រុមហ៊ុនឯកជន ទើបធ្វើអោយប្រជាពលរដ្ឋអាចទទួលបាននូវសេវាកម្មត្រឹមត្រូវ និងស្មើភាពគ្នា។
- សាលាក្រុងភ្នំពេញ និងក្រុមហ៊ុនឯកជនគួរពិនិត្យឡើងវិញនូវព្រំប្រទល់សំរាប់សេវាកម្ម ដោយផ្អែកលើលទ្ធផលត្រួតពិនិត្យដែលបានរៀបចំដោយមន្ទីរបរិស្ថានក្នុងរយៈពេលកន្លងមក។ កិច្ចព្រមព្រៀងគួរត្រូវផ្លាស់ប្តូរផងដែរ ប្រសិនបើចាំបាច់ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផលនៃការត្រួតពិនិត្យ ។

**a.2 ការកែលំអរទីលានចុងក្រោយ**

- សាលាក្រុងភ្នំពេញគួរអភិវឌ្ឍន៍ទីលានចាក់សំរាមថ្មីអោយបានឆាប់បំផុតតាមដែលអាចធ្វើបានដោយការទទួលជំនួយឥតសំណងបរទេស។

- រ.គ.ស.ភ គួរបន្តគំរោងសាកល្បងសំរាប់កែលំអរទីលានចាក់សំរាមស្ទឹងមានជ័យដែលបានផ្តល់ក្នុងការសិក្សានេះ និងទទួលនូវចំណេះដឹង របៀបនៃបច្ចេកទេសនិងប្រតិបត្តិការរហូតដល់ទីលានចាក់សំរាមថ្មីចាប់ដំណើរការ ។

- រ.គ.ស.ភ គួរបង្កើននូវកំរិតប្រតិបត្តិការទីលានអនាម័យនៅក្នុងទីលានចាក់សំរាមស្ទឹងមានជ័យជាជំហាន១ និងកាត់បន្ថយផលប៉ះពាល់បរិស្ថានដល់តំបន់ជុំវិញជាលំដាប់ ។

- រ.គ.ស.ភ គួរប្រឹងប្រែងហើយប្រឹងប្រែងទៀតដើម្បីពន្យល់អ្នកប្រើប្រាស់ទីលាន ដូចជាអ្នកផ្តល់សេវាកម្មប្រមូលសំណល់ដើម្បីធានាអោយគេយល់អំពីការតំលើងថ្លៃការចាក់សំណល់និងព្រមបង់ថ្លៃសំរាប់ការប្រមូលសំណល់ ដោយពន្យល់អំពីផលប្រយោជន៍ដែលនឹងទទួលដូចជារយៈពេលចាក់សំណល់កាន់តែខ្លី កាត់បន្ថយការចំណាយលើការជួសជុលរថយន្តដែលខូចនៅទីលានចាក់សំរាម និងបង្កើនអោយការងារមានប្រសិទ្ធិភាព ។ តាមរយៈការខំប្រឹងប្រែងនេះ រ.គ.ស.ភ គួរធ្វើការតំឡើងថ្លៃការចាក់សំណល់នៅទីលានជាជំហាន១ រហូតឡើងដល់ ៤.៨ដុល្លា/តោន មុនពេលចាប់ផ្តើមប្រតិបត្តិការនៅទីលានថ្មី ។

- រ.គ.ស.ភ គួរបង្កើតប្រព័ន្ធមួយដែលធ្វើអោយប្រជាពលរដ្ឋយល់អំពីការគ្រប់គ្រងសំណល់អោយបានត្រឹមត្រូវ និងទទួលបង់ថ្លៃសេវាកម្មប្រមូលសំណល់ដើម្បីអោយប្រតិបត្តិការការងារនិងទីលានបានល្អដោយបង្ហាញពីប្រតិបត្តិការទីលានប្រកបដោយអនាម័យ ។

### a.3 ទប់ស្កាត់គំនរសំរាមនិងការរ៉ាយប៉ាយសំរាម

- ដើម្បីលប់បំបាត់គំនរសំរាមនិងសំរាមរ៉ាយប៉ាយ អ្នកផ្តល់សេវាកម្ម( រ.គ.ស.ភ និង ស៊ីនទ្រី) គួរបង្កើតបទបញ្ជាចាក់សំរាម ដោយបញ្ជាក់ពីប្រភេទធុងសំរាមដែលត្រូវប្រើ និងពេលវេលា ថ្ងៃ និងកន្លែងចាក់សំរាម ។

- អ្នកផ្តល់សេវាកម្មគួរផ្សព្វផ្សាយពីបទបញ្ជាចាក់សំរាមដល់គ្រប់ប្រជាពលរដ្ឋអោយមានការសហការ ។

- អ្នកផ្តល់សេវាកម្មគួរផ្តល់សេវាកម្មអោយបានត្រឹមត្រូវតាមបទបញ្ជាចាក់សំរាម ។

- ចំពោះផ្នែករដ្ឋបាល( សាលាក្រុងភ្នំពេញ មន្ទីរបរិស្ថាន) គួរបង្កើននូវការផ្តល់ការយល់ដឹងសាធារណៈតាមរយៈការអប់រំប្រជាពលរដ្ឋ( ផលប្រយោជន៍នៃសេវាកម្ម) អំពីតំរូវការនៃអនាម័យសាធារណៈនិងការថែរក្សាបរិស្ថាន ដែលធ្វើអោយពួកគេយកចិត្តទុកដាក់អនុវត្តបទបញ្ជាចាក់សំរាមបានខ្ជាប់ខ្ជួន។ ការអប់រំសាធារណៈគួររួមបញ្ចូលទាំងកម្មវិធីតំរូវអោយលប់បំបាត់ការរ៉ាយប៉ាយសំរាមនិងការបោះសំរាមពាសវាលពាសកាល ។

### a.4 ការជំរុញអោយមាន 3R

នៅក្នុងការសិក្សានេះ គេបានរកឃើញថា បរិមាណសំរាមដែលបញ្ចេញក្នុងមនុស្សម្នាក់១ មានចំនួនតិច (៤៨៧ក្រាម/នាក់/ថ្ងៃ) ហើយនិងប្រព័ន្ធនៃការកែច្នៃសំរាមឯកជនយកមកប្រើប្រាស់មានសភាពរស់រវើក និងបង្កើតបានប្រសើរ ( អត្រាកែច្នៃគឺ៩.៣% ) ។ ទោះជាយ៉ាងណាក្តី ភាគច្រើននៃសំភារៈកែច្នៃទាំងនោះត្រូវបានធ្វើឡើងនៅប្រទេសថៃ និងប្រទេសវៀតណាម ។ យោងលើកត្តានេះដើម្បីជុំរុញ 3Rs (កាត់បន្ថយ ប្រើប្រាស់ឡើងវិញ កែច្នៃ) គេបានណែនាំវិធីសាស្រ្តដូចខាងក្រោម ។

- ដើម្បីរក្សា និងការពារប្រព័ន្ធកែច្នៃដែលមានស្រាប់នេះ សាលាក្រុងភ្នំពេញគួរបង្កើតនូវយន្តការគាំទ្រមួយ (ការផ្តល់ការអប់រំនិងពិតមានដល់អ្នកចាក់ចោលនិងអ្នកប្រមូលសំភារៈដែលមានតំលៃប្រព័ន្ធកម្ចីថវិការខ្នាតតូចជាដើម)សំរាប់ដល់អ្នករើសអេតចាយ និងអ្នករើសសំរាម ។

- ដើម្បីបង្កើនអត្រាកែច្នៃ សំរាមផ្ទះបាយដែលរលួយ (សំរាមផ្ទះបាយ ស្មៅនិងឈើ) ដែលបច្ចុប្បន្ននេះមានប្រមាណ៧០%នៃប្រភពសំរាមសរុបដោយទំងន់ គួរត្រូវបានចាប់ផ្តើមធ្វើការកែច្នៃអោយបានគ្រប់គ្រាន់ ។

ដូច្នេះហើយការធ្វើជីកំប៉ុសពីសំរាម ក៏នឹងត្រូវបានលើកំពស់ ។ ដើម្បីធ្វើបានដូច្នោះដោយគិតចាប់តាំងពីកំរិតនៃសកម្មភាពធ្វើជីកំប៉ុស និងការធ្វើផលិតផល គេចាំបាច់ត្រូវ ១. គេត្រូវសំដៅលើសំណល់ណាដែលចំណាយថវិកាតិចសំរាប់ធ្វើជីកំប៉ុសហើយមានគុណភាពផលិតផលខ្ពស់ ដូចជាសំណល់ទីផ្សារ សំណល់នៅតាមផ្ទះបាយជាដើម ។ ២. សំដៅទៅលើអ្នកទាំងឡាយណាដែលនឹងទិញផលិតផលដែលមានតំលៃខ្ពស់ដូចជាកសិករដែលធ្វើចំការ និងបន្លែដែលជាអតិថិជនសំខាន់ៗ ។ ៣. ជំរុញអោយមានសកម្មភាពធ្វើជីកំប៉ុសថ្នាក់ សហគមន៍ដើម្បីបង្កើនការផលិតជាជំហានៗទៅតាមការកើនឡើងនៃតំរូវការ ។

## b. វិស័យស្ថាប័នគ្រប់គ្រង

### b.1 រដ្ឋបាលនិងការគ្រប់គ្រងស្ថាប័ន

តួនាទីនិងការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធនឹងការគ្រប់គ្រងសំណល់រឹងក្នុងទីក្រុងភ្នំពេញគួរត្រូវបានកំណត់:

**ខុទ្ទកាល័យ:** បង្កើតនិងបញ្ជាគោលនយោបាយគ្រប់គ្រងសំណល់រឹងអោយបានទូលំទូលាយ ។

**ស.ក.ភ.ព:** គ្រប់គ្រងការងារសាងសង់ទីលានចាក់សំរាមដែលប្រតិបត្តិដោយ រ.គ.ស.ភ ។

**ម.ប.ស្ត.ភ:** ដឹកនាំនិងត្រួតពិនិត្យសេវាកម្មចាក់សំណល់ដែលប្រតិបត្តិដោយ រ.គ.ស.ភ និង អប់រំព្រមទាំងផ្តល់ពតិមានជាសាធារណៈដល់អ្នកម៉ៅការឯកជន ។

**រ.គ.ស.ភ:** ប្រតិបត្តិនិងគ្រប់គ្រងការងារចាក់សំណល់ដោយភាពត្រឹមត្រូវ( ការប្រមូល ការកែច្នៃ ទីលានចុងក្រោយ ។ល ។) ។

### b.2 ការចូលរួមពីស្ថាប័នឯកជន និងសាធារណៈ

- សាលាក្រុងភ្នំពេញគួរបង្កើតទំនាក់ទំនងប្រកបដោយភាពសហការរវាងគ្រប់ស្ថាបន័ពាក់ព័ន្ធដូចជា ខ័ណ្ឌ សង្កាត់ ។ល ។ ដើម្បីលុបបំបាត់តំបន់គ្មានសេវាកម្មនិងមានសេវាកម្មមិនគ្រប់គ្រាន់ បន្ថែមលើវិស័យឯកជន ។
- សាលាក្រុងភ្នំពេញគួរផ្សព្វផ្សាយ អប់រំ និងបង្ហាប់ដល់ប្រជាពលរដ្ឋក៏ដូចជារដ្ឋបាលអំពីព្រំប្រទល់រវាងការផ្តល់សេវាកម្មសាធារណៈ រឺឯកជន ។
- ស្ថាប័នឯកជនគួរតែយល់អំពីកាតព្វកិច្ចរបស់សាលាក្រុងភ្នំពេញដែលជានិច្ចកាលត្រូវធានាដល់សាធារណជននូវការផ្តល់សេវាកម្មសាធារណៈដល់ប្រជាពលរដ្ឋហើយស្ថាប័នឯកជន គួរតែយកចិត្តទុកដាក់ពិនិត្រពិចារណារាល់សំណើររបស់សាលាក្រុងភ្នំពេញចំពោះបញ្ហានោះ ។ ស្របពេលជាមួយគ្នាដែរស្ថាប័នឯកជនគួរតែត្រូវទទួលបានការ សហការពីសាលាក្រុងភ្នំពេញដើម្បីទទួលបាននូវការគាំទ្រ និងសហការពីមហាជន ( លើបញ្ហាការបង់ថ្លៃសេវាការចាក់សំណល់ ការចាក់សំណល់ត្រឹមត្រូវ ។ល ។) ដើម្បីបានផ្តល់សេវា ។

### b.3 ការបង្កើតមូលដ្ឋានហិរញ្ញវត្ថុ

- សាលាក្រុងភ្នំពេញត្រូវណែនាំដល់រដ្ឋាករគ្រប់គ្រងសំណល់រាជធានីភ្នំពេញ និងក្រុមហ៊ុនស៊ីនទ្រីដើម្បីគ្រប់គ្រងសេវាកម្មរបស់ពួកគេដោយប្រើប្រាស់ចំណូលដែលបានមកពីការយកតំលៃអ្នកប្រើប្រាស់សេវា ។
- សាលាក្រុងភ្នំពេញគួរសំរួលតំលៃសេវាកម្មអោយសមស្របទៅតាមតំលៃការងារនីមួយៗដូចជា ការប្រមូល និងដឹកជញ្ជូន ការងារបោសថ្នល់ សំអាតសួនច្បារ ទីលានចុងក្រោយនិងការគ្រប់គ្រង និងការសំរេចថ្លៃសំណល់សមស្រប ។ សាលាក្រុងភ្នំពេញគួរស្នើទៅអតិថិជនអោយបង់ថ្លៃសំណល់ដោយពន្យល់ថាអ្នកផ្តល់សេវាកម្មនឹងប្រើប្រាស់កំរៃនោះដើម្បីអោយការងារមានប្រសិទ្ធិភាព ។

- សាលាក្រុងភ្នំពេញគួរសំរួលបន្ទុករបស់ រ.គ.ស.ភ ដោយការទទួលជំនួយឥតសំណងបរទេស ពីព្រោះ រ.គ.ស.ភ ជាអ្នកផ្តល់សេវាកម្មប្រមូលសំណល់នៅតំបន់ដែលគ្មានផលកំរៃសេដ្ឋកិច្ចសំរាប់ក្រុមហ៊ុនឯកជន។

## 7.1.3 គំរោងអទិភាព

### a. គំរោងអទិភាព

គំរោងខាងក្រោមត្រូវបានជ្រើសរើសជាគំរោងអទិភាព ដើម្បីដោះស្រាយបញ្ហាបន្ទាន់ចំពោះមុខ

**តារាង ៧-១: គំរោងអទិភាព និង វិនិយោគ**

(អត្រា: ១,០០០ដុល្លា)

| ឈ្មោះគំរោង | មាតិការ | ការវិនិយោគ (២០០៥ — ២០០៦) | ការវិនិយោគ (២០០៧) |
|---|---|---|---|
| គំរោងអភិវឌ្ឍន៏តំបន់ចាក់សំរាមដង្កោ | ការសាងសង់តំបន់ចាក់សំរាមថ្មី | ៨.៨៩០ | 0 |
| | ការសាងសង់កន្លែងធ្វើជីកំប៉ុស្ត | ១.១៩៤ | 0 |
| | ការសាងសង់រោងជាងជួសជុល | ១៩៧៤ | |
| | **សរុបរង** | **១១,៦៩៨** | 0 |
| គំរោងពង្រីកសេវាកម្មប្រមូលសំណល់ | | ១.៨០៤ | ១៩៥ |
| គំរោងបិទតំបន់ចាក់សំរាមស្ទឹងមានជ័យ | | ៧៥ | ៧៤៥ |
| សរុបរួម | | **១៣.៥៣៧** | ៩៤០ |

### b. ការវាយតំលៃគំរោង

គំរោងអទិភាពនានា ត្រូវបានគេវាយតំលៃដោយយោងលើវិស័យបច្ចេកទេស សង្គម បរិស្ថាន និងហិរញ្ញកិច្ច និងការត្រួតពិនិត្យឃើញថាជាគំរោងសមស្រប។

<u>គំរោងអភិវឌ្ឍន៏ទីលានចាក់សំរាមដង្កោ</u>

តំលៃដែលត្រូវសំរាប់ប្រតិបត្តិការទីលានអនាម័យសមស្របនៅក្នុងករណីបានទទួលជំនួយឥតសំណងបរទេសគឺ ៤.៨ដុល្លា/តោន។ ដូច្នេះហើយ ដើម្បីបញ្ជាក់ថា រ.គ.ស.ភ ពិតជាត្រូវការដើមទុននោះ រ.គ.ស.ភ ត្រូវប្រឹងប្រែងសារជាថ្មី ដើម្បីអោយអ្នកប្រើប្រាស់យល់ ក្នុងកំឡុងពេលប្រតិបត្តិការនៅទីលានបច្ចុប្បន្ននិងតំឡើងថ្លៃទីលានជាលំដាប់។

<u>គំរោងពង្រីកសេវាកម្មប្រមូលសំណល់</u>

នៅថ្ងៃទី 12 ខែ ឧសភា ឆ្នាំ 2004 ក្រុមហ៊ុនស៊ិនទ្រីបានឯកភាពយល់ព្រមលើផែនការមេដែលបានបញ្ជាក់ថា រ.គ.ស.ភ ជាអ្នកផ្តល់សេវាកម្មដល់តំបន់ដែលគ្មានសេវាកម្មប្រមូលសំណល់ ដែលនោះគឺជាលក្ខខ័ណ្ឌដំបូងសំរាប់ការអនុវត្តន៏គំរោងនេះ។ ជាងនេះទៅទៀត គំរោងនេះត្រូវអោយបានអត្រាតំលៃប្រមូលសំណល់៨០%រឺច្រើនជាងនេះ។ ហើយនៅក្នុងគំរោងសាកល្បង យើងបានទទួលអត្រាតំលៃប្រមូលសំណល់៨០%។ ដូច្នេះផែនការពង្រីកសេវាកម្មប្រមូលសំណល់ដោយ រ.គ.ស.ភ ទៅលើតំបន់គោលដៅគឺតំបន់ដែលមិនមានផលចំណេញសេដ្ឋកិច្ចចំពោះក្រុមហ៊ុនឯកជន ដោយទទួលជំនួយឥតសំណងបរទេសសំរាប់ការអនុវត្តន៏របស់ខ្លួន។

<u>ផែនការបិទទីលានចាក់សំរាមស្ទឹងមានជ័យ</u>

តាមលទ្ធផលនៃការវិភាគហិរញ្ញកិច្ចបានរកឃើញថា ការប៉ាន់ស្មានដើមទុនសំរាប់គំរោងនេះត្រូវកើនឡើង តាមរយៈការចាក់សំណល់នៅទីលានចាក់សំរាមថ្មីដង្កោ ត្រឹមតែ0.២៨ដុល្លា/តោនតែប៉ុណ្ណោះដែលត្រូវការ។ ដូច្នេះហើយ ការអនុវត្តន៍គំរោងនេះគឺអាចដំណើរការបាន ហើយបានបង្ហាញអោយឃើញថាទីលានចាក់សំរាមថ្មីដង្កោ គឺជាគំរោង អនុវត្តសំរាប់ផលសេដ្ឋកិច្ចដោយនិរន្តភាព។

## c. បញ្ហាដែលត្រូវពិចារណាសំរាប់ការអនុវត្តន៍គំរោង

បញ្ហាទាំងឡាយខាងក្រោមនេះគួរត្រូវបានពិចារណាសំរាប់ការអនុវត្តន៍គំរោងអទិភាព

<u>វិស័យបច្ចេកទេស</u>

- ក្នុងគំរោងអភិវឌ្ឍន៍ទីលានចាក់សំរាមដង្កោ ការសិក្សាលើស្ថានភាពភូមិសាស្ត្រគួរត្រូវបានធ្វើនៅក្នុងដំណាក់កាលចាប់ផ្តើមសិក្សាលំអិត និងចាត់វិធានការទប់ស្កាត់ការបំពុលទឹកក្រោមដីដោយសារការជ្រាបទឹកសំអុយចេញពីសំរាម។
- បរិមាណលំហូរនៃជាតិទឹកសំអុយគួរត្រូវបានវាស់វែង ហើយចាត់វិធានការណ៏ទប់ស្កាត់ចាំបាច់ ។
- គំរោងសាកល្បងនៃការកែលំអរទីលានចាស់ស្ទឹងមានជ័យដែលអនុវត្តដោយក្រុមសិក្សា គឺជាវិធានការណ៏ចាំបាច់ជាបន្ទាន់មួយ។ នោះគឺជាវិធានការរយៈពេលវែងដែលត្រូវតែធ្វើជាចាំបាច់ចំពោះផែនការបិទទីលាន។ ប្រព័ន្ធត្រួតពិនិត្យគួរត្រូវបានបង្កើត និងបន្តធ្វើនៅក្នុងបរិវេណដែលបិទផងដែរ។ លក្ខខ័ណ្ឌបញ្ឈប់ជាបណ្តោះអាសន្នគួរត្រូវបានបង្កើតនៅពេលបិទទីលាន។

<u>វិស័យសង្គម</u>

- ជាលទ្ធផលនៃការកសាងទីលានថ្មី និងការបិទទីលានចាស់ អ្នករើសសំរាមនឹងបាត់បង់ការងារ ហើយអាជីវកម្មកែច្នៃនៅតំបន់ជុំវិញនឹងត្រូវទទួលផលប៉ះពាល់ ។ សំរាប់អ្នករើសសំរាម គេគួរតែស្ថាបនាមូលដ្ឋានសំរាប់គាំទ្រជីវភាពប្រចាំថ្ងៃរបស់ពួកគេ ដោយមានការសហការណ៏ពីអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ។ រីឯការងារអាជីវកម្មកែច្នៃ រ.គ.ស.ភ គួរតែធ្វើការផ្លាស់ប្តូរមតិជាមួយពួកគេ ដើម្បីរកដំណោះស្រាយកែលំអរស្ថានភាព ។
- មូលដ្ឋានគ្រឹះនៃការបំពេញតួនាទីរបស់គ្រប់ស្ថាប័នពាក់ព័ន្ធនឹងត្រូវបានបង្កើត ដោយផ្អែកលើការយល់ដឹងការយកចិត្តទុកដាក់របស់ ស្ថាប័នពាក់ព័ន្ធ ប្រជាពលរដ្ឋ ក្រុមហ៊ុនឯកជន និងអង្គការក្រៅរដ្ឋាភិបាលនានាលើបញ្ហាការ គ្រប់គ្រងសំណល់រឹង។ ដូច្នេះ បទបញ្ជាសំរាប់ការគ្រប់គ្រងសំណល់ត្រូវតែបង្កើតឡើង។

<u>វិស័យបរិស្ថាន</u>

- តាមលទ្ធផលនៃការស្ទង់មតិអំពីបរិស្ថាន ការស្ទង់មតិលើការវាយតំលៃហេតុផលប៉ះពាល់បរិស្ថាន និងការសិក្សាលើគុណភាពទឹក មានទិន្នន័យខ្លះដែលគួរតែធ្វើការពិនិត្យឡើងវិញ និង ទិន្នន័យខ្លះមានលក្ខណៈមិនច្បាស់លាស់ដែលត្រូវតែចោតសួរ ហើយប៉ារ៉ាម៉ែត្រមួយចំនួនមានបរិមាណកំរិតកំនត់ច្រើនជាងស្តង់ដារបស់ប្រទេសកម្ពុជាទៅទៀត រួមបញ្ចូលទាំង SS, Lead, Cadmium, Total Mercury, Organic Mercury, BOD, COD, Nitrogen as ammonium and TSP ។ ទោះជាយ៉ាងណា ទិន្នន័យនេះគួរត្រូវបានពិនិត្យឡើងវិញ បណ្តាលមកពីសមត្ថភាពរបស់ក្រសួងបរិស្ថានមានកំរិត និងកង្វះខាតឧបករណ៏លើការវិភាគ។ ដើម្បីត្រួតពិនិត្យបញ្ហាបរិស្ថាននៅក្នុងតំបន់គោលដៅអោយបានត្រឹមត្រូវ គេត្រូវធ្វើការមួយសារជាថ្មីឡើងវិញលើទិន្នន័យដែលបញ្ជាក់ខាងលើជាចាំបាច់សំរាប់ជាមូលដ្ឋានទិន្នន័យ។

- ជាចាំបាច់ត្រូវបង្កើតនូវប្រព័ន្ធវាស់វែងមួយដើម្បីអោយឆ្លើយតបទៅនិងកំរិតស្តង់ដានៃប្រទេសកម្ពុជាមុនពេលចាប់ផ្តើមប្រត្តិបត្តការណ៏ ដែលប្រព័ន្ធនេះអាយចាប់បានទិន្នន័យទាបជាងស្តង់ដាកំណត់ ។ ដូច្នេះ ការពង្រឹងការវិភាគទិន្នន័យ និងអ្នកវិភាគទិន្នន័យ ការពង្រឹងប្រព័ន្ធទិន្នន័យ និងការតំឡើងសំភារៈចាំបាច់ គឺត្រូវតែធ្វើជាបន្ទាន់ ។

- ស្របពេលនឹងការសាងសង់ទីលានចាក់សំរាមថ្មីនេះដែរ គួរសាងសង់អណ្តូងមួយនៅតំបន់ទំនាបនៃតំបន់ទ្រនាប់សំរាប់ត្រួតពិនិត្រគុណភាពទឹកក្រោមដី និងការបំពុលទឹកក្រោមដី។

- នៅក្នុងរដូវប្រាំង បរិមាណជាតិបារតដែលបានមកអំពីការយកបាន់សំណាកពីស្ទឹងព្រែកត្នោត និងប្រឡាយនៅឃុំជើងឯក នៅខាងក្នុងនិងជុំវិញទីលានដង្កោ មានកំរិតខ្ពស់ជាងស្តង់ដារបស់ប្រទេសកម្ពុជា ។ ទោះបីជាខិតខំប្រឹងប្រែងដើម្បីរកប្រភពបំពុល តែក្រុមសិក្សានៅតែមិនអាចកំណត់បាន ។ ក្រុមសិក្សាបានសន្និដ្ឋានថាជាតិបំពុលអាចបណ្តាលមកពីថ្នាំសំលាប់សត្វល្អិតដែលប្រើប្រាស់ក្បែរៗនោះ ។ ប្រសិនបើដូច្នេះមែន កំរិតសរីរាង្គបារតប្រាកដជាមានច្រើនជាងនេះ ។ ដូច្នេះ គេត្រូវតែត្រួតពិនិត្រឡើងវិញមិនត្រឹមតែលើកំរិតបារតសុទ្ធប៉ុណ្ណោះទេគឺថែមទាំងកំរិតសរីរាង្គបារតទៀតផង មុនពេលចាប់ផ្តើមប្រត្តិបត្តការណ៏ទីលានដង្កោនោះ ។

## d. ភាពរីកចំរើននៃគំរោងអភិវឌ្ឍន៍ទីលានចាក់សំរាមដង្កោ

### d.1 ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ផ្អែកទៅលើការសិក្សាលើបរិស្ថានជាជំហ៊ានដំបូងនោះ ការវាយតំលៃលើផលប៉ះពាល់បរិស្ថានដែលរួមមានការសាងសង់ទីលាន កន្លែងធ្វើជីកំប៉ុស ហើយនិងរោងជាងជួសជុស ត្រូវបានគេធ្វើឡើងដើម្បកំណត់រកបញ្ហានៃគំរោងដូចខាងក្រោម :

សកម្មភាពសេដ្ឋកិច្ច ហេដ្ឋារចនាសម្ព័ន្ធចរាចរ និងសាធារណៈ ការបំផ្លាញនូវទ្រព្យសម្បត្តិវប្បធម៌ សុខភាពសាធារណៈ ភាពផុយស្រួយនៃសង្គម លក្ខ័ណធារាសាស្រ្ត សត្វនិងរុក្ខជាតិ ទេសភាពនិងសោភណ្ឌ័ភាព ការបំពុលដោយផ្សែង ការបំពុលទឹក ការបំពុលដី សំលេងហើយនិងភាពរំជួយនិងក្លិនមិនល្អ ។ ផលប៉ះពាល់អវិជ្ជមាន ទាំងនោះត្រូវបានកាត់បន្ថយតាមរយៈវិធានការនានាដែលនឹងត្រូវយកមកប្រើប្រាស់នាពេលអនុវត្តគំរោង។

ផ្អែកលើលទ្ធផលការវាយតំលៃហេតុប៉ះពាល់បរិស្ថាន គេបានសន្និដ្ឋាន ថាជាកំរិតដែលអាចទទួលយកបានត្រូវបានគេគ្រោងដោយរៀបចំអោយមានវិធានការទប់ស្កាត់សមស្រប។

ការវាយតំលៃហេតុប៉ះពាល់បរិស្ថានត្រូវបានអនុម័តដោយក្រសួងបរិស្ថាននៃកម្ពុជានៅថ្ងៃទី១កក្កដា២០០៤។

### d.2 ការទិញដីនិងវេទការសាធារណៈ

សាលាក្រុងភ្នំពេញបានទិញដីចំនួន៣១.៤ហិចតានិង៥,៩០០ម$^{២}$ រួចហើយសំរាប់សង់ទីលានចាក់សំរាមថ្មី និងផ្លូវចូលទីលានសំរាបអនុវត្តគំរោងអភិវឌ្ឍន៍ទីលានចាក់សំរាមដង្កោ។

សាលាក្រុងភ្នំពេញបានរៀបចំជាការជួបជុំសាធារណៈចំនួន៣លើក ដោយអញ្ជើញប្រជាពលរដ្ឋរស់នៅក្នុង និងជុំវិញតំបន់គោលដៅ( ៩៦នាក់ នៅថ្ងៃតី១០តុលា២០០៣, ២៧៩នាក់នៅថ្ងៃទិ២៥ធ្នូ២០០៣ និង ៣៥២នាក់នៅថ្ងៃទី១៥កក្កដា២០០៤) និងមានការយល់ស្របជាសាធារណៈ។

## 7.1.4 បញ្ហាលើការគ្រប់គ្រងសំណល់រឹងដទៃទៀតនិងវិធានការណែនាំ

### a. ការគ្រប់គ្រងសំណល់វេជ្ជសាស្រ្ត ( មន្ទីរពេទ្យ)

ការបញ្ចេញបរិមាណនៃសំណល់វិជ្ជសាស្រ្តដែលអាចឆ្លង និងបង្កគ្រោះថ្នាក់ដល់សុខភាព ដែលបានប៉ាន់ស្មានលើមូលដ្ឋាននៃលទ្ធផលនៃការសិក្សាលើសំណល់វិជ្ជសាស្រ្តកន្លងមក គឺមាន០,៩៦តោន/ថ្ងៃរឺស្មើ៣៥០តោន/ឆ្នាំ ។ ប្រព័ន្ធបច្ចេកទេសមួយ (ការបែងចែកសំណល់ដែលអាចឆ្លង និងបង្កគ្រោះថ្នាក់នៅទីកន្លែង ការដឹកជញ្ជូន និងប្រព្រឹត្តកម្មសំណល់) សំរាប់ការគ្រប់គ្រងសំណល់ទាំងនេះគួរតែបានបង្កើតឡើងអោយកាន់តែឆាប់តាមតែអាចធ្វើបាន ។ ដោយសារបរិមាណនៃសំណល់វេជ្ជសាស្រ្តដែល មានគ្រោះថ្នាក់ដែលបានបញ្ចេញរាល់ថ្ងៃមានកំរិតតិចតួចបើប្រៀបធៀបទៅសំណល់រឹងពីគេហដ្ឋាននោះការចាក់ចោលនៃសំណល់បែបនោះមិនមែនជាបន្ទុកធ្ងន់ធ្ងរទេ ក៏ប៉ុន្តែថាវាត្រូវបានគេបែងចែកអោយបានត្រឹមត្រូវ( សំណល់វេជ្ជសាស្រ្តទូទៅមាន៩.៧តោន /ថ្ងៃ ស្មើនិង ៣៥៤០តោន/ឆ្នាំ) ។ ដូច្នេះហើយក្រសួងសុខាភិបាលដែលទទួលខុសត្រូវសំរាប់ការត្រួតពិនិត្យការចាក់សំណល់នៅ វិទ្យាស្ថានវេជ្ជសាស្រ្តនានា ត្រូវតែធានាការបែងចែកសំណល់គ្រោះថ្នាក់អោយបានត្រឹមត្រូវនូវនិងកន្លែង និងគ្រប់ជំហ៊ានរួមមាន ការប្រមូលប្រព្រឹត្តកម្មពាក់កណ្តាលសំរេច ការទុកដាក់ និងចាក់ចោលសំណល់ ។

សំរាប់សំណល់វេជ្ជសាស្រ្តដែលមិនមានគ្រោះថ្នាក់ ក្រោយពីការបែងចែកពីសំណល់គ្រោះថ្នាក់វាត្រូវបានគេប្រមូលនិង ចាក់ចោលដូចជាសំណល់ទូទៅដែរដែលគេកំពុងអនុវត្តនាពេលបច្ចុប្បន្ន ។

សំរាប់សំណល់វេជ្ជសាស្រ្តដែលមិនមានគ្រោះថ្នាក់នោះ ក៏មានបញ្ហាចំពោះការចាក់ចោលដោយស្ថាប័នវេជ្ជសាស្រ្តឯកជនដោយឡដុំដុតខ្នាតតូចមួយចំនួន ព្រោះមានការបំពុលដោយផ្សែងនិងការថែទាំនិងការអនុវត្ត ។ ដោយការសាងសង់ឡដុំដុតខ្នាតធំចាំបាច់ត្រូវពុះពារឧបសគ្គជាច្រើនដូចជាទំហំនិងថវិការ អាស្រ័យដូច្នេះហើយសំរាប់វិធីសាស្រ្តបណ្តោះអាសន្ន ក្រុមសិក្សាបានផ្តល់អនុសាសន៍ចំពោះការចាក់សំណល់នៅវិទ្យាស្ថានវិជ្ជាសាស្រ្តឯកជនទាំងនោះ ដោយប្រើប្រាស់ឡដុំដុតខ្នាតតូចជាមួយនិងការចាក់ចោលនៅទីលានអនាម័យ ដែលអនុម័តដោយក្រសួងបរិស្ថានជាសំណល់ដែលមានលក្ខណសមស្របសំរាប់សំណល់ឧស្សាហ៏កម្មដែលអាចបង្កគ្រោះថ្នាក់ ។ នាពេលអនាគតសំណល់ ទាំងនោះគួរតែត្រូវបានធ្វើប្រព្រឹត្តកម្មទាំងស្រុងដោយឡដុំដុតសមស្របមួយ ។ នៅពេលឡដុតកាកសំណល់គ្រោះថ្នាក់ខ្នាតធំត្រូវបានធ្វើការអនុវត្តគេត្រូវត្រួតពិនិត្យអោយបានម៉ត់ចត់នូវផ្សែង បំពុលដែលចេញពីឡដុំដុតខ្នាតតូចដែលមានស្រាប់មួយចំនួន ។

ការងារកែលំអរបែបនេះត្រូវការបទពិសោធន៏ច្រើន ។ តាមច្បាប់ ស្ថាប័នវេជ្ជសាស្រ្តនានាត្រូវទទួលខុសត្រូវលើតំលៃដឹកជញ្ជូនសំណល់ពីកន្លែងទៅទីលាន ។ ដូច្នេះហើយ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងសុខាភិបាលគួរពិនិត្យរកវិធានការរអោយវិទ្យាស្ថានទាំងនោះក្នុងការទទួលខុសត្រូវចំពោះតំលៃសេវា ។

### b. ការគ្រប់គ្រងសំណល់ឧស្សាហកម្ម

យោងទៅលើការសិក្សាលើវិស័យឧស្សាហកម្មបរិមាណបញ្ចេញ នៃសំណល់ឧស្សាហកម្មដែលអាចមានបង្កគ្រោះថ្នាក់នោះ មានកំរិតតិចតួច (១.៩តោន/ថ្ងៃ=៦៩៤តោន/ឆ្នាំ) បើប្រៀបធៀបទៅនឹងសំណល់ឧស្សាហកម្មដែលមានគ្រោះថ្នាក ់(៥៦.៣តោន/ថ្ងៃ ស្មើនិង ២០,៥៥០តោន/ឆ្នាំ) ។ ជាងនេះទៀតទីលានចាក់សំរាមសំរាប់សំណល់ឧស្សាហកម្មដែលអនុម័តដោយក្រសួងបរិស្ថានដែលមានលក្ខណសមស្របសំរាប់សំណល់ ឧស្សាហកម្មគ្រោះថ្នាក់ដែលមានទីតាំងនៅក្នុងខេត្តកណ្តាល ។ ដូច្នេះហើយមន្ទីរ បរិស្ថាន និងរ.ក.ស.ភ គួរបង្កើតនៅប្រព័ន្ធត្រួតពិនិត្យអោយបានម៉ត់ចត់ទៅលើចំនួនរថយន្តដែលចូលមកទីលានដែលប្រើប្រាស់សំរាប់កាកសំណល់ផ្ទះបាយ ។
សំណល់ឧស្សាហកម្មត្រូវបានចាត់ទុកថាមានកំរិតបំពុលខ្ពស់ ហើយអ្នកដែលបញ្ចេញសំនល់ទាំអនោះនឹងមិនអនុញ្ញាត្តិអោយយកមកចាក់ជាមួយសំនល់ផ្ទះបាយទេ ។

ស្របពេលនេះ បន្ទុក និងស្តង់ដាត្រូវតែរៀបចំជាបន្ទាន់ដោយថ្នាក់ជាតិដើម្បីត្រួតពិនិត្រ និងតាមដានលើបទបញ្ហាទាំងនោះ ហើយអ្នកដែលអ្នកបញ្ចេញសំណល់ត្រូវទទួលខុសត្រូវលើបញ្ហានេះ ។

ចំពោះឧស្សាហកម្មនានាដែលត្រូវ ចាត់ទុកជាប្រភេទអ្នក ផលិតកាកសំណល់ឧស្សាហកម្មគ្រោះថ្នាក់ខ្ពស់នោះ គេមិនត្រូវអនុញ្ញាតិអោយចាក់សំណល់ទាំងនោះនៅទីលានធម្មតាទេ លុះណាតែគេត្រូវបានធានាថា សំណល់ដែលចាក់នោះ មិនមានគ្រោះថ្នាក់ ។

**c. ការគ្រប់គ្រងកាកសំណល់ពីប្រព័ន្ធលូ**

យោងតាមការសិក្សាលើអាងសំណល់ពីលូ បរិមាណភក់ដែលបានចាក់នៅតាមអាងធ្វើប្រព្រឹត្តិកម្មនៅ ទ.ស្ន.ម.ជ មាន តែ៥.៨ម៣ ក្នុងមួយថ្ងៃប៉ុណ្ណោះជាមធ្យម( តាមទិន្នន័យឆ្នាំ ២០០៣) ។ ឧបមាថា ៣០% នៃចំនួនប្រជាជននៅភ្នំពេញដែលមាន ១.២០០.០០០នាក់ កំពុងប្រើអាងប្រព្រឹត្តិកម្មសំណល់ពីលូ នោះជាការប៉ាន់ស្មានបរិមាណបញ្ចេញ ដោយយោងតាមទិន្នន័យប្រទេស ជប៉ុនគឺអាចមាន ៣០៦ម៣ ក្នុងមួយថ្ងៃត្រូវជា **៥៣ដង** ច្រើនជាងបរិមាណបញ្ចេញបច្ចុប្បន្ន ។

ផ្អែកតាមលទ្ធផល❶ អាងទឹកស្អុយមិនដំណើរការទេដោយសារតែភាគច្រើនមានសំណល់ភក់ពេញ ឬ❷ ប្រសិនបើសំណល់ភក់កំពុងត្រូវបានប្រមូល មានន័យថាវាមិនអាចយកទៅចាក់ទីណាផ្សេងមិនត្រឹមត្រូវខុសពីអាងប្រព្រឹត្តិកម្មនៅ ទ.ស្ន.ម.ជ បានឡើយ ។

ដើម្បីកែលំអស្ថានភាពនេះ សាលាក្រុងភ្នំពេញគួរតែចាត់វិធានការមួយចំនួនដូចតទៅ :

- ស្រាវជ្រាវលក្ខខណ្ឌបង្កើតអាង និងប្រមូលសំណល់ភក់ហើយផ្អែកតាមលទ្ធផលរកឃើញត្រូវបង្កើតផែនការគ្រប់គ្រងអាងទឹកស្អុយ និងសំណល់ភក់ទឹកស្អុយ ។
- ពិនិត្យមើលស្តង់ដាគ្រប់គ្រងទឹកស្អុយ និងបង្កើតច្បាប់សំរាប់អាងទឹកស្អុយ ហើយរឹតបន្តឹងចំពោះការចាក់សំណល់ ភក់ទឹកស្អុយមិនបានត្រឹមត្រូវ ។
- ផ្អែកតាមផែនការគ្រប់គ្រងអាងទឹកស្អុយ និងសំណល់ភក់ ត្រូវបង្កើតប្រព័ន្ធប្រមូលនិងកសាងមធ្យោបាយថ្មីធ្វើប្រព្រឹត្តិកម្មសំណល់ភក់ ។
- នៅពេលមធ្យោបាយថ្មីធ្វើប្រព្រឹត្តិកម្មសំណល់ភក់ត្រូវបានកំពុងកសាង ត្រូវថែទាំ និងប្រើអាងប្រព្រឹត្តិកម្មដែលមានស្រាប់នៅទីលានចាក់សំរាមស្ទឹងមានជ័យ ។

# 7.2 អនុសាសន៍

## 7.2.1 អនុសាសន៍សំរាប់ការកែលំអរផែនការមេ

**a. តំបន់ដែលគ្មានសេវាកម្មសំណល់និងតំបន់មានសេវាកម្មតែមិនគ្រប់គ្រាន់**

- សាលាក្រុងភ្នំពេញ និងក្រុមហ៊ុនឯកជន (ស៊ិនទ្រី) គួរតែគូសបញ្ជាក់ពីតំបន់ដែលគ្មានសេវាកម្មសំណល់និងតំបន់ដែលមានសេវាកម្មតែមិនគ្រប់គ្រាន់ដែលមានក្នុងទីក្រុង ហើយធ្វើការកែប្រែកិច្ចសន្យាដើម្បីអនុញ្ញាតិអោយ រ.ស.គ.ភ ផ្តល់សេវាកម្មប្រមូលសំណល់ដល់តំបន់ទាំងនោះ ។
- សាលាក្រុងភ្នំពេញ/មន្ទីរបរិស្ថានរាជធានីភ្នំពេញគួរបង្កើតប្រព័ន្ធសំរាប់ត្រួតពិនិត្យនិងគ្រប់គ្រងសេវាកម្មដែលផ្តល់ដោយ រ.គ.ស.ភ និងក្រុមហ៊ុនឯកជន។

**b. ការបង្កើតនូវប្រព័ន្ធទីលានចាក់ចុងក្រោយសមស្រប**

- រ.គ.ស.ភ គួរតែបន្តគំរោងសាកល្បងស្តីពីការកែលំអទីលានស្ទឹងមានជ័យ ហើយអភិវឌ្ឍសមត្ថភាពរបស់ខ្លួននៃការគ្រប់គ្រងទីលាន ។
- រ.គ.ស.ភ គួរតែបង្កើនកំរិតប្រតិបត្តិទីលានប្រកបដោយអនាម័យនៅទីលានស្ទឹងមានជ័យជាជំហាន១
- រ.គ.ស.ភ គួរតែពន្យល់ពីផលប្រយោជន៍កើនឡើងដែលជាលទ្ធផលនៃការកែលំអរប្រតិបត្តិការណ៍ទីលាន ដល់អ្នកប្រើប្រាស់ ហើយស្នើអោយអ្នកទាំងនោះយល់ពីភាពចាំបាច់នៃការបង្កើនកំរៃទីលាន ហើយយល់ព្រមលើតំលៃនោះ ។
- រ.គ.ស.ភ គួរតែចចារជាមួយអ្នកប្រើប្រាស់ទីលានស្តីពីការបង្កើនតំលៃទីលានជាជំហាន១ដើម្បីគ្របដណ្តប់លើការចំណាយនៃប្រតិបត្តិការណ៍ទីលាន ។
- រ.គ.ស.ភ គួរតែពន្យល់ពីសកម្មភាពនានាដេលបានធ្វើស្តីពីការកែលំអរទីលានស្ទឹងមានជ័យ ហើយបញ្ចុះបញ្ចូលមិនត្រឹមតែប្រជាពលរដ្ឋដែលរស់នៅជុំវិញប៉ុណ្ណោះទេ តែត្រូវដល់ប្រជាជនទាំងអស់ដើម្បីអោយគេចូលរួមការចំណាយសំរាប់ការប្រតិបត្តិទីលានអោយបានសមស្រប ។

c. ការប្រតិបត្តិនៃគំរោងអាទិភាពនានា

- ដោយគិតទៅលើការលំបាកផ្នែក្នុងក្នុងការបង្កើនថវិកា ក្រុមសិក្សាបានផ្តល់អនុសាសន៍ថា សាលាក្រុងភ្នំពេញខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីរកថវិកាដែលជាជំនួយបរទេសសំរាប់អនុវត្តផែនការអភិវឌ្ឍទីលានដង្កោនិងគំរោងពង្រីកសេវាកម្មសំណល់ ។
- ដើម្បីអោយថវិកាគំរោងមាននិរន្តភាពដោយគ្រាន់តែទទួលបានប្រាក់ចំណូលដែលបានមកពីកំរៃសំណល់ សាលាក្រុងភ្នំពេញគួរតែស្វែងរកប្រព័ន្ធកំរៃប្រាក់ចំណូលដែលមានស្ថេរភាព ដោយផ្អែកលើការបង្កើតនូវប្រព័ន្ធអត្រាកំរៃច្បាស់លាស់និងសមស្របដែលអ្នកប្រើប្រាស់អាចទទួលយកបានដោយពេញចិត្ត ។
- សាលាក្រុងភ្នំពេញគួរតែពន្យល់ហើយពន្យល់ទៀតស្តីពីគំរោងអភិវឌ្ឍទីលានដង្កោដល់ប្រជាពលរដ្ឋទាំងអស់ដែលរស់នៅជិតនិងជុំវិញទីតាំងគំរោង រហូតដល់ដំណាក់កាលអនុវត្តគំរោង ដើម្បីធានាថាពួកគេយល់ដឹងគ្រប់គ្រាន់ ហើយនិងបង្កើតនូវការយល់ព្រមជាសារធារណៈ ។
- ដើម្បីត្រួតពិនិត្យប្រតិបត្តិការទីលាននៅទីលានថ្មី មន្ទីរបរិស្ថានគួរតែបង្កើតគណៈកម្មការត្រួតពិនិត្យដោយសហការជាមួយក្រសួងបរិស្ថាន អាជ្ញាធរខ័ណ្ឌ សង្កាត់ ប្រជាពលរដ្ឋ អង្គការក្រៅរដ្ឋាភិបាននានា ។ល។

d. ការទិញដីសំរាប់តំរូវការហេដ្ឋារចនាសម្ព័ន្ធនានាដើម្បីអនុវត្តផែនការមេ

- សាលាក្រុងភ្នំពេញគួរតែទិញដីសំរាប់ការធ្វើប្រព្រឹត្តកម្មសំណល់ និងហេដ្ឋារចនាសម្ព័ន្ធទីលាននានា អោយស្របទៅតាមយុទ្ធសាស្ត្រដែលបានកំណត់ក្នុងផ្នែកទី3នៃរបាយការណ៍នេះ។ ទោះជាយ៉ាងនេះក្តី ការទិញដីកាន់តែលំបាកឡើង១នៅពេលដែលប្រជាជនកាន់តែច្រើនឡើង១កាន់តែមានគំនិតថានេះមិនមែនជាបញ្ហាផ្ទាល់ខ្លួនរបស់ពួកគាត់នោះ។ សាលាក្រុងភ្នំពេញគួរតែស្វែងរកទីតាំងនានាអោយបានមុនសិន។